# អំណោយទានខាងឯវិញ្ញាណ



កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ន

សិក្សាអំពីភាពជាអ្នកដឹកនាំក្នុងគ្រិស្តបរិស័ទ

# ព្រះអំណោយទានខាងឯវិញ្ញាណ

បោះពុម្ពផ្សាយលើកទី មួយ

ដោយ លោក រ៉ូប៊ើត អិល. ប្រាន

សៀវភៅសម្រាប់សិក្សាដោយខ្លួនឯង

បង្កើតឡើង ដោយសហប្រតិបត្តិការជាមួយបុគ្គលិក សាកលវិទ្យាល័យ គ្លូបល

GLOBAL
UNIVERSITY

Address of the Global University office in your area:
Global University – Battambang CAM Office
Salaa Hope – AOG
Phom Romcheck 4, Khum Ratanak
Srok Battambang
Battambang, CAMBODIA

Developed in cooperation with Global University Staff

School for Evangelism and Discipleship
Global University
1211 South Glenstone
Springfield, MO 65804
USA

Translated from the Fourth edition 2012 (English)
First edition 2026 (Khmer)
© 2026 Global University
All right reserved

---

© 2026 CS5151KHM
Khmer: *Spiritual Gifts* by Robert L. Brandt

Unless otherwise indicated, Scripture quotations are from The Khmer Standard Version © 2005
United Bible Societies.
Used by permission. All rights reserved.

PN 01.25.01

www.globaluniversity.edu
www.globalreach.org (Free pdf download)

Khmer version by Battambang CAM Translation office
Project Editor: Kelly Robinette
Head Translator: សែម សិទ្ធី (Sem Sithee)
Translation Staff:
សិទ្ធី ធីម៉ូថេ (Sithee Thimothay)

Additional Proofreading: សែម សិទ្ធី (Sem Sithee)

- និស្សិតត្រូវដាក់ពាក្យ និង ចុះឈ្មោះជាផ្លូវការ ដើម្បីទទួលបានការទទួលស្គាល់
- និស្សិតអាចចុះឈ្មោះបាន នៅក្នុងគេហទំព័រ http://sed.globalutraining.com. គេក៏អាច ផ្ញើសារទៅកាន់ sed@globaluniversity.edu ដើម្បីស្វែងរក ការិយាល័យ ដែលនៅក្នុងប្រទេសរបស់ពួកគេ ដើម្បីចុះឈ្មោះ

# តារាងមាតិកា


កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ ..... ៤
សេចក្ដីណែនាំ ..... ៥

## ជំពូកទីមួយៈ ការណែនាំអំពីព្រះអំណោយទានខាងឯព្រះវិញ្ញាណ

១ ព្រះជាម្ចាស់មានព្រះអំណោយទានសម្រាប់អ្នក ..... ១៦
២ ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យអ្នកស្គាល់ពីព្រះអំណោយទានរបស់ទ្រង់ ..... ២៩

## ជំពូកទីពីរៈ ការស្វែងយល់អំពីព្រះអំណោយទានខាងឯព័ន្ធកិច្ច

៣ ពួកសាវ័ក និង ព្យាការី (អ្នកថ្លែងព្រះបន្ទូល) ..... ៤៦
៤ អ្នកផ្សាយដំណឹងល្អ និង អ្នកគង្វាលព្រមទាំងអ្នកបង្រៀន ..... ៦៣
៥ ព្រះអំណោយទាននៃការបម្រើ ការបង្រៀន និង ការទូន្មាន ..... ៨១
៦ ព្រះអំណោយទាននៃការចែកទាន ការគ្រប់គ្រង មានចិត្តមេត្តាករុណា និង ការជួយ ..... ៩៥

## ជំពូកទីបីៈ ការស្វែងយល់អំពីព្រះអំណោយទានរបស់ព្រះវិញ្ញាណ

៧ ពាក្យសំដីនៃប្រាជ្ញា ពាក្យសំដីនៃចំណេះ និងជំនឿ ..... ១១៦
៨ ការប្រោសឲ្យជាពីជំងឺ ការធ្វើការអស្ចារ្យ និង ការថ្លែងព្រះបន្ទូល ..... ១៣៦
៩ ការសង្កេតស្គាល់វិញ្ញាណ ការនិយាយភាសាចម្លែកអស្ចារ្យ
និង ការបកប្រែន័យភាសាចម្លែកអស្ចារ្យ ..... ១៥៨

អក្ខរានុក្រម ..... ១៧៩
ចម្លើយសម្រាប់ការប្រឡងផ្ទាល់ខ្លួន ..... ១៨២
ការប្រឡងតាមជំពូក ..... ១៨៨
អវសានកថា ..... ២០៣
កម្រងសំណួរសម្រាប់និស្សិត ..... ២០៦
ការណែនាំសម្រាប់ការប្រលងបញ្ចប់ ..... ២០៨

# កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ

ភាពពេញវ័យរបស់គ្រិស្តបរិស័ទ Christian Maturity

ព្រះរាជ្យ ឫទ្ធានុភាព និង សិរីរុងរឿង Kingdom, Power, and Glory

ថ្មគ្រឹះនៃសេចក្តីពិត Cornerstones of Truth

ក្រុមជំនុំគ្រិស្តបរិស័ទ នៅក្នុងព័ន្ធកិច្ច The Christian Church in Ministry

**ព្រះអំណោយទានខាងឯវិញ្ញាណ** Spiritual Gifts

ការដោះស្រាយបញ្ហាជីវិត Solving Life′s Problems

ការអធិស្ឋាន និង ការថ្វាយបង្គំ Prayer and Worship

ជំរំ ព្រះវិហារ និង ព្រះរាជវាំង Tents, Temples and Palaces

មានជីវិតរស់នៅក្នុងព្រះគ្រិស្ត Alive in Christ

ការចាប់ផ្តើមក្រុមជំនុំថ្មី Starting New Churches

ការអធិប្បាយ និង ការបង្រៀន Preaching and Teaching

មនុស្ស កិច្ចការ និង គោលដៅ People, Tasks and Goals

គ្រិស្តបរិស័ទដែលមានទំនួលខុសត្រូវThe Responsible Christian

ការស្វែងយល់ព្រះគម្ពីរ Understanding the Bible

ទីប្រឹក្សា គ្រូបង្រៀន និង មគ្គុទេសក៍ Counselor, Teacher and Guide

ការជួយគ្រិស្តបរិស័ទឲ្យលូតលាស់ Helping Christians Grow

ការចែកចាយដំណឹងល្អ Sharing the Good New

ការរស់នៅដ៏ពេញបរិបូណ៌ Abundant Living

# កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ

## The Christian Service Series

ព្រះអំណោយទានខាងឯវិញ្ញាណ (Spiritual Gifts) គឺជាមុខវិជ្ជាទីប្រាំក្នុងចំណោមមុខវិជ្ជាទាំង១៨ ហើយដែល ស្ថិត នៅក្នុងវគ្គសិក្សាទីមួយ។ ក្នុងកម្មវិធីនៃភាពជាសាវ័កដ៏ជាក់ស្តែងមួយនេះ សម្រាប់អ្នកដឹកនាំថ្មីៗ។ កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ គឺជាការសិក្សាមួយដើម្បីជួយសិស្សឲ្យបានលូតលាស់ នៅក្នុងទំនាក់ទំនងរបស់ពួកគេជាមួយនឹងព្រះគ្រិស្ត និង ទំនាក់ទំនងជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រមទាំងឲ្យបានយល់កាន់តែប្រសើរឡើង អំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់ពួកគេ។

សិស្សនឹងបានសិក្សា អំពីប្រធានបទមូលដ្ឋានគ្រឹះនៃគ្រិស្តបរិស័ទ ដោយមានការបែងចែកជាមូលបទប្រាំមួយយ៉ាង នៅក្នុងវគ្គនីមួយៗ។ វគ្គសិក្សាទាំងនេះ សរសេរតាមបែបសន្ទនា និង មានភាពងាយស្រួលក្នុងការអាន។ តារាងខាងក្រោមនេះ បង្ហាញពីការរៀបចំវគ្គសិក្សានីមួយៗ សម្រាប់កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ។

| មូលបទ<br>Theme | វគ្គទី១<br>Unit One | វគ្គទី២<br>Unit Two | វគ្គទី៣<br>Unit Three |
|---|---|---|---|
| ជីវិតខាងឯវិញ្ញាណ<br>Spiritual Life | ភាពពេញវ័យរបស់គ្រិស្តបរិស័ទ Christian Maturity | ការអធិស្ឋាន និង ការថ្វាយបង្គំ Prayer and Worship | គ្រិស្តបរិស័ទដែលចេះទទួលខុសត្រូវ The Responsible Christian |
| ព្រះគម្ពីរ<br>The Bible | ព្រះរាជ្យ ឫទ្ធានុភាព និង សិរីរុងរឿង Kingdom, Power, and Glory | ជំរំ ព្រះវិហារ និង ព្រះរាជវាំង Tents, Temples and Palaces | ការស្វែងយល់ព្រះគម្ពីរ Understanding the Bible |
| ទេវសាស្ត្រ<br>Theology | ថ្មគ្រឹះនៃសេចក្តីពិត Cornerstones of Truth | ជីវិតរស់នៅក្នុងព្រះគ្រិស្ត Alive in Christ | ទីប្រឹក្សា គ្រូបង្រៀន និង មគ្គុទេសក៍ Counselor, Teacher and Guide |
| ក្រុមជំនុំ<br>The Church | ក្រុមជំនុំគ្រិស្តបរិស័ទទាក់ទងនឹងព័ន្ធកិច្ច The The Christian Church in Ministry | ការចាប់ផ្តើមក្រុមជំនុំថ្មី Starting New Churches | ការជួយគ្រិស្តបរិស័ទឲ្យលូតលាស់ Helping Christians Grow |
| កិច្ចបម្រើ<br>Service | អំណោយទានខាងឯវិញ្ញាណ Spiritual Gifts | ការអធិប្បាយ និង ការបង្រៀន Preaching and Teaching | ការចែកចាយដំណឹងល្អ Sharing the Good News |
| ក្រមសីលធម៌របស់គ្រិស្តបរិស័ទ<br>Christian Ethics | ការដោះស្រាយបញ្ហាជីវិត Solving Life's Problems | មនុស្ស កិច្ចការ និង គោលដៅ People, Tasks and Goals | ការរស់នៅដ៏ពេញបរិបូណ៌ Abundant Living |

# កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ

ជំពូក ១

មុខវិជ្ជា ៥

សៀវភៅសិក្សាផ្ទាល់ខ្លួននេះ គឺជាសៀវភៅមួយក្បាលក្នុងចំណោមសៀវភៅចំនួន១៨ក្បាល( មុខវិជ្ជា) នៃមុខវិជ្ជាបណ្តុះបណ្តាល ការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ នៃសាកលវិទ្យាល័យ គ្លូបល។ សញ្ញាសំគាល់នៅខាងឆ្វេងដៃនេះ សម្រាប់បង្ហាញអំពីលំដាប់លំដោយនៃការសិក្សា មុខវិជ្ជានេះ ដែលត្រូវបែងចែកជា ៣វគ្គដែលមាន ៦ មុខវិជ្ជាក្នុងវគ្គនីមួយៗ។ *ព្រះអំណោយទានខាងឯពវិញ្ញាណ* ជាមុខវិជ្ជាទី៥ ក្នុងជំពូកទី១ ។

វគ្គទាំងអស់ ត្រូវបានរៀនចំ ដើម្បីនាំអ្នក ឲ្យសិក្សាមុខវិជ្ជានេះ ជាលក្ខណៈប្រព័ន្ធសម្រាប់កម្មវិធីសិក្សាទាំងអស់នេះ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកក៏អាចសិក្សា តែមុខវិជ្ជានេះមួយ ឬក៏អាចសិក្សា មុខវិជ្ជាផ្សេងៗទៀតនៅក្នុងកម្មវិធីសិក្សានេះ តាមរបៀបណាក៏បាន។

សម្ភារសិក្សានៅក្នុងកម្មវិធី ការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទនេះ ត្រូវបានបង្កើតឡើង តាមរបៀបដែលអាចរៀនដោយខ្លួនឯង សម្រាប់អ្នកបម្រើព័ន្ធកិច្ចគ្រិស្តបរិស័ទ គ្រប់ជាតិសាសន៍ និង គ្រប់វប្បធម៌។ កម្មវិធីនេះនឹង ផ្ទាល់ជូននិស្សិត នូវចំណេះដឹង និង ជំនាញ ព្រះគម្ពីរ សម្រាប់ការបម្រើជាក់ស្តែងរបស់គ្រិស្តបរិស័ទ។

# កំណត់សំគាល់

សូមអានការណែនាំដំបូង នៃមុខវិជ្ជានេះដោយប្រុងប្រយ័ត្នបំផុត។ ដោយធ្វើតាម ការណែនាំនេះ អ្នកនឹងអាចសម្រេចគោលដៅមុខវិជ្ជារបស់អ្នក ហើយអ្នកនឹងគ្មានការលំបាកក្នុងការវាយប្រឡង ក្នុងជំពូករបស់អ្នកឡើយ។

# សេចក្ដីណែនាំ

"បងប្អូនអើយ ខ្ញុំចង់អោយបងប្អូនជ្រាបយ៉ាងច្បាស់ អំពីព្រះអំណោយទានរបស់ព្រះវិញ្ញាណ។" (គម្ពីរ១កូរិនថូស ១២:១)។

ព្រះអំណោយទានខាងឯវិញ្ញាណ គឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ព្រះកាយរបស់ព្រះគ្រិស្ត។ វាជារឿងគួរឲ្យរំភើប ក្នុងការរៀនអំពីព្រះអំណោយទានទាំងនេះដែលព្រះជាម្ចាស់បានញែកទុកសម្រាប់បុត្រាបុត្រីរបស់ទ្រង់។ ក្រុមជំនុំមិនអាចកកើត ឬ បន្តដំណើរទៅមុខបានឡើយ ប្រសិនបើគ្មានព្រះអំណោយទានទាំងអស់នេះ។

ក្នុងនាមជាអ្នកជឿ យើងត្រូវតែរៀនឲ្យបានច្រើនបំផុតអំពីព្រះអំណោយទានខាងឯវិញ្ញាណ។ នៅពេលដែលយើងមានចំណេះដឹងកាន់តែច្រើន អំពីព្រះអំណោយទានទាំងនេះនឹងកើតមាននៅក្នុងជីវិត និង ព័ន្ធកិច្ចរបស់យើង។ យើងនឹងក្លាយជាព្រះពរដ៏ធំសម្រាប់ក្រុមគ្រួសាររបស់អ្នកជឿ និង ផ្សាយដំណឹងល្អបានយ៉ាងមិនប្រសិទ្ធិភាព។

# ការរៀបរាប់អំពីមុខវិជ្ជា

នៅក្នុងមុខវិជ្ជានេះ យើងនឹងផ្តោតសំខាន់ទៅលើព្រះអំណោយទានខាងឯវិញ្ញាណទាំងបីក្រុមផ្សេងៗពីគ្នា។ យើងនឹងហៅព្រះអំណោយទានទាំងនេះថា (១) ព្រះអំណោយទាននៃព័ន្ធកិច្ច (២) ព្រះអំណោយទានព័ន្ធកិច្ចដទៃទៀត និង (៣) ព្រះអំណោយទានរបស់ព្រះវិញ្ញាណ។

ក្រុមទីមួយ ព្រះអំណោយទាននៃព័ន្ធកិច្ច រួមមានអ្នកជឿដែលព្រះគ្រិស្តបានប្រទានមកឯក្រុមជំនុំឲ្យធ្វើជាអ្នកដឹកនាំ។

នៅក្នុងក្រុមទីពីរ ព្រះអំណោយទានព័ន្ធកិច្ចដទៃទៀត យើងនឹងសិក្សាអំពីព្រះអំណោយទានដែលទុកសម្រាប់អ្នកជឿទាំងអស់។

ហើយនៅក្នុងក្រុមចុងក្រោយ ព្រះអំណោយទានរបស់ព្រះវិញ្ញាណ យើងនឹងសិក្សាអំពីព្រះអំណោយទានទាំងប្រាំបួន ដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រទានមកអ្នកជឿតាមបំណងព្រះហឫទ័យរបស់ទ្រង់។

# វត្ថុបំណងនៃសៀវភៅមេរៀន

នៅពេលដែលអ្នកបញ្ចប់មុខវិជ្ជានេះ អ្នកអាចនឹង ៖

១. រៀបរាប់អំពីសារៈសំខាន់នៃបុគ្គលអ្នកជឿនៅក្នុងក្រុមជំនុំក្នុងនាមជាបណ្តាញសម្រាប់ អំណោយទានខាងឯវិញ្ញាណ។

២. យល់អំពីមុខងារ និង គោលបំណងនៃព្រះអំណោយទានខាងឯវិញ្ញាណទៅតាមប្រភេទនីមួយៗ។

៣. បែងចែករវាងកិច្ចការនៃការកសាងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ជាមួយនឹងកិច្ចការនៃការបំផ្លិចបំផ្លាញរបស់វិញ្ញាណអាក្រក់។

៤. ទទួលស្គាល់ និង ឲ្យតម្លៃ ភាពសម្បូរបែបនៃព្រះអំណោយទានខាងឯវិញ្ញាណ នៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត។

៥. បកស្រាយអំពីភាពខុសគ្នារវាងព្រះអំណោយទានខាងឯវិញ្ញាណ និង ទេពកោសល្យធម្មជាតិ។

៦. ស្វែងរក ឆ្លងកាត់ និងឈោងចាប់ ការអភិវឌ្ឍព្រះអំណោយទានខាងឯវិញ្ញាណនៃព័ន្ធកិច្ចរបស់អ្នក។

៧. ឲ្យតម្លៃព្រះអំណោយទានរបស់ព្រះវិញ្ញាណ ថាជារឿងដែលសំខាន់បំផុតសម្រាប់ជីវិត និង ព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ។

៨. ស្គាល់ និង ចេះដោះស្រាយបញ្ហាដែលទាក់ទងទៅនឹងការប្រើប្រាស់ ព្រះអំណោយទានខាងឯវិញ្ញាណ។

# សៀវភៅមេរៀន

អ្នកនឹងប្រើប្រាស់សៀវភៅ *ព្រះអំណោយទានខាងវិញ្ញាណ* ដែលសរសេរឡើងដោយ លោក រ៉ូប៊ើត អិល. ប្រាន នេះ ទាំងជាសៀវភៅមេរៀន និង ជាសៀវភៅមគ្គុទេសក៍ក្នុងការសិក្សា មុខវិជ្ជានេះផង។ ក្រៅពីនោះ អ្នកត្រូវការ តែព្រះគម្ពីរតែប៉ុណ្ណោះ។

# មុនពេលដែលអ្នកចាប់ផ្តើម

## របៀបរៀនមុខវិជ្ជានេះ

មុខវិជ្ជានេះត្រូវបានសរសេរឡើង ដើម្បីឲ្យអ្នកអាចយកទៅសិក្សាដោយខ្លួនឯងបាន។ យ៉ាងណាក៏ដោយអ្នកអាចរៀនមុខវិជ្ជានេះតាមការរៀបចំក្រុមផ្សេងៗ។ ប្រសិនបើអ្នករៀនដោយខ្លួនឯង ការរៀនរបស់អ្នក អាចបានចប់គ្រប់ជ្រុងជ្រោយ ដោយធ្វើតាមការណែនាំ នៅក្នុងសេចក្តីណែនាំនេះ។ ប្រសិនបើអ្នករៀនជាក្រុម សូមធ្វើតាមការណែនាំបន្ថែមផ្សេងដែលគ្រូរបស់អ្នកដាក់ឲ្យ ដោយយកចិត្តទុកដាក់។

## វិធីប្រើប្រាស់សៀវភៅនេះ

ពេលវេលាដែលអ្នកត្រូវការ សម្រាប់រៀនមេរៀននីមួយៗ អាស្រ័យទៅតាមផ្នែកខុសៗគ្នា ទៅលើចំណេះដឹងរបស់អ្នកចំពោះមុខវិជ្ជា និង ភាពស្ទាត់ជំនាញរបស់អ្នកក្នុងការសិក្សារៀនសូត្រ មុនពេលចាប់ផ្តើមមុខវិជ្ជានោះ។ ពេលវេលាដែលអ្នកត្រូវចំណាយ ក៏អាស្រ័យទៅលើ ថាតើអ្នកអាចធ្វើតាមការណែនាំបានខ្ជាប់ខ្ជួនប៉ុនណា ហើយតើអ្នកបានបង្កើនភាពស្ទាត់ជំនាញ ដែលចាំបាច់ក្នុងការសិក្សាដោយខ្លួនឯងនេះ បានល្អប៉ុនណាដែរ។ ការដាក់គម្រោងកាលវិភាគសិក្សារបស់អ្នក ជាប្រយោជន៍ឲ្យអ្នកអាចចំណាយពេលវេលាគ្រប់គ្រាន់ដើម្បីសម្រេចបានគោលដៅដែលអ្នកនិពន្ធបានដាក់ឲ្យ ក៏ដូចជាគោលដៅផ្ទាល់ខ្លួនរបស់អ្នកផងដែរ។

មេរៀននីមួយៗ រួមបញ្ចូលទាំងសេចក្តីណែនាំ គម្រោង និងវត្ថុបំណងដើម្បីនាំផ្លូវការសិក្សារបស់អ្នក មានទាំងសកម្មភាពក្នុងការរៀន ពាក្យគន្លឹះ លំហាត់អនុវត្តន៍ក្នុងមេរៀន និងលំហាត់សាកល្បងផ្ទាល់ខ្លួននៅចុងមេរៀននីមួយៗ។ ចម្លើយនៃលំហាត់អនុវត្តន៍ មាននៅចុងបញ្ចប់មេរៀននីមួយៗ ហើយចម្លើយនៃលំហាត់សាកល្បងផ្ទាល់ខ្លួន មាននៅខាងចុងបញ្ចប់នៃសៀវភៅ ដូច្នេះអ្នកអាចរំឭកដំណើរការនៃការរៀនសូត្ររបស់អ្នកបាន។

## គំនិតយោបល់សម្រាប់ការសិក្សា

១. ញែកពេលវេលាឲ្យបានស្ងប់ស្ងាត់ និង ទៀងទាត់ សម្រាប់ការសិក្សារបស់អ្នក។ វាមានភាពងាយស្រួលក្នុងការផ្តោតអារម្មណ៍ជាជាង ប្រសិនបើការសិក្សាជាផ្នែកមួយនៃទម្លាប់របស់អ្នក។

២. អធិស្ឋានមុខពេលដែលអ្នកចាប់ផ្តើមការសិក្សារៀនសូត្ររបស់អ្នក។ ដោយមានព្រះគម្ពីរមួយរួមទាំងព្រះវិញ្ញាណដ៏វិសុទ្ធ និង មុខវិជ្ជានេះ អ្នកនឹងបាននៅក្នុងថ្នាក់រៀននៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ទូលសូម ព្រះជាម្ចាស់ដើម្បីឲ្យទ្រង់ជួយអ្នក ស្វែងយល់មេរៀននេះ ហើយយកវានៅដាក់ក្នុងជីវិតរបស់អ្នក។

៣. អានសេចក្តីណែនាំ គម្រោង និងគោលដៅ។ វានឹងផ្តល់ជូនអ្នកនូវសេចក្តីសង្ខេបទូទៅរបស់មេរៀន ជួយអ្នកឲ្យផ្តោតការយកចិត្តទុកដាក់របស់អ្នកទៅលើចំណុចសំខាន់ក្នុងពេលដែលអ្នកកំពុងសិក្សា ហើយវានឹងប្រាប់អ្នកពីអ្វីដែលអ្នកត្រូវរៀន។

៤. អានមេរៀនដោយប្រុងប្រយ័ត្ន។ បើកមើលខគម្ពីរយោង និងធ្វើការកត់ត្រា ដែលអាចមានប្រយោជន៍។ ខគម្ពីរ ជួយបញ្ជាក់បន្ថែមពីលើចំណុចសំខាន់របស់មេរៀន។

៥. ឆ្លើយលំហាត់អនុវត្តន៍ នៅក្នុងចន្លោះដែលបានដាក់ឲ្យ។ ចម្លើយដែលវែងអាចសរសេរនៅក្នុងសៀវភៅកត់ត្រាក៏បាន។ ពេលអ្នកសរសេរ ចម្លើយរបស់អ្នកសូម កត់ត្រាលេខរៀង និងចំណងជើងមេរៀនផងដែរ។ សូមកុំមើលចម្លើយ ភ្លាមៗឡើយ។ ការឆ្លើយចម្លើយដោយខ្លួនឯង នឹងជួយឲ្យអ្នកចងចាំមេរៀនដែលអ្នកបានរៀន។ បន្ទាប់ពីឆ្លើយលំហាត់អនុវត្តន៍រួចហើយ ផ្ទៀងផ្ទាត់ចម្លើយរបស់អ្នកជាមួយចម្លើយដែលបានផ្តល់ជូននៅខាងចុងនៃមេរៀន បន្ទាប់មកពិនិត្យមើលសាឡើងវិញនូវចម្លើយដែលអ្នកឆ្លើយខុស។ ចម្លើយដែលយើងឲ្យ គឺមិននៅតាមលំដាប់លំដោយលេខរៀងទេ ដូច្នេះអ្នកនឹងមិនអាចមើលឃើញចម្លើយនៃសំណួរបន្ទាប់ដោយចៃដន្យឡើយ។ លំហាត់អនុវត្តន៍ទាំងនេះពិតជាសំខាន់ខ្លាំងណាស់។ ពួកវានឹងជួយឲ្យអ្នកបានចងចាំគំនិតសំខាន់របស់មេរៀន ហើយប្រើប្រាស់គោលការណ៍ដែលអ្នកបានរៀនហើយ។

៦. នៅចុងបញ្ចប់នៃមេរៀននីមួយៗ ចូរធ្វើលំហាត់សាកល្បងផ្ទាល់ខ្លួន បន្ទាប់មកពិនិត្យមើលចម្លើយរបស់អ្នកដោយប្រើ ចម្លើយសំខាន់នៅផ្នែកខាងក្រោយនៃសៀវភៅ។

៧. នៅចុងបញ្ចប់នៃជំពូកនីមួយៗ សូមឆ្លើយសំណួរវាយតម្លៃតាមជំពូកនោះ។

៨. ចំណាយពេលវេលារបស់អ្នក និង រៀននៅកន្លែងស្ងប់ស្ងាត់។

## របៀបឆ្លើយសំណួរសិក្សា

មានលំហាត់សិក្សា និង សំណួរសាកល្បងខ្លួនឯងជាច្រើនប្រភេទនៅក្នុងសៀវភៅនេះ។ នៅខាងក្រោមនេះជាមួយឧទាហរណ៍នៃប្រភេទសំណួរនីមួយៗ និងរបៀបឆ្លើយសំណួរ។ ការពន្យល់បញ្ជាក់បន្ថែមនឹងផ្តល់ជូនសម្រាប់ប្រភេទសំណួរផ្សេងៗទៀត។

## សំណួរពហុជម្រើស

សំណួរពហុជម្រើសតម្រូវឲ្យអ្នកជ្រើសរើសចម្លើយមួយក្នុងចំណោមចម្លើយដែលបានឲ្យ។

ឧទាហរណ៍

១. កណ្ឌគម្ពីរសរុបមានចំនួន

ក. ១០០កណ្ឌ

(ខ.) ៦៦កណ្ឌ

គ. ២៧កណ្ឌ

ចម្លើយត្រឹមត្រូវគឺ ខ. ៦៦កណ្ឌ។ អ្នកអាចគូសរង្វង់ជុំវិញ អក្សរ ខ. ដូចដែលបានបង្ហាញនៅខាងលើ។

( សម្រាប់សំណួរពហុជម្រើសខ្លះ មានចម្លើយត្រឹមត្រូវលើសពីមួយ។ ក្នុងករណីនេះ ចូរគូសរង្វង់ជុំវិញអក្សរ នៃចម្លើយត្រឹមត្រូវនីមួយៗ។)

## ចម្លើយត្រូវ/ខុស

ចំណុចឬ សំណួរត្រូវ/ខុស តម្រូវឲ្យអ្នកជ្រើសរើសចម្លើយពីរ ឬ បី ដែលត្រឹមត្រូវ។

## ឧទាហរណ៍

១. តើឃ្លាប្រយោគខាងក្រោមនេះ ប្រយោគណាខ្លះ ដែលត្រឹមត្រូវ?

(ក.) ព្រះគម្ពីរជាព្រះរាជសារសម្រាប់ ពួកអ្នកជឿនៅសព្វថ្ងៃនេះ។

ខ. ព្រះគម្ពីរសរុបទាំងអស់ មាន១២០កណ្ឌ។

(គ.) ព្រះវិញ្ញាណដ៏វិសុទ្ធបានបំភ្លឺឲ្យអ្នកនិពន្ធតាក់តែងព្រះគម្ពីរ

ប្រយោគ ក. និង គ. គឺជាចម្លើយត្រឹមត្រូវ។ អ្នកត្រូវគូសរង្វង់ពីលើអក្សរ ទាំងពីរនេះ ដូចបាន បង្ហាញក្នុងឧទាហរណ៍ស្រាប់។

## សំណួរផ្គូផ្គង

សំណួរផ្គូផ្គង តម្រូវឲ្យអ្នកផ្គូផ្គងអ្វីដែលត្រូវគ្នា។

## ឧទាហរណ៍

៣. ចូរសរសេរលេខនៃឈ្មោះអ្នកដឹកនាំ នៅពីមុខប្រយោគដែលនិយាយពីសកម្មភាពពួកគេបានធ្វើ។

..1..ក) បានទទួលក្រឹត្យវិន័យ នៅលើភ្នំស៊ីណៃ — ១) ម៉ូសេ

..2..ខ) បានដឹកនាំជនជាតិអ៊ីស្រាអែល ឆ្លងកាត់ទន្លេយ័រដាន់ — ២) យ៉ូស្វេ

..2..គ) បានដើរក្បួនជុំវិញ ក្រុងយេរីខូ

..1..ឃ) បានរស់នៅក្នុងវាំងរបស់ស្តេចផារ៉ោន

ឃ្លា ក) និង ឃ) និយាយអំពី លោកម៉ូសេ ហើយ ឃ្លា ខ) និង គ) និយាយអំពីលោក យ៉ូស្វេ។ អ្នកត្រូវតែ សរសេរលេខ ១ នៅត្រង់ ក) និង ឃ) ហើយសរសេរលេខ ២ នៅត្រង់ ខ) និង គ) ដូច បានបង្ហាញក្នុងឧទាហរណ៍ស្រាប់។

# ការប្រឡងតាមជំពូក

នៅចុងបញ្ចប់នៃ មុខវិជ្ជានេះ អ្នកនឹងឃើញការវាយតម្លៃតាមជំពូក និង តារាងចម្លើយ។ សូមធ្វើតាមការណែនាំដែលបានដាក់ជូនដោយប្រុងប្រយ័ត្ន។ ឆ្លើយសំណួរទាំងអស់ រួចផ្ញើតារាងចម្លើយរបស់អ្នកទៅឲ្យគ្រូរបស់អ្នកធ្វើការកែតម្រូវ។ បន្ទាប់មកអ្នកអាចធ្វើការ រំឭកសាឡើងវិញនូវមុខវិជ្ជានេះ ហើយ និង សំណួរដែលទាក់ទងជាមួយព្រះគម្ពីរដែលគិតថាពិបាកសម្រាប់អ្នក ។ ការរំឭកសាឡើងវិញ នូវវត្ថុបំណង លំហាត់អនុវត្តន៍ និង ចម្លើយសាកល្បងខ្លួនឯង  និងលំហាត់ក្នុងជំពូក វាជួយអ្នកឲ្យត្រៀមខ្លួនសម្រាប់ការប្រលងបញ្ចប់។ សម្រាប់និស្សិតដែលរៀនតាមរយៈការិយាល័យជាតិ ឬ ក្រុមសិក្សាតាមតំបន់ អាចទាក់ទងគ្រូ ឬ អ្នកដឹកនាំរបស់ពួកគេ ដើម្បីទទួលបានព័ត៌មានអំពីការវាយតម្លៃតាមជំពូក។ ប្រសិនបើ អ្នកមិនបានរៀនជាផ្លូវការតាមរយៈសាកលវិទ្យាល័យគ្លូបល ឬក្រុមសិក្សាទេ  អ្នកនៅតែអាចទទួលបានផលប្រយោជន៍ពីការវាយតម្លៃសម្រាប់ជំពូកនេះដែរ។

# អំពីអ្នកនិពន្ធ

លោក រ៉ូប៊ើត អិល. ប្រាន ទទួលបានការចាក់ប្រេងតាំងនៅឆ្នាំ ១៩៤០ និង ជាប្រធានប្រតិបត្តិបុព្វជិតនៅក្នុងអគ្គក្រុមប្រឹក្សារបស់ក្រុមជំនុំព្រះជាម្ចាស់។ លោកបានបម្រើការជាគ្រូគង្វាល អស់រយៈពេល១៦ ឆ្នាំ ជាអ្នកត្រួតការប្រចាំតំបន់ ដាខូតាខាងជើង(North Dakota District) និងជាអ្នកត្រួតការប្រចាំតំបន់ មោនថែនណា (Montana District)។ លោកធ្លាប់បម្រើការជាលេខាធិការបេសកកម្មក្នុងប្រទេស National Home សម្រាប់ក្រុមជំនុំព្រះជាម្ចាស់ និង ជាគណៈកម្មការអ្នកដឹកនាំឲ្យមហាវិទ្យាល័យពាយព្យ (Northwest college)របស់ក្រុមជំនុំព្រះជាម្ចាស់ ។ លោកក៏ធ្លាប់ជាសមាជិកនៃគណៈកម្មការបេសកកម្មក្រៅទេសសម្រាប់អគ្គក្រុមប្រឹក្សានៃក្រុមជំនុំព្រះជាម្ចាស់ និងធ្លាប់បានបម្រើការនៅក្នុងគណកម្មការ គោលលិទ្ធិបរិសុទ្ធរបស់ក្រុមជំនុំផងដែរ។

បន្ថែមពីលើការបង្រៀន និង ចែកចាយយ៉ាងធំទូលាយនេះ លោក រ៉ូប៊ើត អិល. ប្រានក៏ជាអ្នកនិពន្ធសម្រាប់ដំណឹងល្អ *the Pentecostal Evangel*, សម្រាប់ថ្នាក់ថ្ងៃអាទិត្យរៀងរាល់បីខែម្តង សម្រាប់ *Enrichment Magazine,* និង the Gospel Publishing Houseនៅ Springfield, Missouri។ លោកបាននិពន្ធសៀវភៅខ្លះៗដូចជា *Praying with Paul, One Way, Gifts for the Marketplace, Tongues the Greatest Gift?, និង The Spirit Helps Us Pray.*

លោក រ៉ូប៊ើត អិល. ប្រាន បានបញ្ចប់ការសិក្សាមកពី សាកលវិទ្យាល័យ North Central University,នៅ Minneapolis, Minnesota និង ត្រូវបានតែងតាំងជាបណ្ឌិតកត្តិយសដោយ Northwest College នៅ Kirkland,ទីក្រុង Washington. លោកបានធ្លាប់បានដឹកនាំការជួបជុំបោះជំរុំ គ្រិះស្ថានសិក្សាព័ន្ធកិច្ច និង ក្រុមប្រឹក្សាតំបន់នៅពាសពេញសហរដ្ឋអាមេរិក និង នៅបណ្តាប្រទេសដទៃទៀតផងដែរ។ លោក រ៉ូប៊ើត អិល. ប្រាន បានទទួលមរណភាពនៅក្នុងឆ្នាំ២០០៧

# ជំពូកទី ២

# ជំពូកទី មួយ
# ការណែនាំអំពីព្រះអំណោយទាន
# ខាងឯវិញ្ញាណ

<u>មេរៀន</u>

១ ព្រះជាម្ចាស់មានព្រះអំណោយទានសម្រាប់អ្នក

២ ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យអ្នកស្គាល់ពីព្រះអំណោយទានរបស់ទ្រង់

**មេរៀនទី** **១**

# ព្រះជាម្ចាស់មាន អំណោយទានសម្រាប់អ្នក

នេះគឺជាមេរៀនទីមួយ ក្នុងចំណោមមេរៀនពីរដែលត្រូវរចនាឡើងដើម្បីផ្តល់ជូនអ្នកនូវ *គ្រឹះមូលដ្ឋាន* សម្រាប់អ្វីៗទាំងអស់ដែលអ្នកនឹងសិក្សានៅក្នុងមុខវិជ្ជានេះ។ នៅក្នុងមេរៀនទីមួយនេះអ្នកនឹងរៀនអំពីសារៈសំខាន់របស់អ្នកនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត។

មានតែសមាជិកនៃព្រះកាយរបស់ព្រះគ្រិស្តប៉ុណ្ណោះដែលអាចទទួលបានព្រះអំណោយទានខាងឯវិញ្ញាណ។ ដូច្នេះហើយបានជា អ្នកត្រូវរៀនឲ្យបានច្រើនបំផុតអំពីព្រះកាយរបស់ទ្រង់ និង របៀបដែលព្រះកាយរបស់ទ្រង់ធ្វើការ។ នៅពេលដែលអ្នកទទួលយកព្រះយេស៊ូជាព្រះអង្គសង្គ្រោះរបស់អ្នក នោះអ្នកបានក្លាយជាផ្នែកមួយនៃព្រះកាយរបស់ទ្រង់។ អ្នកជឿគ្រប់រូប គឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងព្រះកាយមួយនេះ។ ព្រះជាម្ចាស់ប្រទានព្រះអំណោយទានទៅដល់សមាជិកម្នាក់ៗ។ ព្រះអំណោយទាននេះ មានភាពដោយឡែកពីគ្នា ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។

ក្នុងនាមជាមនុស្សជាតិ អ្នកគឺជាផ្នែកមួយនៃគ្រួសារខាងឯលោកីយ៍ ឬក្រុមណាមួយ។ នៅពេលដែលអ្នកបានក្លាយជាអ្នកជឿព្រះយេស៊ូ អ្នកក៏បានក្លាយជាផ្នែកនៃគ្រួសារ ឬ ក្រុមមួយដ៏សំខាន់ជាងនេះទៅទៀត នោះគឺព្រះកាយរបស់ព្រះគ្រិស្ត។ ក្នុងពេលដែលយើងរៀនមេរៀននេះ អ្នកនឹងចាប់ផ្តើមមើលឃើញថាខ្លួនអ្នកសំខាន់កម្រិតល្អ សម្រាប់ព្រះជាម្ចាស់ និង សម្រាប់សមាជិកដទៃទៀតនៃព្រះកាយរបស់ទ្រង់។ អ្នកក៏នឹងរកឃើញថាទ្រង់មានអំណោយពិសេសមួយ ឬច្រើន សម្រាប់អ្នក និងឃើញថាទ្រង់រំពឹងលើរូបអ្នក។

## *គម្រោងនៃមេរៀន*

ក. យើងទាំងអស់គ្នាសុទ្ធតែជាសមាជិកនៃព្រះកាយរបស់ទ្រង់

ខ. សមាជិកទាំងអស់សុទ្ធតែសំខាន់

គ. យើងមិនត្រូវប្រៀបធៀបខ្លួនយើងទៅជាមួយនឹងអ្នកដទៃឡើយ។

ឃ. យើងត្រូវតែស្មោះត្រង់ជាមួយនឹងព្រះអំណោយទានដែលបានមកពីព្រះជាម្ចាស់

## *វត្ថុបំណងនៃមេរៀន*

នៅពេលដែលបញ្ចប់មេរៀនមួយនេះ អ្នកអាចនឹង ៖

១. រៀបរាប់អំពីផ្នែកចម្បងទាំងពីរ នៃព្រះកាយរបស់ព្រះគ្រិស្ត។

២. បកស្រាយអំពីមូលហេតុដែលសមាជិកម្នាក់ៗនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត មានសារៈសំខាន់

៣. និយាយអំពីមូលហេតុទាំងពីរដែលអ្នកជឿ មិនគួរប្រៀបធៀបខ្លួនគេ ទៅជាមួយនឹង អ្នកជឿដទៃទៀត។

៤. និយាយអំពីប្រភពនៃព្រះអំណោយទានខាងឯវិញ្ញាណ

៥. បកស្រាយអំពីរបៀបដែលព្រះអំណោយទានរបស់ព្រះជាម្ចាស់ គួរតែយកមកប្រើប្រាស់។

## *សកម្មភាពក្នុងការសិក្សា*

១. អានសេចក្តីសង្ខេបការវិវត្តន៍មេរៀន ហើយបើកមើលខគម្ពីរយោងនីមួយៗនៅក្នុងព្រះគម្ពីរ។

២. ចាប់ផ្តើមទន្ទេញចងចាំ ខគម្ពីរ១កូរិនថូស ជំពូក១៣។ អ្នកមុខជា អាចនិយាយឡើងវិញនូវខទាំងពីរដំបូងបាន ទម្រាំដល់ពេលអ្នកសិក្សាមេរៀនទីមួយនេះចប់។

៣. សិក្សាអំពីគម្រោងមេរៀន និង វត្ថុបំណងមេរៀន។ ដោយធ្វើដូច្នេះ វានឹងជួយអ្នកស្គាល់ពីអ្វីដែលអ្នកគួរតែរៀន។

៤. ពិនិត្យមើលអក្ខរានុក្រម នៅខាងចុងបញ្ចប់នៃមគ្គុទេសក៍សិក្សានេះ ដើម្បីបានដឹងពីនិយមន័យនៃពាក្យសំខាន់ទាំងឡាយណាដែលអ្នកមិនយល់។

៥. អានមេរៀន និង ធ្វើលំហាត់នៅក្នុងមេរៀន។ ចម្លើយរបស់អ្នកភាគច្រើន អាចធ្វើបាននៅក្នុងមគ្គុទេសក៍សិក្សានេះ។ ប៉ុន្តែបើចំណុចណាមួយដែលត្រូវការចម្លើយវែង សូមសរសេរចម្លើយរបស់អ្នកនៅក្នុងសៀវភៅកត់ត្រារបស់អ្នក។ ពិនិត្យមើលចម្លើយរបស់អ្នកជាមួយនឹងចម្លើយដែលបានផ្តល់ជូននៅក្នុងចុងបញ្ចប់នៃមេរៀន។

៦. ធ្វើសំណួរក្នុងការប្រឡងផ្ទាល់ខ្លួន នៅចុងបញ្ចប់នៃមេរៀន ហើយផ្ទៀងផ្ទាត់ចម្លើយរបស់អ្នកដោយប្រុងប្រយ័ត្ន ជាមួយនឹងចម្លើយដែលយើងបានផ្តល់ជូននៅផ្នែកខាងក្រោយនៃសៀវភៅមេរៀននេះ។ រំឭកឡើងវិញ រាល់ចំណុចណាមួយដែលអ្នកឆ្លើយមិនបានត្រឹមត្រូវ ។

## ពាក្យសំខាន់ៗ

ការយល់ដឹងពីពាក្យសំខាន់ដែលយើងដាក់ឲ្យនៅខាងផ្នែកដំបូងនៃគ្រប់មេរៀន នឹងជួយអ្នកនៅពេលដែលអ្នករៀន។ អ្នកនឹងឃើញមាន តារាងពាក្យសំខាន់ដែលតម្រៀបតាមលំដាប់លំដោយព្យញ្ជនៈ និង អត្ថន័យរបស់វាក្នុងអក្ខរានុក្រមនៅផ្នែកខាងក្រោយនៃសៀវភៅសិក្សាផ្ទាល់ខ្លួននេះ។ ប្រសិនជា អ្នកនៅមានមន្ទិលសង្ស័យ អំពីអត្ថន័យនៃពាក្យណាមួយនៅក្នុងតារាងនេះ អ្នកអាចរកមើលវានៅពេលនេះក៏បាន ឬ នៅពេលអ្នកបានឃើញវា ក្នុងអំឡុងពេលអានមេរៀនរបស់អ្នក។

| | | |
|---|---|---|
| បំពាក់ | អ្នកបម្រើជំនិត | ទេពកោសល្យ |
| មុខងារ | | |

# ក. យើងទាំងអស់គ្នាសុទ្ធតែជាសមាជិកនៃព្រះកាយរបស់ទ្រង់

**វត្ថុបំណងទី ១.** *រៀបរាប់អំពីផ្នែកចម្បងទាំងពីរ នៃព្រះកាយរបស់ព្រះគ្រិស្ត។*

## ព្រះគ្រិស្តគឺជាសិរសា

ពួកយើងត្រូវការជំនួយក្នុងការស្វែងយល់ពីទំនាក់ទំនងរវាងព្រះគ្រិស្តជាមួយនឹងអស់អ្នកជឿលើទ្រង់។ លោកសាវ័កប៉ូលបានប្រើប្រាស់រាងកាយមនុស្សដើម្បី គូសបង្ហាញពីការនេះ។ លោកបានចង្អុលបញ្ជាក់ថាព្រះគ្រិស្តគឺជាសិរសានៃព្រះកាយនោះ។ ពួកយើងទាំងអស់គ្នាក៏បានដឹងថាក្បាលរបស់យើងមានសារៈសំខាន់យ៉ាងណាហើយ។ មានរឿងពីរប្រាកដជាកើតឡើងចំពោះយើង ប្រសិនបើគ្មានក្បាលទេនោះ។ ទីមួយ យើងមុខជាស្លាប់មិនខាន។យើងមិនអាចរស់បានដោយគ្មានក្បាលនោះទេ។ ទីពីរ យើងមុខជាគ្មានចលនា និង គ្មានប្រយោជន៍នោះទេ។ ក្បាលដឹកនាំខ្លួនប្រាណ ទៅធ្វើសកម្មភាពដែលមានន័យ។ ក្នុងរបៀបដូចគ្នានេះ ព្រះគ្រិស្តដែលជាសិរសា សព្វព្រះទ័យដឹកនាំព្រះកាយរបស់ទ្រង់ឲ្យធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់។ ឈ្មោះមួយផ្សេងទៀតនៃព្រះកាយ របស់ព្រះគ្រិស្ត គឺក្រុមជំនុំ ។

### *លំហាត់អនុវត្តន៍*

---

១ ចូរអានគម្ពីរកូឡុស ១:១៥-១៨។ ឆ្លើយនឹងសំណួរខាងក្រោមនេះ។

ក) តើលោកប៉ូលនិយាយសំដៅទៅលើអ្នកណា នៅក្នុងខគម្ពីរនេះ?.........................................

ខ) តើមានពាក្យអ្វីទៀតដែលរៀបរាប់អំពីព្រះកាយរបស់ព្រះគ្រិស្ត? ..........................................

---

នៅក្នុងព្រះគម្ពីរ បាននិយាយជាច្រើនលើកច្រើនសាអំពីព្រះគ្រិស្តដែលជាសិរសា នៃព្រះកាយមួយនោះ។ អ្នកត្រូវតែអានខគម្ពីរនីមួយៗ យ៉ាងប្រុងប្រយ័ត្នចំនួនបីដង៖ គម្ពីរអេភេសូ១:២២-២៣; ៤:១៥-១៦; ៥:២៣ និង គម្ពីរកូឡុស២:១៩។

## អ្នកជឿគឺជាព្រះកាយ

ក្បាលដែលគ្មានខ្លួន គឺឥតបានការ ដូចជាខ្លួនដែលគ្មានក្បាលផងដែរ។ ក្បាលគឺពិតជាសំខាន់ ប៉ុន្តែខ្លួនក៏សំខាន់ដែរ។ ព្រះកាយរបស់ព្រះគ្រិស្ត ត្រូវបានបង្កើតឡើងពីអស់អ្នកដែលជឿលើព្រះនាមរបស់ទ្រង់។ ក្នុងនាមជាអ្នកជឿម្នាក់ អ្នកគឺជាផ្នែកមួយនៃព្រះកាយរបស់ទ្រង់។ នោះគឺជាសេចក្តីពិតដ៏អស្ចារ្យមួយ។ លោកប៉ូលបានសរសេរថា "យើងក៏ដូច្នោះដែរ យើងមានគ្នាច្រើនរួមជាព្រះកាយតែមួយក្នុងអង្គព្រះគ្រិស្ត ហើយម្នាក់ៗជាសរីរាង្គរបស់គ្នាទៅវិញទៅមក" ( គម្ពីររ៉ូម ១២:៥)។

### លំហាត់អនុវត្តន៍

២ ចូរអានគម្ពីរ១កូរិនថូស ១២:១២-១៣; គម្ពីរអេភេសូ ៤:៤; ៥: ២៩-៣០, និង គម្ពីរកូឡូស ១:២៤។ ចូរបំពេញប្រយោគខាងក្រោម ដោយដាក់ចម្លើយត្រឹមត្រូវ។

ក) ព្រះគ្រិស្តគឺជា..............................................................................................នៃព្រះកាយ។

ខ) ឈ្មោះមួយទៀតរបស់ព្រះកាយរបស់ព្រះគ្រិស្តគឺ..................................................................

គ) អ្នកជឿគឺជាសរីរាង្គនៃ...........................................................................របស់ព្រះគ្រិស្ត។

## អ្នកជឿម្នាក់ៗគឺជាសមាជិក

នៅក្នុងព្រះកាយរបស់ព្រះគ្រិស្តមាន ពីរផ្នែកសំខាន់ៗ ៖ (១) មានព្រះសិរសាមួយ និង (២) សមាជិកជាច្រើន។ រូបកាយរបស់យើងមិនគ្រាន់តែមានសមាជិកមួយប៉ុណ្ណោះទេ ប៉ុន្តែមានច្រើនសន្ធឹក។ ដៃ ជើង ម្រាមដៃ បេះដូង ជាដើម សុទ្ធតែជាសមាជិកផ្សេងៗគ្នា នៃរូបកាយរបស់យើង។ ព្រះកាយរបស់ព្រះគ្រិស្តក៏យ៉ាងដូច្នេះដែរ។ អ្នកជឿដ៏ពិតប្រាកដគ្រប់រូបក្លាយជាផ្នែកនៃព្រះកាយរបស់ទ្រង់។ នេះមានន័យថា អ្នកជឿដ៏ពិតគ្រប់រូបនៅក្នុងពិភពលោកនេះ គឺជាផ្នែកនៃព្រះកាយរបស់ទ្រង់៖ "រូបកាយមិនមែនមានសរីរាង្គតែមួយទេ គឺមានច្រើន (គម្ពីរ១កូរិនថូស ១២:១៤)។ មនុស្សម្នាដែលមកពីពូជសាសន៍ ពណ៌សម្បុរ ទឹកដី និង ប្រទេសគ្រប់ទាំងអស់ គឺជាផ្នែកនៃព្រះកាយតែមួយ។

### លំហាត់អនុវត្តន៍

៣ ចូរសរសេរឈ្មោះផ្នែកសំខាន់ៗទាំងពីរនៃព្រះកាយរបស់ព្រះគ្រិស្ត ហើយគូសសញ្ញា X ពីក្រោយផ្នែកដែលអ្នកបានចូលរួមចំណែក។

ក) .......................................................................................................................

ខ) .......................................................................................................................

៤ ចូរគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវ ៖ ដូចទៅនឹងរូបកាយរបស់យើង ព្រះកាយរបស់ព្រះគ្រិស្តមាន

ក) សមាជិកតែមួយ

ខ) សមាជិកជាច្រើន

# ខ. សមាជិកទាំងអស់សុទ្ធតែសំខាន់

**វត្ថុបំណងទី២.** *បកស្រាយអំពីមូលហេតុដែលសមាជិកម្នាក់ៗនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត មានសារៈសំខាន់។*

## សមាជិកគ្រប់រូប សុទ្ធតែជាផ្នែកនៃព្រះកាយ

តើមេជើងរបស់អ្នក នឹងអាចធ្វើអ្វីបានប្រសិនបើវាដាច់ចេញពីរាងកាយរបស់អ្នក? វាមុខជាត្រូវរលួយ និង ត្រឡប់ទៅជាធូលីដី។ ដូច្នេះមេជើងរបស់អ្នកគឺជាផ្នែកសំខាន់មួយនៅក្នុងរូបកាយរបស់អ្នក។ រូបកាយរបស់អ្នកមិនអាចពេញលេញបានឡើយ បើគ្មានវា។ រូបកាយមួយដែលមិនមានគ្រប់ផ្នែកទាំងអស់នៃសរីរាង្គរបស់វា គឺមានដែនកំណត់ចំពោះអ្វីដែលវាអាចធ្វើបាន។ ឧទាហរណ៍ មនុស្សម្នាក់ដែលគ្មានជើង មិនអាចរត់ប្រណាំងបានឡើយ។ មនុស្សម្នាក់ដែលគ្មានភ្នែកមិនអាចមើលឃើញផ្កាយបានឡើយ។ មនុស្សម្នាក់ដែលគ្មានដៃមិនអាចឡើងដើមឈើបានទេ។

សមាជិកគ្រប់រូបនៅក្នុងព្រះកាយរបស់ព្រះគ្រិស្តសុទ្ធតែមានសារៈសំខាន់ណាស់ចំពោះទ្រង់។ "បងប្អូនជាព្រះកាយរបស់ព្រះគ្រិស្ត ហើយម្នាក់ៗជាសរីរាង្គនៃព្រះកាយនេះ តាមចំណែករៀងៗខ្លួន" (គម្ពីរ ១កូរិនថូស ១២:២៧)។ យើងប្រហែលជាអាច ពង្រីកគោលគំនិតមួយនេះបានដោយនិយាយថាសមាជិកនៅក្នុងព្រះកាយរបស់ព្រះគ្រិស្តគឺជាចំណែកនៃព្រះកាយនោះ។ គាត់គឺកំណាត់ ឬ ភាគ នៃព្រះកាយ ដូចជាម្រាមជើងគឺជាចំណែក ជាកំណាត់ ឬ ជាភាគមួយនៃរូបកាយរបស់អ្នកផងដែរ។

### *លំហាត់អនុវត្តន៍*

---

៥ ចូរអានគម្ពីរ១កូរិនថូស ១២:១៥-២៦។ សរសេរអក្សរ **ត** នៅក្នុងចន្លោះបន្ទាត់ ប្រសិនបើប្រយោគនោះត្រឹមត្រូវ ហើយសរសេរអក្សរ **ខ** ប្រសិនបើវាខុស។

..........ក) អ្នកជឿគ្រប់រូបគឺជាផ្នែកនៃព្រះកាយរបស់ព្រះគ្រិស្ត។

..........ខ) សមាជិកគ្រប់រូបនៃព្រះកាយរបស់ព្រះគ្រិស្តគឺខុសគ្នា។

..........គ) សមាជិកនៃព្រះកាយរបស់ព្រះគ្រិស្តមិនត្រូវការគ្នាទៅវិញទៅមកទេ។

---

## សមាជិកគ្រប់រូបមានមុខងារជាក់លាក់ផ្សេងៗគ្នា

ម្រាមជើង និង ត្រចៀករបស់អ្នក មិនបំពេញមុខងារដូចគ្នានោះទេ។ ភ្នែក និង ជើងរបស់អ្នកក៏មិនដូចគ្នាដែរ។ ដូច្នេះហើយ នៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត សមាជិកទាំងអស់មិនមានតួនាទីដូចគ្នាឡើយ។ ផ្ទុយទៅវិញសមាជិកគ្រប់រូប មានមុខងារផ្ទាល់ខ្លួនរបស់គេ។ *មុខងារ* គឺមានន័យថា "កិច្ចការ ឬ កាតព្វកិច្ចពិសេស។" មុខងាររបស់ភ្នែកគឺដើម្បីមើល។ សូមគិតឡើងវិញអំពីមេជើងរបស់អ្នក។ វាប្រហែលជាត្រូវបានគ្របបាំងដោយស្បែកជើង។ អ្នកប្រហែលជាកម្រគិតពីវាណាស់ ប៉ុន្តែវាមានការងារ និង កាតព្វកិច្ចសំខាន់របស់វា។ ក្រៅពីមានមុខងារជាផ្នែកដែលអមជាមួយម្រាមជើងដទៃទៀត ដើម្បីបង្កើតបានជាប្រអប់ជើងដែលគ្រប់លក្ខណៈមួយ វាក៏ជួយទប់លំនឹងខ្លួនរបស់អ្នកទាំងមូលផងដែរ។ ការបាត់បង់មេជើងរបស់អ្នក នោះអ្នកនឹងនឹកវាខ្លាំងណាស់។ គ្រប់ផ្នែកផ្សេងៗទៀត នៃរូបកាយរបស់អ្នកទទួលបានប្រយោជន៍មកពីវា។

អ្នកនឹងជំពប់យ៉ាងងាយ ពេលគ្មានវា។ អ្នកនឹងមិនអាចរត់បានល្អនោះទេ។ អ្នកប្រហែលជាអាចនឹងដើរខ្ញើចៗផងដែរ។

សមាជិកនៃព្រះកាយរបស់ព្រះគ្រិស្តក៏ដូចជាសរីរាង្គនៃរូបកាយរបស់អ្នកផងដែរ។ សមាជិកម្នាក់ៗមានមុខងារផ្ទាល់ខ្លួនរបស់គាត់ និងមានសារៈសំខាន់ណាស់សម្រាប់ទាំងក្បាល និង ផ្នែកផ្សេងៗទៀតនៃរូបកាយ។

### *លំហាត់អនុវត្តន៍*

៦ ចូរអានគម្ពីររ៉ូម ១២:៦-៨ និង គម្ពីរ១កូរិនថូស ១២:១៨-២៥។ សរសេរអក្សរ **ត** នៅក្នុងចន្លោះបន្ទាត់ប្រសិនបើប្រយោគនោះត្រឹមត្រូវ និង សរសេរអក្សរ **ខ** ប្រសិនបើប្រយោគនោះខុស។

..........ក) សមាជិកនៃព្រះកាយរបស់ព្រះគ្រិស្តទាំងអស់មានមុខងារដូចៗគ្នា។

..........ខ) មុខងារមានន័យថារូបកាយ។

..........គ) គ្រប់សមាជិកនៅក្នុងព្រះកាយរបស់ព្រះគ្រិស្តទាំងអស់គឺមានសារៈសំខាន់ ព្រោះតែពួកគេមានមុខងារផ្ទាល់ខ្លួន។

# គ. យើងមិនត្រូវប្រៀបធៀបខ្លួនយើងទៅជាមួយនឹងអ្នកដទៃឡើយ។

**វត្ថុបំណងទី៣.** *និយាយអំពីមូលហេតុទាំងពីរដែលអ្នកជឿ មិនគួរប្រៀបធៀបខ្លួនគេ ទៅជាមួយនឹងអ្នកជឿដទៃទៀត។*

## ការប្រៀបធៀបធ្វើឲ្យព្រះជាម្ចាស់មិនសព្វព្រះទ័យ

ព្រះជាម្ចាស់បានបង្កើតយើងរាល់គ្នា ឲ្យមានលក្ខណៈខុសពីគ្នា ដូចជាទ្រង់បានបង្កើតសរីរាង្គនៃរូបកាយរបស់យើងឲ្យមានលក្ខណៈខុសពីគ្នាផងដែរ។ តើអ្នកគិតថា ព្រះជាម្ចាស់ទ្រង់អាចសព្វព្រះហឫទ័យដែរឬទេ ប្រសិនបើអ្នករអ៊ូរដោយសារតែមេជើងរបស់អ្នកមិនទៅនៅកន្លែងច្រមុះវិញនោះ? ។ យើងដឹងហើយថា ព្រះជាម្ចាស់បានបង្កើតផ្នែកនីមួយៗរបស់យើង ហើយបានដាក់វានៅកន្លែងដែលវាអាចបំពេញគោលបំណងរបស់វាបាន។

នៅពេលដែលយើង ប្រៀបធៀបខ្លួនយើង ទៅជាមួយសមាជិកដទៃទៀត នៃព្រះកាយរបស់ព្រះគ្រិស្ត ហើយរអ៊ូរទាំដោយសារតែយើងមិនដូចជាពួកគេ នោះយើងធ្វើឲ្យព្រះអម្ចាស់មិនសព្វព្រះហឫទ័យហើយ។ ពួកយើងគ្រប់គ្នាត្រូវដឹងថា ទ្រង់បានបង្កើតយើងមកជាខ្លួនយើង និង បានដាក់យើងនៅកន្លែងដែលយើងនៅសម្រាប់ផលប្រយោជន៍នៃព្រះកាយទាំងមូល និង សម្រាប់សិរីរុងរឿងរបស់ទ្រង់ផ្ទាល់ផងដែរ។

ការមិនសប្បាយចិត្ត ដោយសារតែព្រះអំណោយទានរបស់យើងមិនដូចជាព្រះអំណោយទានរបស់អ្នកដទៃទៀត បានធ្វើឲ្យយើងក្លាយជាអ្នកវិនិច្ឆ័យព្រះជាម្ចាស់។ វាហាក់បីដូចជានិយាយថា " ព្រះជាម្ចាស់អើយ ហេតុអ្វីបានទ្រង់មិនប្រទានព្រះអំណោយទាននោះមកឲ្យទូលបង្គំ?" បើអ្នកវិញ តើអ្នកនឹងមានអារម្មណ៍បែបណា ប្រសិនបើអ្នកបានឲ្យកាដូ ទៅឲ្យមិត្តភក្តិបីនាក់របស់អ្នក ដែលវាសមជាមួយនឹងតួនាទី

របស់គេនៅក្នុងជីវិត ហើយមានម្នាក់ក្នុងចំណោមពួកគេ រអ៊ូរទាំព្រោះតែគាត់មិនបានទទួលកាដូដូចអ្នកបានឲ្យទៅពីរនាក់ផ្សេងទៀត? អ្នកមុខជាមិនសប្បាយចិត្តឡើយ។

## *លំហាត់អនុវត្តន៍*

៧ ចូរអានគម្ពីរ ១កូរិនថូស ១២:១៥-១៨ ។ យើងស្វែងយល់នៅក្នុងខគម្ពីរទាំងនេះថា យើងមិនត្រូវប្រៀបធៀបខ្លួនយើងទៅជាមួយអ្នកដទៃសោះឡើយ។ ចូរគូសរង្វង់នៅជុំវិញអក្សរដែលនៅពីមុខមូលហេតុត្រឹមត្រូវ ចំពោះការដែលមិនគួរប្រៀបធៀបខ្លួនទៅជាមួយអ្នកដទៃ។

ក) ការប្រៀបធៀបខ្លួនយើងទៅជាមួយអ្នកដទៃធ្វើឲ្យព្រះអម្ចាស់មិនសព្វព្រះហឫទ័យ។

ខ) ការប្រៀបធៀបខ្លួនយើងទៅជាមួយអ្នកដទៃធ្វើឲ្យយើងបានក្លាយជាផ្នែកមួយនៃព្រះកាយរបស់ព្រះគ្រិស្ត។

គ) ការប្រៀបធៀបខ្លួនយើងទៅជាមួយអ្នកដទៃ បង្ហាញឲ្យយើងបានឃើញថា យើងមិនដឹងថាយើងមានសារៈសំខាន់យ៉ាងណានៅក្នុងព្រះកាយនោះទេ។

## ការប្រៀបធៀប បំបាក់ទឹកចិត្តរបស់មនុស្ស

មានរឿងពីរ នឹងអាចកើតមានឡើងនៅពេលដែលយើងប្រៀបធៀបព្រះអំណោយទានរបស់យើងទៅជាមួយអ្នកដទៃ។ ទីមួយ *ពួកយើង* អាចនឹងបាក់ទឹកចិត្ត ដោយសារតែព្រះអំណោយទានរបស់យើងមិនដូចជារបស់អ្នកដទៃ។ ព្រះអំណោយទានរបស់យើងមើលទៅ មិនសូវជាមានសារៈសំខាន់ដូចរបស់អ្នកដទៃនោះទេ។ ទីពីរ យើងអាចនឹងមានអំណួត ដោយសារតែយើងគិតថាព្រះអំណោយទានរបស់យើង គឺល្អប្រសើរជាងរបស់អ្នកដទៃ ។ ដូច្នេះយើងអាចបំបាក់ទឹកចិត្តរបស់ *អ្នកដទៃ* ។

ពួកយើងម្នាក់ៗត្រូវតែដឹងថា ព្រះជាម្ចាស់ប្រទានព្រះអំណោយទានដែលស័ក្តសមជាមួយយើង។ ខ្ញុំអាចនឹងមានអារម្មណ៍មិនស្រួលនោះទេ បើខ្ញុំព្យាយាមពាក់ទ្រនាប់ជើងប្រពន្ធរបស់ខ្ញុំ។ វានឹងមិនល្មមសោះឡើយ! នាងក៏មិនអាចពាក់របស់ខ្ញុំដែរ។ ទ្រនាប់ជើងរបស់នាងគឺល្មមជាមួយនឹងជើងរបស់នាង។ ក្នុងរបៀបដូចគ្នានេះដែរ ព្រះអំណោយទានដែលព្រះជាម្ចាស់មានសម្រាប់អ្នក គឺសមល្មមសម្រាប់អ្នក។ អ្វីៗដែលទ្រង់មានសម្រាប់សមាជិកដទៃនៃព្រះកាយ គឺសមល្មមសម្រាប់ពួកគេ។ អ៊ីចឹង តើមានប្រយោជន៍អ្វីក្នុងការប្រៀបធៀបព្រះអំណោយទានរបស់យើងជាមួយ ព្រះអំណោយទានដែលសម្រាប់ផ្តល់ទៅឲ្យអ្នកដទៃនោះ?

រឿងមួយទៀតដែលសំខាន់នៅត្រង់នេះ។ លោកប៉ូលបានសរសេរថា "យើងក៏ដូច្នោះដែរ យើងមានគ្នាច្រើនរួមជាព្រះកាយតែមួយក្នុងអង្គព្រះគ្រិស្ត ហើយម្នាក់ៗជាសរីរាង្គរបស់គ្នាទៅវិញទៅមក" (គម្ពីររ៉ូម ១២:៥)។ ដោយយើងនៅក្នុងព្រះកាយតែមួយ នោះគ្មានហេតុផលអ្វីដែលត្រូវប្រៀបធៀបព្រះអំណោយទានរបស់ពួកយើងឡើយ។ ពួកយើងម្នាក់ទទួលបានផលប្រយោជន៍ពីព្រះអំណោយទានរបស់អ្នកដទៃ។ តើហេតុអ្វី បានជាព្យាយាមប្រៀបធៀបជើងរបស់យើងជាមួយនឹងមាត់របស់យើង? ពួកវាមើលទៅមិនដូចគ្នាទេ។ ពួកវាមិនធ្វើសកម្មភាពដូចគ្នាដែរ។ ប៉ុន្តែវាទាំងពីរ គឺចាំបាច់ ហើយវាទាំងពីរចូលរួម

សំខាន់គោលបំណងតែមួយ។ ជើងរបស់យើងបាននាំយើងទៅរកអាហារ។ មាត់របស់យើងបរិភោគវា។ ប៉ុន្តែខ្លួនប្រាណទាំងមូលទទួលបានប្រយោជន៍ដូចគ្នា។ វាក៏ដូចគ្នាជាមួយនឹងសមាជិកនៃព្រះកាយរបស់ព្រះគ្រិស្តដែរ។

## *លំហាត់អនុវត្តន៍*

៨ ចូរអានគម្ពីរ ១កូរិនថូស១២:២១-២៧ ។ បំពេញពាក្យដែលសមស្រប ឬ ពាក្យបំពេញន័យប្រយោគនីមួយៗខាងក្រោម។

ក) នៅពេលដែលយើងប្រៀបធៀបខ្លួនយើងជាមួយនឹងអ្នកដទៃ យើងអាចនឹងបំបាក់ទឹកចិត្ត ទាំង.................................................................................................................. និង..................................................................................................................

ខ) ព្រះអំណោយទានដែលស័ក្តិសមជាមួយយើង គឺបានប្រទានមកឲ្យយើងដោយ.........................

គ) យើងមិនត្រូវប្រៀបធៀបខ្លួនយើងទៅជាមួយអ្នកដទៃ ដោយព្រោះតែយើងទាំងអស់គ្នាសុទ្ធតែជាសមាជិកចាំបាច់នៃ....................................................................ដូចគ្នា។

# ឃ. យើងត្រូវតែស្មោះត្រង់ជាមួយនឹងព្រះអំណោយទានដែលបានមកពីព្រះជាម្ចាស់

**វត្ថុបំណងទី៤.** *និយាយអំពីប្រភពនៃព្រះអំណោយទានខាងឯវិញ្ញាណ។*

## យើងត្រូវតែស្គាល់ពីព្រះអំណោយទាន

អ្នកមានព័ន្ធកិច្ចខាងឯវិញ្ញាណ ដើម្បីធ្វើការ ក្នុងនាមជាសមាជិកនៃព្រះកាយរបស់ព្រះគ្រិស្ត។ ក្នុងការបំពាក់បំប៉ន់អ្នកសម្រាប់ធ្វើកិច្ចការនេះ ព្រះជាម្ចាស់បានប្រទានព្រះអំណោយទានមួយដល់អ្នក ក៏អាចមានព្រះអំណោយទានលើសពីមួយផងដែរ។ សមាជិកគ្រប់រូប មានព្រះអំណោយទានយ៉ាងហោចណាស់មួយ។ ស្ទើរតែគ្រប់ទីកន្លែង នៅក្នុងព្រះគម្ពីរដែលព្រះអំណោយទានត្រូវបានលើកយកមកនិយាយ ដោយបានថ្លែងថា ព្រះអំណោយទានគឺសម្រាប់សមាជិកគ្រប់រូប។

ព្រះអំណោយទានទាំងនេះមិនបានផ្តល់មកឲ្យយើងតាមរយៈ ឪពុកម្តាយ ឬ គ្រូរបស់យើងនោះទេ។ គ្មានមនុស្សណាម្នាក់ មានអំណាចក្នុងការផ្តល់វាបានឡើយ។ ពួកវាក៏មិនមែនជាទេពកោសល្យដែលយើងមានមកពីធម្មជាតិនោះដែរ។

ទេពកោសល្យគឺជាសមត្ថភាពដែលនៅជាមួយមនុស្សតាំងពីគេកើតមក។ មនុស្សខុសគ្នា មានសមត្ថភាពពីធម្មជាតិផ្សេងៗគ្នា។ អ្នកខ្លះហៅវាថា ព្រះអំណោយទាន ប៉ុន្តែពួកវាមិនដូចជាព្រះអំណោយទានខាងឯវិញ្ញាណនោះទេ។ មានអ្នកជឿជាច្រើននាក់មានទេពកោសល្យ។ ឧទាហរណ៍ អ្នកមិនជឿម្នាក់ដែលមានទេពកោសល្យខាងតន្ត្រី ឬ ទេពកោសល្យខាងនិយាយក្នុងទីសាធារណៈ។ ទាំងអស់នេះមិនមែនជាព្រះអំណោយទានខាងឯវិញ្ញាណនោះទេ។

ព្រះអំណោយទានខាងឯវិញ្ញាណគឺបានមកពីប្រភពតែមួយគត់គឺៈ ព្រះជាម្ចាស់។ "គ្រប់អំណោយទានដ៏ល្អវិសេស និងអ្វីៗទាំងប៉ុន្មានដ៏គ្រប់លក្ខណៈដែលយើងបានទទួល សុទ្ធតែមកពីស្ថានលើទាំងអស់ គឺមកពីព្រះបិតាដែលបង្កើតពន្លឺ។ ព្រះអង្គមិនចេះប្រែប្រួលទេ ហើយនៅក្នុងព្រះអង្គ សូម្បីតែស្រមោលនៃការប្រែប្រួលក៏គ្មានផង" (គម្ពីរយ៉ាកុប ១:១៧)។

## *លំហាត់អនុវត្តន៍*

៩ ចូរអានគម្ពីររ៉ូម ១២:៦; គម្ពីរ១កូរិនថូស ១២:៧,១១; គម្ពីរ ១ពេត្រុស ៤:១០។ គូសរង្វង់នៅជុំវិញអក្សរនៅខាងមុខប្រយោគដែលត្រឹមត្រូវនៅខាងក្រោម។

ក) មានបុត្ររបស់ព្រះជាម្ចាស់ ភាគតិចប៉ុណ្ណោះដែលមានព្រះអំណោយទានខាងឯវិញ្ញាណ។

ខ) ព្រះអំណោយទានខាងឯវិញ្ញាណត្រូវបានប្រទានមកយើង ដោយព្រះជាម្ចាស់។

គ) ព្រះអំណោយទានខាងឯវិញ្ញាណ និងទេពកោសល្យគឺដូចតែគ្នា។

ឃ) គ្រូបង្រៀនរបស់យើងអាចផ្តល់ព្រះអំណោយទានខាងឯវិញ្ញាណមកយើងបាន។

# យើងត្រូវតែប្រើប្រាស់ព្រះអំណោយទាននោះ

**វត្ថុបំណងទី៥** *បកស្រាយអំពីរបៀបដែលព្រះអំណោយទានរបស់ព្រះជាម្ចាស់ គួរតែយកប្រើប្រាស់។*

ព្រះគម្ពីរបានផ្តល់ឲ្យយើងនូវច្បាប់យ៉ាងសាមញ្ញ ដែលអាចដាក់ទៅក្នុងព្រះអំណោយទានទាំងអស់របស់ព្រះជាម្ចាស់ៈ "អ្នករាល់គ្នាបានទទួលអំណាចដោយឥតបង់ថ្លៃ ត្រូវជួយគេវិញដោយឥតគិតថ្លៃដែរ" (គម្ពីរម៉ាថាយ ១០:៨)។ ការដាក់ច្បាប់នេះនៅក្នុងព្រះអំណោយទានខាងឯវិញ្ញាណ មានន័យថា ព្រះអំណោយទានដែលសមាជិកនៃព្រះកាយបានទទួល ត្រូវប្រើប្រាស់សម្រាប់បំពេញបំណងដែលវាត្រូវបានប្រទានមកឲ្យយើង។

មានពេលខ្លះ អ្នកជឿមិនបានប្រើប្រាស់ព្រះអំណោយទានខាងឯវិញ្ញាណរបស់ពួកគេទេ ឬ ពួកគេប្រើវាដោយភាពអាត្មានិយម និង គ្មានសេចក្តីស្រឡាញ់។ ក្នុងករណីទាំងពីរនេះ គោលបំណងមិនត្រូវបានបំពេញឲ្យពេញលេញឡើយ។

ដូច្នេះ វាគឺជាតួនាទីរបស់អ្នកជឿក្នុងការ (១) ប្រើប្រាស់ព្រះអំណោយទាននីមួយៗសម្រាប់គោលបំណងរបស់វាដែលបានចែងទុកមក និង (២) អនុញ្ញាតឲ្យសេចក្តីស្រឡាញ់ដឹកនាំការប្រើប្រាស់របស់វាៈ "បងប្អូនម្នាក់ៗបានទទួលព្រះអំណោយទានផ្សេងៗពីគ្នាហើយ ដូច្នេះ ចូរយកព្រះអំណោយទានទាំងនេះទៅបំរើអ្នកឯទៀតៗ អោយសមនឹងនាទីរបស់បងប្អូន ជាអ្នកចាត់ចែងដ៏ល្អ ដែលចែកព្រះអំណោយទានគ្រប់បែបយ៉ាងរបស់ព្រះជាម្ចាស់" (គម្ពីរ១ពេត្រុស ៤:១០)។ ព្រះគម្ពីរប្រើពាក្យថា *ភាពជាអ្នកបម្រើជំនិត* នៅពេលដែលនិយាយអំពីកាតព្វកិច្ចរបស់មនុស្ស។ ភាពជាអ្នកបម្រើមានន័យថា មើលការខុសត្រូវចំពោះទ្រព្យសម្បត្តិរបស់មនុស្សម្នាក់ទៀត។ ក្នុងនាមជាអ្នកជឿ យើងទទួលបានភាពជាអ្នកបម្រើជំនិតនៃព្រះអំណោយទានខាងឯវិញ្ញាណ។ នោះមានន័យថា យើងត្រូវតែមើលការខុសត្រូវចំពោះព្រះអំណោយទានដែលបានផ្តល់មកឲ្យយើង និង ប្រើប្រាស់ពួកវាពង្រីករាជាណាចក្ររបស់ព្រះអម្ចាស់នៃយើង។ មានច្បាប់

ចែងយ៉ាងច្បាស់អំពី ភាពជាអ្នកបម្រើ៖ "រីឯអ្នកមើលខុសត្រូវគួរតែមានចិត្តស្មោះត្រង់" (គម្ពីរ ១កូរិនថូស ៤:២)។ ការប្រើប្រាស់ព្រះអំណោយទានខាងឯវិញ្ញាណដោយភាពស្មោះត្រង់ នាំឲ្យមានសិរីរុងរឿងដល់ព្រះអង្គដែលប្រទានវាមក និង ព្រះពរចំពោះព្រះកាយផង។

សេចក្តីស្រឡាញ់គឺជាគន្លឹះយ៉ាងមានប្រសិទ្ធិភាពក្នុងការប្រើប្រាស់ព្រះអំណោយទានខាងឯវិញ្ញាណ។ ការបែកចេញពីសេចក្តីស្រឡាញ់ ព្រះអំណោយទានខាងឯវិញ្ញាណមិនអាចបំពេញតាមគោលបំណងរបស់វានោះទេ៖ "គឺមានតែជំនឿដែលនាំអោយប្រព្រឹត្តអំពើផ្សេងៗ ដោយចិត្តស្រឡាញ់ប៉ុណ្ណោះទើបសំខាន់" (គម្ពីរកាឡាទី ៥:៦)។

## លំហាត់អនុវត្តន៍

១០ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខប្រយោគដែលត្រឹមត្រូវ។

ក) ព្រះអំណោយទានខាងឯវិញ្ញាណ ត្រូវតែប្រើប្រាស់សម្រាប់ប្រយោជន៍របស់អ្នកដទៃ។

ខ) ភាពជាអ្នកបម្រើជំនិត មានន័យថា ខ្វល់ខ្វាយរឿងរបស់ខ្លួនឯង។

គ) យើងតម្កើងព្រះជាម្ចាស់នៅពេលដែលយើងបានប្រើប្រាស់ព្រះអំណោយទានខាងឯវិញ្ញាណដែលទ្រង់បានប្រទាន ដោយភាពស្មោះត្រង់។

ឃ) ព្រះអំណោយទានខាងឯវិញ្ញាណគឺសំខាន់ខ្លាំងជាងសេចក្តីស្រឡាញ់។

១១ គន្លឹះសម្រាប់ការប្រើប្រាស់ព្រះអំណោយទានខាងឯវិញ្ញាណ ដែលព្រះជាម្ចាស់បានប្រទានមកឲ្យយើងយ៉ាងមានប្រសិទ្ធិភាពគឺ

ក) ប្រាប់អ្នកដទៃថាអ្នកមានព្រះអំណោយទាននោះ។

ខ) ប្រៀបធៀបព្រះអំណោយទានជាមួយអ្នកជិតខាងរបស់អ្នក។

គ) អនុញ្ញាតឲ្យសេចក្តីស្រឡាញ់ដឹកនាំក្នុងការប្រើប្រាស់វា។

ឃ) រង់ចាំឲ្យអ្វីកើតឡើងសិន។

## ***ការប្រឡងផ្ទាល់ខ្លួន***

ត្រូវ/ខុស។ ចូរសរសេរអក្សរ **ត** នៅក្នុងចន្លោះបន្ទាត់ នៅពីមុខប្រយោគនីមួយៗដែលត្រឹមត្រូវ។ សរសេរអក្សរ **ខ** ប្រសិនបើប្រយោគនោះខុស។

......១ ផ្នែកសំខាន់ពីរនៃព្រះកាយរបស់ព្រះគ្រិស្ត គឺព្រះសិរសា និង ព្រះហស្ត។

......២ ព្រះកាយរបស់ព្រះគ្រិស្តមានសមាជិកជាច្រើន។

......៣ សមាជិកខ្លះៗនៃព្រះកាយគឺមិនមានសារៈសំខាន់ឡើយ ព្រោះពួកគេមិនត្រូវបានគេមើលឃើញ។

......៤ សមាជិកផ្សេងៗគ្នានៅក្នុងព្រះកាយរបស់ព្រះគ្រិស្តមានមុខងារខុសៗគ្នា។

......៥ ព្រះគ្រិស្តទ្រង់សព្វព្រះហឫទ័យ នៅពេលដែលយើងប្រៀបធៀបខ្លួនយើងទៅជាមួយអ្នកដទៃ។

......៦ ប្រសិនបើយើងប្រៀបធៀបខ្លួនយើងជាមួយនឹងសមាជិកដទៃទៀតនៅក្នុងព្រះកាយរបស់ព្រះគ្រិស្តនោះយើងអាចបំបាក់ទឹកចិត្តរបស់ពួកគេ។

......៧ ទេពកោសល្យរបស់មនុស្ស មិនមែនជាព្រះអំណោយទានខាងវិញ្ញាណនោះទេ។

......៨ ពួកយើងកើតមកជាមួយនឹងព្រះអំណោយទានខាងវិញ្ញាណ។

......៩ ព្រះជាម្ចាស់មិនប្រទានព្រះអំណោយទានខាងវិញ្ញាណ ដើម្បីគ្រាន់តែឲ្យយើងសប្បាយចិត្តឡើយ។

....១០ ភាពជាអ្នកបម្រើជំនិត រួមមានការប្រើប្រាស់ព្រះអំណោយទានខាងវិញ្ញាណប្រកបដោយភាពស្មោះត្រង់។

....១១ ព្រះអំណោយទានខាងវិញ្ញាណទាំងអស់ បំពេញគោលបំណងរបស់វាបានល្អបំផុតតាមរយៈសេចក្តីស្រឡាញ់។

# ចម្លើយសម្រាប់សំណួរលំហាត់អនុវត្តន៍

១ ក) ព្រះគ្រិស្ត

ខ) អ្នកជឿ ឬ ក្រុមជំនុំ

៧ ក) ការប្រៀបធៀបខ្លួនយើងទៅជាមួយអ្នកដទៃធ្វើឲ្យព្រះអម្ចាស់មិនសព្វព្រះហឫទ័យ។

គ) ការប្រៀបធៀបខ្លួនយើងទៅជាមួយអ្នកដទៃ បង្ហាញឲ្យឃើញថា យើងមិនដឹងថាយើងមានសារៈសំខាន់យ៉ាងណានៅក្នុងព្រះកាយនោះទេ។

២ ក) សិរសា

ខ) ក្រុមជំនុំ

គ) ព្រះកាយ

៨ ក) ខ្លួនយើង , អ្នកដទៃ

ខ) ព្រះជាម្ចាស់

គ) ព្រះកាយ

៣ ក) ព្រះសិរសា

ខ) សមាជិក x

៩ ខ) ជាចម្លើយត្រឹមត្រូវ

៤ ខ) សមាជិកជាច្រើន

១០ ក) និង គ) គឺជាចម្លើយត្រឹមត្រូវ

៥ ក) ត

ខ) ត

គ) ខ

១១ គ) អនុញ្ញាតឲ្យសេចក្ដីស្រឡាញ់ដឹកនាំការប្រើប្រាស់ពួកវា

៦ ក) ខ

ខ) ខ

គ) ត

មេរៀនទី ២

# ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យអ្នកស្គាល់ពីអំណោយទានរបស់ទ្រង់

នៅក្នុងមេរៀនទីមួយ អ្នកបានដឹងថាព្រះជាម្ចាស់មានព្រះអំណោយទានខាងវិញ្ញាណសម្រាប់អ្នកជឿគ្រប់គ្នា។ អ្នកក៏បានរកឃើញថា ព្រះជាម្ចាស់រំពឹងទុកឲ្យអ្នកជឿ ប្រើប្រាស់ព្រះអំណោយទានរបស់ពួកគេប្រកបដោយភាពស្មោះត្រង់ និង ឲ្យអ្នកជឿត្រូវតែមានសេចក្តីស្រឡាញ់ដើម្បីធ្វើឲ្យព្រះអំណោយទានទាំងអស់មានន័យពេញលេញ។ ឥឡូវនេះអ្នកនឹងរៀនរឿងខ្លះៗដែលទាក់ទងទៅនឹងព្រះអំណោយទាននោះផ្ទាល់។

មេរៀនមួយនេះ នឹងជួយអ្នកឲ្យយល់អំពីព្រះអំណោយទាននោះ។ អ្នកនឹងឃើញថា ចំណេះដឹងអំពីព្រះអំណោយទានរបស់ព្រះជាម្ចាស់ គឺសំខាន់ណាស់សម្រាប់អ្នកជឿ។ អ្នកក៏នឹងចាប់ផ្តើមស្គាល់ពី ព្រះអំណោយទានខាងវិញ្ញាណមួយចំនួន និង ស្គាល់ពីរបៀបដែលវាទាក់ទងនឹង ព្រះកាយដែលផ្សំពីអ្នកជឿ។

រឿងដែលគួរឲ្យរីករាយមួយអំពីមេរៀននេះ គឺថា វាអាចជួយអ្នករកឃើញព្រះអំណោយទានខាងវិញ្ញាណដែលព្រះជាម្ចាស់មានសម្រាប់អ្នក។ នៅពេលដែលអ្នកបានរកឃើញព្រះអំណោយទានខាងវិញ្ញាណរបស់អ្នកហើយ អ្នកអាចចាប់ផ្តើមអភិវឌ្ឍវា និង ធ្វើឲ្យវាកាន់តែមានន័យពេញលេញ។

## គម្រោងនៃមេរៀន

ក. សារៈសំខាន់នៃការស្គាល់

ខ. ក្រុមនៃព្រះអំណោយទាន

## វត្ថុបំណងនៃមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹងៈ

១. រៀបរាប់ជាអត្ថបទសរសេរខ្លីមួយ ថាហេតុអ្វីបានជាចំណេះដឹងអំពីព្រះអំណោយទានខាងវិញ្ញាណ គឺមានសារៈសំខាន់សម្រាប់អ្នកជឿ។

២. រៀបរាប់ព្រះអំណោយទានខាងវិញ្ញាណ ទៅតាមក្រុមនីមួយៗ។

៣. បែងចែករវាងព្រះអំណោយទានខាងព័ន្ធកិច្ច ព្រះអំណោយទានដទៃផ្សេងទៀត និង ព្រះអំណោយទាននៃព្រះវិញ្ញាណ។

## សកម្មភាពក្នុងការសិក្សា

១. អានមេរៀន និងគូសបន្ទាត់នៅពីក្រោមពាក្យ ឬ ផ្នែកណាមួយនៃប្រយោគដែលអ្នកមានអារម្មណ៍ថាសំខាន់ពិសេសជាងគេ។

២. បន្តការទន្ទេញខគម្ពីរ១កូរិនថូសជំពូក១៣។ រំឭកខគម្ពីរទាំងពីរដំបូង ដោយធ្វើការសូត្រវាឲ្យឮៗ រួចហើយទន្ទេញខទី ៣ ដល់ទី៤។

៣. ធ្វើជាតារាងមួយដែលមាន ការចែកក្រុមទាំងបីនៃព្រះអំណោយទានខាងវិញ្ញាណ នៅក្នុងសៀវភៅកត់ត្រាមួយផ្សេងទៀត ហើយសរសេរបំពេញព្រះអំណោយទានទាក់ទងចូលក្នុងក្រុមនោះ នៅពេលដែលអ្នកឃើញវានៅក្នុងសេចក្ដីសង្ខេបការរិវត្តន៍មេរៀន។

៤. បើកមើលរាល់ពាក្យទាំងឡាយណាដែលអ្នកមិនអាចយល់បាន ដោយប្រើប្រាស់វចនានុក្រម និងអក្ខរានុក្រមនៃពាក្យសំខាន់ដែលនៅចុងបញ្ចប់សៀវភៅសិក្សានេះ។

៥. ធ្វើការប្រឡង នូវការរិវត្តន៍របស់អ្នក ដោយធ្វើលំហាត់ទៅតាមជំហាននីមួយៗនៅក្នុងមេរៀន។

៦. ធ្វើលំហាត់ប្រឡងផ្ទាល់ខ្លួននៅចុងបញ្ចប់នៃមេរៀន។ ពិនិត្យមើលចម្លើយរបស់អ្នក។ បកទៅមើលមេរៀនវិញ ប្រសិនបើមានចម្លើយដែលខុស ដើម្បីឲ្យប្រាកដថា អ្នកដឹងចម្លើយត្រឹមត្រូវ។

៧. បន្ទាប់ពីអ្នកបានធ្វើលំហាត់ប្រឡងផ្ទាល់ខ្លួនហើយ ចូររំឭកមេរៀនទី១ និង ទី២ (ជំពូកទីមួយ) ឡើងវិញ។ បន្ទាប់មកធ្វើការប្រឡងក្នុងជំពូកទីមួយ

## ពាក្យសំខាន់

គ្រឹះ ដឹកនាំ អធិធម្មជាតិ
បង្កបង្កើត

# ក. សារៈសំខាន់នៃការស្គាល់

**វត្ថុបំណងទី១.** *រៀបរាប់ជាអត្ថបទសរសេរខ្លីមួយ ថាហេតុអ្វីបានជាចំណេះដឹងអំពីព្រះអំណោយទានខាងឯវិញ្ញាណគឺមានសារៈសំខាន់សម្រាប់អ្នកជឿ។*

## ចំណេះដឹងបង្កើតឲ្យមានជំនឿ

ជំនឿគឺជាដួងចិត្តនៃព្រះអំណោយទានខាងឯវិញ្ញាណ និង ការប្រើប្រាស់របស់វា។ រឿងដែលបញ្ជាក់ថាវាគឺជារឿងខាងឯវិញ្ញាណនោះគឺ ដោយសារវិញ្ញាណនេះដែលបង្ហាញឲ្យឃើញពីការត្រូវការជំនឿ។ ជំនឿធ្វើឲ្យយើងក្លាយជាអ្នកជឿ។ ជំនឿក៏ធ្វើឲ្យយើងមាន*ប្រយោជន៍* ក្នុងនាមជាអ្នកជឿតាមរយៈព្រះអំណោយទាននោះផងដែរ។

តើមនុស្សទទួលបានជំនឿដោយរបៀបណា? ចម្លើយគឺសាមញ្ញ ព្រមទាំងប្រាកដច្បាស់ផងដែរ។ ជំនឿ កើតឡើងដោយសារចំណេះដឹងពីព្រះគម្ពីរ។ លោកប៉ូលបានបញ្ជាក់ច្បាស់ នៅពេលដែលលោកបានសរសេរថា "ក៏ប៉ុន្តែ អោយគេអង្វររកព្រះអង្គដូចម្ដេចកើត បើគេមិនជឿ?" ( គម្ពីររ៉ូម១០:១៤)។ ចំណេះដឹងគឺទទួលបានតាមរយៈការឮសារនៃដំណឹងល្អ។ ជំនឿអាចកើតឡើងបាន នៅពេលដែលទទួលបានចំណេះដឹង។

សូមគិតពិចារណាអំពីពួកសាវ័កដែលនៅក្រុងអេភេសូ។ នៅពេលដែលលោកប៉ូលបានជួបពួកគេដំបូងនៅក្នុងគម្ពីរកិច្ចការ ១៩:២ លោកបានសួរទៅពួកគេថា "កាលបងប្អូនចាប់ផ្ដើមជឿនោះ តើបងប្អូនទទួលព្រះវិញ្ញាណដ៏វិសុទ្ធ*ហើយឬនៅ?»។ គេតបមកលោកវិញថា៖ «យើងខ្ញុំមិនដែលទាំងឮថា មានព្រះវិញ្ញាណដ៏វិសុទ្ធផង!" ដោយសារតែពួកគេមិនដែលបានឮ ទើបពួកគេមិនបានដឹងឡើយ។ ដោយសារតែពួកគេមិនដឹង ទើបពួកគេមិនអាចនឹងជឿបាន។

បន្ទាប់មកលោកប៉ូលចាប់ផ្ដើមបង្រៀនពួកគេ។ ពួកគេបានទទួលចំណេះដឹងតាមរយៈការបង្រៀនរបស់លោក ហើយនៅពេលដែលពួកគេមានចំណេះដឹង ជំនឿបានកើតឡើងនៅក្នុងដួងចិត្តរបស់ពួកគេ។ ដូច្នេះ ពួកយើងដឹងថាចំណេះដឹងពីព្រះអំណោយទានខាងឯវិញ្ញាណគឺជាជំហានដំបូង ឆ្ពោះទៅកាន់ជំនឿសម្រាប់ការទទួលបាន និង ស្គាល់ពីព្រះអំណោយទាន ព្រមទាំងការប្រើប្រាស់យ៉ាងមានប្រសិទ្ធិភាពរបស់វាផងដែរ។ ដរាបណាយើងនៅមិនទាន់ស្គាល់ពីព្រះអំណោយទានខាងឯវិញ្ញាណ នោះវានឹងមិនអាចកើតមាននៅក្នុងជីវិត និង ព័ន្ធកិច្ចរបស់យើងដែលព្រះជាម្ចាស់បានគ្រោងទុកនោះឡើយ។

## *លំហាត់អនុវត្តន៍*

១ ចូរអានគម្ពីរ១កូរិនថូស ១២:១; គម្ពីរ១កូរិនថូស ១៤:៣៦; គម្ពីរកិច្ចការ ១៩:១-៧; និង គម្ពីររ៉ូម ១២:៦។ រួចហើយបំពេញនៅក្នុងចន្លោះបន្ទាត់ខាងក្រោម។

ក) នៅក្នុងដួងចិត្តនៃព្រះអំណោយទានខាងវិញ្ញាណទាំងអស់គឺមាន.........................................

ខ) ជំនឿត្រូវបានបង្កើតឡើងមកពី...................................................................................

គ) រឿងដែលសំខាន់បំផុត ដែលយើងចង់បានពីការសិក្សានេះ គឺចំណេះដឹងអំពី.............................

...................................................................................................................................

## ចំណេះដឹងដឹកនាំជំនឿ

ចំណេះដឹងមិនត្រឹមតែបង្កើតបានជំនឿនោះទេ វាថែមទាំងដឹកនាំជំនឿផងដែរ។ ដោយប្រើពាក្យថា *ដឹកនាំ* នេះយើងមានន័យថា វាបានផ្តល់ឲ្យជំនឿនូវតម្រុយនៃទិសដៅ និង កំណត់ដែនខ័ណ្ឌរបស់វាផងដែរ។ ដោយសារមូលហេតុនេះហើយ វាគឺមានសារៈសំខាន់ណាស់ដែលចំណេះដឹងត្រូវតែ ពេញលេញ និង ពិតប្រាកដបំផុត។ ចំណេះដឹងដែលមិនពេញលេញ ឬ មិនពិតប្រាកដ នាំឲ្យជំនឿមានមូលដ្ឋានមិនពេញលេញ និង មិនពិតប្រាកដផងដែរ។ មូលដ្ឋានគឺជាកន្លែងដែលអ្វីមួយឈរជាប់បាន។ ជំនឿដែលគ្មានចំណេះដឹងមូលដ្ឋានមិនត្រឹមត្រូវ គឺប្រៀបដូចជាផ្ទះដែលសាងសង់នៅពីលើគ្រឹះតែពាក់កណ្តាលយ៉ាងដូច្នោះដែរ។

ជាឧទាហរណ៍ មានអ្នកជឿជាច្រើននាក់ធ្លាប់ត្រូវបានគេបង្រៀនថា ព្រះអំណោយទានក្នុងការនិយាយភាសាចម្លែកអស្ចារ្យគឺមិនមែនសម្រាប់មនុស្សជំនាន់យើងនេះទេ។ ជំនឿរបស់ពួកគេក្នុងការទទួលបានព្រះអំណោយទានមួយនេះ គឺខ្វះខាត ព្រោះតែការបង្រៀនមិនពិតមួយនេះ។

ពួកគេអាចត្រឹមត្រូវជឿលើអ្វីដែលពួកគេដឹង ទោះបីជាអ្វីដែលពួកគេគិតថាពួកគេបានដឹងនោះមិនមានចែងតាមគោលការណ៍ព្រះគម្ពីរក៏ដោយ។ ជំនឿរបស់ពួកគេមិនអាចនាំពួកគេ ឲ្យទៅលើសពីចំណេះដឹងរបស់ពួកគេឡើយ។ អ្នកជឿទាំងនេះនឹងរស់នៅក្នុងជីវិតមួយដែលជឿថាព្រះអំណោយទានក្នុងការនិយាយភាសាចម្លែកអស្ចារ្យគឺមិនមែនសម្រាប់ពួកគេនោះទេ ដរាបណាចំណេះដឹងមូលដ្ឋានរបស់ពួកគេត្រូវបានកែតម្រូវ។ ដូច្នេះ វាពិតជាសំខាន់ខ្លាំងណាស់ដែលពួកយើងត្រូវមាន ចំណេះដឹងអំពីព្រះអំណោយទានខាងវិញ្ញាណ ដ៏ពេញលេញ និង ពិតប្រាកដ។

## លំហាត់អនុវត្តន៍

២ ចូរអានគម្ពីរយ៉ូហាន ៨:៣០-៣២។ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅពីខាងមុខប្រយោគនីមួយៗ ដែលត្រឹមត្រូវ។

ក) ចំណេះដឹងដឹកនាំជំនឿ។

ខ) ចំណេះដឹងត្រឹមត្រូវ គឺមិនសំខាន់នោះទេ។

គ) ជំនឿនាំយើងឲ្យទៅហួសចំណេះដឹងរបស់យើងទៅទៀត។

## ចំណេះដឹងកំណត់បទពិសោធន៍

ដោយសារតែចំណេះដឹង បង្កើត និង ដឹកនាំជំនឿរបស់យើង វាក៏ដឹកនាំយើងឲ្យឆ្ពោះទៅកាន់បទពិសោធន៍ផងដែរ។ មានលំដាប់លំដោយមួយដែលយើងត្រូវចងចាំទុកក្នុងគំនិតៈ ១) ចំណេះដឹង, ២) ជំនឿ និង ៣) បទពិសោធន៍។ ដរាបណាយើងមិនស្គាល់ព្រះអំណោយទានខាងឯវិញ្ញាណទេ នោះយើងមិនអាចជឿ ដោយជំនឿទៅលើព្រះអំណោយទានខាងឯវិញ្ញាណទាំងនោះបានឡើយ។ ដរាបណាយើងមិនជឿលើព្រះអំណោយទានខាងឯវិញ្ញាណ នោះវានឹងមិនអាចក្លាយជាផ្នែកមួយនៃបទពិសោធន៍របស់យើង ដែលព្រះជាម្ចាស់បម្រុងទុកនោះបានឡើយ។

សូមរំឭកអំពីបទពិសោធន៍របស់លោកប៉ូលនៅក្រុងអេភេសូ ក្នុងគម្ពីរកិច្ចការជំពូក១៩។ យើងបានដឹងហើយថា ដោយសារតែអ្នកក្រុងអេភេសូទាំងនេះ មិនបានស្គាល់ព្រះវិញ្ញាណដ៏វិសុទ្ធ ទើបពួកគេមិនអាចជឿលើលោកបាន។ ឥឡូវនេះយើងក៏បានដឹងថា ដោយសារតែពួកមិនបានស្គាល់ ដូច្នេះហើយពួកគេមិនអាចមានជំនឿបានឡើយ ពួកគេបានខ្វះខាតបទពិសោធន៍ដែលព្រះជាម្ចាស់រៀបចំសម្រាប់ពួកគេ។ នៅពេលលោកប៉ូល បានដឹងថាពួកគេមិនដែលធ្លាប់ស្គាល់ព្រះវិញ្ញាណដ៏វិសុទ្ធ លោកក៏បានចាប់ផ្តើមបង្រៀនពួកគេ។ លោកបានផ្តល់ចំណេះដឹងថ្មីទៅឲ្យពួកគេ។ នៅពេលនោះពួកគេអាចជឿលើអ្វីដែលពួកគេមិនធ្លាប់បានជឿពីមុនមក ហើយនៅពេលដែលជំនឿរបស់ពួកគេធ្វើសកម្មភាពពីចំណេះដឹងថ្មីរបស់ពួកគេ ពួកគេអាចចូលទៅក្នុងបទពិសោធន៍ដ៏ថ្មីទាំងស្រុង។ បទពិសោធន៍ថ្មីរបស់ពួកគេ អាចត្រូវបានគេដឹងថា មានប្រភពមកពីការទទួលចំណេះដឹងថ្មី ពីការបង្រៀនរបស់លោកប៉ូល។

ការនេះជួយយើងឲ្យមើលឃើញថា តើវាសំខាន់កម្រិតណាដែលត្រូវមានចំណេះដឹងអំពីព្រះអំណោយទានខាងឯវិញ្ញាណ។ បទពិសោធន៍របស់យើងនឹងនៅតែមានកម្រិត ដរាបដល់ពេលយើងបានស្គាល់ជាមុនសិន។ សូមឲ្យយើងគិតអំពីរឿងនេះបន្តិចទៀត។ នៅពេលដែលលោកប៉ូលបានសរសេរសំបុត្រទៅកាន់អ្នកក្រុមកូរិនថូស លោកបញ្ជាក់ថា ពួកគេមានព្រះអំណោយទានរបស់ព្រះវិញ្ញាណៈ

> ដោយរួមជាមួយព្រះអង្គបងប្អូនបានបរិបូណ៌សព្វគ្រប់ទាំងអស់ ទាំងខាងព្រះបន្ទូល ទាំងខាងការស្គាល់ព្រះអង្គ។ សក្ខីភាពរបស់ព្រះគ្រិស្តបានស្ថិតនៅក្នុងបងប្អូនយ៉ាងខ្ជាប់ខ្ជួន។ ហេតុនេះនៅពេលដែលបងប្អូនកំពុងរង់ចាំព្រះយេស៊ូគ្រិស្ត ជាព្រះអម្ចាស់របស់យើងយាង មកយ៉ាងរុងរឿងនោះ បងប្អូនមិនខ្វះព្រះអំណោយទានអ្វីឡើយ។ (គម្ពីរ១កូរិនថូស ១:៥-៧)

វាហាក់បីដូចជា អ្នកក្រុងកូរិនថូស បានស្គាល់ព្រះអំណោយទានខាងឯវិញ្ញាណទាំងនេះ ហើយមានមនុស្សជាច្រើនមានព្រះអំណោយទាននេះផងដែរ ប៉ុន្តែការស្គាល់វា និង មានវាមិនទាន់គ្រប់គ្រាន់នោះទេ។ ពួកគេត្រូវការដឹងពីរបៀបប្រើប្រាស់វា៖ "បងប្អូនអើយ ខ្ញុំចង់អោយបងប្អូនជ្រាបយ៉ាងច្បាស់ អំពីព្រះអំណោយទានរបស់ព្រះវិញ្ញាណ។" (១កូរិនថូស ១២:១)។

ការដឹងពីសេចក្តីអំពីព្រះអំណោយទានទាំងនេះ នឹងនាំយើងទៅកាន់បទពិសោធន៍ដែលប្រកបដោយផលផ្លែក្នុងការប្រើប្រាស់ពួកវា។ នេះគឺជាមូលដ្ឋានដែលយើងត្រូវតែរៀនទាំងអស់ តាមតែអាចធ្វើបាន អំពីព្រះអំណោយទានខាងឯវិញ្ញាណ។

***លំហាត់អនុវត្តន៍***

---

៣ បំពេញប្រយោគនីមួយៗនៅខាងក្រោម។

ក) លំដាប់លំដោយដែលត្រឹមត្រូវក្នុងការទទួលបានព្រះអំណោយទានខាងឯវិញ្ញាណ គឺ ចំណេះដឹង, ........................................................................................................ និង........................................................................................................។

ខ) ជំនឿត្រូវបានបង្កើតឡើង និង ដឹកនាំដោយ........................................................................

គ) ការដឹងពីសេចក្តីអំពីព្រះអំណោយទានទាំងនេះ នឹងនាំយើងទៅកាន់........................................ ដែលប្រកបដោយផលផ្លែក្នុងការប្រើប្រាស់ពួកវា។

# ២. ក្រុមនៃព្រះអំណោយទាន

**វត្ថុបំណងទី២.** *រៀបរាប់ព្រះអំណោយទានខាងឯវិញ្ញាណ ទៅតាមក្រុមនីមួយៗ។*

**វត្ថុបំណងទី៣.** *បែងចែករវាងព្រះអំណោយទានខាងព័ន្ធកិច្ច ព្រះអំណោយទានដទៃទៀត និង ព្រះអំណោយទាននៃព្រះវិញ្ញាណ។*

## ព្រះអំណោយទានខាងឯព័ន្ធកិច្ច

ព្រះគម្ពីរមិនបានសង្កេតស្គាល់ព្រះអំណោយទានខាងឯវិញ្ញាណទៅតាមតារាងនៃក្រុមនីមួយៗរបស់វាទេ។ ពេលខ្លះ វាហាក់បីដូចជាត្រូវបានដាក់ជាក្រុមជាមួយគ្នា។ ការនេះហាក់ដូចជាបង្ហាញថា ព្រះអំណោយទានខាងឯវិញ្ញាណទាំងអស់មានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ។ ទោះជាយ៉ាងណាសម្រាប់គោលដៅរបស់យើងក្នុងពេលនេះ វានឹងមានប្រយោជន៍ជាង ក្នុងការបែងចែកព្រះអំណោយទានទាំងនោះទៅជាបីក្រុម។ ក្រុមនីមួយៗនឹងមានតារាងផ្ទាល់ខ្លួន។ មានព្រះអំណោយទានខ្លះ នៅក្នុងក្រុមមួយហាក់បីដូចជាជាន់គ្នា វានឹងប្រហាក់ប្រហែលជាមួយនឹងព្រះអំណោយទានខ្លះនៅក្នុងក្រុមមួយផ្សេងទៀត។ ការនេះមិនគួរជាបញ្ហាសម្រាប់យើងនោះទេ ដ្បិតព្រះអំណោយទានទាំងអស់បានមកពីព្រះជាម្ចាស់ ហើយមានគោលបំណងរួមតែមួយ គឺដើម្បីកសាងព្រះកាយដែលកើតមកពីអ្នកជឿ និង ដើម្បីតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។

នៅក្នុងតារាងមួយនេះ មានរួមបញ្ចូលព្រះអំណោយទានដែលទាក់ទងខ្លាំងបំផុតជាមួយនឹងទំនួលខុសត្រូវដ៏ខ្ពស់របស់យើង នៅក្នុងព្រះកាយដែលផ្សំពីអ្នកជឿមួយនេះ។ លោកប៉ូលបានផ្តល់មកឲ្យយើងនៅក្នុងព្រះគម្ពីរ អេភេសូ៖

> ព្រះអង្គបានផ្តល់ព្រះគុណមកអោយយើងម្នាក់ៗតាមកំរិតព្រះអំណោយទាន ដែលព្រះគ្រិស្តប្រទានមកយើង។ ហេតុនេះហើយបានជាមានថ្លែងទុកថា «ព្រះអង្គបានយាងឡើងទៅស្ថានខ្ពស់ ព្រះអង្គបាននាំពួកជាប់ជាឈ្លើយទៅជាមួយ ហើយព្រះអង្គប្រទានព្រះអំណោយទានផ្សេងៗដល់មនុស្សលោក»....គឺព្រះអង្គហើយ ដែលបានប្រទានអោយអ្នកខ្លះមានមុខងារជាសាវ័ក* អោយអ្នកខ្លះថ្លែងព្រះបន្ទូល អ្នកខ្លះផ្សាយដំណឹងល្អ*អ្នកខ្លះជាអ្នកគង្វាល និងអ្នកខ្លះទៀតជាអ្នកបង្រៀន ដើម្បីរៀបចំប្រជាជនដ៏វិសុទ្ធអោយបំពេញមុខងារបំរើ និងកសាងព្រះកាយរបស់ព្រះគ្រិស្តឡើង។ (គម្ពីរអេភេសូ ៤:៧-៨,១១-១២)

ដូចនេះ តារាងនៃព្រះអំណោយទាននៃព័ន្ធកិច្ចរបស់យើងត្រង់នេះគឺ៖

| | | |
|---|---|---|
| ១. សាវ័ក | ៣. អ្នកផ្សាយដំណឹងល្អ | ៥. អ្នកបង្រៀន |
| ២. ព្យាការី(អ្នកថ្លែងព្រះបន្ទូល) | ៤. អ្នកគង្វាល | |

អ្នកប្រាជ្ញខ្លះប្រាប់យើងថា អ្នកគង្វាល និង អ្នកបង្រៀន តាមការពិតជាព្រះអំណោយទាននៃព័ន្ធកិច្ចតែមួយ គឺ គ្រូគង្វាលដែលជាអ្នកបង្រៀន។ យើងនឹងរៀនបន្ថែមទៀតអំពីរឿងនេះនៅក្នុងមេរៀនបន្ទាប់របស់យើង។ យើងក៏នឹងចាប់ផ្តើមរៀនបន្ថែមទៀតអំពីការប្រើប្រាស់ព្រះអំណោយទាននីមួយៗផងដែរ។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលមានប្រយោជន៍សម្រាប់យើងក្នុងពេលនេះ គឺក្រឡេកទៅមើលពីគោលបំណងទូទៅ សម្រាប់ព្រះអំណោយទាននៃព័ន្ធកិច្ចទាំងអស់នេះជាមុនសិន។ លោកប៉ូលបានប្រាប់នៅក្នុងគម្ពីរអេភេសូ ៤:១២ ថា ទ្រង់ធ្វើបែបនេះ "ដើម្បីរៀបចំប្រជាជនដ៏វិសុទ្ធអោយបំពេញមុខងារបំរើ និងកសាងព្រះកាយរបស់ព្រះគ្រិស្តឡើង" ។

## *លំហាត់អនុវត្តន៍*

៤ ចូរអានគម្ពីរ១ កូរិនថូស ១២:២៧-៣០។ ចូរគូសរង្វង់ជុំវិញប្រយោគដែលត្រឹមត្រូវ។

ក) ព្រះគម្ពីរបានផ្តល់ឲ្យយើងនូវ តារាងបែងចែកយ៉ាងជាក់លាក់ អំពីក្រុមនីមួយៗនៃអំណោយទានខាងឯវិញ្ញាណ។

ខ) គ្រប់ព្រះអំណោយទានខាងឯវិញ្ញាណទាំងអស់ហាក់បីដូចជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ។

គ) ព្រះអំណោយទានដែលស្ថិតនៅក្នុងក្រុមមួយ អាចស្រដៀងទៅនឹងព្រះអំណោយទាននៅក្នុងក្រុមមួយផ្សេងទៀត។

ឃ) ព្រះអំណោយទានខាងឯវិញ្ញាណទាំងអស់មិនសុទ្ធតែមកពីព្រះជាម្ចាស់នោះទេ។

ង) ព្រះអំណោយទាននៃព័ន្ធកិច្ច គឺនិយាយភាសាចម្លែកអស្ចារ្យ ជំនឿ និង ធ្វើការអស្ចារ្យ។

ច) អ្នកគង្វាល និង អ្នកបង្រៀន អាចចាត់ទុកថា គ្រូគង្វាលដែលបង្រៀនបាន។

# ព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេងទៀត

ក្រុមបន្ទាប់ទៀតនៅក្នុងក្រុមនៃព្រះអំណោយទានខាងឯវិញ្ញាណទាំងបីរបស់យើង យើងមាន *ព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេងទៀត* ។ មុនពេលចូលទៅស្គាល់ថាតើមានព្រះអំណោយទានអ្វីខ្លះ នៅក្នុងក្រុមមួយនេះ សូមឲ្យយើងរំឭកឡើងវិញ អំពីក្រុមទាំងបីជាមុនសិន។

១. ព្រះអំណោយទាននៃព័ន្ធកិច្ច

២. ព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេងទៀត

៣. ព្រះអំណោយទានរបស់ព្រះវិញ្ញាណ

ព្រះអំណោយទានដែលនៅក្នុងក្រុម "ព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេងទៀត" ត្រូវបានរៀបរាប់នៅទាំងនៅក្នុងគម្ពីរ រ៉ូមជំពូក១២ ឬ គម្ពីរ១កូរិនថូសជំពូក១២ផងដែរ។ ព្រះអំណោយទានទាំងនោះប្រហែលជាមិនអាចរាប់ទុកជា ព្រះអំណោយទាននៃព័ន្ធកិច្ច ឬ ព្រះអំណោយទានរបស់ព្រះវិញ្ញាណនោះទេ។ តែនេះមិនមែនមានន័យថា ពួកវាមិនសំខាន់នោះទេ។ នៅគ្រប់ករណីទាំងអស់ ពួកវាបំពេញតម្រូវការពិសេស នៅក្នុងព្រះកាយ។ សូមគិតអំពីបេះដូងរបស់អ្នក។ វាមានទំហំតូចល្មម។ គេមើលវាមិនឃើញទេ។ វាមិនអាចនិយាយបាន។ តើនោះមានន័យថា វាមិនសំខាន់មែនដែរឬទេ? អត់ទេ។ បើគ្មានវា នោះដៃរបស់អ្នក ជើងរបស់អ្នក ក្បាលរបស់អ្នក និង គ្រប់ផ្នែកនៃខ្លួនប្រាណរបស់អ្នកមិនអាចបំពេញកាតព្វកិច្ចរបស់ពួកវាបានឡើយ។

ផ្នែកដែលតូចជាងគេបំផុតគឺ មានមុខងារសំខាន់។ វាបម្រើការសម្រាប់ប្រយោជន៍ខ្លួនប្រាណទាំងមូល។ គេប្រហែលជាអាចមើលឃើញ ឬ មើលមិនឃើញវា ប៉ុន្តែនោះមិនមែនជាអ្វីដែលធ្វើឲ្យវាសំខាន់នោះទេ។ អ្វីដែលធ្វើឲ្យវាមានសារៈសំខាន់នោះគឺថា វាបំពេញគោលបំណង តាមអ្វីដែលព្រះជាម្ចាស់បានដាក់វានៅក្នុងរូបកាយនោះ។ បើគ្មានវា ខ្លួនប្រាណអាចនឹងគ្មានសុខភាពល្អ និង មិនមានសមត្ថភាពក្នុងការធ្វើតាមកាតព្វកិច្ចរបស់វា។ នេះក៏ជារឿងពិត សម្រាប់ព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេងទៀត ដែលទាក់ទងនឹងព្រះកាយដែលផ្សំពីអ្នកជឿទាំងមូលផងដែរ។

ព្រះអំណោយទានទានដែលយើងហៅថា ព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេងទៀត រួមមាន៖

| | | | | | |
|---|---|---|---|---|---|
| ១. | ការបម្រើ | ៤. | ការចែកទាន | ៦. | បង្ហាញក្ដីមេត្តាករុណា |
| ២. | ការបង្រៀន | ៥. | ការនាំមុខ | ៧. | ការជួយ |
| ៣. | ការទូន្មាន | | (ការគ្រប់គ្រង) | | |

## *លំហាត់អនុវត្តន៍*

៥ ចូរអានគម្ពីររ៉ូម ១២:៦-១៣; គម្ពីរ១កូរិនថូស ១២:២៨ និង គម្ពីរ១កូរិនថូស ១២:២២-២៥។ បំពេញចន្លោះបន្ទាត់នៅក្នុងប្រយោគខាងក្រោម។

ក) ក្រុមទាំងបី នៃអំណោយមានដូចជា ៖...........................................................................................

.......................................................................................................................................

ខ) អ្វីដែលធ្វើឲ្យព្រះអំណោយទានមួយមានសារៈសំខាន់នោះគឺថា វាបំពេញ.................................. តាមអ្វីដែលព្រះជាម្ចាស់បានដាក់ឲ្យវា ។

គ) ព្រះអំណោយទានបីនៅក្នុងចំណោមព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេងទៀត គឺ .........................,...............................និង................................................................

៦ ព្រះអំណោយទាននៃព័ន្ធកិច្ចដែលយើងបានដាក់ពីក្រោមចំណុច ព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេង ទៀត គឺមានសារៈសំខាន់ដោយមូលហេតុថាពួកវា

ក) គឺងាយស្រួលយល់

ខ) បំពេញគោលបំណង តាមអ្វីដែលព្រះជាម្ចាស់ត្រូវការ។

គ) ត្រូវបានគេស្គាល់ថា ជាព្រះអំណោយទាននៃព័ន្ធកិច្ចដ៏មានសារៈសំខាន់។

## ព្រះអំណោយទាននៃព្រះវិញ្ញាណ

ព្រះអំណោយទានខាងឯវិញ្ញាណទាំងអស់គឺបានមកពីព្រះជាម្ចាស់។ មានក្រុមនៃព្រះអំណោយទានមួយ ដែលហៅថា "ព្រះអំណោយទាននៃព្រះវិញ្ញាណ"។ ពួកវាមានលក្ខណៈអធិធម្មជាតិ ក្នុងរបៀបពិសេសមួយ។ ពាក្យថា *អធិធម្មជាតិ* បានមកពីពាក្យពីរៈ ១) *អធិ* ដែលមានន័យថា "ខ្ពស់លើស" និង ២) *ធម្មជាតិ* " អ្វីដែលតាមផ្លូវសាមញ្ញធម្មតានៃធម្មជាតិ" ។ វាសំដៅទៅលើពិភពនៃវិញ្ញាណ ឬ សំដៅទៅកាន់ព្រះជាម្ចាស់។ ដូច្នេះ នៅពេលដែលយើងនិយាយថា ព្រះអំណោយទាននៃព្រះវិញ្ញាណគឺ អធិធម្មជាតិ យើងមានន័យថាព្រះអំណោយទាននោះមានប្រភពមកពីព្រះជាម្ចាស់ ហើយឫទ្ធានុភាពរបស់វាក៏បានមកពីព្រះជាម្ចាស់ដែរ។

ជាឧទាហរណ៍ សូមគិតអំពីព្រះអំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យ។ តាមបទពិសោធន៍ និង ការអង្កេតមើលរបស់យើង យើងនិយាយថា មនុស្សទាំងនោះមានសមត្ថភាពក្នុងការរៀនភាសាមួយ ប៉ុន្តែយើងមិននឹកស្មានថាពួកគេនិយាយភាសាដែលពួកគេមិនធ្លាប់បានរៀនពីមុនមកនោះទេ។ យ៉ាងណាមិញ នៅពេលដែលពួកគេទទួលបានព្រះអំណោយទាននិយាយភាសាចម្លែកអស្ចារ្យ មនុស្ស អាចនិយាយភាសាដែលពួកគេមិនធ្លាប់បានរៀនពីមុនមក។ ដូច្នេះ យើងថាព្រះអំណោយទានរបស់ពួកគេគឺអធិធម្មជាតិ។ ពួកគេអាចនិយាយប្រកបដោយសមត្ថភាពពិសេស និង ឫទ្ធានុភាពដែលបានមកពីព្រះជាម្ចាស់។

ព្រះអំណោយទាននៃព្រះវិញ្ញាណ គឺសុទ្ធតែជាអធិធម្មជាតិទាំងអស់។ យ៉ាងនោះហើយ វាមិនអាចកើតឡើងបានតាមមធ្យោបាយរបស់មនុស្សឡើយ។ គ្មានសមត្ថភាពណាមួយរបស់មនុស្ស អាចបង្កើតវាឡើងបានទេ។ ព្រះអំណោយទាននៃព្រះវិញ្ញាណរួមមាន៖

| | | |
|---|---|---|
| ១. ពាក្យសំដីនៃប្រាជ្ញា | ៤. ប្រោសឲ្យជាពីជំងឺ | ៧. សង្កេតឲ្យស្គាល់វិញ្ញាណ |
| ២. ពាក្យសំដីនៃចំណេះ | ៥. ធ្វើការអស្ចារ្យ | ៨. និយាយភាសាចម្លែក |
| ៣. ជំនឿ | ៦. ចេះថ្លែងព្រះបន្ទូល(ទាយ) | ៩. បកប្រែន័យភាសាចម្លែក |

## *លំហាត់អនុវត្តន៍*

៧ យោងតាម គម្ពីរ១កូរិនថូសជំពូក១២ ព្រះអំណោយទានរបស់ព្រះវិញ្ញាណទាំងអស់ ត្រូវបានប្រទានមកពី

ក) អ្នកជឿ

ខ) ព្រះជាម្ចាស់

គ) អ្នកបង្រៀន

ឃ) សាវ័ក

៨ ពាក្យថា "អធិធម្មជាតិ" ដែលយើងបានសិក្សារួចមកហើយនោះ មានន័យថា

ក) ទេពកោសល្យរបស់មនុស្ស។

ខ) អ្វីដែលយើងរៀនបាន ឬ ធ្វើបានដោយសមត្ថភាពខ្លួនឯង។

គ) ខ្ពស់លើសផ្លូវសាមញ្ញធម្មតា របស់ធម្មជាតិ។

៩ ការនិយាយភាសានៃឋានសួគ៌ដែលមិនស្គាល់ គឺបានមកពី

ក) ព្រះអំណោយទានមួយដែលព្រះជាម្ចាស់បានប្រទានសម្រាប់គោលបំណងជាក់លាក់មួយ។

ខ) សមត្ថភាពជាមនុស្សរបស់យើង។

គ) តាមរយៈការរៀនពីច្បាប់ធម្មជាតិ។

១០ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅពីខាងមុខប្រយោគនីមួយៗខាងក្រោមដែលត្រឹមត្រូវ។

ក) ព្រះអំណោយទាននៃព័ន្ធកិច្ច និងព្រះអំណោយទានព័ន្ធកិច្ចដទៃផ្សេងទៀត គឺមានលក្ខណៈខុសពីព្រះអំណោយទាននៃព្រះវិញ្ញាណ។

ខ) ព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេងទៀត គឺមិនសំខាន់នោះទេ។

គ) ព្រះអំណោយទានខាងវិញ្ញាណ ទាំងអស់គឺសុទ្ធតែសំខាន់សម្រាប់យើង ព្រោះពួកវាបំពេញគោលបំណង សម្រាប់ព្រះកាយដែលផ្សំពីអ្នកជឿ។

១១ ខាងក្រោមនេះជាតារាងនៃព្រះអំណោយទានខាងឯវិញ្ញាណមួយចំនួន។ នៅលើចន្លោះបន្ទាត់នីមួយៗ ចូរសរសេរអក្សរ **ព** ប្រសិនបើវាជាព្រះអំណោយទាននៃព័ន្ធកិច្ច សរសេរអក្សរ **ពដ** ប្រសិនបើវាជាព្រះអំណោយទានព័ន្ធកិច្ចដទៃផ្សេងទៀត និង សរសេរអក្សរ **វ** ប្រសិនបើវាជាព្រះអំណោយទាននៃព្រះវិញ្ញាណ។

........ក) ថេះថ្លែងព្រះបន្ទូល

........ខ) អ្នកគង្វាល

........គ) និយាយភាសាចម្លែក

.......ឃ) ការចែកទាន

........ង) ជំនឿ

........ច) ការជួយ

........ឆ) សារ៉ែក

........ជ) ប្រោសឲ្យជាពីជំងឺ

.......ឈ) អ្នកបង្រៀន

.......ញ) ការទូន្មាន

# ការប្រឡងផ្ទាល់ខ្លួន

ចម្លើយខ្លីៗ ។ ចូរបំពេញប្រយោគខាងក្រោមដោយសរសេរពាក្យដែលត្រឹមត្រូវនៅលើបន្ទាត់ដែលបានដាក់ឲ្យ។

១ អំពីអំណោយទានខាងឯវិញ្ញាណ មានគោលការណ៍បីយ៉ាង ផ្តល់ជូនអ្នកនៅក្នុងមេរៀន ដែលអ្នកត្រូវតែដឹងនោះគឺ

ក) ........................................................................................................................

ខ) ........................................................................................................................

គ) ........................................................................................................................

២ រឿងបីយ៉ាងដែលចំណេះដឹង មានទំនាក់ទំនងជាមួយនឹងការប្រើប្រាស់ព្រះអំណោយទានខាងឯវិញ្ញាណមានដូចជា៖

ក) ........................................................................................................................

ខ) ........................................................................................................................

គ) ........................................................................................................................

៣ ដោយប្រើព្រះគម្ពីររបស់អ្នក ចូរសរសេរព្រះអំណោយទាននៃព័ន្ធកិច្ចចំនួនប្រាំ ព្រមទាំងខគម្ពីរដែលរៀបរាប់ពីវា៖

ក) ........................................................................................................................

ខ) ........................................................................................................................

គ) ........................................................................................................................

ឃ) ........................................................................................................................

ង) ........................................................................................................................

ខគម្ពីរយោង..............................................................................................................

៤ ចូរសរសេរព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេងទៀតចំនួនបួន

ក) ........................................................................................................................

ខ) ........................................................................................................................

គ) ........................................................................................................................

ឃ) ........................................................................................................................

៥ ដោយមិនចាំបាច់ប្រើព្រះគម្ពីររបស់អ្នក ចូរសរសេរព្រះអំណោយទាននៃព្រះវិញ្ញាណទាំងប្រាំបួន៖

ក) ..........................................................................................................................

ខ) ..........................................................................................................................

គ) ..........................................................................................................................

ឃ) ..........................................................................................................................

ង) ..........................................................................................................................

ច) ..........................................................................................................................

ឆ) ..........................................................................................................................

ជ) ..........................................................................................................................

ឈ) ..........................................................................................................................

៦ ចូរសរសេរ គម្ពីរ១កូរិនថូស ១៣:១-២ តាមការចងចាំរបស់អ្នក នៅខាងក្រោមនេះ៖

....................................................................................................................................

....................................................................................................................................

....................................................................................................................................

**សំណួរពហុជម្រើស៖** មានចម្លើយត្រឹមត្រូវតែមួយគត់នៅក្នុងសំណួរនីមួយៗ ខាងក្រោម។ ចូរគូររង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយដែលត្រឹមត្រូវ។

៧ ចំណេះដឹងត្រឹមត្រូវអំពីព្រះអំណោយទានខាងវិញ្ញាណគឺមានសារៈសំខាន់ ដោយសារតែវា

ក) អនុញ្ញាតឲ្យយើងអាចឆ្លើយសំណួរអំពីវាបាន។

ខ) ផ្តល់គ្រឹះមូលដ្ឋានសម្រាប់ជំនឿ។

គ) ជួយយើងក្នុងការរៀបរាប់ឈ្មោះនៃព្រះអំណោយទានទាំងនោះ។

៨) ជំនឿត្រូវបានបង្កើតឡើងដោយ

ក) សេចក្តីស្រឡាញ់

ខ) ចំណេះដឹង

គ) ទេពកោសល្យ

៩ អ្នកក្រុងអេភេសូមិនបានទទួលការជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ព្រោះ

ក) ពួកគេមិនចង់ទទួល

ខ) ការជ្រមុជគឺមិនមែនសម្រាប់ពួកគេ

គ) ពួកគេមិនដែលដឹងពីការនោះ

# ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១ ក) ជំនឿ

ខ) ចំណេះដឹងពីព្រះគម្ពីរ

គ) ព្រះអំណោយទានខាងឯវិញ្ញាណ

៦ ខ) បំពេញគោលបំណង តាមអ្វីដែលព្រះជាម្ចាស់ត្រូវការ។

២ ក) គឺជាចម្លើយត្រឹមត្រូវ

៧ ខ) ព្រះជាម្ចាស់

៣ ក) ជំនឿ , បទពិសោធន៍

ខ) ចំណេះដឹង

គ) បទពិសោធន៍

៨ គ) ខ្ពស់លើសផ្លូវសាមញ្ញធម្មតា របស់ធម្មជាតិ។

៤ ខ), គ) និង ច) ជាចម្លើយត្រឹមត្រូវ។

៩ ក) ព្រះអំណោយទានមួយដែលព្រះជាម្ចាស់បានប្រទានសម្រាប់គោលបំណងជាក់លាក់មួយ។

៥ ក) ព្រះអំណោយទាននៃព័ន្ធកិច្ច, ព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេងទៀត និង អំណោយទាននៃព្រះវិញ្ញាណ។

ខ) គោលបំណង

គ) ការទូន្មាន, ការបម្រើ, ការបង្រៀន, ការនាំមុខ,ការចែកទាន, ការបង្ហាញក្តីមេត្តាករុណា, ការជួយ (ចម្លើយបី ពីក្នុងចម្លើយខាងលើនេះ ជាចម្លើយដែលអាចទទួលយកបាន)

១០ ក) និង គ) ជាចម្លើយត្រឹមត្រូវ

១១ ក) វ

ខ) ព

គ) វ

ឃ) ពដ

ង) វ

ច) ពដ

ឆ) ព

ជ) វ

ឈ) ព

ញ) ពដ

# ការប្រឡងជំពូកទីមួយ

ឥឡូវនេះ ដោយអ្នកបានបញ្ចប់ជំពូកទីមួយ អ្នកអាច*ប្រឡងជំពូកទីមួយ* បាន។ ចូររំឭកមេរៀនពីខាងលើ មុនពេលដែលអ្នកចាប់ផ្តើម។ ធ្វើតាមការណែនាំដ៏ប្រុងប្រយ័ត្ន ដើម្បីធ្វើការប្រឡង បន្ទាប់មក បន្តទៅជំពូកទីពីរ។

[illegible]

# ជំពូកទី ពីរ
# ការស្វែងយល់អំពី
# ព្រះអំណោយទានខាងឯព័ន្ធកិច្ច

## មេរៀន

៣ ពួកសាវ័ក និង ព្យាការី

៤ អ្នកផ្សាយដំណឹងល្អ និង អ្នកគង្វាលព្រមទាំងអ្នកបង្រៀន

៥ ព្រះអំណោយទាននៃការបម្រើ ការបង្រៀន និង ការទូន្មាន

៦ ព្រះអំណោយទាននៃការចែកទាន ការនាំមុខ ក្ដីមេត្ដាករុណា និង ការជួយ

មេរៀនទី ៣

# ពួកសាវ័ក និង ព្យាការី

យើងកំពុងកសាងចំណុចគោលសម្រាប់ការស្វែងយល់អំពីព្រះអំណោយទានខាងឯវិញ្ញាណ។ យើងបានឃើញពីសារៈសំខាន់នៃចំណេះដឹង និង ជំនឿ ដែលទាក់ទងជាមួយនឹងព្រះអំណោយទានរួចមកហើយ។ យើងក៏បានកត់សំគាល់ផងដែរ ថា ចំណេះដឹង និង ជំនឿរបស់យើង ជាអ្នកកំណត់ និង ដឹកនាំបទពិសោធន៍របស់យើង។ ឥឡូវនេះ ដោយយើងបានទទួលបានការយល់ដឹង និង  បានចេះច្បាស់អំពីចំណាត់ថ្នាក់នៃព្រះអំណោយទានហើយ នោះយើងអាចនឹងចាប់ផ្តើមការសិក្សារបស់យើងអំពីក្រុមទីមួយ គឺ ព្រះអំណោយទាននៃព័ន្ធកិច្ច។

នៅក្នុងពេលដែលយើងរៀនមេរៀនមួយនេះ យើងនឹងរៀនអំពី វិសាលភាព និង មុខងារ នៃព្រះអំណោយទាននីមួយៗទាំងអស់នោះ។ យើងនឹងរៀនអំពីរបៀបដែលព្រះអំណោយទាននីមួយៗ ចូលរួមនៅក្នុងផ្នែកមួយយ៉ាងធំ ក្នុងការអភិវឌ្ឍព្រះកាយដែលផ្សំដោយអ្នកជឿ។

ក្នុងនាមជាគ្រិស្តបរិស័ទ អ្នកនឹងទទួលបានសមត្ថភាពក្នុងការស្គាល់ប្រភេទផ្សេងៗនៃព្រះអំណោយទាននៃព័ន្ធកិច្ច។ លើសពីនោះទៀត នៅពេលដែលចំណេះដឹងរបស់អ្នកកាន់តែកើនឡើង អ្នកអាចនឹងមានសមត្ថភាពដឹងពីព្រះហស្តរបស់ព្រះជាម្ចាស់ដែលនៅលើជីវិតរបស់អ្នកផ្ទាល់។

## *គម្រោងនៃមេរៀន*

ក. ទ្រង់បានប្រទានឲ្យអ្នកខ្លះទៅ ជាសាវ័ក

ខ. ទ្រង់បានប្រទានឲ្យអ្នកខ្លះ ទៅជាព្យាការី

## *វត្ថុបំណងនៃមេរៀន*

នៅពេលដែលបញ្ចប់មេរៀនមួយនេះ អ្នកអាចនឹង ៖

១. ប្រាប់ពីព្រះនាមរបស់ព្រះដែលបានប្រទាន ព្រះអំណោយទានខាងឯវិញ្ញាណទាំងអស់មក ហើយបកស្រាយពីមុខងារ នៃព្រះអំណោយទានជាសាវ័ក។

២. បកស្រាយពីមុខងារ នៃព្យាការី។

## *សកម្មភាពក្នុងការសិក្សា*

១. មុនពេលយើងចាប់ផ្តើមមេរៀននេះ ចូរអានគម្ពីរអេភេសូ ៤:១-១៦ ដោយប្រុងប្រយ័ត្នចំនួនបីលើក។

២. ចំលងខគម្ពីរអេភេសូ ៤:១១ ដាក់ក្នុងសៀវភៅកត់ត្រារបស់អ្នក ហើយគូសបន្ទាត់នៅពីក្រោមព្រះអំណោយទាននៃព័ន្ធកិច្ចទាំងប្រាំដែលមាននៅក្នុងនោះ។

៣. បើកទៅកាន់និយមន័យនៅចុងបញ្ចប់នៃសៀវភៅសិក្សារបស់អ្នក ដើម្បីទទួលបានន័យរបស់ពាក្យសំខាន់។

៤. ធ្វើលំហាត់អនុវត្តន៍នីមួយៗ ដែលអ្នកឃើញ។

៥. ធ្វើការប្រឡងផ្ទាល់ខ្លួនដែលនៅចុងបញ្ចប់នៃមេរៀន។ ប្រសិនបើអ្នក ឃើញថាខ្លួនអ្នក មិនឆ្លើយចម្លើយបានត្រឹមត្រូវនោះទេ សូមកុំបន្តទៅមេរៀនបន្ទាប់ទៀត ដរាបណាអ្នកឆ្លើយ សំណួរទាំងអស់បានត្រឹមត្រូវជាមុនសិន។ ត្រឡប់មកមើលមេរៀនឡើងវិញ នៅពេលដែលអ្នកត្រូវការជំនួយ។

## *ពាក្យសំខាន់*

| | | |
|---|---|---|
| ធ្លាក់ | ស្គាល់ | បើកសំដែង |
| អធិប្បាយ | ការបណ្តាលចិត្ត | |

# ក. ទ្រង់បានប្រទានឲ្យអ្នកខ្លះទៅ ជាសាវ័ក

**វត្ថុបំណងទី ១.** *ប្រាប់ពីព្រះនាមរបស់ព្រះដែលបានប្រទាន ព្រះអំណោយទានខាងឯវិញ្ញាណទាំងអស់មកហើយ បកស្រាយពីមុខងារ នៃព្រះអំណោយទានជាសាវ័ក។*

## ការស្គាល់ព្រះដែលបានប្រទានឲ្យ

នៅពេលដែលមានការឲ្យអំណោយ វាតែងតែមានការចូលរួមពីភាគីពីរ គឺអ្នកឲ្យ និង អ្នកទទួល។ សារៈសំខាន់នៃអំណោយ គឺផ្អែកទៅលើ *អ្នកណា* ដែលឲ្យវាមក ហើយតើវាគឺជា*អ្វី*។ នៅពេលដែលម្ចាស់ក្សត្រី នៃប្រទេសអង់គ្លេស យាងទៅធ្វើទស្សនកិច្ចនៅសហរដ្ឋអាមេរិក ក្នុងអំឡុងពេលលោក ឌីវ៉ាយត៍ ឌី. អាយសិនហាវើ (Dwight D. Eisenhower) កាន់តំណែងជាប្រធានាធិបតី លោកបានថ្វាយចូកែវឆ្លាក់ដ៏ស្រស់ស្អាត ទៅកាន់ទ្រង់។ លោកបានចំណាយប្រាក់ជាច្រើនទៅលើក្រុមហ៊ុនកែវមួយដែលនៅក្នុងរដ្ឋ ញូវយ៉ក (New York) សម្រាប់ចូនោះ ។ យើងប្រាកដក្នុងចិត្តថា វានឹងបានទៅនៅកន្លែងដ៏សំខាន់មួយក្នុងចំណោមកម្មសិទ្ធិទ្រព្យរបស់ម្ចាស់ក្សត្រី ដោយមានហេតុផលពីរយ៉ាង ៖ (១) វាបានមកពីបុរសម្នាក់ដែលមានឋានៈយ៉ាងសំខាន់ និង (២) វាមានសម្រស់ស្រស់ស្អាត ហើយមានតម្លៃថ្លៃថែមទៀតផង។

ព្រះអំណោយទានជាសាវ័ក គឺមានសារៈសំខាន់ក៏ដោយសារមូលហេតុស្រដៀងគ្នានេះដែរ។ ទីមួយ វាមានសារៈសំខាន់ដោយសារ *អ្នក* ដែលបានប្រទានវាមក និងទីពីរ វាមានសារៈសំខាន់ដោយសារ *អ្វី* ដែលជាវា។ យើងនឹងនិយាយគ្នាអំពីមូលហេតុទីពីរនៅពេលក្រោយ ។ ប៉ុន្តែពេលនេះ យើងនឹងរៀនអំពីព្រះដែលបានប្រទានព្រះអំណោយទាននេះ សម្រាប់ឲ្យអ្នកខ្លះបានក្លាយជាសាវ័ក។

នៅក្នុងគម្ពីរអេភេសូ ៤:៧-១១ បង្ហាញថាព្រះដែលប្រទានព្រះអំណោយទាននោះគឺត្រូវបានគេស្គាល់ថាជាព្រះគ្រិស្ត។ នៅក្នុងខទី៨ នៃជំពូកដដែលនោះ ក៏បានបង្ហាញនៅក្នុង គម្ពីរទំនុកតម្កើង ៦៨: ១៨។ នៅក្នុងខទី៧ យើងបានឃើញពីការបកស្រាយយ៉ាងជាក់ច្បាស់មួយគឺ "ព្រះអង្គបានផ្តល់ព្រះគុណមកអោយយើងម្នាក់ៗតាមកំរិតព្រះអំណោយទាន ដែលព្រះគ្រិស្តប្រទានមកយើង។" ដូច្នោះ យើងអាចសន្និដ្ឋានបានថា ព្រះគ្រិស្តគឺព្រះអង្គដែលបានប្រទាន ព្រះអំណោយទាននៃព័ន្ធកិច្ច។ យើងនឹងរៀនបន្ថែមទៀតអំពី ទ្រង់ដែលជាព្រះអង្គដែលប្រទាន ស្របពេលដែលយើងសិក្សាជំពូកមួយនេះ។

### *លំហាត់អនុវត្តន៍*

---

១. ចូរគូសរង្វង់ជុំវិញអក្សរដែលនៅពីខាងមុខប្រយោគត្រឹមត្រូវនីមួយៗ នៅខាងក្រោមនេះ។

ក) ព្រះអំណោយទានមួយ មានការចូលរួមតែភាគីម្ខាងប៉ុណ្ណោះ។

ខ) គេអាចស្គាល់ពីសារៈសំខាន់នៃព្រះអំណោយទានមួយបាន ដោយផ្អែកលើព្រះអង្គដែលប្រទានវាមក និង តើវាជា*អ្វី*។

គ) គម្ពីររ៉ូមជំពូក១២ ប្រាប់យើងអំពី អ្នកដែលប្រទានព្រះអំណោយទាននៃព័ន្ធកិច្ចនោះមក។

ឃ) ព្រះគ្រិស្តបានប្រទានព្រះអំណោយទានឲ្យអ្នកខ្លះបានក្លាយជាសាវ័ក។

# ការបង្ហាញពីអ្នកទទួល

ដូចអ្វីដែលយើងបាននិយាយរួចមកហើយ ភាគីទាំងពីរគឺមានចំណែកនៅក្នុងគ្រប់ព្រះអំណោយទានទាំងអស់៖ គឺទាំង *អ្នកឲ្យ* និង *អ្នកទទួល*។ យើងបាននិយាយរួចមកហើយថា ព្រះគ្រិស្ដគឺជាព្រះអង្គដែលបានប្រទានព្រះអំណោយទាននៃព័ន្ធកិច្ច។ នៅក្នុងផ្នែកមួយនេះ យើងនឹងដឹងថា អ្នកទទួលគឺជាអ្នកណា។

ចម្លើយគឺមានពីរដង។ នៅក្នុងគម្ពីរ អេភេសូ៤:៨ បាននិយាយថា ព្រះអម្ចាស់ "ប្រទានព្រះអំណោយទាន ផ្សេងៗដល់មនុស្សលោក"។ វាពិតជាពិបាកណាស់ ក្នុងការសន្មតថាតើ "មនុស្សលោក" នោះជាអ្នកណាខ្លះ ទោះជាយ៉ាងណា វាបានបង្ហាញយើងពីសារៈសំខាន់ នៃការអានខគម្ពីរនៃប្រធានបទនោះទាំងមូល ដើម្បីអាចរកឃើញអត្ថន័យរបស់ខគម្ពីរមួយបាន។ នេះគឺជាទម្លាប់ដែលមានប្រយោជន៍មួយដើម្បីអភិវឌ្ឍការអានព្រះគម្ពីរ។ នៅក្នុងគម្ពីរ អេភេសូ៤:១-១៦ បើយោងទៅតាមលោកប៉ូល យើងឃើញថាក្រុមជំនុំទាំងមូលទទួលបានព្រះអំណោយទាននៃព័ន្ធកិច្ច។ នៅក្នុងខទី៤ លោកបាននិយាយថា "ព្រះកាយមានតែមួយ"។ នៅក្នុងខទី១២ លោកបាននិយាយអំពី "ព្រះកាយរបស់ព្រះគ្រិស្ដ"។ ព្រះអំណោយទាននៃព័ន្ធកិច្ចបានប្រទានទៅឲ្យមនុស្សដែលនៅក្នុងព្រះកាយ និង ប្រទានឲ្យសម្រាប់ព្រះកាយទាំងមូលផងដែរ។

ចំពោះបុគ្គលម្នាក់ វាគឺជាការប្រទានឲ្យមានសមត្ថភាពពិសេស និង ការត្រាស់ហៅ ឲ្យក្លាយជាសាវ័ក ។ ចំពោះព្រះកាយទាំងមូលវិញ គឺជាការប្រទានទៅកាន់សាវ័កទាំងនោះផ្ទាល់ នូវគោលបំណងក្នុងការបំពេញតំណែងរបស់ពួកគាត់។ សូមអាននៅក្នុងគម្ពីរអេភេសូ២:១០ និង អេភេសូ៣:៥។

## *លំហាត់អនុវត្តន៍*

---

២ ដើម្បីស្វែងរកអត្ថន័យត្រឹមត្រូវនៃខគម្ពីរមួយ យើងគប្បីត្រូវសិក្សា

ក) ខគម្ពីរនោះតែមួយ

ខ) ខគម្ពីរនៃប្រធានបទទាំងអស់តែម្ដង

គ) យ៉ាងហោចណាស់ពីរខ

៣ ពួកសាវ័កគឺ

ក) កណ្ឌគម្ពីរណាមួយនៅក្នុងព្រះគម្ពីរ

ខ) សមាជិកពិសេសនៅក្នុងព្រះកាយ

គ) មនុស្សគ្រប់គ្នានៅក្នុងព្រះកាយ

៤ ព្រះអំណោយទាននៃព័ន្ធកិច្ច ជាសាវ័កម្នាក់គឺ

ក) បានប្រទានទៅឲ្យបុគ្គលម្នាក់សម្រាប់ការប្រៀនប្រដៅខ្លួនគាត់ផ្ទាល់។

ខ) សម្រាប់តែសាវ័កទាំង ដប់ពីរនាក់ដំបូងតែប៉ុណ្ណោះ។

គ) ឲ្យទៅកាន់បុគ្គលម្នាក់ដើម្បីប្រៀនប្រដៅក្រុមជំនុំ។

## ការអធិប្បាយពីមុខងារ

ព្រះអំណោយទាននៃព័ន្ធកិច្ចមួយដែលត្រូវបានគេស្គាល់ថា សាវ័ក គឺជាតំណែងមួយដែលសំខាន់បំផុតនៅក្នុងព្រះកាយ។ តំណែង មានន័យថាការដាក់ទំនួលខុសត្រូវ ឬ កាតព្វកិច្ច។ ព្រះអំណោយទានមួយនេះត្រូវបានដាក់នៅដំបូងគេ ប្រហែលដោយព្រោះតែវាមានជាប់ទាក់ទងនឹងការបង្កើត និង ការមើលខុសត្រូវ។

មានសាវ័កពីរប្រភេទ។ ទីមួយ គឺមានអ្នកជឿមួយក្រុមជាពិសេស ដែលទទួលបានងារមួយនេះ។ ពួកគេមានគ្នាតែដប់ពីរនាក់តែប៉ុណ្ណោះ។ នៅពេលម្នាក់ក្នុងចំណោមពួកគេ គឺលោកយ៉ូដាស ដែលបានក្បត់ព្រះអម្ចាស់របស់គាត់ ហើយបានបាត់បង់តំណែងជាសាវ័ករបស់គាត់ គាត់ត្រូវបានជំនួសដោយមនុស្សម្នាក់ទៀត៖ "សិស្សនាំគ្នាចាប់ឆ្នោតត្រូវលើលោកម៉ាត់ធាស ហើយលោកម៉ាត់ធាសក៏បានចូលរួមក្នុងក្រុមសាវ័កដប់មួយរូបទៀត។" (គម្ពីរកិច្ចការ ១:២៦)។

ដើម្បីមានសិទ្ធិធ្វើជាសាវ័កម្នាក់ មនុស្សម្នាក់ៗត្រូវបំពេញតាមលក្ខខ័ណ្ឌមួយចំនួន។ លោកលូកា ជាអ្នកសរសេរកណ្ឌគម្ពីរកិច្ចការ បានប្រាប់នៅក្នុងគម្ពីរកិច្ចការ ១:២១-២២ថា "ហេតុនេះ ក្នុងចំណោមអស់អ្នកដែលបានមកតាមយើង នៅពេលព្រះយេស៊ូដឹកនាំយើង គឺចាប់តាំងពីគ្រាដែលលោកយ៉ូហានបានធ្វើពិធីជ្រមុជទឹក*ថ្វាយព្រះអង្គ រហូតដល់ពេលព្រះជាម្ចាស់លើកយកព្រះអង្គចេញពីយើងទៅ"។ ទោះជាយ៉ាងណា យើងមិនប្រាកដទេថា ព្រះអម្ចាស់បានបង្កើតលក្ខខ័ណ្ឌទាំងអស់នេះឡើយ។ វាក៏អាចជាគំនិតដែលមានការព្រមព្រៀងគ្នា ក្នុងចំណោមសាវ័កទាំងដប់មួយនាក់នោះ។

ឥឡូវនេះ យើងប្រឈមមុខជាមួយនឹងសំណួរដ៏ពិបាកឆ្លើយមួយ។ តើលោកប៉ូលជាសាវ័កដូចជាសាវ័កទាំងដប់ពីរដែរឬទេ? មានសំណួរខ្លះមិនងាយស្រួលឆ្លើយនោះទេ។ ក្នុងនាមជាអ្នកសិក្សាព្រះគម្ពីរ យើងត្រូវដឹងថា សំណួររបស់យើងខ្លះៗ ប្រហែលជាមិនអាចមានចម្លើយនោះទេ ដរាបយើងបានទៅឯនគរស្ថានសួគ៌។ ប៉ុន្តែ យើងមិនត្រូវឲ្យការនេះ រារាំងយើងក្នុងការស្វែងរកចម្លើយនោះទេ។ ការស្វែងរក ជួយសម្រួចគំនិតរបស់យើង។ វាធ្វើឲ្យយើងក្លាយជាបាវបម្រើដ៏ល្អរបស់ព្រះអម្ចាស់។

ពេលនេះ សូមត្រឡប់ទៅកាន់លោកប៉ូលវិញ។ តាមរយៈទីបន្ទាល់ផ្ទាល់របស់លោក យើងសន្និតថា លោកចាត់ទុកថាខ្លួនលោកក៏ដូចជាសាវ័កមួយរូបដែរ។ ខាងក្រោមនេះ ជាខគម្ពីរយោងខ្លះៗ ដែលលោកប៉ូលបានបញ្ជាក់យ៉ាងច្បាស់ៗថា ខ្លួនលោកក៏នៅក្នុងចំណោមពួកគេដែរ៖

១. "បើតាមខ្ញុំយល់ឃើញព្រះជាម្ចាស់ប្រទានអោយយើង ដែលជាសាវ័ក*មានឋានៈទាបជាងគេ គឺទុកដូចជាអ្នកដែលត្រូវគេកាត់ទោសប្រហារជីវិតនៅទីសាធារណៈអោយគ្រប់ៗគ្នាឃើញ ។" (គម្ពីរ១កូរិនថូស ៤:៩). ដោយប្រើពាក្យថា *យើង* លោកប៉ូល ប្រហែលជាចាត់ទុកខ្លួនលោកថាជាម្នាក់ក្នុងចំណោមពួកគេនោះហើយ។

២. "តើយើងគ្មានសិទ្ធិនឹងនាំស្ត្រី(ប្រពន្ធ)ម្នាក់ដែលមានជំនឿទៅជាមួយ ដូចសាវ័កឯទៀតៗទេឬ? " (គម្ពីរ១កូរិនថូស៩:៥)។ នៅត្រង់នេះ ពាក្យថា *ឯទៀតៗ* បញ្ជាក់ប្រាប់ថាលោកក៏បាននៅក្នុងក្រុមសាវ័កនោះដែរ។

៣. "ដ្បិតក្នុងចំណោមសាវ័កទាំងអស់ ខ្ញុំជាអ្នកតូចជាងគេ ហើយមិនសមនឹងមានឈ្មោះជាសាវ័កទៀតផង ព្រោះខ្ញុំបានបៀតបៀនក្រុមជំនុំរបស់ព្រះជាម្ចាស់។" ( គម្ពីរ១កូរិនថូស ១៥:៩)។ ពាក្យសំខាន់នៅត្រង់កន្លែងនេះ គឺពាក្យថា *តូចជាងគេ* ដែលបានបង្ហាញយ៉ាងច្បាស់ថាលោកស្ថិតនៅក្នុងចំណោមពួកគេ។ លោកមិនអាចតូចជាងគេបាននោះទេ លើកលែងតែលោកធ្លាប់ជាម្នាក់ក្នុង« ចំណោមពួកគេ។

អ្នកសិក្សាព្រះគម្ពីរខ្លះ មានអារម្មណ៍ថា ក្រុមសាវ័កដែលប្រជុំគ្នានៅក្នុងបន្ទប់ខាងលើនោះ បានបង្កើតកំហុសមួយ ដែលបានតែងតាំងលោកម៉ាត់ធាស។ ពួកគេគិតថាលោកប៉ូលគឺជា ព្រះតម្រិះរបស់ព្រះអម្ចាស់ដែលទ្រង់ជ្រើសឲ្យជំនួសតំណែងលោកយ៉ូដាស។ យើងមិនអាចដឹងប្រាកដនោះទេ។ គម្ពីរវិវរណៈ ២១:១៤ បានថែងថា៖ "កំពែងរបស់ក្រុងមានគ្រឹះដប់ពីរ ហើយនៅលើគ្រឹះទាំងនោះមានចារឹកឈ្មោះសាវ័ក*ទាំងដប់ពីររបស់កូនចៀម។" នាមរបស់មនុស្សអស្ចារ្យជាច្រើននាក់ទៀត នឹងលេចឡើងនៅលើថ្មគ្រឹះទាំងពីរ នៃទីក្រុងយេរូសាឡឹមថ្មី។ តើវានឹងមានឈ្មោះរបស់លោកម៉ាត់ធាស ឬ លោកប៉ូល? យើងនឹងបានឃើញនៅពេលដែលយើងបានទៅដល់ទីនោះ។

សាវ័កទាំងដប់ពីរនាក់មានមុខងារមួយដែលគ្មានសមាជិកនៅក្នុងព្រះកាយរបស់ព្រះគ្រិស្តម្នាក់ណាអាចមានដូចពួកគេបាន។ ពួកគេមានចំណែកក្នុងការបង្កើតក្រុមជំនុំរបស់ទ្រង់នៅក្នុងពិភពលោកនេះ។ មានអ្នកខ្លះនៅក្នុងចំណោមពួកគេក៏បានសរសេរកណ្ឌគម្ពីរដែលយើងបានឃើញនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មីរបស់យើងនេះ។

នៅពេលពួកសាវ័កទាំងដប់ពីរនាក់ មានមុខងារយ៉ាងពិសេសក្នុងនាមជាសាវ័ក ក៏មានព្រះអំណោយទាននៃព័ន្ធកិច្ចមួយទៀតដែលគេស្គាល់ថា ភាពជាសាវ័ក។ យើងមិនត្រូវមានអារម្មណ៍ថាមុខងារទាំងពីរនោះដូចគ្នានោះទេ ទោះបីជាពួកគេមានលក្ខណៈស្រដៀងគ្នាខ្លះក៏ដោយ។ តំណែងរបស់សាវ័កទាំងអស់ដប់ពីរនាក់នៅក្នុងព្រះកាយគឺពិតជាពិសេសខ្លាំងណាស់។ វាមិនអាច ធ្វើឡើងវិញម្តងទៀតឡើយ ប៉ុន្តែភាពជាសាវ័កត្រូវតែជាព្រះអំណោយទាន សម្រាប់គ្រប់សម័យកាលនៃការបង្កើតក្រុមជំនុំ ឬ ព្រះកាយ។

ព្រះយេស៊ូបានប្រទានពួកសាវ័កមកក្នុងព្រះកាយរបស់ទ្រង់ ដើម្បីធ្វើកិច្ចការពិសេសៗ។ មនុស្សមិនត្រូវគិតចង់ក្លាយខ្លួនជាសាវ័កទេ ពុំនោះវាមិនខុសអ្វីពីជីតដូមួយដុំដែលគិតចង់ធ្វើខ្លួនជា កុម្ភការភណ្ឌ (ឆ្នាំង ថូ ក្រឡ)នោះដែរ។ សាវ័កដ៏ពិតមិនត្រូវសម្បីតែគិតបែបនោះចំពោះខ្លួនគេនោះទេ។ អ្វីដែលពួកគេធ្វើជួយឲ្យអ្នកដទៃអាចស្គាល់ពួកគេថាជាសាវ័កបាន។ អស់អ្នកដែលហៅខ្លួនឯងថាជាសាវ័ក ឬ ត្រូវបានតែងតាំងឲ្យធ្វើជាសាវ័កដោយអ្នកដទៃ ប្រហែលមិនមែនជាសាវ័កនោះទេ៖ "អ្នកបានល្បងលមើលពួកដែលតាំងខ្លួនជាសាវ័ក* ហើយឃើញថាពួកនោះមិនមែនជាសាវ័កទេ គឺជាអ្នកកុហក។" (គម្ពីរវិវរណៈ:២:២)។ (សូមមើលគម្ពីរ២កូរិនថូស ១១:១៣)។

អត្ថន័យនៃពាក្យថា *សាវ័ក* នឹងជួយយើងឲ្យយល់ថាតើអ្នកណាជាសាវ័កនោះ និង តើអ្វីទៅជាមុខងារពិតប្រាកដរបស់ពួកគេ។ ពាក្យថា *សាវ័ក* មានន័យថា "ចាត់ឲ្យចេញទៅ" ឬ "បញ្ជូនទៅមុខ" ។ លោកម៉ាថាយ និង លោកម៉ាកុស ប្រើប្រាស់ពាក្យថា *សាវ័ក* នេះតែម្នាក់ម្តងប៉ុណ្ណោះ

(គម្ពីរម៉ាថាយ ១០:២; គម្ពីរម៉ាកុស ៦:៣០)។ នៅក្នុងករណីនីមួយៗ ពាក្យនេះចង្អុលប្រាប់ពីប្រភេទការងារពិសេសមួយ គឺជាកិច្ចការនៃបេសកជន។ តាមរបៀបនេះ ទាំងសាវ័កដប់ពីរនាក់ និង ព្រះអំណោយទាននៃភាពជាសាវ័ក គឺមានលក្ខណៈដូចគ្នា។

ដូច្នេះ សាវ័កម្នាក់គឺជាបុគ្គលដែលត្រូវបានចាត់បញ្ជូនទៅមុខ ដោយព្រះអម្ចាស់ដើម្បីនឹងនាំយកដំណឹងល្អទៅកាន់កន្លែងថ្មីៗ។ កិច្ចការរបស់សាវ័កគឺចាក់គ្រឹះសម្រាប់ផ្នែកថ្មីមួយនៃព្រះកាយ។ រួមជាមួយនឹងការងាររបស់ពួកសាវ័កផ្សេងៗទៀត គឺ ការកសាងឡើង និង មើលការខុសត្រូវព្រះកាយនោះ។ ពួកសាវ័កធ្វើបែបនេះ " ដើម្បីរៀបចំប្រជាជនដ៏វិសុទ្ធអោយបំពេញមុខងារបំរើ និងកសាងព្រះកាយរបស់ព្រះគ្រិស្តឡើង" ( គម្ពីរអេភេសូ ៤:១២)។

ជាឧទាហរណ៍ លោក ខេន ហ្គេត (Ken Gates) បានទៅតំបន់ភាគពាយព្យនៃប្រទេសកាណាដាខាងជើង ក្នុងនាមជាបេសកជនម្នាក់។ មុនពេលដែលលោកចេញទៅ មានអ្នកខ្លះបានព្យាយាមបំបាក់ទឹកចិត្តរបស់គាត់។ គ្រូមួយចំនួនរបស់លោកបានប្រាប់លោកថា លោកមិនអាចក្លាយជាអ្នកចែកចាយព្រះបន្ទូលបានឡើយ។ ពួកគេមិនដែលគិតថាលោកមានលក្ខណៈជាសាវ័កម្នាក់នោះឡើយ។ ចំណែកអ្នកដែលលោកទៅដឹកនាំបម្រើ គេមិនស្វាគមន៍លោកសោះ។ ពួកគេបានព្យាយាមធ្វើឲ្យលោកចាក់ចេញ។ ប៉ុន្តែលោក ខេន បានដឹងថាព្រះជាម្ចាស់ជាអ្នកចាត់លោក ដូច្នេះក៏បន្តនៅ។ មកដល់ពេលនេះ មានអ្នកជឿដ៏អស្ចារ្យជាច្រើននាក់ និង ក្រុមជំនុំជាច្រើននៅក្នុងប្រទេសនោះ។ លោកខេន ហ្គេត បានដាំក្រុមជំនុំនៅទីនោះ។ លោកបានជួយឲ្យអ្នកជឿអភិវឌ្ឍឡើង និង បានលូតលាស់ផង។ លោកក៏បានមើលការខុសត្រូវស្នាព្រះហស្តរបស់ព្រះអម្ចាស់ ប្រៀបដូចជាឪពុកម្នាក់យ៉ាងដូច្នោះដែរ។ លោកមិនដែលធ្លាប់គិតថាចង់ហៅខ្លួនឯងថាជាសាវ័កម្នាក់នោះទេ ប៉ុន្តែអស់អ្នកដែលស្គាល់លោក និង កិច្ចការរបស់លោក គេដឹងថាលោកជាសាវ័កម្នាក់ពិតប្រាកដមែន។

## *លំហាត់អនុវត្តន៍*

៥ សាវ័កដំបូងទាំងដប់ពីរនាក់ ខុសពីសាវ័កក្នុងសម័យថ្មីនេះ ត្រង់ថាពួកគេ

ក) ធ្វើខ្លួនជាសាវ័ក

ខ) ចូលរួមតែនៅក្នុងកិច្ចការបេសកជនតែប៉ុណ្ណោះ

គ) បានសរសេរកណ្ឌព្រះគម្ពីរនៃសម្ព័ន្ធមេត្រីថ្មី

៦ មុខងាររបស់សាវ័កបច្ចុប្បន្ននេះគឺត្រូវ

ក) សរសេរកណ្ឌគម្ពីរសម្រាប់សម្ព័ន្ធមេត្រីថ្មីបន្ថែមទៀត

ខ) នាំយកដំណឹងល្អទៅកាន់កន្លែងថ្មីទៀត ហើយមើលការខុសត្រូវ ការអភិវឌ្ឍនៃស្នាព្រះហស្តរបស់ព្រះជាម្ចាស់នៅទីនោះ។

គ) ខំសិក្សារៀងសូត្រឲ្យពូកែដើម្បីក្លាយជាអ្នកចែកចាយដ៏ល្អម្នាក់។

# ការបកស្រាយពីការអភិវឌ្ឍ

ពួកសាវ័កមិនត្រូវបានបង្កើតមកស្រាប់ៗនោះទេ។ ដំបូងពួកគេគឺជាអ្នកជឿដែរ។ ពួកគេទទួលបានអារម្មណ៍ដឹងពីការត្រាស់ហៅរបស់ព្រះជាម្ចាស់មកលើជីវិតរបស់ពួកគេយ៉ាងខ្លាំង ប៉ុន្តែពួកគេតែងតែមិនដឹងខ្លួនទេថា ពួកគេនឹងក្លាយជាព្រះអំណោយទានយ៉ាងពិសេសរបស់ព្រះគ្រិស្តទៅកាន់ក្រុមជំនុំ។

នៅពេលដែលព្រះជាម្ចាស់ជ្រើសរើសមនុស្សម្នាក់ឲ្យធ្វើជាសាវ័ក ទ្រង់ប្រទានពេលសម្រាប់ឲ្យមនុស្សម្នាក់នោះបានលូតលាស់ និង ត្រៀមខ្លួនសម្រាប់ការងារនោះ។ លោកប៉ូលមិនបានបំពេញតំណែងជាសាវ័ក នៅពេលដែលលោកទទួលបានការសង្គ្រោះដំបូងនោះឡើយ។ ប៉ុន្តែព្រះជាម្ចាស់ដាក់រឿងមួយនៅក្នុងដួងចិត្តរបស់លោក ថាលោកមានការងារពិសេសមួយដើម្បីលោកធ្វើ៖ "គាត់មានប្រសាសន៍ថា "ព្រះនៃបុព្វបុរស*របស់យើង បានជ្រើសរើសបង ដើម្បីអោយបងស្គាល់ព្រះហឫទ័យរបស់ព្រះអង្គ អោយបងបានឃើញព្រះដ៏សុចរិត និងអោយបងបានឮព្រះបន្ទូលរបស់ព្រះអង្គផ្ទាល់តែម្ដង ដ្បិតបងនឹងធ្វើជាបន្ទាល់របស់ព្រះអង្គ នៅមុខមនុស្សទាំងអស់ អំពីហេតុការណ៍ដែលបងបានឃើញ និងអំពីសេចក្ដីដែលបងបានឮ។" (គម្ពីរកិច្ចការ ២២:១៤-១៥)។

វាពិតណាស់ដែល លោកប៉ូលគឺជាប្រភេទសាវ័កពិសេសមួយ។ ប៉ុន្តែរបៀបដែលលោករៀបចំខ្លួនដើម្បីក្លាយជាសាវ័កម្នាក់ គឺដូចគ្នានឹងរបៀបដែលអ្នកជឿបច្ចុប្បន្ននេះរៀបចំខ្លួនដែរ។ មានពីរបីជំហាន ក្នុងការរៀបចំមួយនេះ៖

*១. ការរងទុក្ខ*

អ្នកជឿខ្លះ មិនអាចក្លាយខ្លួនជាសាវ័កបានឡើយ។ ពួកគេមិនស្ម័គ្រចិត្តរងទុក្ខនោះទេ ដែលវាប្រហែលជារឿងចាំបាច់ នៅក្នុងការរៀបចំខ្លួនរបស់សាវ័កមួយរូប។ លោកប៉ូលបានដឹងអំពីរឿងនេះតាំងពីមុនពេលដែលលោកបានក្លាយជាសាវ័កទៅទៀត៖ "ខ្ញុំនឹងបង្ហាញប្រាប់គាត់អោយដឹងថា គាត់ត្រូវរងទុក្ខលំបាកជាច្រើន ព្រោះតែឈ្មោះរបស់ខ្ញុំ" (គម្ពីរកិច្ចការ ៩:១៦)។ ការរងទុក្ខជួយរៀបចំមនុស្សតាមរបៀបពិសេសមួយ ដើម្បីធ្វើជាអ្នកដឹកនាំនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត។ អ្នកណាដែលមិនធ្លាប់រងទុក្ខ មិនអាចដឹកនាំបម្រើអ្នកដទៃដូចជាអ្នកដែលធ្លាប់បានរងទុក្ខនោះឡើយ។ អ្នកណាដែលមិនសុខចិត្តរងទុក្ខ អ្នកនោះក៏មិនបានរៀបចំខ្លួនដើម្បីនាំយកដំណឹងល្អទៅកាន់កន្លែងថ្មីមួយដែលពួកគេអាចនឹងរងទុក្ខជាងនេះផងដែរ។ ការរងទុក្ខ រៀបចំមនុស្សសម្រាប់ការរងទុក្ខកាន់តែច្រើនទៀត។

*២. ការកើនឡើង*

សូម្បីតែព្រះយេស៊ូក៏បានកើនឡើងជាលំដាប់ នៅពេលដែលទ្រង់កំពុងរៀបចំអង្គទ្រង់សម្រាប់ព័ន្ធកិច្ចរបស់ទ្រង់ដែរ៖ "ព្រះយេស៊ូមានវ័យចំរើនឡើង ហើយមានប្រាជ្ញាកាន់តែវាងវៃ ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់ និងជាទីគាប់ចិត្តមនុស្សផងទាំងពួង។" (គម្ពីរលូកា២:៥២)។ នៅពេលដែលយើងនិយាយថាព័ន្ធកិច្ចរបស់ទ្រង់*បានកើនឡើង* យើងមានន័យថាវាលូតលាស់ ឬ ត្រូវបានដាក់
បន្ថែម។ ដូច្នេះហើយ បានជាព្រះយេស៊ូមានវ័យចំរើនឡើង ហើយមានប្រាជ្ញាកាន់តែវាងវៃ។ ទ្រង់បានបន្ថែម វ័យ និង ប្រាជ្ញារបស់ទ្រង់។ ប្រសិនបើការនេះចាំបាច់សម្រាប់ទ្រង់ តើវាចាំបាច់យ៉ាងណាទៅ

សម្រាប់ការ រៀបចំខ្លួនរបស់ពួកសាវ័កនោះ? លោកប៉ូលបានរៀបចំខ្លួនដោយបង្កើននូវ " រីឯលោកសូល (ឈ្មោះមួយទៀតគឺ លោកប៉ូល) វិញ លោកមានកម្លាំងចិត្តកាន់តែខ្លាំងឡើងៗ" ( គម្ពីរកិច្ចការ ៩:២២)។ ពាក្យថា*កម្លាំង* ដែលប្រើនៅត្រង់នេះ ហាក់បីដូចជាមានន័យត្រង់សំដៅ "កម្លាំងខាងវិញ្ញាណ"។ លោកត្រូវស្គាល់គឺឫទ្ធានុភាពដ៏មានចេស្តារបស់ព្រះជាម្ចាស់ តាមរបៀបដ៏ពិតប្រាកដមួយ។ ជាថ្មីម្តងទៀត ប្រសិនបើលោកប៉ូល ដែលជាសាវ័កដ៏អស្ចារ្យម្នាក់ ត្រូវការរៀបចំខ្លួនបែបនេះ យើងអាចដឹងយ៉ាងជាក់ច្បាស់ថា សាវ័កទាំងអស់ផ្សេងទៀតក៏នឹងត្រូវការវាដូចគ្នាដែរ។

*៣. ការរៀនសូត្រ*

ការរៀនសូត្រគឺសំខាន់ណាស់សម្រាប់អ្នកជឿគ្រប់រូប។ វារឹតតែសំខាន់សម្រាប់ពួកសាវ័ក ព្រោះពួកគេជាអ្នកដឹកនាំនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត។ សូមគិតអំពីលោកប៉ូល ម្តងទៀត។ លោកគឺពិតជាគំរូដ៏ល្អមួយ។ មុនពេលដែលលោកក្លាយជាសាវ័ក លោកត្រូវតែចំណាយពេលវេលា រៀនសូត្រនៅឯទីរហោស្ថាន(សូមមើលនៅក្នុងគម្ពីរ កាឡាទី ១:១៦-១៨)។ នៅទីបញ្ចប់ លោកប៉ូលបានត្រៀមជាស្រេចដើម្បីចាប់ផ្តើម ទីបន្ទាល់យ៉ាងមានប្រសិទ្ធិភាពអំពីព្រះអម្ចាស់។

***លំហាត់អនុវត្តន៍***

៧ ចូរគូសរង្វង់នៅជុំវិញអក្សរពីមុខប្រយោគដែលត្រឹមត្រូវនៅខាងក្រោម។

ក) មនុស្សកើតជាសាវ័កតែម្តង។

ខ) អស់អ្នកដែលត្រូវក្លាយជាសាវ័កត្រូវការការរៀបចំខ្លួនជាមុខ។

គ) លោកប៉ូលបានក្លាយជាសាវ័កភ្លាមៗក្រោយពេលដែលលោកបានកែប្រែចិត្ត។

ឃ) ការរងទុក្ខប្រហែលជាចាំបាច់នៅក្នុងការរៀបចំសាវ័ក។

# ខ. ទ្រង់បានប្រទានឲ្យអ្នកខ្លះ នៅជាព្យាការី

**វត្ថុបំណងទី២.** *បកស្រាយពីមុខងារ នៃព្យាការី។*

## ការស្គាល់ព្រះដែលបានប្រទានឲ្យ

យើងបានដឹងហើយថាព្រះគ្រិស្តគឺជាព្រះដែលបានប្រទានព្រះអំណោយទាននៃព័ន្ធកិច្ចទាំងអស់។ ដោយសារមូលហេតុនេះហើយ បានជាគ្រប់ព្រះអំណោយទានទាំងអស់សុទ្ធតែសំខាន់។ អ្វីដែលពិត នៅក្នុងព្រះអំណោយទាននៃសាវ័ក ក៏ពិតនៅក្នុងព្រះអំណោយទាននៃព្យាការី និង នៅក្នុងព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេងទៀតដែរ។ ព្រះអំណោយទាននីមួយៗត្រូវបានប្រទានមកដោយព្រះគ្រិស្ត ទៅកាន់ព្រះកាយរបស់ទ្រង់។ ទាំងសមត្ថភាព និង ការត្រាស់ហៅយ៉ាងដូច្នេះ គឺព្រះគ្រិស្តបានប្រទានទៅកាន់សមាជិកពិសេស នៃព្រះកាយរបស់ទ្រង់។ យើងអាចនិយាយបានថា ទ្រង់ប្រទានអ្នកដឹកនាំ សម្រាប់ព្រះកាយរបស់ទ្រង់។

សាវ័ក និង ព្យាការីគឺមិនមែនសម្រាប់មនុស្សគ្រប់គ្នាទេ។ ព្រះគម្ពីរបានថែងថា ទ្រង់ប្រទានឲ្យ*អ្នកខ្លះ* ក្លាយជាសាវ័ក ហើយ*អ្នកខ្លះទៀត* ក្លាយជាព្យាការី។ ពាក្យថាអ្នកខ្លះបានបញ្ជាក់យ៉ាងច្បាស់ថា មិនមែនមនុស្ស *ទាំងអស់គ្នា* សុទ្ធតែជាសាវ័ក ហើយមិនមែនមនុស្ស *ទាំងអស់គ្នា* សុទ្ធតែជាព្យាការីដែរ។ ទ្រង់ប្រទានឲ្យមនុស្សខ្លះ ដើម្បីទៅបំពេញតាមតំណែងនីមួយៗ។ ការនេះបានរំឭកយើងអំពីសំណួររបស់លោកប៉ូលៈ "ប្រសិនបើរូបកាយទាំងមូលសុទ្ធតែជាភ្នែក ធ្វើម្តេចនឹងស្តាប់ឮបាន? ហើយបើរូបកាយទាំងមូលសុទ្ធតែជាត្រចៀក ធ្វើម្តេចនឹងដឹងក្លិនបាន?" (គម្ពីរ១កូរិនថូស ១២:១៧)។

ចូរគិតអំពីព្រះអង្គដែលជាអ្នកប្រទានឲ្យ។ យើងបានអាននៅក្នុងគម្ពីរ១កូរិនថូស ១២:២៨ ៖ "ព្រះជាម្ចាស់បានតែងតាំងអោយមានសាវ័ក* បន្ទាប់មក ព្រះអង្គតែងតាំងអ្នកថ្លែងព្រះបន្ទូល"។ នៅក្នុងគម្ពីរអេភេសូ ព្រះអង្គដែលបានប្រទានមកនោះ ត្រូវបានគេស្គាល់ថាជាព្រះជាម្ចាស់។ នៅក្នុងគម្ពីរអេភេសូក្រោយមកទៀត ព្រះអង្គដែលបានប្រទានមកនោះ ត្រូវបានគេស្គាល់ថាជា ព្រះគ្រិស្ត។ តើយើងយល់យ៉ាងដូចម្តេចចំពោះការនេះ? គ្មានបញ្ហានោះទេ។ ព្រះគ្រិស្តគឺជាព្រះជាម្ចាស់ ដ្បិតទ្រង់គឺជា អង្គមួយនៅក្នុងចំណោមអង្គទាំងបី នៃព្រះត្រីឯក។ ត្រីឯក មានន័យថាបីរួមមកតែមួយ គឺព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ។ ក៏ដូចគ្នាដែរ រាល់ព្រះអំណោយទានដែលព្រះជាម្ចាស់ប្រទានមក ទ្រង់ប្រទានមកតាមរយៈព្រះគ្រិស្ត ។ សូមអានគម្ពីរយ៉ាកុប ១:១៧ និង គម្ពីរអេភេសូ ៤:១-១១។

## *លំហាត់អនុវត្តន៍*

៨ ចូរសរសេរអក្សរ ត នៅក្នុងចន្លោះបន្ទាត់នៅពីមុខប្រយោគដែលត្រឹមត្រូវ និង សរសេរអក្សរ ខ ប្រសិនបើចម្លើយខុស។

.........ក) សមាជិកគ្រប់គ្នានៅក្នុងព្រះកាយគឺត្រូវតែក្លាយជាព្យាការី។

.........ខ) មានតែសមាជិកខ្លះនៅក្នុងព្រះកាយតែប៉ុណ្ណោះដែលត្រូវបានត្រាស់ហៅឲ្យធ្វើជាព្យាការី។

.........គ) ព្រះជាម្ចាស់ប្រទានព្រះអំណោយទាននៃព័ន្ធកិច្ចមកតាមរយៈព្រះគ្រិស្ត។

# ការបង្ហាញពីអ្នកទទួល

បើតាមន័យមួយ ព្យាការីដែលជាអ្នកទទួលព្រះអំណោយទានមួយនេះ គឺជាព្រះកាយរបស់ព្រះគ្រិស្ត។ នៅក្នុងន័យមួយទៀត បុគ្គលដែលត្រូវបានត្រាស់ហៅឲ្យធ្វើជាព្យាការីនោះគឺជា អ្នកទទួលវិញ។ ព្យាការី គឺត្រូវបានត្រាស់ហៅ និង រៀបចំដើម្បីក្លាយខ្លួនជាព្រះអំណោយទានរបស់ព្រះគ្រិស្ត ទៅដល់ព្រះកាយរបស់ទ្រង់។ តើអ្នកនោះមានចំណែកចូលរួមនៅក្នុងការក្លាយខ្លួនជាព្យាការីនោះដែរឬទេ? តើព្រះជាម្ចាស់ជ្រើសរើសមនុស្សពិសេសៗសម្រាប់តំណែង ឬ ឋានៈនៅក្នុងការបម្រើមួយនេះ ដោយគ្មានមូលហេតុឬ? យើងបានដឹងហើយថាព្រះជាម្ចាស់ ទ្រង់មានសិទ្ធិធ្វើដូច្នេះបាន៖ " ឱមនុស្សអើយ តើអ្នកមានឋានៈអ្វីបានជាហ៊ានជជែកតវ៉ានឹងព្រះជាម្ចាស់បែបនេះ? តើដីឥដ្ឋមានដែលនិយាយទៅកាន់ជាងស្មូនថា «ហេតុអ្វីបានជាលោកធ្វើអោយខ្ញុំមានរូបរាងយ៉ាងនេះ»ដែរឬទេ?។" (គម្ពីររ៉ូម ៩:២០) ។ ប៉ុន្តែអ្នកជឿគឺមិនដូចជាថូដីឥដ្ឋនោះទេ។ អ្នកជឿមានការសម្រេចចិត្តរបស់ខ្លួន។ គឺថា ពួកគេមានអំណាចក្នុងការជ្រើសរើស។ អ្វីៗ

ដែលកើតឡើងទៅលើអ្នកជឿ គឺយ៉ាងហោចណាស់ ក៏ជាចំណែកនៃការសម្រេចចិត្តរបស់គេផ្ទាល់។ ឥរិយាបថនៃដួងចិត្តរបស់ពួកគេក៏ជាប់ទាក់ទងនឹងជម្រើសរបស់ព្រះជាម្ចាស់ដែរ។ ចូដីតដួគ្មានឥរិយាបថទេ ។ មនុស្សមាន។ *ឥរិយាបថ* មានន័យថា "របៀបគិត ធ្វើសកម្មភាព ឬ មានអារម្មណ៍"។ ព្រះជាម្ចាស់ជ្រាបពីឆន្ទៈរបស់យើង។ ទ្រង់ក៏ជ្រាបពីរបៀបនៃការគិត ធ្វើសកម្មភាព ឬមានអារម្មណ៍របស់យើងដែរ។ ទ្រង់ព្រះតម្រិះពីរឿងទាំងនេះនៅពេលទ្រង់ជ្រើសរើសព្យាការីដែរ។

ដាវីឌគឺជាស្តេចនៅក្នុងជំនាន់សម្ព័ន្ធមេត្រីចាស់។ ទ្រង់ក៏ជាព្យការីម្នាក់ផងដែរ។ ព្យាការីនៅជំនាន់សម្ព័ន្ធមេត្រីចាស់ គឺមានអ្វីខ្លះដែលខុសពីព្យាការីនៅជំនាន់សម្ព័ន្ធមេត្រីថ្មី។ ប៉ុន្តែយើងនៅតែអាចរៀនបានយ៉ាងច្រើន ដោយគិតអំពីមូលហេតុដែលព្រះជាម្ចាស់ជ្រើសរើសស្តេចដាវីឌឲ្យធ្វើជាអំណោយយ៉ាងពិសេសសម្រាប់ប្រជាជនរបស់ទ្រង់ គឺជនជាតិអ៊ីស្រាអែលនោះ។ នៅក្នុងរឿងរ៉ាវក្នុងជំនាន់សម្ព័ន្ធមេត្រីចាស់ យើងឃើញថា ស្តេចដាវីឌមិនត្រូវបានព្រះជ្រើសរើសដោយសារតែ អាយុរបស់លោក ឋានៈរបស់លោកនៅក្នុងគ្រួសារ បទពិសោធន៍របស់លោក ឬ រូបភាពខាងក្រៅរបស់លោកនោះឡើយ។ នៅជំនាន់នោះ តាមពួកមនុស្សគេអាចនឹងជ្រើសរើសយកអេលាប ជាបងប្រុស។ តាមទំនៀមទំលាប់ បងប្រុស ត្រូវបានជ្រើសរើស មុនប្អូនប្រុស សម្រាប់តំណែងជាអ្នកដឹកនាំ។ ទោះបីជាដាវីឌមានវ័យក្មេងជាងគេ ព្រះជាម្ចាស់បានជ្រើសរើសលោកសម្រាប់តំណែងជាអ្នកដឹកនាំដ៏ខ្ពង់ខ្ពស់។ តើហេតុអ្វី? លោកមើលទៅក៏ល្អសមណាស់ដែរ ប៉ុន្តែលោកមិនត្រូវបានព្រះជាម្ចាស់ជ្រើសរើសដោយមូលហេតុនោះឡើយ។ លោកនៅក្មេង ប៉ុន្តែនោះក៏មិនមែនជាមូលហេតុដែរ។ ចម្លើយគឺមាននៅក្នុងគម្ពីរកិច្ចការ ១៣:២២៖ "យើងរកបានមនុស្សម្នាក់ ជាទីគាប់ចិត្តយើងណាស់ គឺដាវីឌជាបុត្ររបស់អ៊ីសាយ ដ្បិតដាវីឌនឹងបំពេញតាមបំណងទាំងប៉ុន្មានរបស់យើង"។ លោកត្រូវបានជ្រើសរើសឲ្យធ្វើជាស្តេចផង និង ជាព្យាការីផង ដ្បិតព្រះជាម្ចាស់ទតឃើញពី បំណងចិត្ត និង ឥរិយាបថរបស់លោក។

ព្យាការី និង ព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេងទៀត គឺត្រូវបានរៀបចំ និង ប្រទានមកឲ្យព្រះកាយរបស់ព្រះគ្រិស្ត ព្រោះព្រះជាម្ចាស់ទតឃើញពីគុណសម្បត្តិដែលនៅខាងក្នុង។សូមអាននៅក្នុងគម្ពីរ១សាំយូអែល ១៦:១-១៣ និង គម្ពីរកិច្ចការ ២២:១៤។

## *លំហាត់អនុវត្តន៍*

៩ យោងទៅតាមគម្ពីរកិច្ចការ ១៣:២២ ស្តេចដាវីឌត្រូវបានជ្រើសរើសសម្រាប់មូលហេតុ*ពិសេស* មួយ។ ចូរគូសរង្វង់នៅជុំវិញអក្សរដែលនៅពីមុខមូលហេតុដែលត្រឹមត្រូវនៅខាងក្រោម។

ក) លោកគឺជាព្យាការីដែលជាជម្រើសរបស់លោកសាំយូអែល។

ខ) លោកគឺជាកូនប្រុសដែលក្មេងជាងគេ។

គ) លោកមើលទៅល្អសមសួន។

ឃ) លោកមានឥរិយាបថដួងចិត្តដែលព្រះជាម្ចាស់កំពុងតែស្វែងរក។

ង) លោកមានបទពិសោធន៍ក្នុងការឃ្វាលសត្វចៀម ដូច្នេះលោកអាចជាអ្នកដឹកនាមដ៏ល្អសម្រាប់ប្រជាជនរបស់ទ្រង់។

## ការអធិប្បាយពីមុខងារ

ព្រះអំណោយទាននៃព័ន្ធកិច្ចដែលគេស្គាល់ថា *ព្យាការី* នេះមានមុខងារសំខាន់ៗពីរ៖ (១) ទាយទុកមុន ដែលពាក្យនេះមានន័យថា "ប្រាប់អំពីហេតុការណ៍មួយមុនពេលដែលវាកើតឡើង" និង (២) ថ្លែងប្រកាស "ដែលវាមានន័យថា "ប្រាប់ទៅកាន់ ឬ និយាយចេញមកក្រៅ"។ ព្យាការីនិយាយប្រកបដោយការបណ្ដាលចិត្ត។ នោះគឺថា ពួកគេនិយាយចេញទៅ នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំពួកគេ។ ពួកគេក៏អធិប្បាយសាររបស់ព្រះជាម្ចាស់ទៅកាន់មនុស្សផងដែរ។ *ការអធិប្បាយ* មានន័យថា "ប្រាប់ពីអត្ថន័យ"។ បុគ្គលម្នាក់និយាយឡើងក្នុងនាមជាសាវ័កបានតែនៅពេលដែលគាត់ផ្ដល់អត្ថន័យ សម្រាប់សាររបស់ព្រះជាម្ចាស់ រាល់ពេលណាដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រទានមកកាន់ពួកគេ។

ពួកព្យាការី ធ្វើការទស្សន៍ទាយ។ *ទស្សន៍ទាយ* មានន័យដូចជា *ទាយទុកមុន* ដែរ។ ព្យាការីក្នុងសម្ព័ន្ធមេត្រីចាស់តែងតែទាយទុកហេតុការណ៍ មុខពេលដែលវាកើតឡើងទៅទៀត។ បន្ទាប់មកពួកគេបកស្រាយអត្ថន័យសារដែលមកពីព្រះជាម្ចាស់ទៅកាន់មនុស្សម្នា។

មុខងារព្យាការីក្នុងសម្ព័ន្ធមេត្រីថ្មី គឺមានលក្ខណៈដូចគ្នាដែរ។ ព្យការីក៏និយាយសាររបស់ព្រះជាម្ចាស់ទៅកាន់មនុស្ស បន្ទាប់មកធ្វើការបកស្រាយអត្ថន័យ ប៉ុន្តែក៏មានភាពខុសគ្នាផងដែរ។ ពាក្យរបស់ព្យាការីនៅជំនាន់សម្ព័ន្ធមេត្រីចាស់ មិនសូវឃើញមាននៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលបានផ្ដល់ឲ្យស្រេចនោះឡើយ ( ទោះជាយ៉ាងណាពួកគេមិនបានទាស់ប្រឆាំងនឹងព្រះបន្ទូលនោះឡើយ)។ មានម្ដងម្កាលប៉ុណ្ណោះដែល លោកលើកពាក្យចេញមកពីឯកសារជាសំណេរ។ ពួកព្យាការីនៅក្នុងជំនាន់សម្ព័ន្ធមេត្រីថ្មីវិញ តែងតែដាក់ការសាកល្បង និង ការលើកទឹកចិត្តដែលផ្អែកទៅលើសេចក្ដីពិតដែលបានទទួលពីមុនមកហើយ។ ព័ន្ធកិច្ចរបស់លោកយូដាស និងលោកស៊ីឡាសក្នុងគម្ពីរកិច្ចការ១៥:៣២ គឺជាគំរូដ៏ល្អមួយ។ ដូច្នេះ ព្យាការីនាំយកសារពិសេសមកពីព្រះជាម្ចាស់ តាមរយៈព្រះវិញ្ញាណរបស់ទ្រង់ ទៅបំពេញតម្រូវការរបស់មនុស្សនៅក្នុងពេលណាមួយ។

មានពេលខ្លះដែលព្យាការីនៅក្នុងសម្ព័ន្ធមេត្រីថ្មីទទួលបានសារពីព្រះជាម្ចាស់ដែលទាយពីអនាគតបាន។ នៅក្នុងកណ្ឌគម្ពីរកិច្ចការ មានបុរសម្នាក់ឈ្មោះ អកាប៊ូស ដែលត្រូវបានគេហៅថា ជាព្យាការី៖ "យើងស្នាក់នៅទីនោះជាច្រើនថ្ងៃ។ ពេលនោះ មានព្យាការីមួយរូបឈ្មោះអកាប៊ូស ធ្វើដំណើរមកពីស្រុកយូដា។" (គម្ពីរកិច្ចការ ២១:១០)។ យើងបានដឹងថា មានពីរដង លោកធ្វើការទាយហេតុការណ៍ដែលនឹងកើតមាន។ លោកអកាប៊ូស "ដោយព្រះវិញ្ញាណបានបំភ្លឺ គាត់ក្រោកឡើងប្រាប់ពួកអ្នកជឿអោយដឹងថា បន្តិចទៀតនឹងមានកើតទុរ្ភិក្សនៅលើផែនដីទាំងមូល (ទុរ្ភិក្សនោះក៏កើតមានមែន គឺនៅក្នុងរជ្ជកាលព្រះចៅអធិរាជក្លូឌាស)។ ( គម្ពីរកិច្ចការ ១១:២៨)។ សម្រាប់រឿងរ៉ាងទីពីរ សូមអាននៅក្នុងគម្ពីរកិច្ចការ ២១:១១។

យើងអាចធ្វើការសាកល្បង ព្យាការីដែលបានធ្វើការទស្សន៍ទាយនោះ ដើម្បីដឹងថាតើសាររបស់ពួកគេគឺមកពីព្រះជាម្ចាស់មែនឬអត់។ ប្រសិនបើការទស្សន៍ទាយនោះមិនបានកើតឡើងពិតនោះទេ ពួកគេប្រាកដជានិយាយតាមតែចិត្តរបស់គេហើយ "ប្រសិនបើមានព្យាការីណាម្នាក់ប្រកាសថា ស្រុកបានសុខសាន្ត យើងដឹងថា ព្រះអម្ចាស់ចាត់ព្យាការីនោះអោយមកមែន លុះត្រាណាតែស្រុកបានសុខសាន្តដូចពាក្យគាត់ប្រកាស»។( គម្ពីរយេរេមា ២៨:៩)។

លោកពេត្រុសគឺជាឧទាហរណ៍មួយដ៏ល្អ សម្រាប់ព្យាការីសម្ព័ន្ធមេត្រីថ្មី ក្នុងនាមជាអ្នកថ្លែងប្រកាស។ លោកគឺជាសាវ័កម្នាក់ក្នុងចំណោមសាវ័កទាំងដប់ពីរ។ លោកក៏ជាព្យាការីម្នាក់។ មានពេលខ្លះមនុស្សត្រូវបានប្រទានឲ្យមានព្រះអំណោយទានច្រើនជាងមួយប្រភេទ។ ក្រោយពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធបានចាក់បង្ហូរមក ដូចមានរៀបរាប់នៅក្នុងគម្ពីរ កិច្ចការ២:១-១២ មានមនុស្សច្រើនកោះករប្រមូលគ្នាមកមើលថាតើមានរឿងអ្វីកើតឡើង។ ពួកគេបានសួរថា«តើហេតុការណ៍នេះ មានន័យដូចម្ដេច?" បន្ទាប់មក លោកពេត្រុសបានមានប្រសាសន៍ក្នុងនាមជាព្យាការី។ លោកថ្លែងប្រកាសសាររបស់ព្រះជាម្ចាស់ នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំលោក។ ព្រះវិញ្ញាណដ៏វិសុទ្ធបានដាក់ការទស្សន៍ទាយមកពីសម្ព័ន្ធមេត្រីចាស់ នៅក្នុងគំនិតរបស់លោក។ លោកពេត្រុសមិនមានពេលវេលារៀបចំអ្វីដែលនឹងនិយាយនោះទេ។ លោកដឹងតែនិយាយចេញទៅ។ លោកក៏ទទួលបានសមត្ថភាពមកពីព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីបកស្រាយអត្ថន័យនៃសារនោះផងដែរ។

មុខងារសំខាន់បំផុតរបស់ព្យាការី មានបង្ហាញច្បាស់នៅក្នុងគម្ពីរអេភេសូ ៤:១២ "ដើម្បីរៀបចំប្រជាជនដ៏វិសុទ្ធអោយបំពេញមុខងារបំរើ និងកសាងព្រះកាយរបស់ព្រះគ្រិស្តឡើង"។ មនុស្សដែលថ្លែងប្រកាសសាររបស់ព្រះជាម្ចាស់ នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធបក់មកលើពួកគេ គេបំពេញគោលបំណងទាំងពីរបានល្អណាស់។ដំបូង ពួកគេជួយប្រជាជនរបស់ព្រះជាម្ចាស់ឲ្យត្រៀមខ្លួនសម្រាប់ការបម្រើរបស់គ្រិស្តបរិស័ទ។ នៅពេលដែលមនុស្សស្គាល់ព្រះវិញ្ញាណដ៏វិសុទ្ធដែលគង់លើគ្រូបង្រៀននោះហើយ ពួកគេ នឹងរៀនបានច្រើន។ ពួកគេរៀនពីអ្វីដែលបានថ្លែងចេញមក។ ពួកគេរៀនពីព្រះវិញ្ញាណ តាមរយៈអ្នកដែលនាំសារនោះមក។

### *លំហាត់អនុវត្តន៍*

១០ ចូរគូសរង្វង់ជុំវិញអក្សរពីមុខឃ្លាទាំងឡាយណាដែលបំពេញប្រយោគត្រឹមត្រូវ។ មុខងាររបស់ព្យាការីគឺ

ក) ដើរក្នុងចំណោមមនុស្សដោយមានមោទនភាព។

ខ) ធ្វើឲ្យគេស្គាល់ខ្លួនថាជាអ្នកដឹកនាំដ៏អស្ចារ្យ។

គ) ប្រាប់មនុស្សអំពីសាររបស់ព្រះជាម្ចាស់។

ឃ) បកស្រាយសាររបស់ព្រះជាម្ចាស់ទៅកាន់មនុស្ស។

## ការបកស្រាយពីការអភិវឌ្ឍ

ព្រះអំណោយទានរបស់ព្រះជាម្ចាស់ តែងតែអាចបំពេញមុខងារបានល្អបំផុត តាមរយៈមនុស្សដែលបានរៀបចំខ្លួនបានល្អ។ សូមគិតអំពីសាររបស់លោកពេត្រុសម្ដងទៀត។ លោកបានរៀបចំខ្លួន ដោយធ្វើខ្លួនគាត់ឲ្យប្រកបដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ ចំណេះដឹងរបស់លោកអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ក៏ជាផ្នែកដ៏មានសារៈសំខាន់ណាស់ ក្នុងការអភិវឌ្ឍផងដែរ។

មានបីជំហានសំខាន់ៗក្នុងការអភិវឌ្ឍរបស់ព្យាការីៈ

១. *អធិស្ឋានរាល់ថ្ងៃ*។ ព្យាការីដែលមិនដែលអធិស្ឋាន មិនយូរប៉ុន្មាននឹងលែងជាព្យាការីទៀតហើយ។ អធិស្ឋានអាចធ្វើឲ្យបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ ប្រសិនបើមនុស្សមិនបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធទេនោះ ពួកគេមិនអាចក្លាយជាព្យាការីបានឡើយ។ ការអធិស្ឋានក៏ជួយឲ្យព្យាការីដឹងខ្លួនថា នៅពេលណាដែលពួកគេត្រូវបានដឹកនាំដោយព្រះវិញ្ញាណដ៏វិសុទ្ធ។

២. *ស្គាល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់* ។ ព្យាការីបង្កើនប្រសិទ្ធិភាពរបស់ពួកគេ នៅពេលដែលពួក គេបានកើនចំណេះដឹងរបស់ពួកគេអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ៖ "ចូរខំប្រឹងធ្វើយ៉ាងណាអោយបានគាប់ព្រះហឫទ័យព្រះជាម្ចាស់ និងចូលជិតព្រះអង្គក្នុងឋានៈជាកម្មករ ដែលគ្មានអ្វីនាំអោយអៀនខ្មាស ព្រោះខ្លួនបានចែកផ្សាយព្រះបន្ទូលនៃសេចក្ដីពិត យ៉ាងត្រឹមត្រូវ។" (គម្ពីរ២ធីម៉ូថេ ២:១៥)។ ព្យាការីគឺជាគ្រូបង្រៀននៅពេលណាដែលពួកគេថ្លែងប្រកាសសាររបស់ព្រះជាម្ចាស់។

៣. *ការប្រើប្រាស់ព្រះអំណោយទាន*។ ដូចសាច់ដុំនៅក្នុងជើង និង ដៃរបស់យើង ដែលលូតលាស់ដោយការប្រើប្រាស់វា នោះព្រះអំណោយទានដែលទទួលបានមកពីព្រះគ្រិស្ត ក៏បានអភិវឌ្ឍឡើងដោយការប្រើប្រាស់វាយ៉ាងដូច្នោះដែរ។ នៅពេលដែលព្យាការីចាប់ផ្ដើមថ្លែងប្រកាសដំបូង ពួកគេអាចមានភាពភ័យខ្លាច។ នេះមិនមែនមានន័យថាពួកគេមិននិយាយប្រកបដោយព្រះវិញ្ញាណនោះទេ។ វាមានន័យថា ពួកគេត្រូវរៀនបន្ថែមទៀតអំពីការអនុញ្ញាតឲ្យព្រះវិញ្ញាណ កាន់តែមានសេរីភាពក្នុងការប្រើប្រាស់ពួកគាត់។ នៅពេលដែលព្រះអំណោយទានត្រូវបានគេប្រើប្រាស់ វាបានអភិវឌ្ឍកាន់តែពេញលេញឡើង។

## លំហាត់អនុវត្តន៍

១១ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខប្រយោគល្អបំផុតក្នុងការរៀបរាប់ពីរបៀបដែលព្យាការីអាចអភិវឌ្ឍព្រះអំណោយទានរបស់ពួកគាត់បាន។

ក) រៀបចំខ្លួន និង ទទួលបានការអនុញ្ញាតពីព្រះជាម្ចាស់។

ខ) អធិស្ឋាន និង ចាប់ផ្ដើមប្រើប្រាស់ព្រះអំណោយទាននោះ។

គ) សិក្សារៀនសូត្រតាមតែអាចធ្វើទៅបាន អំពីព្យាការី។

ឃ) អានព្រះបន្ទូលរបស់ព្រះជាម្ចាស់អំពីព្យាការីទាំងឡាយណាដែលមិនគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់។

# ការប្រឡងផ្ទាល់ខ្លួន

**សំណួរផ្គូផ្គង។** ចូរផ្គូផ្គងនិយមន័យដែលនៅខាងស្តាំ ទៅនឹងពាក្យដែលនៅខាងឆ្វេង ដោយសរសេរអក្សរដែលត្រឹមត្រូវនៅក្នុងចន្លោះបន្ទាត់។

| | | | |
|---|---|---|---|
| ..........១ | អធិប្បាយ | ក) | ប្រាប់ទៅកាន់ ឬ និយាយចេញមកក្រៅ |
| ..........២ | ការសម្រេចចិត្ត | ខ) | ចាត់បញ្ជូនទៅ |
| ..........៣ | ថ្លែងប្រកាស | គ) | ជ្រើសរើស |
| ..........៤ | ទាយទុកមុន | ឃ) | ទស្សន៍ទាយ |
| ..........៥ | សាវ័ក | ង) | ប្រាប់ពីអត្ថន័យ |

**ត្រូវ/ ខុស។** ចូរសរសេរអក្សរ **ត** នៅក្នុងចន្លោះបន្ទាត់ ប្រសិនបើប្រយោគនោះត្រឹមត្រូវ។ សរសេរអក្សរ **ខ** ប្រសិនបើវាខុស។

..........៦ លោកប៉ូលបានក្លាយជាសាវ័កម្នាក់ភ្លាមៗ ក្រោយពេលដែលលោកទទួលព្រះគ្រិស្តជាព្រះអង្គសង្គ្រោះរបស់លោក។

..........៧ មិនមែនមនុស្សគ្រប់គ្នាត្រូវបានត្រាស់ហៅឲ្យធ្វើជាព្យាការី ឬ ជាសាវ័កឡើយ។

..........៨ មុខងាររបស់សាវ័កសព្វថ្ងៃនេះ គឺមិនខុសអ្វីពីមុខងាររបស់សាវ័កដំបូងទាំងដប់ពីរនាក់នោះទេ។

..........៩ ក្រុមជំនុំជាអ្នកកំណត់ថា តើសមាជិករូបណាដែលស័ក្តិសមទទួលព្រះអំណោយទាននៃព័ន្ធកិច្ច។

.........១០ ព្រះអំណោយទានមិនបានអភិវឌ្ឍឡើងភ្លាមៗនៅពេលដែលទទួលបានវានោះឡើយ វាអភិវឌ្ឍលូតលាស់បាននៅពេលដែលពួកគេប្រើប្រាស់វា។

**បំពេញប្រយោគ។** ចូរបំពេញប្រយោគខាងក្រោម ដោយសរសេរពាក្យដែលបាត់ នៅលើចន្លោះបន្ទាត់ដែលបានដាក់ឲ្យ។

១១ អ្នកដែលប្រទានព្រះអំណោយទានខាងឯវិញ្ញាណទាំងអស់មកគឺ...........................................

**ចម្លើយខ្លីៗ** ។ ចូរសរសេរចម្លើយរបស់សំណួរនៅលើបន្ទាត់ដែលបានផ្តល់ឲ្យ។

១២ តើអ្វីខ្លះជាទំនួលខុសត្រូវចម្បងទាំងពីររបស់ពួកសាវ័ក?

...................................................................................................................

...................................................................................................................

១៣ តើអ្វីខ្លះជាមុខងារសំខាន់ទាំងពីររបស់ពួកព្យាការី?

......................................................................................................................................................

......................................................................................................................................................

# ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១ ខ) និង ឃ) ជាចម្លើយត្រឹមត្រូវ។

៧ ខ) និង ឃ) ជាចម្លើយត្រឹមត្រូវ។

២ ខ) ខគម្ពីរនៃប្រធានបទទាំងអស់តែម្តង

៨ ក) ខ

ខ) ត

គ) ត

៣ ខ) សមាជិកពិសេសនៅក្នុងព្រះកាយ

៩ ឃ) លោកមានឥរិយាបថដួងចិត្តដែលព្រះជាម្ចាស់កំពុងតែស្វែងរក។

៤ គ) ឲ្យទៅកាន់បុគ្គលម្នាក់ដើម្បីប្រៀនប្រដៅក្រុមជំនុំ។

១០ គ) ប្រាប់មនុស្សអំពីសាររបស់ព្រះជាម្ចាស់។

ឃ) បកស្រាយសាររបស់ព្រះជាម្ចាស់ទៅកាន់មនុស្ស។

៥ គ) បានសរសេរកណ្ឌព្រះគម្ពីរនៃសម្ព័ន្ធមេត្រីថ្មី

១១ ខ) អធិស្ឋាន និង ចាប់ផ្តើមប្រើប្រាស់ព្រះអំណោយទាននោះ។

៦ ខ) នាំយកដំណឹងល្អទៅកាន់កន្លែងថ្មីទៀត ហើយមើលការខុសត្រូវ ការអភិវឌ្ឍនៃស្នាព្រះហស្តរបស់ព្រះជាម្ចាស់នៅទីនោះ។

# មេរៀនទី ៤

# អ្នកផ្សាយដំណឹងល្អ និងអ្នកគង្វាល ព្រមទាំងអ្នកបង្រៀន

នៅក្នុងមេរៀនមុន យើងបានសិក្សារួចមកហើយអំពី ព្រះអំណោយទាននៃព័ន្ធកិច្ចពីរយ៉ាង គឺ សាវ័ក និង ព្យាការី។ យើងបានដឹងថា សាវ័កគឺមានពីរប្រភេទ។ ទីមួយ មានក្រុមពិសេសមួយដែលហៅថា សាវ័កទាំងដប់ពីរ។ ពួកគាត់ធ្វើកិច្ចការជាមួយព្រះយេស៊ូ ក្នុងការដាំក្រុមជំនុំ។ មានអ្នកខ្លះ ក្នុងចំណោមពួកគាត់បានសរសេរកណ្ឌគម្ពីរនៃគម្ពីរសម្ព័ន្ធមេត្រីថ្មី។ ក្រុមទីពីរ មានរៀបរាប់នៅក្នុងគម្ពីរអេភេសូ ៤:១១-១២ ពួកគាត់ត្រូវចេញទៅកាន់តំបន់ថ្មីទៀតដាំក្រុមជំនុំ និង អភិវឌ្ឍព្រះកាយរបស់ព្រះគ្រិស្ត។ ប៉ុន្តែ ពួកគាត់មិនត្រូវ សរសេរកណ្ឌគម្ពីរឡើយ ដ្បិតកិច្ចការនោះបានបញ្ចប់ទៅជាមួយនឹងកណ្ឌគម្ពីរនៅក្នុងសម្ព័ន្ធមេត្រីថ្មីរួចហើយ។ យើងក៏បានដឹងថា ព្យាការីមានកាតព្វកិច្ច ពីរយ៉ាង គឺ ថ្លែងប្រកាស និង ទាយទុកមុន។ ពេលនេះយើង ត្រៀមជាស្រេចដើម្បីរៀនអំពីព្រះអំណោយទានទាំងបីដែលនៅសល់ ក្នុងក្រុមនេះ។

មេរៀននេះនឹងធ្វើឲ្យយើងកាន់តែជិតស្និទ្ធជាមួយព្រះអំណោយទាននៃព័ន្ធកិច្ច ដែលហៅថា អ្នកផ្សាយដំណឹងល្អ និង អ្នកគង្វាលព្រមទាំងអ្នកបង្រៀន។ យើងនឹងសិក្សាអំពីអ្នកគង្វាល និង អ្នកបង្រៀននៅក្នុងចំណុចផ្នែកតែមួយ ព្រោះភាគច្រើនគេយល់ស្របថា ព្រះអំណោយទានទាំងពីរគឺប្រើនៅក្នុងព័ន្ធកិច្ចតែមួយ។

ព្រះជាម្ចាស់ប្រើមនុស្សជាច្រើននាក់ នៅក្នុងព្រះអំណោយទាននៃព័ន្ធកិច្ចទាំងនេះ។ ដូច្នេះ អ្នកក៏អាចនឹងទទួលអារម្មណ៍ថាព្រះហស្តរបស់ព្រះជាម្ចាស់ដឹកនាំអ្នកចូលទៅក្នុងព្រះអំណោយទានមួយណា ក្នុងចំណោមព្រះអំណោយទានទាំងនេះដែរ។

## គម្រោងនៃមេរៀន

ក. ទ្រង់ប្រទានឲ្យអ្នកខ្លះក្លាយជាអ្នកផ្សាយដំណឹងល្អ

ខ. ទ្រង់ប្រទានឲ្យអ្នកខ្លះ ជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀន

## វត្ថុបំណងនៃមេរៀន

នៅពេលដែលបញ្ចប់មេរៀនមួយនេះ អ្នកអាចនឹង ៖

១. ស្គាល់ថាអ្នកផ្សាយដំណឹងជាអ្វី ហើយរៀបរាប់មុខងាររបស់អ្នកផ្សាយដំណឹងល្អ។

២. រៀបរាប់អំពីព្រះអំណោយទាននៃព័ន្ធកិច្ច ដែលគេហៅថា អ្នកគង្វាល និង អ្នកបង្រៀន។

៣. រៀបរាប់ និង បកស្រាយ អំពីគោលបំណង និងមុខងាររបស់ព្រះអំណោយទាននៃព័ន្ធកិច្ចទាំងអស់។

៤. ទទួលអារម្មណ៍ដឹងថា តើព្រះអម្ចាស់កំពុងធ្វើការនៅក្នុងជីវិតរបស់អ្នកដើម្បីអភិវឌ្ឍព័ន្ធកិច្ច ឬក៏អត់។

## សកម្មភាពក្នុងការសិក្សា

១. អានគម្ពីរកិច្ចការ ជំពូក ៧ និង ៨ និង គម្ពីរ១ធីម៉ូថេ៤:១-១៦.

២. បន្តទន្ទេញចងចាំ គម្ពីរ ១កូរិនថូសជំពូក១៣ ។ នៅពេលដែលអ្នកបានរៀនចប់មេរៀននេះហើយ អ្នកអាចនឹងសូត្រឡើងវិញ ខទី១ ដល់ទី៧បាន។

៣. អានមេរៀននេះយឺតៗ។ គូសបន្ទាត់នៅពីក្រោមចំណុចសំខាន់។

៤. បើកទៅផ្នែកខាងក្រោយនៃសៀវភៅរបស់អ្នក ដើម្បីរកនិយមន័យពាក្យសំខាន់ដែលអ្នកមិនយល់

៥. ធ្វើរាល់សំណួរទាំងឡាយណាដែលអ្នកឃើញ។ ផ្ទៀតផ្ទាត់ចម្លើយរបស់អ្នកជាមួយនឹងចម្លើយ ដែលបានផ្តល់ឲ្យនៅចុងបញ្ចប់នៃមេរៀន។

៦. ធ្វើការប្រឡងផ្ទាល់ខ្លួននៅចុងបញ្ចប់នៃមេរៀន ហើយផ្ទៀតផ្ទាត់ចម្លើយរបស់អ្នក។

## ពាក្យសំខាន់

| | | |
|---|---|---|
| ភ្ជាប់គ្នា | ទុក្ករបុគ្គល | ភាពអាត្មានិយម |
| ព្រះត្រៃឯកភាពពេញលេញ | ការបន្តពូជ | |

# ក. ទ្រង់ប្រទានឲ្យអ្នកខ្លះក្លាយជាអ្នកផ្សាយដំណឹងល្អ

**វត្ថុបំណងទី១.** *ស្គាល់ថាអ្នកផ្សាយដំណឹងជាអ្វី ហើយរៀបរាប់មុខងាររបស់អ្នកផ្សាយដំណឹងល្អ។*

## ការស្គាល់អ្នកដែលបានប្រទានឲ្យ

នៅពេលដែលកំពុងសិក្សាមេរៀនទីមួយរបស់យើង អំពីព្រះអំណោយទាននៃព័ន្ធកិច្ច យើងបានដឹងថា ព្រះគ្រិស្តគឺជាអ្នកប្រទានព្រះអំណោយទានទាំងនេះ។ យើងក៏បានឃើញផងដែរថា បើនិយាយទាក់ទងនឹងអ្នកណាដែលបានប្រទានព្រះអំណោយទានទាំងនេះ នៅក្នុងគម្ពីរអេភេសូ៤:១១ និង គម្ពីរ ១កូរិនថូស ១២:២៨ គឺនិយាយមិនខុសគ្នាទេ។ យើងក៏បានដឹងថា ព្រះគ្រិស្ត និង ព្រះជាម្ចាស់គឺដូចគ្នា ព្រោះតែព្រះជាម្ចាស់ គឺព្រះបីរួមមកតែមួយ គឺព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះគ្រិស្តគឺជាអង្គព្រះទីពីរ នៅក្នុងព្រះត្រៃឯកភាពពេញលេញ។ ដូច្នេះ យើងអាចនិយាយបានថា ព្រះគ្រិស្តគឺជាព្រះជាម្ចាស់។

ពេលនេះយើងនឹងរៀនអំពីអ្នកដែលបានប្រទានឲ្យនោះបន្ថែមទៀត។ នៅក្នុងគម្ពីរអេភេសូជំពូកទី៤ ព្រះគ្រិស្ត ដែលត្រូវបានគេស្គាល់ថាជាព្រះសិរសា៖ "បើយើងប្រព្រឹត្តតាមសេចក្តីពិតដោយចិត្តស្រឡាញ់ យើងនឹងបានចំរើនឡើងគ្រប់វិស័យទាំងអស់ ឆ្ពោះទៅកាន់ព្រះគ្រិស្តជាសិរសា" (ខ១៥)។ អ្វីដែលបានទៅដល់ខ្លួនប្រាណ គឺត្រូវឆ្លងកាត់ក្បាលជាមុនសិន។ នេះក៏រាប់ទាំងព្រះអំណោយទាននៃព័ន្ធកិច្ចទាំងពីរ និងការចិញ្ចឹមបីបាច់សម្រាប់ព្រះកាយផងដែរ៖ នៅក្រោមការគ្រប់គ្រងរបស់ព្រះគ្រិស្ត ព្រះកាយទាំងមូល "ផ្គត់ផ្គង់អោយព្រះកាយទាំងមូលតភ្ជាប់គ្នាដោយសន្លាក់ឆ្អឹង និងសរសៃព្រមទាំងចំរើនឡើង តាមតែព្រះជាម្ចាស់ប្រទានអោយ។" (គម្ពីរកូឡុស ២:១៩)។

តាមធម្មជាតិ ក្បាលរបស់យើងមានមុខងារទូទៅបីយ៉ាង៖ (១) វាដឹង (២) វាឃើញពីតម្រូវការដែលត្រូវបំពេញ និង (៣) វាគ្រប់គ្រង។ មុខងារទាំងអស់នេះក៏ យកទៅប្រើជាមួយព្រះគ្រិស្ត នៅក្នុងទំនាក់ទំនងជាមួយនឹង ព្រះអំណោយទាននៃព័ន្ធកិច្ច។

## ព្រះសិរសាដឹងពីតម្រូវការរបស់ព្រះកាយ

ប្រអប់ជើងរបស់យើងវាមិនដឹងអំពីតម្រូវការខាងរូបកាយរបស់ខ្លួនយើងឡើយ។ មិនថាជាដៃ ជើង ឬផ្នែកណាមួយនៃខ្លួនប្រាណឡើយ។ នៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត មានពេលខ្លះសមាជិកធ្វើការសម្រេចចិត្តដោយខ្លួនឯងក្នុងការជ្រើសរើសសមាជិកណាម្នាក់ ឲ្យធ្វើជាសាវ័ក ជាព្យាការី ជាអ្នកផ្សាយដំណឹងល្អ ឬជាអ្នកគង្វាល និងអ្នកបង្រៀន។ នោះវាដូចជា ជើងទៅប្រាប់ដៃថាតើមុខងាររបស់ដៃគឺជាអ្វីយ៉ាងដូច្នោះដែរ។ គឺមានតែព្រះគ្រិស្តជាព្រះសិរសាតែប៉ុណ្ណោះដែលដឹងពីតម្រូវការនៃព្រះកាយរបស់ទ្រង់បាន។ ទ្រង់អាចសម្រេចព្រះទ័យថា តើអ្វីដែលសមាជិកនៃព្រះកាយរបស់ទ្រង់អាចបម្រើបានចំពោះតម្រូវការទាំងនោះ។សមាជិកអាចជួយគ្នាទៅវិញទៅមក ប៉ុន្តែពួកគេមិនអាចផ្តល់ព្រះអំណោយទានខាងវិញ្ញាណបាននោះទេ។ មានតែព្រះអង្គ ដែលជាព្រះសិរសាប៉ុណ្ណោះ គឺជាអ្នកប្រទានឲ្យ។

## ព្រះសិរសាទតឃើញថាតម្រូវការរបស់ព្រះកាយត្រូវបានបំពេញ

ពេលខ្លះក្បាលបានដឹងថា ខ្លួនប្រាណត្រូវការទឹកដោះគោបន្ថែមទៀត ដោយសារតែឆ្អឹងរបស់វាងាយបាក់ខ្លាំងពេក។ ក្បាលឃើញថា ទឹកដោះគោគឺត្រូវតែឲ្យដើម្បីបំពេញតម្រូវការមួយនេះបាន។ នៅក្នុងរបៀបដូចគ្នានេះដែរ ព្រះគ្រិស្តជាព្រះសិរសា ទតឃើញថាតម្រូវការរបស់ព្រះកាយទ្រង់ត្រូវបាន
បំពេញ។

## ព្រះសិរសាគ្រប់គ្រងព្រះកាយ

បន្ទាប់ពីវាបានឃើញថា តម្រូវការរបស់ខ្លួនប្រាណនោះត្រូវបានបំពេញហើយ ក្បាលនឹងដាក់បញ្ជាទៅឲ្យផ្នែកនីមួយៗនៃខ្លួនប្រាណទាំងមូល។ ជើងដែលមានសុខភាពល្អមិន សម្រេចថាតើអ្វីដែលល្អសម្រាប់ខ្លួនប្រាណនោះទេ។ ផ្ទុយទៅវិញ វាទទួលបញ្ជាពីក្បាល ដើម្បីជួយបំពេញតម្រូវការរបស់ខ្លួនប្រាណ។ ដូចគ្នាដែរ បន្ទាប់ពីបានប្រទានព្រះអំណោយទានសម្រាប់ព្រះកាយរបស់ទ្រង់រួចហើយ ព្រះគ្រិស្តក៏ដាក់បញ្ជាសម្រាប់ការប្រើប្រាស់ពួកវាផង។

### *លំហាត់អនុវត្តន៍*

១ ចូរគូសរង្វង់ជុំវិញអក្សរនៅពីមុខពាក្យទាំងឡាយណាដែលរៀបរាប់ពីមុខងាររបស់ព្រះសិរសាមានល្អបំផុត។

ក) ស្ដាប់បង្គាប់

ខ) គ្រប់គ្រង

គ) បម្រើ

ឃ) ដឹង

ង) ផ្គត់ផ្គង់

# ការបង្ហាញពីអ្នកទទួល

គ្រប់ព្រះអំណោយទានទាំងអស់មានអ្នកទទួលរបស់វា។ ជាថ្មីម្ដងទៀត យើងនឹកចាំថាទាំសមាជិកម្នាក់ៗ និង ព្រះកាយទាំងមូលសុទ្ធតែចូលរួមនៅក្នុងការទទួល។ សមាជិកម្នាក់ៗទទួលព្រះអំណោយទានឲ្យក្លាយជាអ្នកផ្សាយដំណឹងល្អ ហើយព្រះកាយជាអ្នកទទួលពួកគេ។

តើអ្នកណាដែលត្រូវបានជ្រើសរើសឲ្យក្លាយជាអ្នកផ្សាយដំណឹងល្អ? តើអ្នកណា ទទួលបានព្រះអំណោយទាននៃព័ន្ធកិច្ចនេះ? នៅក្នុងន័យមួយ អ្នកជឿម្នាក់ៗត្រូវតែជាអ្នកផ្សាយដំណឹងល្អ៖ "ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ "ចូរនាំគ្នាទៅគ្រប់ទីកន្លែងក្នុងពិភពលោក ហើយប្រកាសដំណឹងល្អ*ដល់មនុស្សលោកទាំងអស់ចុះ។ អ្នកណាជឿ ហើយទទួលពិធីជ្រមុជទឹក* ព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ រីឯអ្នកដែលមិនជឿនឹងត្រូវទទួលទោស" (ម៉ាកុស ១៦:១៥-១៦)។ អ្នកខ្លះអាចនឹងនិយាយថា " អូ! ខគម្ពីរនោះមិនសំដៅមកលើខ្ញុំទេ។ បទបញ្ជានោះគឺផ្ដល់មកសម្រាប់តែសាវ័កទាំង១១រូប ដែលជាសាវ័កពិសេសប៉ុណ្ណោះ។" យើងត្រូវតែទៅមើលខគម្ពីរមួយទៀត ដែលបាននិយាយទៅកាន់ពួកសាវ័កទាំងដប់ពីរ ដែល

ប្រាប់ពួកគេឲ្យបង្រៀនអ្នកជឿថ្មី "ត្រូវបង្រៀនគេអោយប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។" (គម្ពីរម៉ាថាយ ២៨:២០)។ ពិតណាស់ ពួកសាវ័កទាំងដប់មួយនាក់ទទួលបង្គាប់ឲ្យ "ចេញទៅពេញពិភពលោកទាំងមូល និង ធ្វើការចែកចាយ" ប៉ុន្តែក្រោយមកពួកគេទទួលបង្គាប់ឲ្យបង្រៀនអ្នកជឿថ្មីៗ ពីការស្ដាប់បង្គាប់បញ្ញាគ្រប់ទាំងអស់។ ដូច្នេះ យើងសន្និដ្ឋានថា អ្នកជឿទាំងអស់ ត្រូវតែក្លាយខ្លួនជាអ្នកផ្សាយដំណឹងល្អ។ ប៉ុន្តែយ៉ាងណាមិញ អ្នកផ្សាយដំណឹងល្អដែលមានព្រះអំណោយទាននៃព័ន្ធកិច្ចគឺមានលក្ខណៈខុសគ្នាខ្លះៗ។

ព្រះជាម្ចាស់ទ្រង់ជ្រាប ថាតើសមាជិកនៃព្រះកាយណាម្នាក់ដែលទ្រង់អាចប្រើប្រាស់ជាអ្នកផ្សាយដំណឹងល្អបានល្អបំផុត។ ព័ន្ធកិច្ចរបស់ពួកគេប្រហែលជាមិនចាប់ផ្ដើមពីការផ្សាយដំណឹងល្អនោះទេ។ ក្រៅពីពួកសាវ័ក នៅក្នុងគម្ពីរកិច្ចការ មានអ្នកផ្សាយដំណឹងល្អពីរនាក់ដំបូងដែលយើងបានស្គាល់ គឺលោកភីលីព និង លោកស្ទេផាន។ អ្នកទាំងពីរចាប់ផ្ដើមដោយធ្វើជាអ្នកកាន់ប្រាក់៖

> "មិនគួរអោយយើងខ្ញុំ ចោលការប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅបំរើតុឡើយ។ ហេតុនេះ បងប្អូនអើយ សូមនាំគ្នាជ្រើសរើសយកបុរសប្រាំពីររូបក្នុងចំណោមបងប្អូនដែលជាអ្នកមានកេរ្តិ៍ឈ្មោះល្អ ហើយពោរពេញដោយព្រះវិញ្ញាណ និងប្រាជ្ញាឈ្លាសវៃ។ យើងខ្ញុំនឹងតែងតាំងគេអោយបំពេញមុខងារនេះ។" .... គេក៏ជ្រើសយកលោកស្ទេផាន ដែលពោរពេញដោយជំនឿ និងដោយព្រះវិញ្ញាណដ៏វិសុទ្ធ* (និង) លោកភីលីព។ (គម្ពីរកិច្ចការ ៦:២-៣,៥)

ឯអ្នកដទៃទៀតក៏ត្រូវបានជ្រើសរើសសម្រាប់ការងារនោះដែរ ប៉ុន្តែក្នុងចំណោមពួកគេ ទាំងអស់ មានតែលោកស្ទេផាន និង លោកភីលីព ប៉ុណ្ណោះដែលបានក្លាយជាអ្នកផ្សាយដំណឹងល្អ។ លោកស្ទេផានត្រូវបានគេសម្លាប់ ប្រហែលជាបន្ទាប់ពីការផ្សាយដំណឹងល្អដំបូងរបស់លោក។ លោកភីលីពត្រូវបានគេហៅថាជា អ្នកផ្សាយដំណឹងល្អ នៅក្នុងគម្ពីរកិច្ចការ ២១:៨ ៖ "យើងបន្តដំណើរដល់ក្រុងសេសារា។ យើងបានចូលផ្ទះលោកភីលីព ជាអ្នកផ្សាយដំណឹងល្អ"។ លោកភីលីពបានក្លាយជាអ្នកផ្សាយដំណឹងល្អ នៅប្រមាណឆ្នាំ ៣៣ នៃគ្រិស្តសករាជ។ លោកនៅបន្តធ្វើជាអ្នកផ្សាយដំណឹងល្អ រហូតដល់ឆ្នាំ៦០ នៃគ្រិស្តសករាជ នោះបញ្ជាក់ថាការផ្សាយដំណឹងល្អគឺជាការងាររបស់លោកពេញមួយជីវិត។

មូលហេតុមួយដែលលោកស្ទេផាន និង លោកភីលីព ត្រូវបានជ្រើសរើសសម្រាប់ទំនួលខុសត្រូវដ៏អស្ចារ្យមួយនេះ អាចជាភាពស្មោះត្រង់របស់ពួកគេជាមួយនឹងកិច្ចការរបស់ព្រះអម្ចាស់។ ចូរអានគម្ពីរលូកា ១៩:១១-១៩ ដើម្បីរៀនអំពីរបៀបដែលព្រះជាម្ចាស់ប្រទានរង្វាន់ឲ្យអស់អ្នកដែលស្មោះត្រង់ជាមួយនឹងទំនួលខុសត្រូវរបស់គេ។

នៅមានមូលហេតុផ្សេងទៀត ដែលអ្នកជឿទាំងពីររូបនេះ ត្រូវបានជ្រើសរើសដោយព្រះសិរសាឲ្យធ្វើជាអ្នកផ្សាយដំណឹងល្អ។ ពួកគេប្រកបដោយព្រះវិញ្ញាណដ៏វិសុទ្ធ និង មានប្រាជ្ញា។ គម្ពីរកិច្ចការ ៦:៨ បានចាត់ទុកលោកស្ទេផានថាជាបុរសម្នាក់ "ពោរពេញដោយព្រះគុណ និងឫទ្ធានុភាព"។

អស់អ្នកដែលត្រូវបានជ្រើសរើសដោយព្រះសិរសាឲ្យក្លាយជាអ្នកផ្សាយដំណឹងល្អ ពួកគេត្រូវបានជ្រើសរើសដោយមូលហេតុមួយចំនួន។ មូលហេតុទាំងនេះ រួមបញ្ចូលទាំង ភាពស្មោះត្រង់ និង ភាពប្រកបដោយព្រះវិញ្ញាណដ៏វិសុទ្ធ ប្រាជ្ញា ជំនឿ និង ឫទ្ធានុភាព។ ព្រះជាម្ចាស់ក៏ប្រហែលជាស្វែងរក

សមត្ថភាពផ្សេងទៀតដែរ។ ត្រូវចងចាំផងដែរថា ទ្រង់ជ្រាបថាអ្នកណាដែលនឹងមានសមត្ថភាពត្រឹមត្រូវ តាំងពីមុនពេលដែលមនុស្សណាម្នាក់ដឹងថាពួកគេមានសមត្ថភាពនោះទៅទៀត។ ជាឧទាហរណ៍ ទ្រង់អាចនឹងត្រាស់ហៅយុវជនម្នាក់ឲ្យធ្វើជាអ្នកផ្សាយដំណឹងល្អ មុនពេលដែលយុវជននោះ ឬ អ្នកណាម្នាក់ដឹងថាគាត់មានសមត្ថភាពដ៏ចាំបាច់មួយនោះទៅទៀត។ ទ្រង់ត្រាស់ហៅលោកសាំយូអែលឲ្យធ្វើជាព្យាការីនៅក្នុងសាសន៍អ៊ីស្រាអែល នៅពេលដែលលោកនៅមានវ័យក្មេងខ្ចីនៅឡើយ។ (សូមមើលនៅក្នុងគម្ពីរ១សាំយូអែលជំពូក៣)

បន្ទាប់មកអ្នកទទួលនោះគឺជាអ្នកណាដែលព្រះជាម្ចាស់ជ្រាបថា មានសមត្ថភាព ឬ អ្នកណាដែលព្រះជាម្ចាស់នឹងធ្វើឲ្យមានសមត្ថភាព សម្រាប់ការងារមួយនោះ។

## *លំហាត់អនុវត្តន៍*

២ ការសម្រេចចិត្តថាអ្នកណាដែលនឹងទទួលបានព្រះអំណោយទានពិសេសនៃព័ន្ធកិច្ច ដើម្បីក្លាយ ជាអ្នកផ្សាយដំណឹងល្អនោះ ត្រូវបានធ្វើឡើងដោយ

ក) ពួកសាវ័ក

ខ) ព្រះសិរសា

គ) ព្រះកាយ

ឃ) សមាជិកផ្សេងទៀតនៃព្រះកាយ

៣ តើសមត្ថភាពបែបណាខ្លះដែលយើងរំពឹងថានឹងឃើញមាននៅក្នុងអស់អ្នកដែលត្រូវបានជ្រើសរើសឲ្យក្លាយជាអ្នកផ្សាយដំណឹងល្អ? ចូរគូសរង្វង់ជុំវិញអក្សរនៅពីមុខចម្លើយទាំងឡាយណាដែលត្រឹមត្រូវ។

ក) ពេញដោយជំនឿ និង ឫទ្ធានុភាព

ខ) សមត្ថភាពធ្វើដំណើរផ្លូវឆ្ងាយ

គ) ស្មោះត្រង់នៅក្នុងក្រុមជំនុំ

ឃ) ប្រកបដោយព្រះវិញ្ញាណដ៏វិសុទ្ធ និង ប្រាជ្ញា

## ការអធិប្បាយពីមុខងារ

មុខងារសំខាន់បំផុតរបស់អ្នកផ្សាយដំណឹងល្អ គឺយល់ដឹងពីអត្ថន័យនៃពាក្យថា *អ្នកផ្សាយដំណឹងល្អ*។ អ្នកផ្សាយដំណឹងល្អគឺមានន័យថា "អ្នកដែលប្រកាសដំណឹងល្អ"។ ប្រហែលជាមានដំណឹងល្អច្រើនប្រភេទនៅក្នុងពិភពលោក។ ដំណឹងល្អត្រូវបានប្រកាសដោយអ្នកផ្សាយដំណឹងល្អ គឺនិយាយអំពីដំណឹងល្អរបស់ព្រះគ្រិស្ត។ លោកប៉ុលបានធ្វើការបកស្រាយសង្ខេបនៅក្នុងគម្ពីរ ១កូរិនថូសជំពូក១៥ អំពីអ្វីទៅដែលជាដំណឹងល្អរបស់ព្រះគ្រិស្ត ។ វារួមបញ្ចូលចំណុចសំខាន់ៗបីយ៉ាង៖ (១) ព្រះគ្រិស្តសុគតសម្រាប់បាបរបស់យើង បើយោងទៅតាមខគម្ពីរ (២) សពទ្រង់ត្រូវបានបញ្ចុះ និង (៣) ទ្រង់មានព្រះជន្មរស់ឡើងវិញម្តងទៀតនៅថ្ងៃទីបី បើយោងទៅតាមខគម្ពីរ។

ស្របពេលដែលមុខងារសំខាន់បំផុតរបស់អ្នកផ្សាយដំណឹងល្អ គឺប្រាប់ដំណឹងល្អអំពីព្រះគ្រិស្ត ពួកគេក៏មានមុខងារមួយទៀតដែរ។ ការប្រាប់ដំណឹងល្អអំពីព្រះគ្រិស្ត តាមធម្មតាគឺសម្រាប់តែអ្នកដែលមិនជឿ ប៉ុន្តែសម្រាប់លោកប៉ុលវិញ នៅពេលដែលលោកនិយាយអំពីព្រះអំណោយទាននៃព័ន្ធកិច្ចនៅក្នុងគម្ពីរអេភេសូជំពូក ៤ លោកបានដាក់ទំនួលខុសត្រូវទៅលើអ្នកផ្សាយដំណឹងល្អ ដើម្បីធ្វើការរៀបចំមនុស្សរបស់ព្រះជាម្ចាស់ "ដើម្បីរៀបចំប្រជាជនដ៏វិសុទ្ធអោយបំពេញមុខងារបំរើ និងកសាងព្រះកាយរបស់ព្រះគ្រិស្តឡើង" (ខទី១២)។ មធ្យោបាយដែលការនេះអាចសម្រេចទៅបាន គឺមានតែតាមរយៈគំរូ ។ នៅក្នុងព្រះគម្ពីរមានគំរូល្អៗជាច្រើនសម្រាប់យើងរាល់គ្នា។

យើងអាចយល់ដឹងពីមុខងាររបស់អ្នកផ្សាយដំណឹងល្អបានកាន់តែប្រសើរឡើង ប្រសិនបើយើងសាកល្បងជីវិត និង ព័ន្ធកិច្ចរបស់មនុស្សម្នាក់ដែលត្រូវបានគេហៅថាអ្នកផ្សាយដំណឹងល្អនៅក្នុងព្រះគម្ពីរនោះគឺលោកភីលីព។ សិក្សាសមត្ថភាពដែលទាក់ទងនឹងលោកភីលីព ដែលមានរៀបរាប់នៅខាងក្រោមនេះ ដោយយកចិត្តទុកដាក់៖

១. លោកបានទៅក្រុងសាម៉ារី និងចែកចាយអំពីព្រះគ្រិស្ត (គម្ពីរកិច្ចការ ៨:៥)
២. លោកបាននិយាយទៅកាន់មនុស្សម្នា និង ធ្វើការអស្ចារ្យ (គម្ពីរកិច្ចការ ៨:៦)
៣. លោកនាំឲ្យមានសេចក្តីអំណរទៅដល់ទីក្រុង ( គម្ពីរកិច្ចការ ៨:៨)
៤. លោកបានជ្រមុជទឹកឲ្យអស់អ្នកដែលទទួលជឿ ( គម្ពីរកិច្ចការ ៨:១២)
៥. លោកបានស្តាប់បង្គាប់ព្រះអម្ចាស់ ដោយមិនខ្វល់ពីកន្លែងដែលលោកត្រូវទៅបម្រើដឹកនាំនោះឡើយ (គម្ពីរកិច្ចការ ៨:២៦-២៧)
៦. លោកទទួលបានទិសដៅច្បាស់លាស់ពីព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីរកិច្ចការ ៨:២៩)
៧. លោកចែកចាយ ដំណឹងល្អពីព្រះគ្រិស្ត ជាមួយនឹងមនុស្សតែម្នាក់ (គម្ពីរកិច្ចការ ៨:៣០-៣៥)
៨. លោកចែកចាយដំណឹងល្អពីព្រះគ្រិស្តនៅក្នុងទីក្រុងជាច្រើន (គម្ពីរកិច្ចការ៨:៤០)
៩. លោកផ្សាយដំណឹងល្អទៅឲ្យក្រុមគ្រួសាររបស់លោកផ្ទាល់ ( គម្ពីរកិច្ចការ ២១:៩)

យើងក៏អាចរៀនខ្លះៗ អំពីអ្នកផ្សាយដំណឹងល្អ តាមរយៈការដកពិសោធន៍ជីវិត និង ព័ន្ធកិច្ចរបស់លោកស្ទេផានផងដែរ។ ព្រះគម្ពីរមិនបានហៅលោកថាជាអ្នកផ្សាយដំណឹងល្អម្នាក់ដោយសារតែព័ន្ធកិច្ចរបស់លោកឡើយ។ សូមចំណាំ រឿងទាំងប៉ុន្មានខាងក្រោមនេះ៖

១. លោកសំដែងឫទ្ធិបាដិហារិយ៍ និងទីសំគាល់ធំៗក្នុងចំណោមប្រជាជន (គម្ពីរកិច្ចការ ៦:៨)
២. លោកធ្វើសកម្មភាពប្រកបដោយប្រាជ្ញាអស្ចារ្យ និង ឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ (គម្ពីរកិច្ចការ ៦:១០)។
៣. លោកសំដៅការល្អ នៅក្នុងពេលដែលលោកត្រូវបានគេបៀតបៀន (គម្ពីរកិច្ចការ ៦:១៥)។
៤. លោកចែកចាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ច្បាស់ៗ និងប្រកបដោយឫទ្ធានុភាព (គម្ពីរកិច្ចការ ៧:៥១-៥៣)។
៥. លោកថ្លែងប្រាប់ពីសេចក្តីពិតដោយគ្មានភាពភ័យខ្លាច ទោះបីលោកត្រូវបាត់បង់ជីវិតក៏ដោយ (គម្ពីរកិច្ចការ ៧:៥១-៥៣)។

៦. លោកលើកលែងទោសឲ្យអ្នកសម្លាប់លោក (គម្ពីរកិច្ចការ៧:៦០)

៧. លោកបានក្លាយជាទុក្ករបុគ្គល របស់ក្រុមជំនុំដំបូងបំផុត។

មិនមែនអ្នកផ្សាយដំណឹងល្អទាំងអស់ត្រូវតែមានបទពិសោធន៍ដូចជាលោកភីលីព និង លោកស្ទេផាននោះទេឡើយ ប៉ុន្តែយើងអាចរៀនយ៉ាងច្រើនអំពីមុខងារមូលដ្ឋាននៃព្រះអំណោយទាននេះពីពួកគាត់។

ខគម្ពីរយោងមួយទៀតដែលគួរតែដកពិសោធន៍គឺ "ត្រូវបំពេញកិច្ចការជាអ្នកផ្សព្វផ្សាយដំណឹងល្អ" (គម្ពីរ២ធីម៉ូថេ ៤:៥)។ នេះគឺជាភស្តុតាងបញ្ជាក់ថាព្រះអំណោយទាននេះ ពេលខ្លះភ្ជាប់គ្នានឹងព្រះអំណោយទានមួយផ្សេងទៀត។ លោកធីម៉ូថេ ជាអ្នកទទួលបានការបង្គាប់បញ្ជាមួយនេះ កាលនោះលោកក៏ជាអ្នកគង្វាលផង។ យើងនឹងសិក្សាអំពីមុខងារ ចម្បងរបស់អ្នកគង្វាលនៅ ផ្នែកបន្ទាប់ទៀតនៃមេរៀននេះ។ យើងត្រូវតែចាំថា អ្នកគង្វាលក៏អាចជាអ្នកផ្សាយដំណឹងល្អដែរ។ ព័ន្ធកិច្ចទាំងពីរនេះ មានចំណុចជាច្រើនស្រដៀងគ្នា។

### *លំហាត់អនុវត្តន៍*

៤ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅពីមុខប្រយោគ ទាំងឡាយណាដែលត្រឹមត្រូវនៅខាងក្រោម។

ក) អ្នកផ្សាយដំណឹងល្អ "អ្នកដែលចាត់បញ្ជូន"

ខ) ការចែកចាយដំណឹងល្អអំពីព្រះគ្រិស្ត ជាទូទៅគឺសម្រាប់អ្នកមិនទាន់ជឿ

គ) អ្នកផ្សាយដំណឹងល្អម្នាក់មានមុខងារតែមួយប៉ុណ្ណោះ

ឃ) អ្នកគង្វាល មិនគួរព្យាយាមធ្វើកិច្ចការរបស់អ្នកផ្សាយដំណឹងល្អនោះឡើយ

## ការបកស្រាយពីការអភិវឌ្ឍ

ព្រះអំណោយទាននៃព័ន្ធកិច្ចទាំងអស់ត្រូវការការអភិវឌ្ឍ ទោះបីជាត្រូវបានប្រទានមកដោយព្រះគ្រិស្តក៏ដោយ។ ទារកមួយប្រហែលជាមនុស្សដែលមានទ្រុងទ្រាយល្អឥតខ្ចោះ ប៉ុន្តែមិនមែនមានន័យថា វាបានលូតលាស់ពេញលេញនោះទេ។ វាត្រូវការការអភិវឌ្ឍជាច្រើនឆ្នាំដើម្បីលូតលាស់បានពេញលេញ។ ព្រះអំណោយទាននៃអ្នកផ្សាយដំណឹងគឺ ព្រះអំណោយទានដ៏ល្អ និង ឥតល្អខ្ចោះ ដែលបានមកពីព្រះសិរសានៃព្រះកាយនោះ ប៉ុន្តែមុនពេលដែលវាបានទៅដល់ភាពមានប្រយោជន៍ វាត្រូវការការអភិវឌ្ឍជាច្រើន។ យើងនឹងគិតអំពី ដំណាក់កាលទាំងបួនក្នុងការអភិវឌ្ឍព្រះអំណោយទាននេះ។

### អធិស្ឋានឲ្យបានច្រើន

ពួកសាវ័កទាំងដប់ពីរក៏ធ្លាប់ជាអ្នកផ្សាយដំណឹងល្អដែរ។ សូមចំណាំរឿងដែលព្រះគម្ពីរបានថ្លែងអំពីការអធិស្ឋានរបស់ពួកគាត់៖ "យើងខ្ញុំនឹងគិតតែពីអធិស្ឋាន និងបំរើព្រះបន្ទូល" (គម្ពីរកិច្ចការ ៦:៤) សូមអានផងដែរ នៅក្នុងគម្ពីរកិច្ចការ ៣:១-៦ និង ១០:៩។ ការអធិស្ឋានអាចធ្វើឲ្យអ្នកផ្សាយដំណឹងល្អបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅពេលដែលពួកគេបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ការចែកចាយរបស់ពួកគេក៏ទទួលបានលទ្ធផលផងដែរ។

## សិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ឲ្យបានច្រើន

ព្រះគម្ពីរគឺជាដាវរបស់ព្រះវិញ្ញាណ ។ (សូមមើលនៅក្នុងគម្ពីរអេភេសូ ៦:១៧)។ យើងដាក់ដាវនៅក្នុងព្រះហស្តរបស់ទ្រង់ ដើម្បីជាប្រយោជន៍ឲ្យយើងបានស្គាល់ពីព្រះបន្ទូល។ ការចែកចាយព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺ ជាដួងចិត្តនៃការផ្សាយដំណឹងល្អ ។ (សូមអាននៅក្នុងគម្ពីរ ២ធីម៉ូថេ ២:១៥)

## រៀនស្តាប់ និង ធ្វើតាមព្រះសូរសៀងរបស់ព្រះជាម្ចាស់ឲ្យបានច្រើន

ការដឹកនាំជាពិសេសមកពីព្រះវិញ្ញាណដ៏វិសុទ្ធគឺមានសារៈសំខាន់ណាស់សម្រាប់អ្នកផ្សាយដំណឹងល្អ។ (សូមមើលនៅក្នុងគម្ពីរកិច្ចការ ៨:២៩; ៩:១០-១៧; ១៦:៦-១១)។ យើងរាល់គ្នារៀនតាមរយៈបទពិសោធន៍។ បទពិសោធន៍បង្រៀនយើងពីរបៀបបែងចែកគំនិតផ្ទាល់ខ្លួនរបស់យើង ពីអ្វីដែលព្រះជាម្ចាស់អាចមានព្រះបន្ទូលមកកាន់យើង។

## ធ្វើការផ្សាយដំណឹងល្អឲ្យបានច្រើន

គ្មានមធ្យោបាយណាផ្សេងទៀតអាចអភិវឌ្ឍព្រះអំណោយទាននៃព័ន្ធកិច្ចនៃការផ្សាយដំណឹងល្អឲ្យបានល្អប្រសើរជាងការធ្វើការផ្សព្វផ្សាយដំណឹងល្អនោះទេ។ យើងអាចមើលឃើញការនេះ នៅក្នុងព័ន្ធកិច្ចរបស់លោក ស៊ី អឹម វ៉ាត  ដែលជាអ្នកផ្សាយដំណឹងល្អដ៏មានសមត្ថភាពខ្ពស់ម្នាក់នៅក្នុងសម័យយើង។ ប៉ុន្តែលោកមិនមែនជាអ្នកផ្សាយដំណឹងដែលមានសមត្ថភាពខ្ពស់សម្បើមនោះទេ។ នៅអំឡុងពេលការថ្វាយបង្គំមួយ ក្នុងគ្រាដែលលោកចាប់ផ្តើមព័ន្ធកិច្ចរបស់លោកជាលើកដំបូង លោកបានភ្លេចអំពីអ្វីដែលលោកត្រៀមនិយាយ។ លោកក៏ចាកចេញពីការថ្វាយបង្គំនោះ ទាំងមិនបានធ្វើការចែកចាយ។ នោះមិនមែនមានន័យថាលោកមិនមែនជាអ្នកផ្សាយដំណឹងល្អនោះទេ។ វាគ្រាន់តែមានន័យថា លោកត្រូវការបទពិសោធន៍បន្ថែមទៀត ក្នុងការផ្សាយដំណឹងល្អ។ លោកបានដាក់ខ្លួនលោកទៅក្នុងកិច្ចការនេះ មួយឆ្នាំហើយមួយឆ្នាំទៀត។ លោកបានប្រើព្រះអំណោយទានរបស់លោកនៅគ្រប់ឱកាស ហើយក៏ត្រូវបានគេស្គាល់ថា ជាអ្នកផ្សាយដំណឹងល្អដ៏មានសមត្ថភាពខ្ពស់ម្នាក់។

## *លំហាត់អនុវត្តន៍*

---

៥ ការអភិវឌ្ឍព្រះអំណោយទានព័ន្ធកិច្ចនៃការផ្សាយដំណឹងល្អ មានទាក់ទងទៅនឹង

ក) ការសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់

ខ) ការរៀនស្តាប់ព្រះសូរសៀងរបស់ព្រះជាម្ចាស់

គ) ការផ្សព្វផ្សាយដំណឹងល្អ។

# ខ. ទ្រង់ប្រទានឲ្យអ្នកខ្លះ ជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀន

**វត្ថុណងទី២.** *រៀបរាប់អំពីព្រះអំណោយទាននៃព័ន្ធកិច្ច ដែលគេហៅថា អ្នកគង្វាលព្រមទាំងបង្រៀន*

**វត្ថុបំណងទី៣.** *រៀបរាប់ និង បកស្រាយ អំពីគោលបំណង និងមុខងាររបស់ព្រះអំណោយទាននៃព័ន្ធកិច្ចទាំងអស់។*

## ការស្គាល់អ្នកដែលបានប្រទានឲ្យ

ដោយយើងបានរៀនជាច្រើនមកហើយ យើងបានសំគាល់ឃើញចំណុចសំខាន់ៗបី អំពីអ្នកដែលបានប្រទានព្រះអំណោយទានខាងព័ន្ធកិច្ច។

១. យើងបានរៀនឲ្យដឹងថា អ្នកដែលបានប្រទានឲ្យនោះគឺជាព្រះគ្រិស្ដ។

២. យើងបានរៀនឲ្យដឹងថា អ្នកដែលបានប្រទានឲ្យនោះ ជាព្រះគ្រិស្ដ ទ្រង់ក៏ជាព្រះជាម្ចាស់ដែរ។

៣. យើងបានរៀនឲ្យដឹងថា អ្នកដែលបានប្រទានឲ្យនោះជាព្រះគ្រិស្ដ ទ្រង់ជាព្រះសិរសានៃព្រះកាយ

ពេលនេះ យើងបានរៀនឲ្យដឹងហើយថា អ្នកដែលបានប្រទានឲ្យ ជាព្រះគ្រិស្ដ ទ្រង់ក៏ជាព្រះអង្គសង្គ្រោះរបស់ព្រះកាយផងដែរ៖ "ព្រះគ្រិស្ដនាំមុខក្រុមជំនុំ* ហើយជាព្រះសង្គ្រោះរបស់ក្រុមជំនុំដែលជាព្រះកាយព្រះអង្គ" (គម្ពីរអេភេសូ ៥:២៣)។ ព្រះអង្គសង្គ្រោះមានន័យថា "អ្នករំដោះ" ។ តើអ្នកដែលបានប្រទានឲ្យនោះ ជាប់ទាក់ទងនឹងព្រះកាយ ក្នុងនាមជាអ្នករំដោះនៅក្នុងព្រះអំណោយទានព័ន្ធកិច្ចដោយរបៀបណា? យើងនឹងកត់ចំណាំរបៀបបីយ៉ាង។

### ទ្រង់រំដោះឲ្យផុតពីចិត្តរឹងរូស

ចិត្តរឹងរូសគឺជាឧបសគ្គដ៏ធំទៅដល់ជំនឿ។ តាមរយៈព្រះអំណោយទាននៃអ្នកបង្រៀនរបស់ទ្រង់ ព្រះសិរសាបានប្រទានការរំដោះឲ្យផុតពីចិត្តរឹងរូស។ អ្នកបង្រៀនដាក់ចំណេះដឹង ដើម្បីដកចិត្តរឹងរូសដែលជាឧបសគ្គដល់ជំនឿនៅក្នុងព្រះកាយនោះចេញ។

### ទ្រង់រំដោះឲ្យផុតពីភាពអាត្មានិយម

មុខងារមួយដ៏ធំបំផុតរបស់ព្រះអំណោយទានជាអ្នកគង្វាល គឺការរំដោះសមាជិកនៃព្រះកាយ ឲ្យផុតពីភាពអាត្មានិយម។ ការនេះអាចធ្វើទៅបាន ដោយការដឹកនាំពួកគេចូលទៅក្នុងជីវិតដែលមានព្រះគ្រិស្ដជាគោល។

### ទ្រង់រំដោះពួកគេឲ្យផុតពីទុក្ខលំបាក

"ព្រះអម្ចាស់នឹងយាងមក តាមព្រះបន្ទូលសន្យារបស់ព្រះអង្គ ឥតបង្អែបង្អង់ ដូចអ្នកខ្លះនឹកស្មាននោះឡើយ។ ព្រះអង្គសំដែងព្រះហឫទ័យអត់ធ្មត់ចំពោះបងប្អូន ព្រោះទ្រង់មិនសព្វព្រះហឫទ័យអោយនរណាម្នាក់ត្រូវវិនាសទេ គឺទ្រង់សព្វព្រះហឫទ័យអោយមនុស្សលោកគ្រប់ៗរូបកែប្រែចិត្តគំនិតវិញ។" (គម្ពីរ២ពេត្រុស ៣:៩)។ ទុក្ខលំបាកគឺជាផ្នែកមួយនៃជីវិតរស់នៅ។ សូម្បីតែសមាជិករបស់ព្រះកាយក៏មានទុក្ខលំបាកដែរ។ តាមរយៈព្រះអំណោយទានជាអ្នកគង្វាល ព្រមទាំងជាអ្នកបង្រៀន អ្នកដែលបានប្រទានឲ្យនោះ ទ្រង់រំដោះយើងពីទុក្ខលំបាករបស់យើង។ នេះមិនមែនមានន័យថា អ្នកជឿគេចផុតពីទុក្ខលំបាក

ទាំងអស់ក្នុងពេលតែមួយនោះឡើយ។ វាមិនមែនមានន័យថា តាមរយៈព័ន្ធកិច្ចជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀន ពួកគេអាចគេចផុតពីភាពបរាជ័យដែលបានមកពីទុក្ខលំបាកនោះឡើយ។ ពួកគេត្រូវរៀនពីផលចំណេញដែលបានមកពីទុក្ខលំបាក ហើយធ្វើវាឲ្យទៅជាឈ្នាន់ ដើម្បីបានជីវិតដ៏មានប្រយោជន៍ថែមទៀត។

ទាំងនេះគ្រាន់តែជារឿងដ៏គួរឲ្យព្រួយព្រះទ័យខ្លះ សម្រាប់អ្នកដែលបានប្រទានឲ្យ ក្នុងនាមទ្រង់ជាព្រះអង្គសង្គ្រោះរបស់ព្រះកាយ និង ជាអ្នកដែលបានប្រទានឲ្យមានជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀន។

## *លំហាត់អនុវត្តន៍*

៦ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយណាដែលត្រឹមត្រូវ។

ក ) អ្នកដែលបានប្រទានព្រះអំណោយទាននៃព័ន្ធកិច្ចហៅថា ព្រះអង្គសង្គ្រោះរបស់ព្រះកាយ។

ខ) ព្រះអង្គសង្គ្រោះមានន័យថា អ្នករកឃើញ។

គ) មុខងារមួយរបស់អ្នកគង្វាលព្រមទាំងអ្នកបង្រៀនគឺរំដោះអ្នកជឿឲ្យផុតពី ការប្រកាន់យកព្រះគ្រិស្តជាគោល។

ឃ) អ្នកគង្វាលព្រមទាំងអ្នកបង្រៀនជួយអ្នកជឿឲ្យទទួលបានផលចំណេញពីទុក្ខលំបាករបស់គេ។

# ការបង្ហាញពីអ្នកទទួល

និយាយអំពីព្រះអំណោយទាននៃព័ន្ធកិច្ច អ្នកគង្វាលព្រមទាំងអ្នកបង្រៀនគឺជាព្រះអំណោយទានដែលមានច្រើនជាងគេ។ មានអ្នកគង្វាលព្រមទាំងអ្នកបង្រៀនច្រើនជាសាវ័ក ព្យាការី និង អ្នកផ្សាយដំណឹងល្អទៅទៀត។ មូលហេតុនោះគឺថា ព្រះកាយត្រូវការពួកគេច្រើន។ អ្នកគង្វាលព្រមទាំងអ្នកបង្រៀនគឺអាចបំពេញតម្រូវការជាច្រើនរបស់ព្រះកាយ។

តើអ្នកណាដែលទទួលបានព្រះអំណោយទាននេះ? នៅក្នុងការសិក្សាអំពីព្រះអំណោយទានព័ន្ធកិច្ចដទៃផ្សេងទៀត យើងបានដឹងថា ព្រះសិរសានៃក្រុមជំនុំ ទ្រង់សព្វព្រះហឫទ័យនឹងសមត្ថភាពជាក់លាក់មួយនៅក្នុងព័ន្ធកិច្ចរបស់ទ្រង់។ សមត្ថភាពទាំងនេះមានដូចជា ភាពស្មោះត្រង់ ប្រាជ្ញា ជំនឿ ភាពពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ និង ឫទ្ធានុភាព។ សមត្ថភាពទាំងនេះក៏សំខាន់ណាស់ដែរសម្រាប់ព្រះអំណោយទានជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀន។ លើសពីនោះទៅទៀត មានសមត្ថភាពមួយដែលចាំបាច់ជាងគេ។ នេះគឺសមត្ថភាពនៃសេចក្ដីស្រឡាញ់ និង ថែទាំចំពោះមនុស្ស។ នោះហើយបានជាពាក្យថា *អ្នកគង្វាល* តែងតែយកមកប្រើដើម្បីចង្អុលបង្ហាញពីព័ន្ធកិច្ចរបស់អ្នកគង្វាលព្រមទាំងអ្នកបង្រៀន។ អ្នកគង្វាលស្រឡាញ់ និង ថែទាំចៀមរបស់ពួកគេ។

អ្នកដែលបានប្រទាន ព្រះអំណោយទាននេះ ទ្រង់ផ្ទាល់ក៏ជាអ្នកគង្វាលដ៏ល្អសម្រាប់ហ្វូងចៀមរបស់ទ្រង់។ ទ្រង់ត្រូវបានគេហៅថា អ្នកគង្វាលល្អ។ អស់អ្នកដែលទទួលបានព្រះអំណោយទានជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀន គឺត្រូវស្ថិតក្រោមអ្នកគង្វាលល្អនោះ។ នោះហើយបានជា គេត្រូវមានសេចក្ដីស្រឡាញ់ និង ការថែទាំដូចជាអ្នកគង្វាលល្អ ដែលទ្រង់ក៏ជាព្រះអង្គសង្គ្រោះរបស់ព្រះកាយផងដែរ។

## *លំហាត់អនុវត្តន៍*

៧ មនុស្សណាម្នាក់នឹងទទួលបានព្រះអំណោយទានជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀន។ តើសមត្ថភាពអ្វីខ្លះដែលព្រះអង្គសង្គ្រោះនៃព្រះកាយទ្រង់សព្វព្រះទ័យចង់បាន នៅពេលដែលទ្រង់ស្វែងរកមនុស្សធ្វើជាព្រះអំណោយទាននេះសម្រាប់ព្រះកាយរបស់ទ្រង់?

..............................................................................................................................................

..............................................................................................................................................

៨ តើអ្នកគង្វាល ដូចជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀនត្រង់ចំណុចណា?

..............................................................................................................................................

..............................................................................................................................................

## ការអធិប្បាយពីមុខងារ

ព្រះគម្ពីរបាននិយាយច្រើនអំពី ព្រះអំណោយទានជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀន ជាងព្រះអំណោយទាននៃព័ន្ធកិច្ចដទៃទៀត។ យើងបានបកស្រាយ អ្នកគង្វាល និង អ្នកបង្រៀននេះ ជាមួយគ្នា ព្រោះតែមានអ្នកសិក្សាព្រះគម្ពីរជាច្រើននាក់បានយល់ស្របថា ទាំងពីរនេះជាព្រះអំណោយទានតែមួយ។ ដោយពាក្យថា *អ្នកគង្វាលព្រមទាំងអ្នកបង្រៀន* យើងចង់មានន័យថា *អ្នកគង្វាលដែលមានព័ន្ធកិច្ចបង្រៀន*។

នៅពេលដែលយើងចាប់ផ្តើមសិក្សាពីមុខងាររបស់អ្នកគង្វាលព្រមទាំងអ្នកបង្រៀននេះ យើងត្រូវត្រឡប់ទៅមើលគម្ពីរអេភេសូ៤:១១-១២ ដែលលោកមានប្រសាសន៍ថា "គឺព្រះអង្គហើយ ដែលបានប្រទានអោយ....អ្នកខ្លះជាអ្នកគង្វាល និងអ្នកខ្លះទៀតជាអ្នកបង្រៀន ដើម្បីរៀបចំប្រជាជនដ៏វិសុទ្ធអោយបំពេញមុខងារបំរើ និងកសាងព្រះកាយរបស់ព្រះគ្រិស្តឡើង"។ យើងបានឃើញថា *មុខងារ*នៃព្រះអំណោយទានព័ន្ធកិច្ចគឺការរៀបចំប្រជាជនរបស់ព្រះជាម្ចាស់សម្រាប់ព័ន្ធកិច្ច។

មានកណ្ឌគម្ពីរមួយចំនួននៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី គឺសម្រាប់អ្នកគង្វាល។ គេហៅវាថា គម្ពីរសំបុត្រសម្រាប់អ្នកគង្វាល។ កណ្ឌគម្ពីរនោះមានសំបុត្រពីរ ទៅកាន់លោកធីម៉ូថេ និង ទៅកាន់លោកទីតុស។ វាត្រូវបានសរសេរផ្ញើរទៅកាន់ពួកគង្វាលដោយផ្ទាល់ និយាយអំពីមុខងាររបស់ពួកគេ។ អ្នកគួរអានកណ្ឌគម្ពីរនីមួយៗឲ្យបានពីរ ឬបីដង។

ដើម្បីជួយអ្នកឲ្យយល់ពីមុខងាររបស់អ្នកគង្វាលព្រមទាំងអ្នកបង្រៀន យើងនឹងយកអ្នកគង្វាលហ្វូងចៀមមកធ្វើជាឧទាហរណ៍។

## អ្នកគង្វាលស្រឡាញ់ហ្វូងចៀមរបស់ពួកគេ ហើយស្ម័គ្រចិត្តលះបង់ជីវិតដើម្បីពួកវា

សូមអានគម្ពីរយ៉ូហាន ១០:១១-១៥។ អ្នកគង្វាលល្អគឺជាគំរូ ដ៏ប្រសើរសម្រាប់អ្នកគង្វាលថ្នាក់ក្រោម។ អ្នកគង្វាលព្រមទាំងអ្នកបង្រៀនធ្វើបានតែរឿងបន្តិចបន្តួចប៉ុណ្ណោះសម្រាប់ហ្វូងចៀមរបស់ពួកគេ លុះត្រាតែពួកគេស្រឡាញ់ហ្វូងចៀមនោះជាមុនសិន។ សេចក្តីស្រឡាញ់គឺជាគ្រឹះសម្រាប់មុខងារ ដែលប្រកបដោយផលផ្លែរបស់ព្រះអំណោយទានខាងឯវិញ្ញាណទាំងអស់។

## អ្នកគង្វាលផ្តល់អាហារឲ្យហ្វូងចៀមរបស់ពួកគេ

"ស៊ីម៉ូនកូនលោកយ៉ូហានអើយ! តើអ្នកស្រឡាញ់ខ្ញុំ ជាងអ្នកទាំងនេះស្រឡាញ់ខ្ញុំឬ?... សុំថែរក្សាកូនចៀមរបស់ខ្ញុំផង......សុំឃ្វាលហ្វូងចៀមរបស់ខ្ញុំផង!" (គម្ពីរយ៉ូហាន២១:១៥-១៦)។ នៅពេលដែលលោកពេត្រុសបានសរសេរសំបុត្រលើកដំបូងរបស់លោកទៅកាន់ពួកចាស់ទុំ ( អ្នកគង្វាល) លោកបានណែនាំពួកគេឲ្យ "សូមមើលថែរក្សាហ្វូងចៀមដែលព្រះជាម្ចាស់ផ្ញើទុកនឹងបងប្អូន ដោយចិត្តស្មោះស្ម័គ្រស្របតាមព្រះហឫទ័យព្រះជាម្ចាស់ គឺមិនមែនដោយទើសទ័ល ឬដោយចង់បានកំរៃអ្វីដែរ តែត្រូវមើលថែរក្សាដោយសុទ្ធចិត្ត។ (គម្ពីរ១ពេត្រុស ៥:២)។

ការផ្តល់អាហារសម្រាប់ហ្វូងចៀម ត្រូវតែជាអាហារដែលទាំងកូនចៀម និង ចៀមធំអាចស៊ីបាន។ សម្រាប់កូនចៀម ដែលជាអ្នកជឿថ្មី យើងមានទឹកដោះនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ (សូមមើលគម្ពីរ១ពេត្រុស២:២ និង គម្ពីរហេប្រឺ ៥:១៣)។ សម្រាប់ចៀមពេញវ័យ ត្រូវតែមានអាហាររឹង (សូមមើលគម្ពីរ១កូរិនថូស ៣:១-២ និង គម្ពីរហេប្រឺ៥:១៤)។

សូមអានការណែនាំរបស់លោកប៉ូលសម្រាប់លោកធីម៉ូថេ ដែលជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀនម្នាក់ "សេចក្តីទាំងអស់ដែលអ្នកបានឮពីខ្ញុំនៅមុខសាក្សីជាច្រើននាក់ ត្រូវប្រគល់អោយបងប្អូនណាដែលស្មោះត្រង់ និងមានសមត្ថភាពអាចបង្រៀនបន្តទៅអ្នកផ្សេងទៀតចុះ។" (គម្ពីរ២ធីម៉ូថេ ២:២) ។ ជាច្រើនលើក លោកប៉ូលបង្គាប់ឲ្យលោកធីម៉ូថេ បង្រៀន។ "អ្នកត្រូវដាស់តឿន និងបង្រៀនសេចក្តីទាំងនេះ" (គម្ពីរ១ធីម៉ូថេ៤:១១)។ "អ្នកត្រូវបង្រៀន និងដាស់តឿនគេតាមសេចក្តីទាំងនេះ" (គម្ពីរ១ធីម៉ូថេ ៦:២)។ "រីឯអ្នកបំរើរបស់ព្រះអម្ចាស់.... ត្រូវរួសរាយចំពោះមនុស្សទូទៅ ត្រូវចេះបង្រៀន និងអធ្យាស្រ័យដល់គេ" (គម្ពីរ២ធីម៉ូថេ ២:២៤)។

## អ្នកគង្វាលគឺជាអ្នកដឹកនាំហ្វូងចៀមរបស់ពួកគេ

អ្នកគង្វាលសត្វចៀមត្រូវតែដឹកនាំពួកវា។ ព្រះគម្ពីរបានចែងថា៖ "លុះគាត់បញ្ចេញចៀមចេញពីក្រោលអស់ហើយ គាត់ដើរនាំមុខវា" (គម្ពីរយ៉ូហាន ១០:៤)។ អ្នកគង្វាលល្អនៃហ្វូងចៀមរបស់ព្រះជាម្ចាស់គឺជាគំរូដ៏ល្អបំផុតសម្រាប់អ្នកគង្វាលព្រមទាំងអ្នកបង្រៀន។ ដូចទៅនឹងអ្នកគង្វាលល្អដែលជាគំរូរបស់អ្នកគង្វាលព្រមទាំងអ្នកបង្រៀន អ្នកគង្វាលព្រមទាំងអ្នកបង្រៀនក៏ត្រូវតែជាគំរូសម្រាប់ហ្វូងចៀមផងដែរ " កុំប្រើអំណាចជិះជាន់អស់អ្នកដែលព្រះជាម្ចាស់ប្រទានមកអោយបងប្អូនថែរក្សានោះឡើយ គឺត្រូវធ្វើជាគំរូដល់ហ្វូងចៀមវិញ" (គម្ពីរ១ពេត្រុស៥:៣)។

"ក្នុងការនិយាយស្ដីក្ដី កិរិយាមារយាទក្ដី ចិត្តស្រឡាញ់ក្ដី ជំនឿក្ដី និងចិត្តបរិសុទ្ធក្ដី ត្រូវធ្វើជាគំរូដល់អស់អ្នកជឿ" (គម្ពីរ១ធីម៉ូថេ ៤:១២)។ អ្នកដឹកនាំល្អដើរមុន អ្នកដែលដើរតាម ព្រមទាំង ធ្វើជាគំរូរបស់ពួកគេផង។

## អ្នកគង្វាលការពារហ្វូងចៀមរបស់ពួកគេ

សូមអានគម្ពីរយ៉ូហាន ១០:១១-១២។ "ដូច្នេះ សូមបងប្អូនថែរក្សាខ្លួនឯង និងថែរក្សាក្រុមអ្នកជឿទាំងមូលផង ព្រោះព្រះវិញ្ញាណដ៏វិសុទ្ធបានផ្ទុកផ្ដាក់អោយបងប្អូនធ្វើជាអ្នកទទួលខុសត្រូវនេះ ដើម្បីអោយបងប្អូនថែរក្សាក្រុមជំនុំរបស់ព្រះជាម្ចាស់ ..... ខ្ញុំដឹងច្បាស់ថា ពេលខ្ញុំចេញផុតទៅ នឹងមានមនុស្សចិត្តសាហាវដូចចចក នាំគ្នាចូលមកក្នុងចំណោមបងប្អូន គេនឹងធ្វើបាបក្រុមអ្នកជឿឥតត្រាប្រណីឡើយ" (គម្ពីរកិច្ចការ២០:២៨-២៩)។ នេះគឺជាទំនួលខុសត្រូវដ៏ធំមួយ។ ការការពារល្អបំផុតដែល អ្នកគង្វាលព្រមទាំងអ្នកបង្រៀនអាចផ្ដល់ឲ្យទៅកាន់ហ្វូងចៀមគឺជាការយល់ដឹងយ៉ាងច្បាស់លាស់អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។

## អ្នកគង្វាលទន្ទឹងចង់បានការបង្កើតកូនចៅ

អ្នកគង្វាលចង់ឲ្យចៀមរបស់ពួកគេ បង្កើតចៀមឲ្យបានច្រើន។ ភាគច្រើន អ្វីៗដែលពួកគេធ្វើគឺត្រូវបានជំរុញដោយគោលបំណងមួយនោះ។ អ្នកគង្វាលព្រមទាំងអ្នកបង្រៀនមានគោលបំណងស្រដៀងៗគ្នា។ សូមចាំពាក្យរបស់អ្នកគង្វាលល្អ "ខ្ញុំមានចៀមឯទៀតៗ ដែលមិននៅក្នុងក្រោលនេះទេ។ ខ្ញុំត្រូវតែនាំចៀមទាំងនោះមកដែរ" (គម្ពីរយ៉ូហាន១០:១៦)។ ហេតុនេះហើយបានជាលោកប៉ូលសរសេរសំបុត្រទៅកាន់លោកធីម៉ូថេថា៖ "ត្រូវបំពេញកិច្ចការជាអ្នកផ្សព្វផ្សាយដំណឹងល្អ" ( គម្ពីរ២ធីម៉ូថេ ៤:៥)។ នៅពេលដែលអ្នកគង្វាលព្រមទាំងអ្នកបង្រៀនបំពេញមុខងារជាអ្នកផ្សាយដំណឹងល្អ មានរឿងពីរយ៉ាងនឹងកើតមានឡើង។ ទីមួយពួកគេនឹងនាំសមាជិកថ្មីៗចូលទៅក្នុងព្រះកាយរបស់ព្រះគ្រិស្ដ។ ទីពីរ ពួកគេក៏បង្រៀនហ្វូងចៀមអំពីរបៀបនាំសមាជិកថ្មីៗឲ្យចូលមក ដោយបានធ្វើជាគំរូឲ្យហ្វូងចៀមផងដែរ។

## *លំហាត់អនុវត្តន៍*

---

៩ ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយណាដែលត្រឹមត្រូវ សម្រាប់បង្គប់ប្រយោគតទៅ នេះ។ អ្នកគង្វាលព្រមទាំងអ្នកបង្រៀនគឺដូចជាអ្នកគង្វាល ព្រោះពួកគេ

ក) ស្រឡាញ់ និង ថែទាំមនុស្សរបស់ពួកគេ។

ខ) ផ្ដល់អាហារដូចជាទឹកដោះ និង អាហាររឹងនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ សម្រាប់មនុស្សរបស់ពួកគេ។

គ) ទុកមនុស្សរបស់ពួកគេចោល ដើម្បីឲ្យពួកគេបានរៀនពីរបៀបប្រយុទ្ធជាមួយសត្រូវ។

ឃ) ប្រើអំណាចគ្រប់គ្រងលើមនុស្សរបស់ពួកគេ។

*គោលបំណង* នៃការបង្កើតកូនចៅ គឺដើម្បីកសាងព្រះកាយរបស់ព្រះគ្រិស្ត។ តើអ្វីជា គោលបំណង របស់ព្រះគ្រិស្ត ក្នុងការកសាងព្រះកាយរបស់ទ្រង់។ លោកប៉ូលប្រាប់យើងថាវាជាអ្វីនៅក្នុងគម្ពីរអេភេសូ ៤:១៣-១៦។ សូមធ្វើការដកពិសោធន៍ ខគម្ពីរនេះដោយយកចិត្តទុកដាក់ ហើយកត់សំគាល់ចំណុចខាងក្រោម៖

## ជំនឿតែមួយ

ពិតជាទំនួលខុសត្រូវមួយដ៏ធំមែន ដែលបានដាក់ទៅលើអស់អ្នកដែលមានព្រះអំណោយទាននៃព័ន្ធកិច្ច! ពួកគេត្រូវបញ្ចេញកម្លាំងពលកម្ម ដើម្បីនាំព្រះកាយដែលផ្សំពីអ្នកជឿឲ្យរួមគ្នាក្នុងជំនឿ។ ការរួបរួមគ្នា មានន័យថា "តែមួយ" ។ ( សូមមើលនៅក្នុងគម្ពីរទំនុកតម្កើង ១៣៣:១)។ លក្ខខ័ណ្ឌដែលជំនឿតែមួយនេះគឺជារឿងមួយដែលងាយទទួលបានបំផុត គឺការមានវិញ្ញាណតែមួយ។ (សូមមើលគម្ពីរ អេភេសូ ៤:៣) ។ វិញ្ញាណតែមួយ គឺជាដីដែលជួយឲ្យជំនឿតែមួយអាចបង្កបង្កើតបានល្អបំផុត។ បើគ្មានវិញ្ញាណតែមួយនោះទេ ជំនឿតែមួយនឹង ទៅជាត្រជាក់ និង គ្មានជីវិតរស់ឡើយ។ វិញ្ញាណតែមួយមិនងាយនឹងរក្សាទុកនោះឡើយ។ យើងត្រូវធ្វើការច្រើនទៅលើវា។ វាទាមទារឲ្យមានទំនាក់ទំនងដ៏ត្រឹមត្រូវជាមួយព្រះគ្រិស្ត និងជាមួយសមាជិកនៃព្រះកាយរបស់ទ្រង់។ វាទាមទារឲ្យមានឥរិយាបថនៃសេចក្តីស្រឡាញ់ និង ការអត់ទោស។

ជំនឿតែមួយមានន័យថា "ការជឿលើរឿងតែមួយ"។ វាមានន័យថាជឿលើអ្វីៗដែលព្រះគម្ពីរបានចែង។ ដូច្នេះ គោលបំណងមួយសម្រាប់អំណោយទានព័ន្ធកិច្ច គឺនាំព្រះកាយចូលទៅក្នុងជំនឿតែមួយ។

## គំនិតតែមួយ

នេះគឺជាគំនិតចេះដឹងបែបពិសេសមួយ។ វាគឺជា "ការស្គាល់ព្រះបុត្រារបស់ព្រះជាម្ចាស់" (គម្ពីរអេភេសូ ៤:១៣)។ វាមិនគ្រាន់តែជាចំណេះដឹង*អំពី* ព្រះគ្រិស្តនោះទេ។ វាមានន័យថា ការស្គាល់ *ទ្រង់* ។ យ៉ាងហោចណាស់ មានមធ្យោបាយបីយ៉ាងដែលយើងអាចស្គាល់ទ្រង់បាន (សូមមើលនៅក្នុងគម្ពីរភីលីព ៣:១០)។

១. ត្រូវស្គាល់ឫទ្ធានុភាពដែលបានប្រោសព្រះអង្គអោយមានព្រះជន្មរស់ឡើងវិញ។
២. ត្រូវចូលរួមជាមួយព្រះអង្គដែលរងទុក្ខលំបាក។
៣. ត្រូវអោយបានដូចព្រះអង្គដែលសោយទិវង្គត។

ព្រះអំណោយទានព័ន្ធកិច្ចដែលបានប្រទានមកនេះ ក៏ដើម្បីនឹងនាំព្រះកាយទាំងមូលចូលទៅក្នុងចំណេះដឹងតែមួយយ៉ាងសំខាន់មួយនេះ។

## មនុស្សពេញវ័យ

នៅក្នុងគម្ពីរបកប្រែចាស់ បានចែងថា៖ "មនុស្សគ្រប់ល័ក្ខណ៍" (គម្ពីរអេភេសូ ៤:១៣)។ ពាក្យថា*គ្រប់ល័ក្ខណ៍* មានន័យថា " ពេញលេញ" ។ បទគម្ពីរគឺជាឧបករណ៍ដែលត្រូវបានប្រើប្រាស់ដោយអស់អ្នកដែលជាព្រះអំណោយទានរបស់ក្រុមជំនុំ។ គំរូប្លង់សម្រាប់នាំផ្លូវពួកគេនៅក្នុងកិច្ចការដែលគេធ្វើគឺ "កំពស់របស់ព្រះគ្រិស្តដែលបំពេញអ្វីៗទាំងអស់" (គម្ពីរអេភេសូ៤:១៣)។ គំរូប្លង់មានន័យថា "ផែនការដែលដឹកនាំ

អ្នកសាងសង់” ។ មានទំនាក់ទំនងមួយយ៉ាងសំខាន់រវាង គោលបំណងដ៏ខ្ពង់ខ្ពស់ ក្នុងការអភិវឌ្ឍមនុស្សពេញវ័យ និង គោលបំណងដ៏ខ្ពង់ខ្ពស់របស់ព្រះជាម្ចាស់សម្រាប់ក្រុមជំនុំ។ គោលបំណងនោះគឺថា ទ្រង់អាចមានបុត្រជាច្រើនទៀត ដែលមានសណ្ឋានដូចជាព្រះបុត្រារបស់ទ្រង់។ (សូមមើលគម្ពីរ រ៉ូម ៨:២៨-៣០)

នៅពេលដែលព្រះអំណោយទាននៃព័ន្ធកិច្ច ដំណើរការតាមមុខងាររបស់វា ហើយអ្នកជឿបានពេញវ័យ នោះសមាជិកថ្មីនឹងកើតមានបន្ថែមទៀតនៅក្នុងព្រះកាយ។ ព្រះកាយដែលមានសុខភាពល្អ និងពេញវ័យ អាចបង្កបង្កើតខ្លួនបាន។

## ការបកស្រាយពីការអភិវឌ្ឍ

**វត្ថុបំណងទី៤.** *ទទួលអារម្មណ៍ដឹងថា តើព្រះអម្ចាស់កំពុងធ្វើការនៅក្នុងជីវិតរបស់អ្នកដើម្បីអភិវឌ្ឍព័ន្ធកិច្ច ឬក៏អត់។*

លក្ខខ័ណ្ឌ សម្រាប់ការអភិវឌ្ឍអ្នកគង្វាលព្រមទាំងអ្នកបង្រៀនគឺប្រហាក់ប្រហែលលក្ខខ័ណ្ឌសម្រាប់ការអភិវឌ្ឍអ្នកផ្សាយដំណឹងល្អដែរ។ សូមរំឭកមេរៀនរបស់យើងដែលទាក់ទងនឹងការអភិវឌ្ឍព្រះអំណោយទាននៃព័ន្ធកិច្ច។

### *លំហាត់អនុវត្តន៍*

១០ ចូររៀបរាប់ដោយប្រើពាក្យរបស់អ្នកផ្ទាល់ ពីរបៀបដែលយើងអាចទទួលអារម្មណ៍ដឹងថាអ្នកដែលបានប្រទានព្រះអំណោយទាននេះ ទ្រង់ធ្វើការនៅក្នុងជីវិតជាអ្នកជឿរបស់អ្នក។

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

# ការប្រឡងផ្ទាល់ខ្លួន

សំណួរពហុជម្រើស។ ជម្រើសចម្លើយត្រឹមត្រូវសម្រាប់សំណួរនីមួយៗ។ ចូរគូសរង្វង់ជុំវិញអក្សរនៅមុខចម្លើយទាំងឡាយណាដែលត្រឹមត្រូវ។

១ ព្រះអំណោយទាននៃព័ន្ធកិច្ចមានដូចជា

ក) អ្នកគង្វាលព្រមទាំងអ្នកបង្រៀន

ខ) ការរួបរួមខាងឯវិញ្ញាណ

គ) អប៉ូឡូស

ឃ) អ្នកផ្សាយដំណឹងល្អ

ង) សាវ័ក

ច) សេចក្តីស្រឡាញ់

ឆ) ព្យាការី

២ នៅក្នុងមេរៀនរបស់យើង យើងបានឃើញថា អ្នកដែលបានប្រទានព្រះអំណោយទាននៃព័ន្ធកិច្ចគឺត្រូវបានគេស្គាល់ដោយនាមជាច្រើន ដែលអាចនឹងជួយយើងឲ្យយល់កាន់តែច្បាស់អំពីទ្រង់។ ចូរគូសរង្វង់ជុំវិញនាមណាដែលមិនប្រើសម្រាប់ទ្រង់។

ក) ព្រះសិរសា

ខ) ព្រះវិញ្ញាណដ៏វិសុទ្ធ

គ) ព្រះកាយ

ឃ) ព្រះជាម្ចាស់

៣ មុខងារគោលរបស់ព្រះអំណោយទាននៃព័ន្ធកិច្ចគឺការកសាង

ក) អ្នកគង្វាលនៃក្រុមជំនុំ

ខ) សមាជិកម្នាក់ៗនៅក្នុងក្រុមជំនុំ

គ) ក្រុមជំនុំជាព្រះកាយ

៤ យើងបានឃើញថា ព្រះអំណោយទាននៃព័ន្ធកិច្ចអាចអភិវឌ្ឍបានតាមរយៈ

ក) ការអធិស្ឋាន

ខ) ការសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់

គ) រៀនស្តាប់ និង ធ្វើតាមព្រះសូរសៀងរបស់ព្រះជាម្ចាស់

ឃ) ប្រើប្រាស់ព្រះអំណោយទាននោះ

៥ សរសេរដោយការចងចាំនៅ គម្ពីរ១កូរិនថូស ១៣:៥-៦។

..........................................................................................................................

..........................................................................................................................

# ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១ ខ) គ្រប់គ្រង

ឃ) ដឹង

ង) ផ្គត់ផ្គង់

៦ ក) និង ឃ) ជាចម្លើយត្រឹមត្រូវ

២ ខ) ព្រះសិរសា

៧ ទ្រង់សព្វព្រះទ័យចង់បានអ្នកជឿណាម្នាក់ដែលស្រឡាញ់ និង ថែទាំប្រជារាស្ត្ររបស់ព្រះអង្គ។

៣ ក) ពេញដោយជំនឿ និង ឫទ្ធានុភាព

គ) ស្មោះត្រង់នៅក្នុងក្រុមជំនុំ

ឃ) ប្រកបដោយព្រះវិញ្ញាណដ៏វិសុទ្ធ និង ប្រាជ្ញា

៨ អ្នកគង្វាលស្រឡាញ់ និងថែទាំចៀមរបស់ពួកគេ

៤ ខ) ជាចម្លើយត្រឹមត្រូវ

៩ ក) ស្រឡាញ់ និង ថែទាំមនុស្សរបស់ពួកគេ។

ខ) ផ្តល់អាហារដូចជាទឹកដោះ និង អាហាររឹងនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ សម្រាប់មនុស្សរបស់ពួកគេ។

៥ ក) ការសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់

ខ) ការរៀនស្តាប់ព្រះសូរសៀងរបស់ព្រះជាម្ចាស់

គ) ការផ្សព្វផ្សាយដំណឹងល្អ។

១០ ចម្លើយរបស់អ្នកផ្ទាល់

មេរៀនទី ៥

# អំណោយទាននៃការបម្រើ ការបង្រៀន និង ការទូន្មាន

យើងបានបញ្ចប់ការសិក្សារបស់យើងអំពីអំណោយទាយទាំងបួន ដែលយើងហៅថាព្រះអំណោយទាននៃព័ន្ធកិច្ចនោះហើយ។ ដោយគម្ពីរអេភេសូជំពូក៤ រាប់ឃើញព្រះអំណោយទាន៥យ៉ាង នោះដោយសារតែយើងបានចាត់ទុកអ្នកគង្វាល និង អ្នកបង្រៀនថាជាព្រះអំណោយទានតែមួយ។

នៅក្នុងមេរៀនមុននេះ យើងបានសិក្សាអំពីអ្នកផ្សាយដំណឹងល្អ និង អ្នកគង្វាលព្រមទាំងអ្នកបង្រៀន។ យើងបានដឹងថា ស្របពេលដែលអ្នកជឿគ្រប់រូបត្រូវតែធ្វើការផ្សាយដំណឹងល្អ មានសមាជិកមួយចំនួនប៉ុណ្ណោះដែលទទួលការត្រាស់ហៅជាពិសេសឲ្យធ្វើជាអ្នកផ្សាយដំណឹងល្អ។ យើងក៏បានឃើញថា មានអ្នកជឿដែលក្លាយជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀនច្រើនជាងព្រះអំណោយទានបីផ្សេងទៀត។ មានការយកចិត្តទុកដាក់ជាពិសេស ទៅលើការសិក្សាអំពីគោលបំណងដែលព្រះគ្រិស្ត នៅពេលដែលទ្រង់ប្រទានព្រះអំណោយទាននៃព័ន្ធកិច្ចមកឲ្យយើង។

ពេលនេះយើងបានត្រៀមជាស្រេចក្នុងការសិក្សាក្រុមមួយទៀតនៃព្រះអំណោយទានខាងវិញ្ញាណ គឺ ព្រះអំណោយទានព័ន្ធកិច្ច*ដទៃផ្សេងទៀត*។ ស្របពេលដែលមានមនុស្សជាច្រើនជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀន ក៏មានសមាជិកជាច្រើនទៀតនៃព្រះកាយរបស់ព្រះគ្រិស្ត ដែលមិនបានទទួលព្រះអំណោយទានសម្រាប់តំណែងនោះ ឬ សម្រាប់តំណែងផ្សេងទៀតយើងបានរៀបរាប់ពីមុនមកហើយនោះទេ។ តែនោះមិនមែនមានន័យថា ពួកគេមិនមានព្រះអំណោយទានខាងវិញ្ញាណនោះឡើយ។ នៅក្នុងមេរៀននេះ យើងនឹងរៀនអំពីព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេងទៀត និង ឃើញថាអ្នកជឿជាច្រើនអាចទទួលបានវា។

អ្នកប្រហែលជាគ្មានអារម្មណ៍ដឹងពីការដឹកនាំពិសេសរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ នៅក្នុងទំនាក់ទំនងជាមួយនឹងព្រះអំណោយទាននៃព័ន្ធកិច្ចនោះទេ។ ប្រសិនមិនមានទេ អ្នកអាចនឹងស្គាល់ពីព្រះអំណោយទានរបស់ព្រះជាម្ចាស់បានប្រទានមកឲ្យអ្នកបាន មុនពេលដែលអ្នកបញ្ចប់មេរៀននេះទៅទៀត។ ចូរអធិស្ឋាននៅពេលដែលអ្នករៀនមេរៀននេះ ដើម្បីឲ្យព្រះជាម្ចាស់នឹងដឹកនាំអ្នក។

## គម្រោងនៃមេរៀន

ក. ព្រះអំណោយទាននៃការបម្រើ
ខ. ព្រះអំណោយទាននៃការបង្រៀន
គ. ព្រះអំណោយទាននៃការទូន្មាន

## វត្ថុបំណងនៃមេរៀន

នៅពេលអ្នកបានបញ្ចប់មេរៀននេះ អ្នកអាចនឹងៈ

១. រៀបរាប់អំពីព្រះអំណោយទាននៃការបម្រើ និង ធ្វើការស្រង់ប្រភេទខ្លះនៃកិច្ចការដែលមានរួមបញ្ចូលនៅក្នុងព្រះអំណោយទានមួយនេះ។
២. បកស្រាយពីភាពខុសគ្នារវាងព្រះអំណោយទាននៃការបង្រៀន និង ព្រះអំណោយទាននៃអ្នកគង្វាលព្រមទាំងអ្នកបង្រៀន។
៣. រៀបរាប់អំពីព្រះអំណោយទាននៃការទូន្មាន។

## សកម្មភាពក្នុងការសិក្សា

១. អានគម្ពីរកិច្ចការជំពូក១ ដល់៦ ។ នៅពេលដែលអ្នកអានតាមជំពូកនីមួយៗ ចូរធ្វើការកត់ត្រាប្រភេទខុសគ្នានៃព័ន្ធកិច្ចដែលបានឃើញ ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។ ជាឧទាហរណ៍ នៅក្នុងជំពូកទី៤ អ្នកនឹងឃើញមានព័ន្ធកិច្ចនៃការចែកទាន។ សូមមើលនៅខទី៣៤ ដល់ ៣៧។
២. ទន្ទេញ គម្ពីរ១កូរិនថូសជំពូក១៣ បន្តទៀត។ សូមសរសេរខទី ១ដល់ ៧ តាមការចងចាំ ដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក។ នៅពេលដែលអ្នកបញ្ចប់មេរៀននេះ យើងអាចនឹងដកស្រង់៨ ខដំបូងបាន។
៣. សូមអានមេរៀននេះដោយប្រុងប្រយ័ត្ន។ គូសបន្ទាត់នៅពីក្រោមចំណុចណាដែលអ្នកចង់ចងចាំ។
៤. សិក្សានិយមន័យពាក្យសំខាន់ដែលអ្នកមិនយល់ច្បាស់ ដោយមើលវានៅក្នុងអក្ខរានុក្រម។
៥. ធ្វើលំហាត់សិក្សាទាំងអស់ដែលអ្នកបានជួប។ ត្រឡប់ទៅមើលមេរៀន ដើម្បីរកចម្លើយត្រឹមត្រូវសម្រាប់សំណួរណាដែលអ្នកឆ្លើយមិនបានត្រឹមត្រូវ។
៦. ធ្វើការប្រឡងផ្ទាល់ខ្លួនដែលមាននៅចុងបញ្ចប់នៃមេរៀន ហើយពិនិត្យមើលចម្លើយរបស់អ្នកដោយប្រុងប្រយ័ត្ន។ រំឭកចំណុចណាដែលអ្នកឆ្លើយមិនបានត្រឹមត្រូវ។

## ពាក្យសំខាន់

| | | |
|---|---|---|
| សហាគមន៍ | ត្រួតលើ | បកប្រែ |
| ទំនុកចិត្ត | | |

# ក. ព្រះអំណោយទាននៃការបម្រើ

**វត្ថុបំណងទី១.** *រៀបរាប់អំពីព្រះអំណោយទាននៃការបម្រើ និង ធ្វើការស្រង់ប្រភេទខ្លះនៃកិច្ចការដែលមានរួមបញ្ចូលនៅក្នុងព្រះអំណោយទានមួយនេះ។*

មានការបកស្រាយខ្លះ មានភាពចាំបាច់ណាស់ នៅពេលដែលយើងរៀបចំចូលទៅក្នុងមេរៀននេះដែលវាផ្ដែកលើព្រះអំណោយទាន រៀបរាប់នៅក្នុងគម្ពីររ៉ូមជំពូក១២ ។ វាពិតជាមានការពិបាកណាស់ដើម្បីធ្វើការចែកក្រុម ព្រះអំណោយទានខាងឯវិញ្ញាណឲ្យបានច្បាស់។ ដូច្នេះ នៅពេលដែលយើងរៀនពីមេរៀនមួយ ទៅមេរៀនមួយ យើងនឹងសង្កេតឃើញមានចំណុចត្រួតគ្នាខ្លះៗ។ យើងមិនគួរបារម្ភពីការនេះឡើយដ្បិតព្រះអំណោយទានទាំងអស់នេះគឺមកពីប្រភពតែមួយ។

ការរៀបរាប់ព្រះអំណោយទាននេះចាប់ផ្ដើមដោយការថ្លែងព្រះបន្ទូលជាមុខសិន។ ដោយសារតែការការថ្លែងព្រះបន្ទូល មានរៀបរាប់នៅក្នុងចំណោមព្រះអំណោយទានរបស់ព្រះវិញ្ញាណ យើងនឹងមិនផ្ដោតសំខាន់លើវានៅក្នុងជំពូកមួយនេះឡើយ។ នៅជិតចុងបញ្ចប់គម្ពីរ១កូរិនថូសជំពូក១២ គឺមានការរៀបរាប់អំពីព្រះអំណោយទានខាងឯវិញ្ញាណ។ នៅក្នុងការរៀបរាប់នេះ គឺមានព្រះអំណោយទានខាងឯវិញ្ញាណទាំងបីក្រុមតែម្ដង។

## ការកំណត់និយមន័យពីព្រះអំណោយទាន

"អ្នកណាទទួលព្រះអំណោយទានខាងបំរើ ចូរបំរើទៅ" (គម្ពីររ៉ូម១២:៧)

នៅក្នុងព្រះគម្ពីរបកប្រែចាស់ ពាក្យថាបម្រើគឺ "ជួយផ្គត់ផ្គង់" និង "ការជួយផ្គត់ផ្គង់"។ នៅក្នុងខគម្ពីរខាងក្រោមនេះ ពាក្យទាំងពីរនេះអាចប្រើប្រាស់ជំនួសគ្នាទៅវិញទៅមកបាន ជាមួយនឹងពាក្យ "បម្រើ" និង "ការបម្រើ"។ ពាក្យថាការជួយផ្គត់ផ្គង់ត្រូវបានប្រើជាច្រើនដងនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មីភាសាក្រិក។ វាត្រូវបានគេប្រើជាលើកដំបូងនៅក្នុងគម្ពីររ៉ូម ១២:៧។ វាក៏ត្រូវបានគេឃើញនៅក្នុងគម្ពីរ២កូរិនថូស ៨:៤ ៖ " ពួកគេបានទទូចសុំយើងមេត្តាអនុញ្ញាត អោយគេចូលរួមបំរើការងារនេះ គឺផ្ញើប្រាក់ទៅជួយប្រជាជនដ៏វិសុទ្ធ។" នៅក្នុងករណីនេះ មនុស្សមួយក្រុមដែលមកពីក្រុមជំនុំនៅស្រុកម៉ាសេដូន ចង់ឲ្យលោកប៉ូល និងអស់អ្នកដែលធ្វើការជាមួយលោក បានសហការជាមួយពួកគេដើម្បីផ្គត់ផ្គង់ តម្រូវការរបស់អ្នកជឿ ដែលកំពុងមានទុក្ខ។

កន្លែងមួយទៀតដែលពាក្យថា *ជួយផ្គត់ផ្គង់* ត្រូវបានគេប្រើ គឺនៅក្នុងគម្ពីរ២កូរិនថូស ៩:១ " ចំពោះរឿងផ្ញើជំនួយទៅជូនប្រជាជនដ៏វិសុទ្ធនោះ មិនបាច់អោយខ្ញុំសរសេរជំរាបបងប្អូនទេ" ។ គោលគំនិតមួយនេះក៏ដូចគ្នានឹង គម្ពីរ២កូរិនថូស ៨:៤ដែរ។ ដូច្នេះ យើងសន្និដ្ឋានថាព្រះអំណោយទាននៃការបម្រើ ជាទូទៅគឺមានទាក់ទងនឹងការបំពេញតម្រូវការរបស់អ្នកដទៃ។ វាអាចត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ។ នៅក្នុងន័យមួយ ព្រះអំណោយទាននៃការបម្រើ បានបង្គ្រប់ន័យ ព្រះអំណោយទានខាងឯវិញ្ញាណទាំងអស់។ នេះក៏ដោយសារតែព្រះអំណោយទានទាំងអស់ ដែលបានប្រទានមកគឺដើម្បីជួយយើងឲ្យបម្រើអ្នកដទៃ។ នៅក្នុងមេរៀននេះ យើងនឹងនិយាយអំពីព្រះអំណោយទានសំខាន់ដែលវាទាក់ទងនឹងការបំពេញតម្រូវការខាងសាច់ឈាមរបស់អ្នកដទៃ។

## លំហាត់អនុវត្តន៍

១ ពាក្យដែលបកស្រាយអត្ថន័យរបស់ពាក្យថា ជួយផ្គត់ផ្គង់ បានល្អបំផុតគឺ

........................................................................................................................................

# ការបកស្រាយ និង អធិប្បាយពីព្រះអំណោយទាននេះ

យើងអាចឃើញរឿងរបស់នាងឌ័រកាស នៅក្នុងគម្ពីរកិច្ចការ ៩:៣៦-៤១។ នាងមានព្រះអំណោយទាននៃការបម្រើ។ នាង "តែងប្រព្រឹត្តអំពើល្អ និងធ្វើទានជាច្រើន" (គម្ពីរកិច្ចការ ៩:៣៦) ។ តើនាងបានធ្វើរឿងអ្វីខ្លះ? នាងបានដេរសំលៀកបំពាក់ឲ្យស្រ្តីមេម៉ាយក្រីក្រ។ នៅពេលដែលនាងបានស្លាប់ភ្លាមៗ លោកពេត្រុសបានទៅដល់ផ្ទះនាង៖ "ស្ត្រីមេម៉ាយទាំងប៉ុន្មានបាននាំគ្នាចូលមកជិតលោក ទាំងយំសោក និងបង្ហាញអាវវែង អាវក្រៅដែលនាងឌ័រកាសបានដេរ កាលនាងរស់នៅជាមួយគេនៅឡើយ។" (គម្ពីរកិច្ចការ ៩:៣៩)។

នៅមានស្ត្រីមេម៉ាយ និង កុមារកំព្រាជាច្រើននាក់នៅក្នុងពិភពលោកនេះ។ មានមនុស្សក្រីក្រជាច្រើននាក់ដែលនៅជុំវិញខ្លួនយើង។ យើងអាចឃើញពួកគេស្ទើរតែនៅក្នុងគ្រប់សហគមន៍ទាំងអស់។ វាពិតជាអស្ចារ្យខ្លាំងណាស់ ដែលមនុស្សរបស់ព្រះជាម្ចាស់ខ្លះ គេមានព្រះអំណោយទាននៃការបម្រើដូចជានាងឌ័រកាសដែរ!

វាប្រហែលមកពីនាងឌ័រកាស មានទេពកោសល្យពីធម្មជាតិក្នុងការកាត់ដេរ សំលៀកបំពាក់។ ព្រះជាម្ចាស់ បានប្រទានឲ្យនាងនូវ ទេពកោសល្យ និង ការខ្វល់ខ្វាយពីមនុស្សក្រីក្រ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធរបស់ទ្រង់។ ឯលទ្ធផលដែលទទួលបាននោះគឺព្រះអំណោយទាននៃការបម្រើ។ បើគ្រាន់តែមានទេពកោសល្យគឺមិនគ្រប់គ្រាន់នោះទេ។ នៅពេលដែលព្រះជាម្ចាស់ អាចយកបានទេពកោសល្យរបស់យើង តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធហើយ ទ្រង់មានមធ្យោបាយដ៏អស្ចារ្យដើម្បីធ្វើឲ្យវាក្លាយទៅជាអំណោយទាននៃការបម្រើបាន។

យើងបានសិក្សាអំពីលោកស្ទេផាន និង លោកភីលីពរួចមកហើយ។ លោកទាំងពីរបានក្លាយជាអ្នកផ្សាយដំណឹងល្អ។ ប៉ុន្តែមុនពេលដែលព្រះអំណោយទាននៃការផ្សាយដំណឹងបានកើតមាននៅក្នុងពួកគាត់ ពួកគាត់ធ្លាប់មានព្រះអំណោយទាននៃការបម្រើរួចមកហើយ។ យើងបានឃើញហើយថា ពួកគាត់ត្រូវបានជ្រើសរើសឲ្យចាត់ចែងប្រាក់កាសរបស់ក្រុមជំនុំ។ ពួកលោកទាំងពីរនាក់ប្រហែលជាមានទេពកោសល្យសម្រាប់ការចាត់ចែងប្រាក់កាសរួចមកហើយ ប៉ុន្តែនេះមិនមែនជាព្រះអំណោយទាននៃការបម្រើបានឡើយ រហូតដល់ពេលដែលមានព្រះវិញ្ញាណដ៏វិសុទ្ធរួមផ្សំជាមួយ ដែលនៅពេលនោះពួកគាត់បានចាប់ផ្តើមជួយផ្គត់ផ្គង់តម្រូវការរបស់ស្ត្រីមេម៉ាយនៅក្នុងក្រុមជំនុំ។

ស្ទើរតែគ្រប់ទេពកោសល្យពីធម្មជាតិទាំងអស់ អាចក្លាយជាព្រះអំណោយទាននៃការបម្រើបាន។ ការនេះអាចកើតមានឡើងនៅពេល មនុស្សដែលមានទេពកោសល្យនោះ មានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ ជាឧទាហរណ៍ សូមគិតអំពីមនុស្សដែលមានទេពកោសល្យក្នុងការច្រៀង។ ការច្រៀងគឺមិនមែនជា

ព្រះអំណោយទាននៃការបម្រើនោះទេ។ វាគឺជាទេពកោសល្យ។ ប៉ុន្តែ នៅពេលមនុស្សដែលមានទេពកោសល្យមានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ទេពកោសល្យរបស់គាត់អាចក្លាយជាព្រះអំណោយទាននៃការបម្រើបាន។

តើអ្នកមានទេពកោសល្យដែរឬទេ ? ចូរថ្វាយវាទៅព្រះអម្ចាស់ ហើយទ្រង់អាចប្រើប្រាស់វា ជាព្រះអំណោយទាន ដែលមនុស្សជាច្រើនអាចទទួលបានព្រះពរតាមរយៈអ្នកបាន។

***លំហាត់អនុវត្តន៍***

២ ភាពខុសគ្នារវាងទេពកោសល្យ និង ព្រះអំណោយទាននៃការបម្រើគឺថា

ក) អ្នកកើតមកជាមួយនឹងព្រះអំណោយទានស្រាប់ មិនជាមួយនឹងទេពកោសល្យឡើយ។

ខ) គ្រប់គ្នាមានទេពកោសល្យ ប៉ុន្តែព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការតាមរយៈ អ្នកណាម្នាក់ដែលមានព្រះអំណោយទាននៃការបម្រើ។

គ) ទេពកោសល្យអាចទិញដោយលុយបាន តែមិនមែនព្រះអំណោយទាននោះទេ។

## គោលបំណងនៃព្រះអំណោយទាននេះ

ព្រះអំណោយទាននៃការបម្រើត្រូវបានប្រទានមកដើម្បីបំពេញតម្រូវការរបស់មនុស្សទាំងនៅក្នុង និងនៅក្រៅព្រះកាយរបស់ព្រះគ្រិស្ត។ មធ្យោបាយមួយដ៏មានប្រសិទ្ធិភាពក្នុងការនាំមនុស្សចូលមកឯព្រះគ្រិស្ត គឺត្រូវបានធ្វើតាមរយៈការជួយផ្គត់ផ្គង់តម្រូវការរបស់គេជាមុនសិន។

នៅក្នុងគម្ពីរយ៉ូហានជំពូក ៩ បានប្រាប់យើងថា ព្រះគ្រិស្តបានប្រោសបុរសខ្វាក់ឲ្យភ្លឺភ្នែក។ បុរសខ្វាក់ភ្នែកនោះ មានតម្រូវការមួយធំណាស់ ហើយព្រះយេស៊ូបានជួយបំពេញ។ បន្ទាប់មកព្រះយេស៊ូទទួលបានការទុកចិត្តពីគាត់ ហើយមានព្រះបន្ទូលថា "តើអ្នកជឿលើបុត្រមនុស្ស*ឬទេ?។ គាត់ទូលព្រះអង្គថា៖ «លោកម្ចាស់អើយ តើនរណាជាបុត្រមនុស្ស សូមប្រាប់ខ្ញុំអោយដឹងផង ដើម្បីអោយខ្ញុំជឿលើព្រះអង្គ" ។ អ្វីដែលព្រះយេស៊ូបានធ្វើសម្រាប់បុរសនោះដោយបានបំពេញតម្រូវការខាងរូបកាយរបស់គាត់ វាបានធ្វើឲ្យគាត់បានជឿ។

នៅពេលដែលយើងជួយបំពេញតម្រូវការរបស់អ្នកដទៃ តម្រូវរបស់ពួកគេត្រូវបានបំពេញ ហើយកិច្ចការរបស់ព្រះជាម្ចាស់ចម្រើនឡើងដោយសារការនោះដែរ។

***លំហាត់អនុវត្តន៍***

៣ មធ្យោបាយមួយដើម្បីនាំដំណឹងល្អចូលទៅក្នុងដួងចិត្តមនុស្សគឺ

.............................................................................................................................

# ខ. ព្រះអំណោយទាននៃការបង្រៀន

**វត្ថុបំណងទី២.** *បកស្រាយភាពខុសគ្នារវាងព្រះអំណោយទាននៃការបង្រៀន និង ព្រះអំណោយទានជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀន។*

## ការកំណត់និយមន័យពីព្រះអំណោយទាននេះ

"អ្នកណាទទួលព្រះអំណោយទានខាងបង្រៀន ចូរបង្រៀនទៅ" (គម្ពីររ៉ូម១២:៧)

ការបង្រៀនដែលប្រើនៅត្រង់នេះគឺមានន័យថា "ការបង្ហាញពីរបៀបធ្វើអ្វីមួយ៖ បង្វឹក, ការអប់រំ"។ ដូច្នេះ យើងដឹងថាព្រះអំណោយទាននៃការបង្រៀនរួមមាន៖ (១) ការបង្ហាញអ្នកដទៃពីរបៀបធ្វើអ្វីមួយ (២) បង្វឹកអ្នកដទៃពីរបៀបធ្វើអ្វីមួយ និង (៣) អប់រំអ្នកដទៃ រួមទាំងការផ្តល់ចំណេះដឹងផងដែរ។

ភាពខុសគ្នារវាងព្រះអំណោយទានជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀន និង ព្រះអំណោយទាននៃការបង្រៀន គឺថាអ្នកគង្វាលព្រមទាំងអ្នកបង្រៀនមានទាក់ទងនឹងការដឹកនាំនៅក្នុងព័ន្ធកិច្ច។ ចំណែកឯព្រះអំណោយទាននៃការបង្រៀន គឺមិនកំណត់នៅលើអ្នកដឹកនាំក្រុមជំនុំណាម្នាក់ឡើយ។ សមាជិកណាក៏ដោយដែលនៅក្នុងព្រះកាយរបស់ព្រះគ្រិស្តគឺអាចមានព្រះអំណោយទាននៃការបង្រៀន។ ខ្លះទៀតអាចជាទេពកោសល្យក្នុងការបង្រៀន។ នៅពេលមនុស្សដែលមានទេពកោសល្យនេះ បានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ពួកគេនឹងអាចរកឃើញថាព្រះអំណោយទានរបស់ពួកគេបានក្លាយជាព្រះអំណោយទាននៃការបង្រៀន។

តើនេះមានន័យថា ស្ត្រីក៏អាចបង្រៀនបានដែរមែនឬទេ? ពិតមែនហើយ។ អ្នកខ្លះក៏មានសំណួរនៅពេលដែលគេបានអានគម្ពីរ១ធីម៉ូថេ ២:១១-១២។ ប៉ុន្តែលោកប៉ូលមិនបានមានប្រសាសន៍ថា ស្ត្រីមិនអាចមានព្រះអំណោយទាននៃការបង្រៀននោះឡើយ។ នៅក្នុងសំបុត្រមួយដែលសរសេរទៅកាន់លោកទីតុស លោកមានប្រសាសន៍ថា "រីឯលោកយាយចាស់ៗវិញ ក៏ដូច្នោះដែរ ....គាត់ត្រូវចេះផ្តល់យោបល់ល្អៗ" (គម្ពីរទីតុស ២:៣) ។ សំដីរបស់លោកប៉ូល គឺផ្អែកលើគោលការណ៍ដែល ស្ត្រីមិនត្រូវមានអំណាចចាត់ចែងលើបុរសនៅក្នុងក្រុមជំនុំនោះឡើយ។ នៅក្នុងស្ថានភាពខ្លះ ប្រសិនបើ មិនអនុញ្ញាតឲ្យស្ត្រីបង្រៀនដោយសារតែមូលហេតុនេះ មិនគួរដាក់ទំនួលខុសត្រូវទាំងនេះទៅលើពួកគេ វាល្អជាជាង។ ស្ត្រីម្នាក់ធ្វើការបង្រៀនគឺមិនខុសនោះទេ ប៉ុន្តែនៅពេលដែលមានបញ្ហា មិនគួរចោទប្រកាន់នរណាម្នាក់ឡើយ។ ប្រសិនបើស្ត្រីណាម្នាក់មានព្រះអំណោយទាននៃការបង្រៀន នោះគាត់នឹងស្វែងរកការនាំផ្លូវពីព្រះអម្ចាស់ និងអនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធអភិវឌ្ឍព្រះអំណោយទានរបស់គាត់ឲ្យបានត្រឹមត្រូវ។

## *លំហាត់អនុវត្តន៍*

៤ ការបង្រៀនមានន័យថា

ក) ការណែនាំ

ខ) ការចែករំលែកចំណេះដឹង

គ) ការធ្វើខ្លួនជាគំរូ

ឃ) ការបង្ខឹក

៥ ព្រះអំណោយទាននៃការបង្រៀនក៏អាចប្រទានទៅឲ្យស្ត្រីបានដែរ ប្រសិនបើគាត់

ក) ទាមទារចង់បានវា ព្រោះតែនាងមានទេពកោសល្យ។

ខ) អនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធអភិវឌ្ឍវាឲ្យបានត្រឹមត្រូវ។

# ការបកស្រាយ និង អធិប្បាយពីព្រះអំណោយទាននេះ

ការបង្រៀនអាចធ្វើទៅបាន ដោយប្រើប្រាស់មធ្យោបាយជាច្រើន។ យើងនឹងលើកយកមធ្យោបាយពីរយ៉ាងសំខាន់ជាងគេ មកពិចារណានៅត្រង់ចំណុចនេះ។

## ការបង្រៀនអាចធ្វើបានដោយ គំរូ

លោកប៉ុលបានសរសេរសំបុត្រទៅកាន់អ្នកគង្វាលព្រមទាំងអ្នកបង្រៀន លោកទីតុស អំពីការនេះនៅក្នុងគម្ពីរទីតុស២:៣-៥។ ផ្នែកមួយនៃការងាររបស់លោកទីតុស គឺជាការបង្រៀន។ លោកបានបង្រៀនស្ត្រីចាស់ៗ អំពីរបៀបបង្រៀនស្ត្រីវ័យក្មេង។ លោកត្រូវធ្វើការនេះដោយបង្ហាញស្ត្រីចាស់ៗពីរបៀបធ្វើជាគំរូល្អសម្រាប់ស្ត្រីវ័យក្មេង។ ខាងក្រោមនេះគឺជាការរៀបរាប់ អំពីអ្វីដែលលោកបានប្រាប់ទៅស្ត្រីចាស់ៗ ឲ្យធ្វើ៖

- ពួកគាត់ត្រូវកាន់កិរិយាមារយាទ សមជាអ្នកដែលមានជីវិតដ៏វិសុទ្ធ។
- ពួកគាត់មិនត្រូវ និយាយមួលបង្កាច់គេ (នោះមានន័យថា ពួកគាត់មិនត្រូវនិយាយកុហក ដែលអាចធ្វើឲ្យអ្នកដទៃឈឺចាប់នោះឡើយ)។
- ពួកគាត់មិនត្រូវជាអ្នកចំណូលស្រា។
- ពួកគាត់ត្រូវចេះស្រឡាញ់ស្វាមីរបស់ពួកគាត់។
- ពួកគាត់ត្រូវមានចិត្តធ្ងន់ និង មានចរិយាបរិសុទ្ធ។
- ពួកគាត់ត្រូវជាមេផ្ទះដ៏ល្អ។
- ពួកគាត់ត្រូវគោរពចុះចូលនឹងស្វាមីរបស់ពួកគាត់។
- ពួកគាត់មិនត្រូវមួលបង្កាច់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។

ស្ត្រីចាស់ៗអាចបង្រៀនបានដោយការនិយាយប្រាប់ស្ត្រីវ័យក្មេង។ ពួកគាត់អាចធ្វើបែបនេះក៏បាន ប៉ុន្តែពួកគាត់អាចបង្រៀនបានកាន់តែល្អប្រសើរតាមរយៈគំរូរបស់ពួកគាត់។ ការនេះអាចឲ្យទៅអនុវត្តនៅក្នុងគ្រប់វប្បធម៌។ ការបង្រៀនដោយធ្វើជាគំរូគឺជាការបង្ហាញអ្នកដទៃពីរបៀបធ្វើអ្វីម្យ៉ាង។ សម្រាប់មនុស្សដែលមានពេញដោយព្រះវិញ្ញាណ នេះអាចជាព្រះអំណោយទាននៃការបង្រៀនរបស់ពួកគាត់។

## ការបង្រៀនអាចធ្វើបាន តាមរយៈការចែករំលែកចំណេះដឹង

ព្រះយេស៊ូតែងតែធ្វើបែបនេះ។ "សេចក្តីបង្រៀនរបស់ទ្រង់នៅលើភ្នំ" នៅក្នុងគម្ពីរម៉ាថាយជំពូក៥ បានចែងថា៖ "សិស្ស*នាំគ្នាចូលមកគាល់ព្រះអង្គ ព្រះអង្គក៏មានព្រះបន្ទូលបង្រៀនគេ" (ខ១ ដល់ ខ២)។ នៅក្នុងសេចក្តីបង្រៀនរបស់ទ្រង់ ទ្រង់បានប្រទានចំណេះដឹងអំពីរបៀបរស់នៅដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់ ទៅកាន់ពួកគេ។ យើងបានឃើញតាំងពីដើមដំបូងនៃមុខវិជ្ជានេះហើយ ថាចំណេះដឹងមានសារៈសំខាន់យ៉ាងណា។ យើងបានដឹងថាវា ជាគ្រឹះសម្រាប់ជំនឿ។ អ្នកដែលចែករំលែកចំណេះដឹងតាមរយៈការបង្រៀន បានធ្វើឲ្យជំនឿអាចកើតមានឡើងបាន។ នេះគឺជាមុខងារដ៏សំខាន់មួយរបស់ព្រះអំណោយទាននៃការបង្រៀន។

ចំណេះដឹងដែលអ្នកបង្រៀនផ្តល់ឲ្យ ត្រូវតែជាចំណេះដឹងអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ គ្រូបង្រៀនផ្តល់អត្ថន័យឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះអំណោយទាននៃការបង្រៀនបានធ្វើការ នៅពេលដែលឪពុកម្តាយបង្រៀនកូនៗ របស់ពួកគាត់អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះអំណោយទាននេះបានធ្វើការ នៅពេលគ្រូបង្រៀនថ្នាក់ថ្ងៃអាទិត្យ ឬ គ្រូបង្រៀននៅក្នុងសាលាគម្ពីរ គេបង្រៀននៅក្នុងថ្នាក់របស់ពួកគេ។ ព្រះអំណោយទាននេះធ្វើការ នៅពេលដែលអ្នកជឿបង្រៀនមិត្តរបស់ពួកគេ ឬគ្រូមិត្តរបស់គេអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។

ប្រសិនបើគ្រូបង្រៀននៅសាលារដ្ឋ មានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ យើងមិនត្រូវមើលរំលងឱកាសដែលពួកគាត់ អាចបង្រៀនបាននោះទេ គាត់ក៏អាចមានព្រះអំណោយទាននៃការបង្រៀននេះដែរ

## *លំហាត់អនុវត្តន៍*

---

៦ ចូរសរសេរអក្សរ ត នៅក្នុងចន្លោះបន្ទាត់ដែលនៅពីមុខប្រយោគត្រឹមត្រូវ និង អក្សរ ខ នៅពីមុខប្រយោគមិនត្រឹមត្រូវ។

........ក) ការបង្រៀនអាចធ្វើទៅបាន តាមមធ្យោបាយជាច្រើន។

........ខ) ការបង្រៀនចែករំលែកចំណេះដឹង ដែលបង្កើតបានជាជំនឿ។

........គ) នៅពេលដែលយើងបង្រៀនដោយការបញ្ចេញអាកប្បកិរិយាបែបណា មានន័យថាយើងកំពុងបង្រៀនដោយធ្វើជាគំរូ។

## គោលបំណងនៃព្រះអំណោយទាននេះ

មុខងារនៃការបង្រៀនគឺជាការចែករំលែកចំណេះដឹង។ គោលបំណងរបស់វា គឺធ្វើឲ្យមាន ជំនឿ ការរស់នៅត្រឹមត្រូវ និង ការប្រព្រឹត្ត អាចកើតឡើងបាន។ យើងដឹងហើយថា ជំនឿ ការរស់នៅត្រឹមត្រូវ និង ការប្រព្រឹត្ត វាមានសារៈសំខាន់យ៉ាងណា ចំពោះសមាជិកព្រះកាយរបស់ព្រះគ្រិស្ត។ បើគ្មានចំណុចទាំងនេះទេ ព្រះកាយរបស់ព្រះគ្រិស្តមិនអាចកើតមានបានឡើយ។ ត្រង់នេះ ជួយយើងឲ្យយល់ពីតម្លៃដ៏អស្ចារ្យរបស់ព្រះអំណោយទាននៃការបង្រៀន។

### *លំហាត់អនុវត្តន៍*

---

៧ ព្រះអំណោយទាននៃការបង្រៀនគឺពិតជាមានសារៈសំខាន់ណាស់ ព្រោះ

ក) មនុស្សគ្រប់គ្នាអាចមានវា។

ខ) វាធ្វើឲ្យយើងក្លាយជាគំរូដ៏ល្អ។

គ) វាចាក់គ្រឹះមូលដ្ឋានសម្រាប់ជំនឿ។

---

# គ. ព្រះអំណោយទាននៃការទូន្មាន

**វត្ថុបំណងទី៣.** *រៀបរាប់អំពីព្រះអំណោយទាននៃការទូន្មាន។*

## ការកំណត់និយមន័យពីព្រះអំណោយទាននេះ

*ទូន្មាន* គឺមានន័យថា "ការហៅមកជិត ឬ ការត្រាស់ហៅ"។ នៅពេលដែលនិយមន័យមួយនេះត្រូវបានយកទៅប្រើនៅក្នុង *ព្រះអំណោយទាន* នៃការទូន្មាន វាមានន័យថា ការត្រាស់ហៅអ្នកជឿឲ្យចូលជិតព្រះជាម្ចាស់ ឬ ទៅជិតបំណងព្រះហឫទ័យណាមួយរបស់ព្រះជាម្ចាស់។ វាក៏មានន័យថាការត្រាស់ហៅអ្នកជឿឲ្យធ្វើសកម្មភាពអ្វីមួយផងដែរ។ បន្ទាប់មក អ្នកជឿដែលមានព្រះអំណោយទាននៃការទូន្មាន ត្រូវហៅមនុស្សឲ្យមកជិតព្រះជាម្ចាស់ ឬ មកជិតបំណងព្រះហឫទ័យណាមួយរបស់ព្រះជាម្ចាស់។

# ការបកស្រាយ និង អធិប្បាយពីព្រះអំណោយទាននេះ

"អ្នកដែលលើកទឹកចិត្តបងប្អូន ចូរលើកទឹកចិត្តគេទៅ" (គម្ពីររ៉ូម ១២:៨)

ពាក្យប្រើសម្រាប់ពាក្យថា *លើកទឹកចិត្ត* នៅក្នុងព្រះគម្ពីរបកប្រែចាស់ គឺពាក្យ "ទូន្មាន" ។ តាំងពីដើមមកដល់ចំណុចនេះ យើងមិនបានយកចិត្តទុកដាក់ខ្លាំងចំពោះការណែនាំរបស់លោកប៉ូលនៅក្នុងគម្ពីររ៉ូម ជំពូក១២ ដែលមានទាក់ទងនឹងព្រះអំណោយទានដែលយើងកំពុងរៀននៅពេលនេះទេ។ យើងមិនចង់មើលរំលងចំណុចនេះឡើយ។ នៅក្នុងព្រះគម្ពីរបកប្រែចាស់ លោកបានជំរុញឲ្យអស់អ្នកដែលមានព្រះអំណោយទានទាំងនេះ *ចាំតែធ្វើតាម* ព្រះអំណោយទានរបស់ពួកគេ។ តើលោកមានន័យយ៉ាងដូចម្តេច? លោកមានន័យថា ពួកគេត្រូវអភិវឌ្ឍ និង ប្រើប្រាស់ព្រះអំណោយទានរបស់ពួកគេ។ យើងត្រូវព្យាយាមធ្វើឲ្យព្រះអំណោយទានរបស់យើងមានប្រយោជន៍ តាមតែអាចធ្វើទៅបាន៖

" ឬជាការទូន្មាន ចូរ [ឲ្យគាត់ចាំតែ] ទូន្មានទៅ" (រ៉ូមគម្ពីរ ១២ គម្ពីរបកប្រែចាស់) ។ នេះមានន័យថា ពួកគេត្រូវតែប្រើប្រាស់ព្រះអំណោយទានរបស់ពួកគេ និង ព្យាយាមអភិវឌ្ឍវា។

មានមនុស្សជាច្រើននាក់ ដែលនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត អាចនឹងមានព្រះអំណោយទាននៃការទូន្មាននេះ។ យើងនឹងបានយល់កាន់តែច្បាស់ថែមទៀត នៅពេលដែលយើងសង្កេតមើលឲ្យកាន់តែដិតដល់អំពីរបៀបដែលព្រះអំណោយទាននេះបំពេញមុខងារនៅក្នុងក្រុមជំនុំដំបូង។ នៅពេលដែលយើងបានដកពិសោធន៍ខគម្ពីរ ដោយប្រើពាក្យថា *ទូន្មាន* (គម្ពីរបកប្រែចាស់) យើងឃើញថា វាទាក់ទងនឹងការត្រាស់ហៅអ្នកជឿ។ ពួកគេត្រូវបានត្រាស់ហៅឲ្យ

១. ស្មោះត្រង់ និង មានភក្តីភាពចំពោះព្រះជាម្ចាស់ (គម្ពីរកិច្ចការ ១១:២៣)។

២. បន្តជំនឿយ៉ាងខ្ជាប់ខ្ជួន (គម្ពីរកិច្ចការ ១៤:២២)។

៣. ធ្វើកិច្ចការមួយចំនួន(គម្ពីរ២កូរិនថូស ៩:៥)។

៤. ធ្វើការផ្គាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ឲ្យកាន់តែច្រើនឡើងៗ (គម្ពីរ១ថេស្សាឡូនិក ៤:១)។

៥. ព្រមានអស់អ្នកដែលរស់គ្មានសណ្តាប់ធ្នាប់ សំរាលទុក្ខអស់អ្នកដែលបាក់ទឹកចិត្ត ជួយទ្រទ្រង់អស់អ្នកទន់ខ្សោយ មានចិត្តអត់ធ្មត់ ចំពោះមនុស្សទូទៅ កុំឲ្យប្រព្រឹត្តអំពើអាក្រក់តបនឹងអំពើអាក្រក់និង សង្វាតធ្វើអំពើល្អ (គម្ពីរ១ថេស្សាឡូនិក ៥:១៤-១៥)។

៦. ធ្វើការ និងបរិភោគអាហារដែលបានមកពីកម្លាំងញើសឈាមរបស់ខ្លួន។ (គម្ពីរ២ថេស្សាឡូនិក ៣:១២)

៧. ទូលសូមអង្វរ អធិស្ឋានឲ្យ និង ទូលសូមការលើកលែងទោស សំរាប់មនុស្សទាំងអស់ផង។ (គម្ពីរ១ធីម៉ូថេ ២:១)។

៨. មានចិត្តធ្ងន់ (គម្ពីរទីតុស ២:៦)

៩. តយុទ្ធការពារជំនឿ (គម្ពីរយូដាសខ ៣)

ខគម្ពីរទាំងអស់ខាងលើនេះ បានផ្ដល់ឲ្យយើងនូវគំនិតល្អៗ អំពីអត្ថន័យនៃពាក្យថា ការទូន្មាន។ អ្នកជឿណាក៏ដោយ ដែលជួយបងប្អូនរបស់គាត់ ចំពោះរឿងដែលរៀបរាប់ខាងលើនេះបាន គឺអាចចាត់ទុកថាមានព្រះអំណោយទាននៃការទូន្មានបានហើយ។ ពួកសាវ័ក អាចធ្វើការទូន្មានបាន។ សាវ័ក អ្នកផ្សាយដំណឹងល្អ និង អ្នកគង្វាលព្រមទាំងអ្នកបង្រៀនក៏អាចធ្វើការទូន្មានបាន។ សឹងតែគ្រប់អ្នកជឿទាំងអស់ដែលមានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ គឺអាចមានព្រះអំណោយទាននៃការទូន្មានបាន។

បងប្អូនអ្នកជឿទាំងអស់ត្រូវតែយកចិត្តទុកដាក់នឹងខគម្ពីរហេព្រើ ៣:១៣ នេះ៖ "ចូរដាស់តឿនគ្នាទៅវិញទៅមក ជារៀងរាល់ថ្ងៃ" ។ នៅក្នុងគម្ពីរបកប្រែចាស់បានចែងថា៖ "ចូរកំឡាចិត្តគ្នាទៅវិញទៅមកជារាល់ថ្ងៃវិញ ក្នុងកាលដែលនៅតែហៅថា «ថ្ងៃនេះ»នៅឡើយ" ។ អ្នកជឿណាដែលជួយបងប្អូនពួកគេជារៀងរាល់ថ្ងៃ ហើយមានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ នោះពិតជានឹងទទួលបានស្គាល់សេចក្ដីអំណរនៅក្នុងព្រះអម្ចាស់។

## *លំហាត់អនុវត្តន៍*

៨ ចូរសរសេរអក្សរ ត នៅក្នុងចន្លោះខាងមុខប្រយោគត្រឹមត្រូវ។ សរសេរអក្សរ ខ នៅមុខប្រយោគដែលខុស។

.........ក) រាល់ព្រះអំណោយទានដែលព្រះជាម្ចាស់ប្រទានមកឲ្យយើង គឺមិនត្រូវការអភិវឌ្ឍថែមទៀតឡើយ។

.........ខ) រឿងដែលសំខាន់ជាងគេបំផុតដែលយើងធ្វើនៅពេលដែលយើងទូន្មានមនុស្ស គឺការសួរសំណួរ។

.........គ) មានតែបុគ្គលពិសេសប៉ុន្មាននាក់តែប៉ុណ្ណោះដែលអាចក្លាយជាអ្នកទូន្មានបាន។

.........ឃ) បើយើងធ្វើតាមបង្គាប់របស់ព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ ដោយជួយអ្នកដទៃ នោះយើងត្រូវបានចាត់ទុកថាមានព្រះអំណោយទាននៃការទូន្មាន។

# គោលបំណងនៃព្រះអំណោយទាននេះ

ការទូន្មានមានមុខងារជាច្រើននៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត។ ស្ទើរតែគ្រប់អ្នកជឿទាំងអស់ ត្រូវការការទូន្មាន។ មានអ្នកខ្លះទៀតត្រូវការ ការទូន្មានជាញឹកញាប់ ជាពិសេសអ្នកណាដែលកំពុងប្រឈមមុខនឹងបញ្ហា និងការសាកល្បងក្នុងជីវិត។ ដូចនេះ យើងអាចនិយាយបានថា គោលបំណងរបស់ព្រះអំណោយទាននៃការទូន្មាន គឺការហៅអ្នកជឿឲ្យដើរជិតជាមួយព្រះជាម្ចាស់ ឬ ហៅពួកគេទៅកាន់បំណងព្រះហឫទ័យណាមួយរបស់ព្រះជាម្ចាស់។ ការទូន្មានក៏មានន័យថា ត្រូវហៅអ្នកជឿឲ្យធ្វើសកម្មភាពណាមួយ ដែលនឹងជួយពួកគេ ឬអ្នកដទៃ ក្នុងដំណើររបស់ពួកគេជាមួយព្រះជាម្ចាស់។

## លំហាត់អនុវត្តន៍

៩ អ្នកជឿភាគច្រើនបានដឹងពីតម្រូវការរបស់ខ្លួន ដែលត្រូវការមានការហៅឲ្យទៅជិតព្រះជាម្ចាស់ ឬ អំពីតម្រូវការរបស់ពួកគេ ដែលត្រូវការ ការលើកទឹកចិត្តឲ្យធ្វើអ្វីមួយ។ អ្នកជឿអាចជួយគ្នា តាមរយៈ

..............................................................................................................................................

# ការប្រឡងផ្ទាល់ខ្លួន

**ត្រូវ/ខុស។** ចូរសរសេរអក្សរ ត នៅក្នុងចន្លោះបន្ទាត់នៅពីមុខប្រយោគត្រឹមត្រូវ និង អក្សរ ខ នៅក្នុងប្រយោគណាដែលខុស។

..........១ ការបែងចែកក្រុមនៃព្រះអំណោយទានខាងឯវិញ្ញាណឲ្យបានច្បាស់លាស់ គឺមានសារសំខាន់ណាស់។

..........២ ព្រះអំណោយទានខាងឯវិញ្ញាណទាំងអស់គឺសុទ្ធតែបានមកពីព្រះជាម្ចាស់។

..........៣ ការបម្រើមានន័យថា ការបំពេញតម្រូវការរបស់អ្នកដទៃ។

..........៤ ទេពកោសល្យពីធម្មជាតិ និងព្រះអំណោយទានខាងឯវិញ្ញាណគឺដូចគ្នា។

..........៥ ការបង្រៀនមានន័យថា "ការបង្ហាញពីរបៀបធ្វើអ្វីម្យ៉ាង"។

..........៦ ព្រះអំណោយទាននៃការបម្រើ មិនអាចជួយនៅក្នុងការផ្សាយដំណឹងល្អបានទេ។

..........៧ អ្នកជឿត្រូវតែជាអ្នកគង្វាល ដើម្បីទទួលបានព្រះអំណោយទាននៃការបង្រៀន។

..........៨ ឪពុកម្ដាយដែលនៅផ្ទះរបស់គាត់ ក៏អាចមានព្រះអំណោយទាននៃការបង្រៀនដែរ។

..........៩ ស្ត្រីមិនអាចបង្រៀននៅក្នុងក្រុមជំនុំបានទេ។

........១០ កិច្ចការដ៏សំខាន់របស់អ្នកបង្រៀន គឺការផ្ដល់ចំណេះដឹងអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។

.........១១ ចំណេះដឹងគឺជាគ្រឹះមូលដ្ឋានសម្រាប់ជំនឿ។

........១២ *ការទូន្មាន* មានន័យដូចគ្នានឹង *ការផ្សាយដំណឹងល្អ*

........១៣ អ្នកជឿអាចទូន្មានគ្នាទៅវិញទៅមកបាន។

........១៤ គោលបំណងនៃការទូន្មានគឺត្រូវហៅមនុស្សឲ្យដើរជិតជាមួយព្រះជាម្ចាស់។

# ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១ ការបម្រើ

៦ ក) ត

ខ) ត

គ) ត

២ ខ) គ្រប់គ្នាអាចមានទេពកោសល្យ ប៉ុន្តែព្រះវិញ្ញាណដ៏វិសុទ្ធធ្វើការតាមរយៈ អ្នកណាម្នាក់ដែលមានព្រះអំណោយទាននៃការបម្រើ។

៧ គ) វាចាក់គ្រឹះមូលដ្ឋានសម្រាប់ជំនឿ។

៣ ការបំពេញតម្រូវការរបស់ពួកគេ។

៨ ក) ខ

ខ) ខ

គ) ខ

ឃ) ត

៤ ចម្លើយទាំងអស់គឺជាចម្លើយត្រឹមត្រូវ

៩ ព្រះអំណោយទាននៃការទូន្មាន

៥ ខ) អនុញ្ញាតឲ្យព្រះវិញ្ញាណដ៏វិសុទ្ធអភិវឌ្ឍវាឲ្យបានត្រឹមត្រូវ។

មេរៀន ៦

# អំណោយទាននៃការចែកទាន ការគ្រប់គ្រង ការបង្ហាញពីក្តីមេត្តាករុណា និង ការជួយ

នៅក្នុងមេរៀនមុនរបស់យើង យើងបានសិក្សាអំពីព្រះអំណោយទាននៃព័ន្ធកិច្ចចំនួនបីយ៉ាងដែលមាននិយាយនៅក្នុងគម្ពីររ៉ូមជំពូក១២។ នៅពេលដែលយើងរៀនមេរៀននោះ យើងបានចាប់ផ្តើមមើលឃើញថាសមាជិកទាំងអស់នៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត ទទួលបានផលប្រយោជន៍ពីអំណោយទានទាំងនោះ។ មានអ្នកខ្លះទទួលបានព្រះអំណោយទានពិសេសៗ ហើយទាំងអស់គ្នាក៏ទទួលបានព្រះពរតាមរយៈព្រះអំណោយទានដែលបានប្រទានឲ្យព្រះកាយនោះដែរ។

ពេលនេះយើងបានត្រៀមជាស្រេច ក្នុងការសិក្សាព្រះអំណោយទានខាងឯព័ន្ធកិច្ចចំនួនបួនយ៉ាងបន្ថែមទៀត។ ព្រះអំណោយទាននីមួយៗក៏មានមុខងារ និង គោលបំណងយ៉ាងសំខាន់ផងដែរ។ ស្របពេលដែលចំណេះដឹងរបស់យើងអំពីព្រះអំណោយទានទាំងនេះបានកើនឡើង នោះព្រះពរដែលយើងទទួលពីព្រះអំណោយទានទាំងនោះក៏កើនឡើងដែរ។

យើងត្រូវតែរៀនមេរៀននេះដោយផ្ទង់ចិត្ត ជាមួយនឹងដួងចិត្តដែលបើកចំហសម្រាប់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ថ្វាយសិរីរុងរឿងទៅដល់ព្រះជាម្ចាស់នៅពេលដែលអ្នកបានមើលឃើញពីសារៈសំខាន់របស់ព្រះអំណោយទាននៃព័ន្ធកិច្ចទាំងនេះ នៅក្នុងជីវិតរបស់អ្នក។

## គម្រោងនៃមេរៀន

ក. ព្រះអំណោយទាននៃការចែកទាន

ខ. ព្រះអំណោយទាននៃការគ្រប់គ្រង

គ. ព្រះអំណោយទាននៃការបង្ហាញពីក្ដីមេត្តាករុណា

ឃ. ព្រះអំណោយទាននៃការជួយ

## វត្ថុបំណងនៃមេរៀន

នៅពេលអ្នកបានបញ្ចប់មេរៀននេះ អ្នកអាចនឹងៈ

១. បកស្រាយពីមុខងារ និង គោលបំណងរបស់ព្រះអំណោយទាននៃការចែកទាន

២. បកស្រាយពីមុខងារ និង គោលបំណងរបស់ព្រះអំណោយទាននៃការគ្រប់គ្រង

៣. បកស្រាយពីមុខងារ និង គោលបំណងរបស់ព្រះអំណោយទាននៃការបង្ហាញពីក្ដីមេត្តាករុណា

៤. បកស្រាយពីមុខងារ និង គោលបំណងរបស់ព្រះអំណោយទាននៃការជួយ

## សកម្មភាពក្នុងការសិក្សា

១. ទន្ទេញ ខគម្ពីរ១កូរិនថូសជំពូក១៣បន្តទៀត។ ដល់ពេលដែលអ្នក រៀនមេរៀននេះចប់ អ្នកអាចនឹងសូត្រ ៩ ខដំបូងដោយមិនចាំបាច់មើលព្រះគម្ពីរ។

២. សរសេររៀបរាប់ជាចំណុចៗ ពីព្រះអំណោយទាននៃព័ន្ធកិច្ចទាំងប្រាំពីរនៅក្នុងក្រុមនេះ ដាក់ក្នុងសៀវភៅកត់ត្រារបស់អ្នក។

៣. អានមេរៀននេះដោយប្រុងប្រយ័ត្ន។ គូសរង្វង់ជុំវិញព្រះអំណោយទាននីមួយ នៅពេលដែលអ្នកបានឃើញវានៅក្នុងមេរៀននេះ។ ធ្វើដូចនេះ នឹងជួយអ្នកឲ្យចងចាំវា។

៤. បើកមើលពាក្យសំខាន់នៅក្នុងអក្ខរានុក្រម។

៥. ធ្វើការប្រឡងផ្ទាល់ខ្លួន ដូចដែលអ្នកបានធ្វើនៅក្នុងមេរៀនមុនៗ។

៦. បន្ទាប់ពីអ្នកធ្វើការប្រឡងផ្ទាល់ខ្លួនរួចហើយ ចូររំឭកមេរៀនទី ៣ ដល់ទី៦ (ជំពូកទីពីរ)។ បន្ទាប់មក ធ្វើ*ការប្រឡងជំពូកទីពីរ* ។

## ពាក្យសំខាន់

| | | |
|---|---|---|
| វង្វេងវង្វាន់ | ការអង្វរជួស | សារធាតុ |
| ចិត្តសប្បុរស | ធ្វើជាអធិបតី | អាណិតអាសូរ |

# ក. ព្រះអំណោយទាននៃការចែកទាន

**វត្ថុបំណងទី១.** *បកស្រាយពីមុខងារ និង គោលបំណងរបស់ព្រះអំណោយទាននៃការចែកទាន។*

## ការកំណត់និយមន័យព្រះអំណោយទាននេះ

"អ្នកដែលចែកទ្រព្យរបស់ខ្លួន ចូរចែកដោយចិត្តស្មោះសរ" (គម្ពីររ៉ូម១២:៨)

ការចែកទាន គឺមិនត្រូវការអត្ថន័យអ្វីច្រើននោះទេ។ យើងទាំងអស់គ្នាសុទ្ធតែយល់ហើយថាវាមានន័យថា ការឲ្យ។ ប៉ុន្តែ *ព្រះអំណោយទាននៃការចែកទាន* គឺត្រូវការការឲ្យនិយមន័យ។ ដោយពាក្យថា *ព្រះអំណោយទាននៃការចែកទាន* យើងសំដៅទៅលើព្រះអំណោយទានរបស់ព្រះជាម្ចាស់ដែលជួយឲ្យអ្នកជឿធ្វើឲ្យអ្វីៗដែលពួកគេមាន ដោយសេរី និង ប្រកបដោយចិត្តសប្បុរស ដើម្បីបំពេញតម្រូវការរបស់អ្នកដទៃ និង បំពេញតាមកិច្ចការរបស់ព្រះជាម្ចាស់។ *ព្រះអំណោយទាននៃការចែកទាន* មានជាប់ទាក់ទងនឹងលុយរបស់យើងក៏ពិតមែន ប៉ុន្តែវាក៏ទាក់ទងនឹង រឿងមួយចំនួនទៀតដូចជា ពេលវេលា កម្លាំង និង ទេពកោសល្យ របស់យើងផងដែរ។

## ការបកស្រាយ និង អធិប្បាយពីព្រះអំណោយទាននេះ

ទោះបីជាគ្រិស្តបរិស័ទទាំងអស់ត្រូវមានចិត្តសប្បុរស ក៏នៅមានអ្នកខ្លះដែលមានព្រះអំណោយទានក្នុងការចែកទានដ៏លើសលប់ និងប្រកបជាមួយអំណរដ៏អស្ចារ្យ។ ព្រះអំណោយទាននៃការចែកទានបានមកពីការរួបរួមគ្នារវាង សមត្ថភាពរបស់មនុស្ស និងសមត្ថភាពរបស់ព្រះជាម្ចាស់។ សមត្ថភាពរបស់យើងពេលខ្លះមានដែនកំណត់ ប៉ុន្តែសមត្ថភាពរបស់ព្រះជាម្ចាស់មិនមានដែនកំណត់ឡើយ។ វាពិតជាអស្ចារ្យណាស់នៅពេលដែលសមត្ថភាពតែបន្តិចបន្តួចរបស់យើង និង សមត្ថភាពដ៏អស្ចារ្យរបស់ព្រះជាម្ចាស់បានមករួមជាមួយគ្នា! នេះជារឿងដែលកើតឡើងនៅក្នុងការអភិវឌ្ឍព្រះអំណោយទាននៃការចែកទាន។

ប្រសិនបើយើងសិក្សាដោយយកចិត្តទុកដាក់អំពីការពិភាក្សារបស់លោកប៉ូលអំពីប្រធានបទនេះ នៅក្នុងគម្ពីរ២កូរិនថូសជំពូក៨ និង ជំពូក៩ នោះយើងនឹងទទួលបានជំនួយដ៏មានតម្លៃមួយ ក្នុងការស្វែងយល់អំពីការចែកទានរបស់គ្រិស្តបរិស័ទជាទូទៅ និង ជាពិសេសអំពីព្រះអំណោយទាននៃការចែកទាននេះតែម្តង។ ខាងក្រោមនេះគឺជាគំនិតខ្លះៗ ដែលយើងរកឃើញនៅក្នុងខគម្ពីរទាំងនេះ៖

១. *ព្រះអំណោយទាននៃការចែកទានអាចអភិវឌ្ឍទៅមុខ នៅពេលដែលដើរតាមគំរូរបស់អ្នកដទៃ។*
"គេ [ ស្រុកម៉ាសេដូន ] ថ្វាយខ្លួនទៅព្រះអម្ចាស់ បន្ទាប់មក គេក៏ដាក់ខ្លួនបំរើយើង ស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ។ (គម្ពីរ២កូរិនថូស ៨:៥)។

២. *ព្រះអំណោយទាននៃការចែកទានគឺមានសារៈសំខាន់ណាស់នៅក្នុងជីវិតរបស់គ្រិស្តបរិស័ទ។* "បងប្អូនបានចំរើនឡើងយ៉ាងបរិបូណ៌គ្រប់វិស័យទាំងអស់ គឺមានជំនឿ មានសំនួនវោហារ មានចំណេះ មានចិត្តខ្នះខ្នែងគ្រប់យ៉ាង ព្រមទាំងមានចិត្តស្រឡាញ់យើងផង។ ហេតុនេះ ចំពោះការ ប្រមូលតង្វាយ ចូរចំរើនឡើងយ៉ាងបរិបូណ៌ដូច្នោះដែរ។" (គម្ពីរ២កូរិនថូស ៨:៧)។

៣. *ព្រះអំណោយទាននៃការចែកទានគឺមិនត្រូវបានគ្រប់គ្រងដោយច្បាប់នោះទេ។* "ខ្ញុំនិយាយបែបនេះមិនមែនបញ្ជាបងប្អូនទេ"។ (គម្ពីរ២កូរិនថូស៨:៨)

៤. *ព្រះអំណោយទាននៃការចែកទាន ត្រូវបានស្តែងបង្ហាញឲ្យឃើញច្បាស់បំផុត តាមរយៈព្រះអម្ចាស់យេស៊ូផ្ទាល់។* "ដ្បិតបងប្អូនស្គាល់ព្រះគុណរបស់ព្រះអម្ចាស់យេស៊ូគ្រិស្ត"ស្រាប់ហើយ គឺព្រះអង្គមានសម្បត្តិដ៏ច្រើន ទ្រង់បានដាក់ខ្លួនមកជាអ្នកក្រព្រោះតែបងប្អូន ដើម្បីអោយបងប្អូនបានទៅជាអ្នកមានដោយភាពក្រីក្ររបស់ព្រះអង្គ។" (គម្ពីរ២កូរិនថូស ៨:៩)

៥. *ព្រះអំណោយទាននៃការចែកទាន ថ្វាយកិត្តិនាម និង ផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ជាខ្លាំង។* "ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងអ្នកណាដែលធ្វើអំណោយដោយចិត្តរីករាយ។" (គម្ពីរ២កូរិនថូស ៩:៧)

៦. *យើងទទួលបានការធានាយ៉ាងច្បាស់ថា តម្រូវការរបស់យើងនឹងត្រូវបានបំពេញ។* "ព្រះអង្គអាចនឹងប្រទានពរដ៏ហូរហៀរគ្រប់យ៉ាងដល់បងប្អូន ដើម្បីអោយបងប្អូនមានអ្វីៗទាំងអស់ដែលបងប្អូនត្រូវការដ៏ចាំបាច់នោះជានិច្ច ...." (គម្ពីរ២កូរិនថូស ៩:៨)។

៧. *ព្រះអំណោយទាននៃការចែកទាន បញ្ជាក់អំពី ព្រះហឫទ័យរបស់ព្រះអម្ចាស់នៅក្នុងការល្អគ្រប់យ៉ាង។* "ហើយថែមទាំងនៅសល់បរិបូណ៌សំរាប់ចែកទានផង" (គម្ពីរ២កូរិនថូស ៩:៨)។

៨. *ព្រះអំណោយទាននៃការចែកទានអាចធ្វើឲ្យទទួលបានរង្វាន់ដ៏អស្ចារ្យ ។* ចំណុចចុងក្រោយមួយនេះមិនមាននិយាយនៅក្នុងគម្ពីរ២កូរិនថូសនោះទេ តែមាននៅក្នុងគម្ពីរភីលីព ៤:១៧វិញ។ "ត្រង់ណេះមិនមែនមានន័យថា ខ្ញុំប្រាថ្នាចង់បានជំនួយពីបងប្អូនទេ តែខ្ញុំចង់អោយបងប្អូនបានទទួលព្រះពរដ៏បរិបូណ៌។" (នោះគឺនៅឯស្ថានបរមសុខ)។

មានរឿងមួយនៅក្នុងគម្ពីរ ១ ពង្សាវតារក្សត្រ ១៧:៨-១៦ ដែលអាចបង្រៀនយើងបានច្រើន អំពីព្រះអំណោយទាននៃការចែកទាន។ លោកអេលីយ៉ាដែលជាព្យាការីម្នាក់ បានទៅជួបស្ត្រីមេម៉ាយម្នាក់ នៅក្នុងអំឡុងពេលមានគ្រោះទុរ្ភិក្ស។ នៅពេលដែលលោកមកដល់ផ្ទះរបស់នាង លោកបានឃើញនាងកំពុងតែរើសអុស។ លោកបានសុំទឹក និង នំបុ័ងនាងបរិភោគ។ នាងបានប្រាប់ទៅលោកថា អ្វីដែលនាងមាននៅក្នុងផ្ទះរបស់នាង គឺ "ម្សៅមួយក្តាប់ក្នុងខាប់ និងប្រេងបន្តិចនៅក្នុងដបប៉ុណ្ណោះ"។ នាងនិយាយទៀតថា៖ "នាងខ្ញុំកំពុងតែរើសអុសពីរអង្កត់នេះយកទៅដុតនំបុ័ងសំរាប់នាងខ្ញុំ និងកូនទទួលទាន។ ពេលទទួលទានរួចហើយ យើងខ្ញុំទាំងពីរនាក់ម្តាយកូននឹងស្លាប់ទាំងអស់គ្នា"។

យើងប្រហែលជាបានឃើញច្បាស់ហើយថា នាងបានគិតថា ខ្លួន*គ្មានអ្វី*នឹងផ្តល់ឲ្យនោះទេ។ ប៉ុន្តែលោកអេលីយ៉ា បានបង្រៀននាងនូវមេរៀនអស្ចារ្យមួយ។ លោកបានសុំឲ្យស្ត្រីមេម៉ាយនោះប្រើប្រាស់អ្វីទាំងអស់ដែលនាងមាន មកដុតនំបុ័ងមួយដុំសម្រាប់លោក។ ប្រសិនបើយើងមិនដឹងដំណើររឿងដល់ចប់នោះទេ យើងអាចនឹងនិយាយថា " ព្យាការីអ្វីអាក្រក់យ៉ាងនេះ ដែលសុំឲ្យស្ត្រីមេម៉ាយ ធ្វើបែបនេះទាំងគ្មានក្រែងចិត្តអ្វីសោះ!" ប៉ុន្តែលោកអេលីយ៉ា បានដឹងពីអ្វីដែលព្រះជាម្ចាស់នឹងធ្វើ ដូច្នេះហើយបានជាលោកសុំឲ្យនាងឲ្យរបស់ទាំងអស់ដែលនាងមាន។ នោះគឺជាគន្លឹះសម្រាប់ការស្វែងរកឃើញដ៏អស្ចារ្យមួយ។ សូមចាំថា យើងបានចាក់គ្រឹះសម្រាប់ព្រះអំណោយទាននៃការចែកទាន នៅពេលណាដែលយើងឲ្យ។ ព្រះអំណោយទាននៃការចែកទានមិនមែន គ្រាន់តែធ្លាក់ពីលើមេឃចូលក្នុងដួងចិត្តរបស់យើងប៉ុណ្ណោះទេ។ ដើម្បីទទួលបានវា យើងត្រូវធ្វើសកម្មភាព ។ យើងត្រូវចែកអ្វីដែលយើងមាន។

មនុស្សខ្លះអាចនឹងបដិសេធសំណើររបស់ព្យាការីរូបនេះ ហើយអាចបាត់បង់ឱកាសដ៏អស្ចារ្យដើម្បីបានមើលឃើញកិច្ចការរបស់ព្រះជាម្ចាស់។ ព្រះវិញ្ញាណអាចមានព្រះបន្ទូលប្រាប់យើងឲ្យចែកទាន ដូចដែលទ្រង់បានមានព្រះបន្ទូលមកកាន់ស្ត្រីមេម៉ាយតាមរយៈព្យាការីនោះផងដែរ។ ព្រះអំណោយទាននៃការចែកទាន បានមកជារបស់យើងនៅពេលដែលយើងស្តាប់បង្គាប់តែប៉ុណ្ណោះ។

មានរឿងដ៏អស្ចារ្យមួយបានកើតឡើងចំពោះស្ត្រីមេម៉ាយនោះ។ បន្ទាប់ពីនាងឲ្យលោកអេលីយ៉ា ដោយចិត្តស្តាប់បង្គាប់ នាងក៏បានឃើញថា នាងនៅមានសល់ប្រេង និង ម្សៅដដែល ដូចមុនពេលដែលនាងបានដុតនំប៉ុងសម្រាប់លោកព្យាការីដែរ។បន្ទាប់មកក៏បានមើលឃើញរឿងមួយទៀត។ នាងបានឃើញថា នាងនៅមានម្សៅ និង ប្រេងយ៉ាងច្រើន សម្រាប់ផ្គត់ផ្គង់រហូតដល់ពេលដែលគ្រោះទុរ្ភិក្ស កន្លងផុតទៅទៀត។ នាងមិនគ្រាន់តែមានគ្រប់គ្រាន់សម្រាប់ខ្លួនឯងនោះទេ តែនាងក៏មានគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការរបស់អ្នកដទៃផងដែរ៖ "ពួកគេមានអាហារបរិភោគ ជាយូរថ្ងៃទាំងនាងទាំងកូននាង និងលោកអេលីយ៉ា" ។

ទោះបីជាយើងតែងតែផ្សារភ្ជាប់ព្រះអំណោយទាននៃការចែកទាន ទៅនឹងលុយ ប៉ុន្តែព្រះអំណោយទាននេះមានន័យថា អំណោយមួយដែលបានមកពីការឲ្យអ្វីៗដែលអ្នកមាន។ វាអាចជា ប្រាក់កាស ពេលវេលា កម្លាំង និង ទេពកោសល្យរបស់អ្នក។

ប្រសិនបើយើងស្តាប់បង្គាប់តាមព្រះវិញ្ញាណដ៏វិសុទ្ធដោយចែកអ្វីៗដែលយើងមានដោយចិត្តសប្បុរស នោះតម្រូវការរបស់យើងក៏នឹងត្រូវបានបំពេញដែរ។ កាន់តែអស្ចារ្យជាងនេះទៅទៀត យើងនឹងទទួលបានច្រើនជាងអ្វីដែលយើងឲ្យអ្នកដទៃទៀត។ នៅពេលដែលព្រះអំណោយទាននៃការចែកទានបំពេញមុខងារទៅតាមអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ នោះការចែកទានរបស់យើងមិនត្រូវបានដឹកនាំដោយសមត្ថភាពរបស់យើងតែមួយមុខ ដើម្បីធ្វើការចែកទាននោះឡើយ។ វាត្រូវបានដឹកនាំដោយសមត្ថភាពរបស់ព្រះជាម្ចាស់ ដូចជានៅពេលករណីស្ត្រីមេម៉ាយនោះអ៊ីចឹងដែរ ។

ហេតុផលដ៏ខ្ពង់ខ្ពស់បំផុត សម្រាប់ព្រះអំណោយទាននៃការចែកទាននោះគឺថា យើងនឹងអាចចែកទានឲ្យអ្នកដទៃបានកាន់តែច្រើន។

## *លំហាត់អនុវត្តន៍*

១ ព្រះអំណោយទាននៃការចែកទានគឺជាព្រះអំណោយទាន

ក) ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងទទួលបានកាន់តែច្រើនសម្រាប់ខ្លួនយើង។

ខ) ដែលទាមទារឲ្យយើងត្រូវតែមានលុយ។

គ) ដែលជួយយើងចែកទានដោយសេរី និង ដោយចិត្តសប្បុរស។

ឃ) ដែលជួយយើងឲ្យចែកទាន ដើម្បីឲ្យយើងកាន់តែចែកទានបានកាន់តែច្រើនទៀត។

## គោលបំណងនៃព្រះអំណោយទាននេះ

តើអ្វីជាគោលបំណងនៃព្រះអំណោយទានមួយនេះ? ព្រះអំណោយទានទាំងអស់ដែលប្រទានមកគឺសម្រាប់គោលបំណងពិសេស។ ព្រះអំណោយទានទាំងអស់បានប្រទានមក គឺដើម្បីបំពេញតម្រូវការនៃព្រះកាយរបស់ព្រះគ្រិស្ត។ ព្រះអំណោយទានក៏ជួយឲ្យព្រះកាយបំពេញបេសកម្មរបស់ខ្លួនផងដែរ។ គោលបំណងពិសេសសម្រាប់អំណោទាននៃការចែកទានគឺ ជាការផ្គត់ផ្គង់តម្រូវការនៃព្រះកាយរបស់ព្រះគ្រិស្ត និង ដើម្បីបំពេញតម្រូវការសមាជិករបស់ខ្លួន។

### *លំហាត់អនុវត្តន៍*

២ ព្រះអំណោយទាននៃការចែកទាន បានប្រទានមកឲ្យអ្នកជឿ ព្រោះ

ក) តាមរយៈព្រះអំណោយទាននេះ តម្រូវការសាច់ឈាមរបស់ព្រះកាយត្រូវបានបំពេញ។

ខ) វាជាមធ្យោបាយមួយដែលអ្នកជឿ អាចរកលុយបានសម្រាប់ខ្លួនគេ។

គ) មនុស្សចូលចិត្តឲ្យលុយ។

# ខ. ព្រះអំណោយទាននៃការគ្រប់គ្រង

**វត្ថុបំណងទី២.** *បកស្រាយពីមុខងារ និង គោលបំណងរបស់ព្រះអំណោយទាននៃការគ្រប់គ្រង ។*

## ការកំណត់និយមន័យពីព្រះអំណោយទាននេះ

"អ្នកដែលដឹកនាំ ចូរដឹកនាំដោយចិត្តខ្នះខ្នែង" (គម្ពីររ៉ូម ១២:៨)។

នៅក្នុងគម្ពីរបកប្រែចាស់ អ្នកកាន់អំណាចត្រូវបានគេហៅថា "អ្នកនាំមុខ" ។ *ការនាំមុខ* មានន័យថា " ការឈរមុខ ឬ ធ្វើជាអធិបតី" ។ នៅក្នុងគម្ពីរ១កូរិនថូស ១២:២៨ ព្រះអំណោយទាននៃការនាំមុខ ត្រូវបានគេហៅថា "ការណែនាំ"។ នៅក្នុងគម្ពីរបកប្រែចាស់ គេប្រើពាក្យថា "ការគ្រប់គ្រង" ។

ព្រះអំណោយទាននៃការគ្រប់គ្រង គឺជាព្រះអំណោយទានដែលបានប្រទានមកឲ្យសមាជិកមួយចំនួននៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត សម្រាប់គោលបំណង ឲ្យឈរពីមុខ (ដឹកនាំ) ព្រះកាយទ្រង់ ធ្វើជាអធិបតីលើព្រះកាយ និង នាំផ្លូវព្រះកាយ។

## ការបកស្រាយ និង អធិប្បាយពីព្រះអំណោយទាននេះ

សូមគិតមើលថា តើកងទ័ពមួយនឹងទៅជាយ៉ាងណា បើគ្មានឧត្តមសេនីយ និង នាយទាហានផ្សេងៗទៀតនោះ។ អ្នកប្រាកដជាអាចទាយបានហើយថា និងមានបញ្ហាអ្វីកើតមានឡើងចំពោះកងទ័ពនោះ ប្រសិនបើ "ម្នាក់ៗធ្វើអ្វីៗតាមតែខ្លួនយល់ឃើញ" (គម្ពីរចៅហ្វាយ ១៧:៦)។ កងទ័ពបែបនោះ នឹងមិនអាចមានជ័យជំនះនៅក្នុងសង្គ្រាមបានឡើយ។ ព្រះកាយរបស់ព្រះគ្រិស្តក៏ត្រូវការមនុស្សដែលនឹងមកឈរនៅពីមុខ ធ្វើជាអធិបតី និង នាំផ្លូវនៅក្នុងកិច្ចការផ្សេងៗផងដែរ។

ព្រះគ្រិស្ត ដែលជាព្រះសិរសានៃព្រះកាយនេះ អាចត្រូវបានប្រៀបធៀបទៅនឹងឧត្តមសេនីយ នៃកងទ័ពដ៏ធំមួយផងដែរ។ ទ្រង់គង់ជាអធិបតីលើព្រះកាយទាំងមូល និង នាំផ្លូវក្នុងកិច្ចការផ្សេងៗរបស់គេផង។ ប៉ុន្តែគ្រិស្តបរិស័ទ ក៏ត្រូវការឲ្យធ្វើការគ្រប់គ្រងលើ និង នាំផ្លូវអ្នកជឿជាច្រើនក្រុមទៀត ដែលជាផ្នែកនៃព្រះកាយទាំងមូលនៅក្នុងពិភពលោកផងដែរ។ ក្រុមនៃអ្នកជឿទាំងអស់ត្រូវការនរណាម្នាក់ដែលមានព្រះអំណោយទានខាងការគ្រប់គ្រង។ អ្នកជឿទាំងអស់ទទួលបានបញ្ជាឲ្យ "ចូរទុកចិត្តលើអ្នកដឹកនាំបងប្អូន ព្រមទាំងស្តាប់បង្គាប់លោកទាំងនោះទៀតផង" (គម្ពីរហេប្រឺ ១៣:១៧)។ ដូច្នេះ ព្រះសិរសានៃព្រះកាយទ្រង់ប្រទានព្រះអំណោយទាននៃការគ្រប់គ្រងទៅដល់គ្រិស្តបរិស័ទមួយចំនួន។

មិនមែនអ្នកជឿទាំងអស់ ត្រូវក្លាយជាអ្នកគ្រប់គ្រងនោះទេ ផ្ទុយទៅវិញ មានតែអ្នកខ្លះតែប៉ុណ្ណោះដែលត្រូវមានព្រះអំណោយទាននៃការគ្របគ្រង។ អស់អ្នកដែលមានព្រះអំណោយទាននេះ ទទួលបានសមត្ថភាពពិសេសៗដូចជា ការរៀបចំ ការគ្រប់គ្រង និង ការដឹកនាំ។ មុខងាររបស់ពួកគេគឺមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងព្រះកាយ៖ "ប្រសិនបើបងប្អូនណាម្នាក់ ចង់បានមុខងារជាអភិបាលគាត់មានបំណងបំពេញមុខងារដ៏ប្រសើរហើយ" (គម្ពីរ១ធីម៉ូថេ ៣:១) ។ គំនូសបំព្រួញខាងក្រោមនឹងជួយអ្នក ឲ្យមើលឃើញពីខ្សែនៃសិទ្ធិអំណាចដែលព្រះជាម្ចាស់បានបង្កើតឡើង។

**ព្រះគ្រិស្ត ជាព្រះសិរសានៃក្រុមជំនុំ**

↓

អ្នកដឹកនាំព្រលឹងវិញ្ញាណចម្បង (អ្នកគង្វាល និង អ្នកចាស់ទុំ)

↓

អ្នកដឹកនាំបន្ទាប់បន្សំ ដែលជួយគ្រប់គ្រងចាត់ចែង (អ្នកជំនួយ)

↓

សមាជិកក្រុមជំនុំ

នៅក្នុងព្រះគម្ពីរ មាននាមមួយចំនួនដែលត្រូវគេដាក់ឲ្យសមាជិកនៃព្រះកាយរបស់ព្រះគ្រិស្តទាំងឡាយ ណាដែលមានព្រះអំណោយទាននៃការគ្រប់គ្រងនេះ៖

១. *អ្នកដឹកនាំក្រុមជំនុំ* (អ្នកគង្វាល ឬ អ្នកអភិបាល)

"គាត់ត្រូវចេះមើលខុសត្រូវលើក្រុមគ្រួសាររបស់គាត់ផ្ទាល់ ព្រមទាំងអោយកូនចៅរបស់គាត់ចេះស្តាប់បង្គាប់ និងមានកិរិយាថ្លៃថ្នូរទាំងស្រុង ព្រោះថា ប្រសិនបើមនុស្សម្នាក់មិនចេះមើលខុសត្រូវលើក្រុមគ្រួសាររបស់ខ្លួនផង ធ្វើម្ដេចនឹងអោយគាត់មើលខុសត្រូវលើក្រុមជំនុំ*របស់ព្រះជាម្ចាស់កើត!"
(គម្ពីរ១ធីម៉ូថេ ៣:៤-៥)

តំណែងរបស់អ្នកដឹកនាំក្រុមជំនុំ(អ្នកអភិបាល) គឺជាទំនួសខុសត្រូវមួយដ៏ធំបំផុតនៅក្នុងក្រុមជំនុំតាមតំបន់។ អ្នកអភិបាល ត្រូវបានតែងតាំងដោយសមាជិកក្រុមជំនុំ ឲ្យធ្វើជាអ្នកថែរក្សា ឬ អ្នកមើលការខុសត្រូវ។ ពួកគេក៏ត្រូវបានគេហៅថាក្រុមចាស់ទុំ ឬ ក្រុមព្រឹទ្ធាចារ្យ ហើយពួកគេមានទំនួលខុសត្រូវចាត់ចែងកិច្ចការរបស់ក្រុមជំនុំ។ ក្រុមព្រឹទ្ធាចារ្យ ក៏ត្រូវបានគេហៅថា អ្នកគង្វាលព្រមទាំងអ្នកបង្រៀនដែរ ព្រោះពួកគាត់ក៏ ឃ្វាលមនុស្សរបស់ព្រះជាម្ចាស់ដែរ។ នៅក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី យើងឃើញពីការរៀបចំដើម្បីបំពេញតម្រូវការនេះ។

ក្រុមចាស់ព្រឹទ្ធាចារ្យ ត្រូវតែមានសមត្ថភាពវៃឆ្លាតដើម្បីបង្រៀនបាន ប៉ុន្តែពួកគាត់អាចរៀបចំចាត់អ្នកផ្សេងដែលមានព័ន្ធកិច្ចខាងអ្នកគង្វាលព្រមទាំងអ្នកបង្រៀនមកដើម្បីជួយពួកគាត់បាន។ គោលការណ៍ទំនួលខុសត្រូវរបស់ក្រុមចាស់ព្រឹទ្ធាចារ្យគឺធ្វើជាអធិបតីលើ និង នាំផ្លូវព្រះកាយដែលផ្គុំឡើងពីអ្នកជឿមួយនេះ។

២. *អ្នកជំនួយ*

អ្នកជឿដែលមិនមែនជាអ្នកដឹកនាំព្រលឹងវិញ្ញាណពេញពេល ដូចជាបានរៀបរាប់ឈ្មោះទាំងប៉ុន្មាននៅខាងលើ ក៏ប្រហែលមានព្រះអំណោយទាននៃការគ្រប់គ្រងផងដែរ។ ពួកគេធ្វើការក្រោមអ្នកដឹកនាំ និងអ្នកគង្វាលព្រមទាំងអ្នកបង្រៀនចម្បង។ គម្ពីរ១ធីម៉ូថេ ៣:៨ ប្រហែលជាអាចធ្វើឲ្យរឿងនេះកាន់តែច្បាស់ថែមទៀត ពួកគេត្រូវបានចាត់ទុកថាជាអ្នកជំនួយរបស់ក្រុមជំនុំ។ គឺថា ពួកគេជួយអ្នកដឹកនាំ ចាត់ចែងក្រុមអ្នកជឿ៖ "ហេតុនេះ បងប្អូនអើយ សូមនាំគ្នាជ្រើសរើសយកបុរសប្រាំពីររូបក្នុងចំណោមបងប្អូនដែលជាអ្នកមានកេរ្តិ៍ឈ្មោះល្អ ហើយពោរពេញដោយព្រះវិញ្ញាណ និងប្រាជ្ញាឈ្លាសវៃ។ យើងខ្ញុំនឹងតែងតាំងគេអោយបំពេញមុខងារនេះ" (គម្ពីរកិច្ចការ ៦:៣)។

ដោយសារតែការគ្រប់គ្រងនៅក្នុងព្រះកាយរបស់ព្រះគ្រិស្តគឺមានភាពចាំបាច់ខ្លាំង តម្រូវការព្រះអំណោយទាននៃការគ្រប់គ្រងគឺមានភាពងាយស្រួលស្វែងយល់ណាស់។ នៅកន្លែងណាដែលគ្មានអ្នកដឹកនាំ អ្នកនៅធ្វើជាអធិបតីលើ ឬ អ្នកនាំផ្លូវ នោះក៏គ្មានការគ្រប់គ្រងដែរ។ កន្លែងណាដែលគ្មានការគ្រប់គ្រង កន្លែងនោះមុខជាគ្មាននរណាឲ្យធ្វើការគ្រប់គ្រងនោះទេ។ បើគ្មានការគ្រប់គ្រង និង ព្រះអំណោយទាននៃការគ្រប់គ្រង នោះព្រះកាយរបស់ព្រះគ្រិស្តទន់ខ្សោយ និង មិនអាចបំពេញកិច្ចការរបស់ខ្លួនបានឡើយ។ ដូច្នេះ ព្រះអំណោយទាននៃការគ្រប់គ្រង គឺពិតជាមានសារៈសំខាន់ណាស់។

### *លំហាត់អនុវត្តន៍*

៣ ព្រះអំណោយទាននៃការគ្រប់គ្រងគឺជា

ក) ព្រះអំណោយទាននៃការធ្វើជាអធិបតីលើ និង នាំផ្លូវក្រុមអ្នកជឿ។

ខ) ព្រះអំណោយទានដែលអ្នកជឿភាគច្រើនត្រូវមាន។

គ) មិនចាំបាច់ដើម្បីអភិវឌ្ឍកិច្ចការរបស់ព្រះជាម្ចាស់។

៤ អស់អ្នកដែលមានព្រះអំណោយទាននៃការគ្របគ្រង អាចមានសមត្ថភាពនឹង............................
..................................................និង.........................................................................

៥ អ្នកជឿដែលមានព្រះអំណោយទាននៃការគ្រប់គ្រងត្រូវបានគេហៅថា

ក) អ្នកដឹកនាំក្រុមជំនុំ

ខ) អ្នកផ្សាយដំណឹងល្អ

គ) ក្រុមចាស់ទុំ

## គោលបំណងនៃព្រះអំណោយទាននេះ

មុខងារព្រះអំណោយទាននៃការគ្រប់គ្រង គឺការគ្រប់គ្រង។ គោលបំណងព្រះអំណោយទាននៃការគ្រប់គ្រងនេះគឺដើម្បីផ្ដល់នូវការរួបរួម និង ជាកម្លាំងដល់ព្រះកាយរបស់ព្រះគ្រិស្ដ ដើម្បីឲ្យវាអាចបំពេញគោលបំណងរបស់វានៅក្នុងពិភពលោក។ សាកគិតមើលថា តើកងទ័ពមួយនឹងទៅជាយ៉ាងណា ប្រសិនបើកូនទាហានគ្រប់គ្នាធ្វើការសម្រេចចិត្តដោយខ្លួនឯង ថាកន្លែងណាដែលគេគួរទៅ ហើយអ្វីដែលគួរតែធ្វើ នោះ។ វាប្រាកដជាមានការច្របូកច្របល់។ មុខងាររបស់មន្ត្រីទាហាន គឺដើម្បីដឹកនាំ ធ្វើជាអធិបតីលើ និង នាំផ្លូវកូនទាហានដទៃផ្សេងទៀត ដើម្បីឲ្យគោលដៅរបស់ពួកគេ អាចសម្រេចបាន។ វាក៏ដូចគ្នាទៅនឹងព្រះកាយរបស់ព្រះគ្រិស្ដដែរ។

### *លំហាត់អនុវត្តន៍*

៦ ព្រះអំណោយទាននៃការគ្រប់គ្រង ត្រូវបានប្រទានទៅឲ្យព្រះកាយរបស់ព្រះគ្រិស្ដដើម្បីឲ្យវាអាច

ក) ក្លាយដូចជាកងទ័ពមួយដែរ។

ខ) បម្រើព្រះជាម្ចាស់តាមវិធីដែលល្អបំផុតតាមតែអាចធ្វើទៅបាន។

គ) មានអ្នកដឹកនាំក្រុមជំនុំ ក្រុមចាស់ទុំ និង អ្នកផ្សាយដំណឹងល្អ។

# គ. ព្រះអំណោយទាននៃការបង្ហាញពីក្តីមេត្តាករុណា

**វត្ថុបំណងទី៣.** *បកស្រាយពីមុខងារ និង គោលបំណងរបស់ព្រះអំណោយទាននៃការបង្ហាញពីក្តីមេត្តាករុណា។*

## ការកំណត់និយមន័យព្រះអំណោយទាននេះ

"អ្នកដែលចែកទានដល់ជនក្រីក្រ [ក្នុងគម្ពីរបកប្រែចាស់ គឺការមេត្តាករុណា] ចូរចែកអោយគេដោយចិត្តត្រេកអរ" (រ៉ូម ១២:៨)។

*មេត្តាករុណា* មានន័យថា "ភាពប្រណីសន្តោស" ឬ "មានចិត្តភាតរភាពជាមួយនឹងនរណាម្នាក់ដែលជាការមានចិត្ត*ជាមួយ* មនុស្សម្នាក់ទៀត ឬ មានចិត្ត*សម្រាប់* មនុស្សម្នាក់ទៀត"។ វាក៏មានន័យថា "អាណិតអាសូរ" ផងដែរ។

ដូច្នេះព្រះអំណោយទាននៃការបង្ហាញពីក្តីមេត្តាករុណា គឺជាព្រះអំណោយទានដែលបង្ហាញអ្នកដទៃថាអ្នកមានចិត្តជាមួយគេ និង មានចិត្តសម្រាប់គេផងដែរ។ វាគឺជាព្រះអំណោយទានដែលអាចឲ្យយើងអាណិតអាសូរអ្នកដទៃ។

## ការបកស្រាយ និង អធិប្បាយពីព្រះអំណោយទាននេះ

មានការទាមទារដ៏ខ្លាំងមួយ ចំពោះព្រះអំណោយទាននៃការបង្ហាញពីក្តីមេត្តាករុណា ទាំងនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត និង ក្នុងចំណោមអ្នកមិនជឿផងដែរ។ មនុស្សគឺមានភាពក្រៀមក្រំ ភាពឯកោ និងទុក្ខសោកសៅ។ មនុស្សចាំបាច់ត្រូវការនរណាម្នាក់ដែលអាចឈរក្បែរពួកគេ និងមានសេចក្តីប្រណីសន្តោសសម្រាប់ពួកគេ។ ព្រះអំណោយទាននៃការបង្ហាញពីក្តីមេត្តាករុណានេះហើយ ដែលបំពេញតម្រូវការមួយនេះ។

គំរូ និង ការស្តែងបង្ហាញដ៏ល្អបំផុតអំពីព្រះអំណោយទាននៃការបង្ហាញពីក្តីមេត្តាករុណា គឺព្រះអម្ចាស់យេស៊ូទ្រង់ផ្ទាល់។

សូមក្រឡេកទៅមើលការកត់ត្រាអំពីទ្រង់៖

១. "កាលព្រះអង្គទតឃើញមហាជន ទ្រង់មានព្រះហឫទ័យអាណិតអាសូរគេពន់ពេកណាស់ ព្រោះអ្នកទាំងនោះអស់កម្លាំងល្វើយ ធ្លាក់ទឹកចិត្ត ប្រៀបបីដូចជាចៀមដែលគ្មានគង្វាលថែទាំ។" (គម្ពីរម៉ាថាយ ៩:៣៦)។

២. "កាលព្រះយេស៊ូយាងឡើងពីទូក ទតឃើញមហាជនដ៏ច្រើនយ៉ាងនេះ ព្រះអង្គមានព្រះហឫទ័យអាណិតអាសូរគេពន់ពេកណាស់ ហើយទ្រង់ក៏ប្រោសអ្នកជំងឺអោយបានជា។" (គម្ពីរម៉ាថាយ ១៤:១៤)

៣. "ព្រះយេស៊ូមានព្រះហឫទ័យអាណិតអាសូរអ្នកទាំងពីរពន់ពេកណាស់ ព្រះអង្គក៏ពាល់ភ្នែកគេ។ រំពេចនោះ គេមើលឃើញភ្លាម ហើយនាំគ្នាដើរតាមព្រះយេស៊ូទៅ។" (គម្ពីរម៉ាថាយ ២០:៣៤)

៤. "ព្រះយេស៊ូមានព្រះហឫទ័យអាណិតអាសូរគាត់ពន់ពេកណាស់ ព្រះអង្គក៏លូកព្រះហស្ដទៅពាល់គាត់ ទាំងមានព្រះបន្ទូលថា៖ «ខ្ញុំយល់ព្រមហើយ ចូរអោយបានជាស្អាតបរិសុទ្ធចុះ!" (គម្ពីរម៉ាកុស ១:៤១)។

៥. "ខ្ញុំអាណិតអាសូរបណ្ដាជននេះពន់ពេកណាស់ ដ្បិតគេនៅជាមួយខ្ញុំអស់រយៈពេលបីថ្ងៃមកហើយ ហើយគ្មានអ្វីបរិភោគសោះ" (គម្ពីរម៉ាកុស ៨:២)។

៦. "កាលព្រះអម្ចាស់ឃើញស្ដ្រីមេម៉ាយនោះ ព្រះអង្គមានព្រះហឫទ័យអាណិតអាសូរគាត់យ៉ាងខ្លាំង។ ព្រះអង្គមានព្រះបន្ទូលទៅគាត់ថា៖ "សូមកុំយំអី!"" (គម្ពីរលូកា ៧:១៣)។

ព្រះយេស៊ូមានព្រះហឫទ័យយ៉ាងជ្រាលជ្រៅជាមួយមនុស្ស និងសម្រាប់មនុស្សផង។ ទ្រង់ក៏*បានបង្ហាញ ពី*ក្ដីមេត្តាករុណារបស់ទ្រង់ទៅចំពោះមនុស្សផងដែរ។ នៅក្នុងរឿងអ្វីដែលនិយាយអំពីទ្រង់ ថាទ្រង់មានក្ដីមេត្តាករុណានោះ វាក៏បានបង្ហាញឲ្យបានឃើញច្បាស់ដែរថាទ្រង់បានធ្វើអ្វីទាំងអស់ដែលទ្រង់អាចធ្វើសម្រាប់មនុស្សនោះ។ វាមិនទាន់គ្រប់គ្រាន់នៅឡើយ បើគ្រាន់តែមានចិត្ត*សម្រាប់*មនុស្ស និង *ជាមួយ* មនុស្សនោះ។ យើងត្រូវ*បង្ហាញ*មនុស្សថាយើងពិតជាមានចិត្តសម្រាប់ពួកគេ និង ជាមួយគេពិតប្រាកដមែន ដោយការបម្រើពួកគេ។ សម្រាប់អ្នកដែលមានទុក្ខសោក ត្រូវមានពាក្យដើម្បីកំសាន្តចិត្ត។ សម្រាប់អ្នកឯកោ ត្រូវតែមានមិត្តភាពសម្រាប់គេ។ សម្រាប់អ្នកដែលបាក់ទឹកចិត្ត ត្រូវមានពាក្យលើកទឹកចិត្តគេ។ សម្រាប់អ្នកមានបាប ត្រូវមានការខ្វល់ខ្វាយប្រកបសេចក្ដីស្រឡាញ់សម្រាប់គេ។

ជាឧទាហរណ៍ វាគឺជាការល្អដែលមានចិត្តជាមួយ និង សម្រាប់មនុស្សកំព្រាឪពុក និង ស្ដ្រីមេម៉ាយ ប៉ុន្តែការមានចិត្តជាមួយពួកគេ និងសម្រាប់ពួកគេ គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ យើងក៏ត្រូវតែជួយពួកគេក្នុងភាពជាក់ស្តែងផងដែរ៖ "រីឯសាសនាដ៏បរិសុទ្ធ ឥតខ្ចោះនៅចំពោះព្រះភក្ត្រព្រះបិតាជាម្ចាស់វិញ គឺស្ថិតនៅលើការទៅសួរសុខទុក្ខក្មេងកំព្រា និងស្ដ្រីមេម៉ាយដែលមានទុក្ខលំបាក ព្រមទាំងស្ថិតនៅលើការរក្សាខ្លួនអោយផុតពីអំពើសៅហ្មងរបស់លោកីយ៍នេះ" (គម្ពីរយ៉ាកុប ១:២៧)។

វាជារឿងសំខាន់ណាស់ ដែលក្រុមជំនុំមួយត្រូវមានអ្នកជឿជាច្រើននាក់ដែលមានព្រះអំណោយទាននៃការបង្ហាញពីក្ដីមេត្តាករុណា។ ព្រះអំណោយទានមួយនេះ ជួយគាំទ្រព្រះអំណោយទានទាំងអស់ទៀត។ ជាឧទាហរណ៍ អ្នកជឿដែលមានព្រះអំណោយទានខាងការផ្សាយដំណឹងល្អ ក៏ត្រូវមានព្រះអំណោយទាននៃការបង្ហាញពីក្ដីមេត្តាករុណាផងដែរ ព្រោះព្រះអំណោយទាននៃការបង្ហាញពីក្ដីមេត្តាករុណានេះ នឹងជួយពួកគេឲ្យមានចិត្តសម្រាប់ និង ជាមួយមនុស្សដែលមិនទាន់បានទទួលការសង្គ្រោះ។ បន្ទាប់មក ព្រះអំណោយទាននៃការផ្សាយដំណឹងល្អ នឹងកាន់តែមានប្រសិទ្ធិភាព។

លោកបារណាបាសគឺជាគំរូមួយដ៏ល្អសម្រាប់អ្នកដែលមានព្រះអំណោយទាននៃការបង្ហាញពីក្ដីមេត្តាករុណា។ លោកគឺជាមនុស្សម្នាក់ដែលមានចិត្តប្រណីសន្តោសខ្លាំងណាស់ ហើយចិត្តប្រណីសន្តោសនេះបានធ្វើឲ្យលោកបានបម្រើមនុស្សមួយចំនួនដែលក្រីក្របំផុត។ សូមអានខគម្ពីរទាំងនេះអំពីលោក ៖ គម្ពីរកិច្ចការ ៩:២៧ ; ១១:២៥-២៦; ១៥:៣៧-៣៩។

### *លំហាត់អនុវត្តន៍*

៧ *សេចក្តីមេត្តាករុណា* មានន័យថា

ក) អំណាច

ខ) សេចក្តីស្រឡាញ់

គ) ចិត្តអាណិតអាសូរ

ឃ) ចិត្តប្រណីសន្តោស

៨ មនុស្សត្រូវការនរណាម្នាក់ដើម្បីបង្ហាញពួកគេពី ចិត្តប្រណីសន្តោស នៅពេលដែលពួកគេ

ក) រឹងមាំ និង ល្អប្រសើរ

ខ) ក្រៀមក្រំ និង ឯកោ

គ) អ្នកផ្សាយដំណឹងល្អ

ឃ) ជាមនុស្សមានបាប។

៩ ព្រះអំណោយទាននៃការបង្ហាញពីក្តីមេត្តាករុណាគឺជា

ក) ព្រះអំណោយទានមួយដែលអ្នកជឿជាច្រើននាក់គួរតែមាន។

ខ) ព្រះអំណោយទានមួយដែលមានតែអ្នកផ្សាយដំណឹងល្អត្រូវការ។

គ) ព្រះអំណោយទានមួយដែលបម្រើតាមសេចក្តីត្រូវការរបស់មនុស្សជាច្រើន។

## គោលបំណងនៃព្រះអំណោយទាននេះ

មុខងារព្រះអំណោយទាននៃការបង្ហាញពីក្តីមេត្តាករុណា គឺជួយឲ្យអ្នកជឿមានចិត្តជាមួយ និង សម្រាប់អ្នកដទៃ និង មានចិត្តអាណិតអាសូរចំពោះពួកគេ។

គោលបំណងព្រះអំណោយទាននេះ គឺដើម្បីបង្ហាញអ្នកដែលខ្វះខាតពីក្តីមេត្តា តាមរយៈការឈរនៅក្បែរ និង ជួយពួកគេនៅពេលខ្វះខាតយ៉ាងពិតប្រាកដ។ ពិតជាព្រះអំណោយទានដ៏ពិសេសមែន!

### *លំហាត់អនុវត្តន៍*

១០ ចូរគូសរង្វង់ជុំវិញអក្សរត្រឹមត្រូវ ដើម្បីបំពេញប្រយោគដូចតទៅនេះ៖ នៅពេលដែលអ្នកជឿម្នាក់មានចិត្តសម្រាប់ ឬ ជាមួយអ្នកជឿម្នាក់ទៀតនៅក្នុងពេលដែលគេក្រៀមក្រំ យើងហៅការនោះថា

ក) ជាមុខងាររបស់ព្រះអំណោយទាននៃការបង្ហាញពីក្តីមេត្តាករុណា។

ខ) ជាគោលបំណងរបស់ព្រះអំណោយទាននៃការបង្ហាញពីក្តីមេត្តាករុណា។

# ឃ. ព្រះអំណោយទាននៃការជួយ

**វត្ថុបំណងទី៤.** *បកស្រាយពីមុខងារ និង គោលបំណងរបស់ព្រះអំណោយទាននៃការជួយ។*

## ការកំណត់និយមន័យពីព្រះអំណោយទាននេះ

"ក្នុងក្រុមជំនុំមុនដំបូងបង្អស់ ព្រះជាម្ចាស់បានតែងតាំង.... ព្រះអំណោយទានខាងជួយអ្នកដទៃ" (គម្ពីរ១កូរិនថូស ១២:២៨)។

ពាក្យថា *ជួយ* មានន័យថា "ធ្វើឲ្យធូរស្បើយ ឬ ជំនួយ" ។ *ព្រះអំណោយទាននៃការជួយ* គឺជាព្រះអំណោយទាន ដែលធ្វើឲ្យអ្នកជឿ អាចជួយ ឬ រំដោះទុក្ខអ្នកដទៃដោយការធ្វើល្អ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ។

## ការបកស្រាយ និង អធិប្បាយពីព្រះអំណោយទាននេះ

មិនត្រូវឲ្យសមាជិកណាម្នាក់នៅក្នុងព្រះកាយរបស់ព្រះគ្រិស្តមានអារម្មណ៍ថា គ្មានព្រះអំណោយទានខាងឯវិញ្ញាណសម្រាប់ពួកគេឡើយ។ មិនមែនគ្រប់គ្នាអាចក្លាយ ជាសាវ័ក ជាព្យាការី ជាអ្នកផ្សាយដំណឹងល្អ ឬ  អ្នកគង្វាលនិងអ្នកបង្រៀននោះទេ ប៉ុន្តែសមាជិកទាំងអស់ អាចមានព្រះអំណោយទាននៃការជួយនេះបាន។ អ្នកជឿខ្លះ មានព្រះអំណោយទានពិសេសមកពីព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីក្លាយជាអ្នកជួយតែម្ដង។ ពួកគេទទួលបានសមត្ថភាពពិសេសដើម្បី ផ្ដល់ភាពធូរស្បើយសម្រាប់អ្នកដទៃ។ សូមយើងសិក្សាខគម្ពីរខ្លះ ដែលនឹងបង្ហាញយើងពីរបៀបព្រះអំណោយទាននៃការជួយ បំពេញមុខងារ នៅក្នុងក្រុមជំនុំដំបូងបង្អស់។

១. "បន្ទាប់មក ដោយលោកអប៉ូឡូសមានបំណងធ្វើដំណើរទៅកាន់ស្រុកអាខៃ ពួកបងប្អូនក៏នាំគ្នាលើកទឹកចិត្តគាត់អោយទៅ ថែមទាំងសរសេរសំបុត្រទៅជំរាបពួកសិស្ស*នៅស្រុកនោះ អោយទទួលគាត់ដោយរាក់ទាក់ផង។" (គម្ពីរកិច្ចការ ១៨:២៧)

២. "សូមជំរាបសួរលោកអ៊ើបាន់ដែលធ្វើការបំរើព្រះគ្រិស្តរួមជាមួយ" (គម្ពីររ៉ូម ១៦:៩)

យើងមិនបានដឹងថាបុរសម្នាក់នេះបានធ្វើអ្វីដើម្បី ជួយលោកប៉ូលនោះទេ។ គាត់ប្រហែលជាបានធ្វើការចែកចាយ និង ការបង្រៀនខ្លះៗ។ ប្រហែលជាគាត់បានជួយ ដោយការដឹកនាំមនុស្សក្នុងការច្រៀងសរសើរតម្កើង។ គាត់ប្រហែលជាបានជួយដោយការចាត់ចែងប្រាក់កាសសម្រាប់ក្រុមរបស់លោកប៉ូល។ ទោះជាយ៉ាងណា គាត់ប្រហែលជាបានជួយដោយការសួរសុខទុក្ខអ្នកដែលទើបប្រែចិត្តថ្មី។ យើងបានត្រឹមតែ ស្មានពីរបៀបដែលគាត់បានជួយតែប៉ុណ្ណោះ។ យើងក៏អាចឃើញពីរបៀបដែលអ្នកជឿមានព្រះអំណោយទាននៃការជួយ មានតម្លៃខ្លាំងចំពោះព្រះកាយរបស់ព្រះគ្រិស្ត។

៣. "រីឯអ្នកវិញ មិត្តដ៏ស្មោះត្រង់អើយ សូមជួយនាងទាំងពីរនាក់នេះផង ដ្បិតនាងធ្លាប់បានតយុទ្ធរួម ជាមួយខ្ញុំ ព្រោះតែដំណឹងល្អ" (គម្ពីរភីលីព ៤:៣)

អ្នកប្រាជ្ញខ្លះបានបកស្រាយឃ្លា "តយុទ្ធរួមជាមួយខ្ញុំ" ឲ្យទៅជាមានន័យថា " ប្រយុទ្ធរួមជាមួយខ្ញុំ" ។ នៅត្រង់នេះ យើងឃើញថា ស្រ្តីក៏អាចមានព្រះអំណោយទាននៃការជួយផងដែរ។ ប៉ុន្តែក៏មិនដឹងថាពួកគេអាចជួយបានដោយរបៀបណាផងដែរ។ តើពួកគេអាចជួយបាន តាមរយៈការជួបជុំជាមួយនឹងស្រ្តីដែលជឿថ្មីៗបានដែរឬទេ? តើពួកគេអាចនឹង បានជួយដោយការរៀបចំអាហារសម្រាប់លោកប៉ូល និង ក្រុមរបស់លោកបានដែរឬទេ? តើពួកគេអាចជាអ្នកជួយ តាមរយៈការទូលអង្វរ និង ការអធិស្ឋានសម្រាប់មនុស្សបានដែរឬទេ? តើពួកគេអាចធ្វើការដេរសំលៀកបំពាក់ សម្រាប់លោកប៉ូល និង ក្រុមរបស់លោក ព្រមទាំងបោកសំអាតសំលៀកបំពាក់នោះ បានដែរឬទេ? សុទ្ធតែអាចធ្វើបានទាំងអស់ ដ្បិតព្រះអំណោយទាននៃការជួយគឺរួមបញ្ចូលទាំងការងារតូចតាចផងដែរ។

មានអ្នកខ្លះជឿថា នៅក្នុងក្រុមជំនុំដំបូងបង្អស់ ស្រ្តីដែលមានព្រះអំណោយទាននៃការជួយ ត្រូវបានគេហៅដោយនាមពិសេសមួយ។ ពួកគេត្រូវបានហៅថា អ្នកជំនួយស្រី ។ "ខ្ញុំទុកដាក់នាងភីបេ ជាបងប្អូនយើងនឹងអ្នករាល់គ្នា នាងជាអ្នកជំនួយដល់ពួកជំនុំ នៅក្រុងកេងគ្រា" (គម្ពីររ៉ូម ១៦:១ គម្ពីរបកប្រែចាស់) នៅក្នុងខគម្ពីរនេះជាភាសាក្រិចសម្រាប់*អ្នកបម្រើ* ថា "អ្នកជំនួយស្រី" ។

ជារឿងពិតណាស់ ដែលមនុស្សប្រុសមានព្រះអំណោយទានពិសេសក្នុងការជួយ ហើយត្រូវបានត្រាស់ហៅឲ្យបម្រើការជាអ្នកជំនួយក្រុមជំនុំ៖ "ដ្បិតបងប្អូនណាបំពេញមុខងារជាអ្នកជំនួយបានល្អ នឹងបានទទួលកិត្តិយស ព្រមទាំងមានចិត្តអង់អាចមោះមុត ដោយអាងលើជំនឿក្នុងអង្គព្រះគ្រិស្តយេស៊ូ។" (គម្ពីរ១ ធីម៉ូថេ ៣:១៣)

មានក្រុមជំនុំតូចមួយនៅអាមេរិកខាងត្បូងដែលមានចលនាដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។ មានមនុស្សជាច្រើនដែលបានសង្គ្រោះ និង បានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ អ្នកគង្វាលព្រមទាំងអ្នកបង្រៀនក៏ជាបងប្អូនដ៏ស្មោះត្រង់។ គាត់បានចែកចាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ និង បានទៅសួរសុខទុក្ខមនុស្សជាច្រើនផងដែរ។ នៅក្នុងចំណោមអ្នកជឿទាំងអស់ មានស្រ្តីមាឌតូចម្នាក់ ដែលគេមិនសូវជាចាប់អារម្មណ៍ពីនាងទេ។ នាងមិនបាននិយាយច្រើន ជាសាធារណៈនោះទេ ប៉ុន្តែមើលទៅនាងហាក់បីដូចជាកំពុងតែអធិស្ឋានគ្រប់ពេល ។ នាង ជួយអ្នកគង្វាលបានច្រើនណាស់។ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ នាងមានព្រះអំណោយទាននៃការជួយនៅក្នុងនាង។

### *លំហាត់អនុវត្តន៍*

១១ ចូរសរសេរអក្សរ ត នៅពីមុខប្រយោគដែលត្រឹមត្រូវ និង អក្សរ ខ នៅពីមុខប្រយោគណាដែលខុស នៅខាងក្រោមនេះ។

........ក) ព្រះអំណោយទាននៃការជួយ ផ្ដល់នូវជំនួយ និង ភាពធូរស្បើយសម្រាប់អ្នកដទៃ។

........ខ) មានអ្នកជឿមួយចំនួនតូចប៉ុណ្ណោះដែលត្រូវការ ឲ្យមានព្រះអំណោយទាននៃការជួយនេះ។

........គ) ទាំងបុរស និង ស្ត្រីសុទ្ធតែអាចមានព្រះអំណោយទាននៃការជួយ។

........ឃ) នៅក្នុងក្រុមជំនុំដំបូងបង្អស់ ស្ត្រីដែលមានព្រះអំណោយទាននៃការជួយ ត្រូវបានគេហៅថាអ្នកជំនួយ។

## គោលបំណងនៃព្រះអំណោយទាននេះ

មុខងារព្រះអំណោយទាននៃការជួយ គឺការផ្ដល់ឲ្យអ្នកជឿដែលនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ដ នូវសមត្ថភាពក្នុងការជួយអ្នកដឹកនាំ និង ក្រុមជំនុំទូទៅ ជាមួយនឹងការងាររបស់ពួកគេ។

គោលបំណងសម្រាប់ព្រះអំណោយទាននៃការជួយ គឺការជួយធ្វើការងារជាក់ស្ដែង ដើម្បីពង្រីកអាណាចក្ររបស់ព្រះជាម្ចាស់។ មុខងារ គឺនិយាយពីសមត្ថភាពក្នុងការជួយ ។ ឯគោលបំណងវិញគឺនិយាយអំពីការជួយជាក់ស្ដែង។

ជាឧទាហរណ៍ យើងអាចនិយាយបានថា បងប្អូនណាម្នាក់មានសមត្ថភាពពិសេសក្នុងការអធិស្ឋាន។ នោះគឺជាមុខងាររបស់ព្រះអំណោយទាននៃការជួយ។ យ៉ាងណាមិញ សមត្ថភាពនៃការអធិស្ឋានរបស់គាត់នឹងមិនមានប្រយោជន៍អ្វីដល់ក្រុមជំនុំឡើយ ដរាបណាគាត់ប្រើប្រាស់ព្រះអំណោយទាននៃការជួយរបស់គាត់ ដោយធ្វើការអធិស្ឋាន។ នៅពេលដែលគាត់អធិស្ឋាន គោលបំណងរបស់ព្រះអំណោយទាននៃការជួយរបស់គាត់ គឺកំពុងត្រូវបានបំពេញ។

### *លំហាត់អនុវត្តន៍*

១២ បងប្អូនដែលមានពេញដោយព្រះវិញ្ញាណម្នាក់ មានព្រះអំណោយទានពិសេសសម្រាប់ជួយអ្នកគង្វាលរបស់គាត់ក្នុងការចុះសួរសុខទុក្ខអ្នកជំងឺ។ តើប្រយោគនេះបញ្ជាក់អំពីមុខងារ ឬមួយក៏ គោលបំណងរបស់ព្រះអំណោយទាន?

ក) មុខងារ

ខ) គោលបំណង

# ការប្រឡងផ្ទាល់ខ្លួន

**ចម្លើយខ្លីៗ។** ចូរសរសេរចម្លើយទៅនឹងសំណួរនៅលើបន្ទាត់ដែលបានផ្តល់ជូន។

១ ចូររាប់របៀបបីយ៉ាង ដែលមនុស្សអាចបម្រើតាមរយៈព្រះអំណោយទាននៃការជួយ។

........................................................................................................................................

........................................................................................................................................

........................................................................................................................................

២ ចូររាប់នាមទាំងបី ដែលប្រើសម្រាប់ហៅ អស់អ្នកដែលមានព្រះអំណោយទាននៃការគ្រប់គ្រង។

.......................................................... ..................................................................

..........................................................

៣ ចូរសរសេរឈ្មោះព្រះអំណោយទាន នៅពីក្រោមនិយមន័យនីមួយៗរបស់វា។

ក) ការធ្វើជាអធិបតីលើ និង ការនាំផ្លូវ ក្រុមអ្នកជឿ។

.......................................................................................................................................

ខ) ការជួយ ឬ រំដោះទុក្ខអ្នកដទៃដោយការធ្វើល្អ

........................................................................................................................................

គ) ការចែកទានដោយសេរី និង ចិត្តសប្បុរស ដើម្បីបំពេញតម្រូវការរបស់អ្នកដទៃ។

........................................................................................................................................

ឃ) ការបង្ហាញប្រាប់អ្នកដទៃថា អ្នកមានចិត្តជាមួយគេ និង សម្រាប់គេ។

........................................................................................................................................

៤ ចូរបើកមើលខគម្ពីរនីមួយៗ ហើយសរសេរឈ្មោះព្រះអំណោយទានដែលរៀបរាប់នៅក្នុងខគម្ពីរទាំងនោះ នៅក្នុងចន្លោះបន្ទាត់ខាងក្រោម។

ក) គម្ពីរកិច្ចការ១៥:៣៧-៣៩ ..........................................................................................

ខ) គម្ពីរកិច្ចការ១៨:២៧ ...............................................................................................

គ) គម្ពីរ១ពង្សាវតារក្សត្រ ១៧:៨-១៦.................................................................................

ឃ) គម្ពីរកិច្ចការ ៦:១-៣...............................................................................................

ង) គម្ពីរម៉ាកុស ១:៤១.................................................................................................

៥ ចូរសរសេរឈ្មោះព្រះអំណោយទាននៃព័ន្ធកិច្ចទាំងបី ដែលបានសិក្សានៅក្នុងមេរៀនមុន។

............................................................ ...................................................................

............................................................

**បំពេញប្រយោគ។** ចូរសរសេរបំពេញប្រយោគ នៅលើចន្លោះបន្ទាត់ដែលបានដាក់ឲ្យ។

៦ មនុស្សដែលមានព្រះអំណោយទាននៃ.......................................................................................
មានសមត្ថភាព ការរៀបចំ ការគ្រប់គ្រង និង ការដឹកនាំ។

៧ ព្រះអំណោយទានដែលមានគោលបំណងជួយតម្រូវ ហិរញ្ញវត្ថុរបស់អ្នកដទៃ គឺជាព្រះអំណោយទាន
នៃ.....................................................................................................................................

# ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១ គ) ដែលជួយយើងចែកទានដោយសេរី និង ដោយចិត្តសប្បុរស។
 ឃ) ដែលជួយយើងឲ្យចែកទាន ដើម្បីឲ្យយើងកាន់តែចែកទានបានកាន់តែច្រើនទៀត។

៧ គ) ចិត្តអាណិតអាសូរ
 ឃ) ចិត្តប្រណីសន្ដោស

២ ក) តាមរយៈព្រះអំណោយទាននេះ តម្រូវការសាច់ឈាមរបស់ព្រះកាយត្រូវបានបំពេញ។

៨ ខ) ក្រៀមក្រំ និង ឯកោ
 ឃ) ជាមនុស្សមានបាប។

៣ ក) ព្រះអំណោយទាននៃការធ្វើជាអធិបតីលើ និង នាំផ្លូវក្រុមអ្នកជឿ។

៩ ក) ព្រះអំណោយទានមួយដែលអ្នកជឿជាច្រើននាក់គួរតែមាន។
 គ) ព្រះអំណោយទានមួយដែលបម្រើតាមសេចក្ដីត្រូវការរបស់មនុស្សជាច្រើន។

៤ ដឹងនាំ, ធ្វើជាអធិបតី និង នាំផ្លូវ

១០ ក) ជាមុខងាររបស់ព្រះអំណោយទាននៃការបង្ហាញពីក្ដីមេត្តាករុណា។

៥ ក) អ្នកដឹកនាំក្រុមជំនុំ
 គ) ក្រុមចាស់ទុំ

១១ ក) ត
 ខ) ខ
 គ) ត
 ឃ) ខ

៦ ខ) បម្រើព្រះជាម្ចាស់តាមវិធីដែលល្អបំផុតតាមតែអាចធ្វើទៅបាន។

១២ ខ) គោលបំណង

## ការប្រឡងតាមជំពូកទីពីរ

ឥឡូវនេះ ដោយអ្នកបានបញ្ចប់ជំពូកទីពីរ អ្នកអាចឆ្លើយនឹង*សំណួរប្រឡងជំពូកទីពីរ* បាន។ ចូររំឭកមេរៀនពីខាងលើ មុនពេលដែលអ្នកចាប់ផ្ដើម។ ធ្វើតាមការណែនាំដោយប្រុងប្រយ័ត្ន ដើម្បីធ្វើការប្រឡងបន្ទាប់មក បន្តទៅជំពូកទីបី។

[illegible]

# ជំពូកទី បី
# ការស្វែងយល់អំពីព្រះអំណោយទាន របស់ព្រះវិញ្ញាណ

## មេរៀន

៧ ពាក្យសំដីនៃប្រាជ្ញា ពាក្យសំដីនៃចំណេះ និងជំនឿ

៨ ការប្រោសឲ្យជាពីជំងឺ ការធ្វើការអស្ចារ្យ និង ការថ្លែងព្រះបន្ទូល

៩ ការសង្កេតស្គាល់វិញ្ញាណ ការនិយាយភាសាចម្លែកអស្ចារ្យ និង ការបកប្រែន័យ ភាសាចម្លែកអស្ចារ្យ

មេរៀនទី ៧

# ពាក្យសំដីនៃប្រាជ្ញា ពាក្យសំដីនៃចំណេះ និងជំនឿ

នៅក្នុងមេរៀនទាំងបួនកន្លងមករបស់យើង យើងបានសិក្សាពីរក្រុមនៃព្រះអំណោយទានខាងឯវិញ្ញាណៈ (១) ព្រះអំណោយទាននៃព័ន្ធកិច្ច និង (២) ព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេងទៀត។ យើងបានគត់សំគាល់ឃើញថា មួយក្រុមដំបូងនៃព្រះអំណោយទាននេះ ត្រូវបានប្រទានទៅឲ្យអ្នកដឹកនាំនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត។ ដូច្នេះ មានចំនួនអ្នកជឿដែលអាចទទួលបានព្រះអំណោយទានទាំងនេះគឺមានកំណត់។ ឯព្រះអំណោយទានក្រុមទីពីរ គឺផ្ទុយពីនោះ។ អ្នកជឿសឹងតែគ្រប់គ្នាយ៉ាងហោចណាស់ក៏អាចមានព្រះអំណោយទានមួយក្នុងចំណោមព្រះអំណោយទានទាំងនេះដែរ។

ជាមួយនឹងមេរៀននេះយើងនឹងចាប់ផ្ដើមសិក្សាពីក្រុមព្រះអំណោយទានចុងក្រោយរបស់យើង គឺព្រះអំណោយទានរបស់ព្រះវិញ្ញាណ។ យើងនឹងយកចិត្តទុកដាក់ជាពិសេសទៅលើ រឿងដែលថាព្រះអំណោយទាននីមួយៗនៃព្រះអំណោយទានទាំងនេះ គឺត្រូវបានប្រទានមកដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងក៏នឹងចងចាំផងដែរថា ព្រះអំណោយទានទាំងនេះគឺ មិនអាចកើតមានឡើងបាន តាមរយៈតែសមត្ថភាព និង ទេពកោសល្យរបស់មនុស្សនោះទេ។

យើងនឹងដឹងរឿងមួយទៀតឆាប់ៗនោះគឺ ឫទ្ធានុភាពបន្ថែម ដែលបានមកតាមរយៈការជ្រមុជនៅក្នុងព្រះវិញ្ញាណ គឺមានសម្ដែងនៅក្នុងព្រះអំណោយទានរបស់ព្រះវិញ្ញាណដែរ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យឫទ្ធានុភាពរបស់ទ្រង់ បានត្រូវស្ដែងចេញតាមរយៈបុត្ររបស់ទ្រង់គ្រប់គ្នាទាំងអស់។ ទ្រង់សព្វព្រះហឫទ័យ ឲ្យឫទ្ធានុភាពរបស់ទ្រង់បានសម្ដែងចេញតាមរយៈអ្នក។ នៅពេលដែលអ្នករៀនអំពីព្រះអំណោយទានទាំងនេះ យើងនឹងចាប់ផ្ដើមមើលឃើញថាអ្នកអាចត្រូវបានប្រើប្រាស់ដោយព្រះវិញ្ញាណសម្រាប់ការសម្ដែងព្រះអំណោយទានទាំងនោះ យ៉ាងមានប្រសិទ្ធិភាព ។

## គម្រោងនៃមេរៀន

ក. ពាក្យសំដីនៃប្រាជ្ញា

ខ. ពាក្យសំដីនៃចំណេះ

គ. ជំនឿ

## វត្ថុបំណងនៃមេរៀន

នៅពេលដែលបញ្ចប់មេរៀនមួយនេះ អ្នកអាចនឹង ៖

១. បកស្រាយឃ្លា " ពាក្យសំដីនៃប្រាជ្ញា" និង ថ្លែងប្រាប់ពីមុខងារ និង គោលបំណងរបស់ព្រះអំណោយទានមួយនេះ។

២. រៀបរាប់មុខងារ និង គោលបំណងរបស់ ពាក្យសំដីនៃចំណេះ។

៣. ប្រាប់ពីរបៀបដែលមនុស្សម្នាក់អាចដឹងថា តើគេបានទទួលពាក្យសំដីនៃចំណេះឬទេ។

៤. បកស្រាយពីមុខងារ និង គោលបំណងរបស់ព្រះអំណោយទាននៃជំនឿ។

៥. ប្រាប់ពីរបៀបដែលមនុស្សម្នាក់អាចដឹងថា គេមានព្រះអំណោយទាននៃជំនឿឬទេ។

## សកម្មភាពក្នុងការសិក្សា

១. អានគម្ពីរ១កូរិនថូស ជំពូក១២។

២. អានសេចក្តីសង្ខេបការវិវត្តន៍មេរៀន។ សរសេរនិយមន័យខ្លីៗ របស់ព្រះអំណោយទានទាំងបីដែលមាននៅក្នុងមេរៀននេះដាក់ក្នុងសៀវភៅកត់ត្រារបស់អ្នក។

៣. សិក្សាពាក្យសំខាន់នៅក្នុងអក្ខរានុក្រមដោយយកចិត្តទុកដាក់ មុនពេលធ្វើការសិក្សាចាប់ផ្តើមសិក្សាមេរៀននេះ។

៤. ធ្វើការប្រឡងផ្ទាល់ខ្លួន ដូចដែលបានធ្វើនៅក្នុងមេរៀនមុនដែរ។

៥. ទន្ទេញខគម្ពីរ ១កូរិនថូសជំពូក១៣បន្តទៀត។ សរសេរខគម្ពីរ ៩ខ ដំបូងតាមការចងចាំរបស់អ្នកដាក់នៅក្នុងសៀវភៅកតត្រារបស់អ្នក។នៅពេលដែលបញ្ចប់មេរៀននេះ យើងនឹងអាចសូត្រ ១០ខ ដំបូងនៃខគម្ពីរនេះ។

## ពាក្យសំខាន់

| | | |
|---|---|---|
| បណ្តាញ | ឧបករណ៍ | ខ្ពង់ខ្ពស់លើស |
| សាសន៍ដទៃ | ជំនឿស៊ប់ | ស្ងួរសៀង |

# ក. ពាក្យសំដីនៃប្រាជ្ញា

**វត្ថុបំណងទី១.** *បកស្រាយឃ្លា " ពាក្យសំដីនៃប្រាជ្ញា" និង ថ្លែងប្រាប់ពីមុខងារ និង គោលបំណងរបស់ព្រះអំណោយទានមួយនេះ។*

យើងបានត្រៀមខ្លួនហើយស្រេចដើម្បីសិក្សាពី ព្រះអំណោយទានរបស់ព្រះវិញ្ញាណ។ ដើម្បីចាប់ផ្ដើមមេរៀននេះ សូមមើលការណែនាំរបស់លោកប៉ូលអំពីប្រធានបទនេះនៅក្នុងគម្ពីរ ១កូរិនថូស១២:១

"បងប្អូនអើយ ខ្ញុំមិនចង់ឲ្យអ្នករាល់គ្នាល្ងង់ខ្លៅទេ។"(គកស១៦)

នៅពេលដែលយើងចាប់ផ្ដើមសិក្សាមុខវិជ្ជានេះ យើងបានឃើញពីតម្លៃដ៏អស្ចារ្យរបស់ចំណេះដឹងនៅក្នុងទំនាក់ទំនងទៅនឹងព្រះអំណោយទានខាងឯវិញ្ញាណ។ លោកប៉ូលបានដឹងពីសារៈសំខាន់នៃចំណេះដឹងហើយ។ បំណង់ចិត្តដ៏ខ្លាំងបំផុតរបស់គាត់ គឺចង់ជួយអ្នកជឿឲ្យរួចផុតពីភាពឆោតល្ងង់៖ "បងប្អូនអើយ ខ្ញុំមិនចង់ឲ្យអ្នករាល់គ្នានៅល្ងង់" (គម្ពីរ១កូរិនថូស ១០:១ពគប)។ លោកបាននិយាយដូចគ្នានេះចំនួនប្រាំលើក នៅក្នុងសំបុត្រសម្រាប់អ្នកដឹកនាំរបស់លោក៖ គម្ពីររ៉ូម ១:១៣; គម្ពីរ១កូរិនថូស ១០:១; ១២:១គម្ពីរ ២កូរិនថូស ១:៨ និង គម្ពីរ ១ថេស្សាឡូនិក ៤:១៣។

លោកប៉ូលបានដឹងច្បាស់ថា ការមានចំណេះដឹងដ៏ពិតនៅគ្រប់វិស័យទាំងអស់គឺមានភាពចាំបាច់ណាស់។ លោកបានដឹងថាវានឹងធ្វើឲ្យព្រះអំណោយទានរបស់ព្រះវិញ្ញាណ កាន់តែមានន័យច្បាស់ និង មានប្រសិទ្ធិភាព តាមអ្វីដែលព្រះជាម្ចាស់ទ្រង់សព្វព្រះហឫទ័យ។

ពួកអ្នកជឿអាចទទួលបានព្រះអំណោយទានបានដោយមិនចាំបាច់មានចំណេះដឹងច្រើន ដូចគ្នានឹងអ្នកក្រុងកូរិនថូសអ៊ីចឹងដែរ។ "បងប្អូនមិនខ្វះព្រះអំណោយទានអ្វីឡើយ" (គម្ពីរ១កូរិនថូស ១:៧)។ ទោះជាយ៉ាងណា បើចង់ឲ្យព្រះអំណោយទានកាន់តែមានប្រយោជន៍ វាត្រូវពឹងផ្អែកលើចំណេះដឹងដ៏ពិតមួយ។

នៅពេលដែលយើងសិក្សាពីព្រះអំណោយទានទាំងនេះ យើងនឹងស្វែងរកឲ្យឃើញច្បាស់នូវចំណេះដឹងដែលមានមូលដ្ឋានគ្រឹះផ្អែកលើព្រះគម្ពីរ អំពីព្រះអំណោយទាននីមួយៗ។ យើងចង់យល់ដឹងព្រះអំណោយទានទាំងនេះឲ្យកាន់តែច្បាស់។ យើងមិនគ្រាន់តែចង់ស្គាល់ព្រះអំណោយទានទាំងនេះទេ តែយើងចង់ឃើញព្រះអំណោយទានទាំងនេះធ្វើសកម្មភាពផងដែរ។ យើងត្រូវទូលសូមឲ្យព្រះវិញ្ញាណដ៏វិសុទ្ធបានបើកគំនិតរបស់យើង ដើម្បីបានយល់ដឹងឲ្យកាន់តែច្បាស់។

## និយមន័យ ពាក្យសំដីនៃប្រាជ្ញា

"គឺព្រះអង្គប្រទានអោយម្នាក់ចេះនិយាយប្រកបដោយប្រាជ្ញា" (គម្ពីរ១កូរិនថូស១២:៨)។ នៅក្នុងព្រះគម្ពីរបកប្រែចាស់បាននិយាយថា "ដ្បិតទ្រង់ប្រទានឲ្យម្នាក់មាន*ពាក្យសំដីនៃប្រាជ្ញាវាងវៃ*ដោយសារព្រះវិញ្ញាណ" ( សូមមើលអក្សរទ្រេត) ។ ប្រាជ្ញាគឺជា ការវិនិច្ឆ័យបានល្អដែលផ្អែកលើចំណេះដឹង។ ពាក្យសំដីនៃប្រាជ្ញានោះ គឺជាពាក្យដែលបានមកពី ការវិនិច្ឆ័យបានល្អ ដែលផ្អែកលើចំណេះដឹង។ ក៏ប៉ុន្តែសម្រាប់ព្រះអំណោយទានវិញ គឺលើសពីនោះទៅទៀត។

ពាក្យថា *ពាក្យសំដី* គឺជាគន្លឹះ។ វាមកពីភាសាក្រិកថា *ឡូកូស*។ ពាក្យថា *ឡូកូស* មានន័យថា "បង្ហាញនៃ, ប្រធានបទនៃ, ខ្លឹមសារនៃ" ។ ដោយ ព្រះអំណោយទានរបស់ព្រះវិញ្ញាណ គឺជារបស់ដែលមកពីព្រះជាម្ចាស់ដាច់ខាត នោះយើងដឹងថាពាក្យសំដីនៃប្រាជ្ញាគឺជាការស្តែងបង្ហាញដែលបានមកពីព្រះជាម្ចាស់។ វាមិនមែនជាការបង្ហាញប្រាជ្ញានោះទេ។ ប្រាជ្ញាដែលយើងនិយាយនៅត្រង់នេះ គឺបានមកពីព្រះជាម្ចាស់ផ្ទាល់តែម្តង។ ប្រាជ្ញានោះគឺជាប្រាជ្ញារបស់ទ្រង់។

ដូច្នេះ តាមរយៈព្រះអំណោយទានពាក្យសំដីនៃប្រាជ្ញា ព្រះវិញ្ញាណដ៏វិសុទ្ធប្រទានឲ្យអ្នកជឿមួយចំណែកនៃព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់។

ឃ្លាថា "ពាក្យសំដីនៃប្រាជ្ញា" គេនិយាយសំដៅទៅ *ចំណែកដ៏តូចមួយ* ។ វាក៏ហាក់ដូចជានិយាយសំដៅទៅលើប្រាជ្ញាពិសេស ដែលទុកសម្រាប់តម្រូវការពិសេសមួយ។ យើងអាចនិយាយបានថា វាគឺជាផ្នែកតូចមួយនៃប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ដែលបាននិយាយឡើងនៅក្នុងពេលវេលាមួយដ៏ស័ក្តិសម។

## ***លំហាត់អនុវត្តន៍***

១ ពាក្យសំដីនៃប្រាជ្ញាគឺជា

ក) ផ្នែកតូចមួយនៃប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ដែលបាននិយាយឡើងនៅក្នុងពេលវេលាមួយ ដ៏ស័ក្តិសម។

ខ) ព្រះអំណោយទានមួយដែលធ្វើឲ្យមនុស្សមានប្រាជ្ញាចាប់ពីនោះតទៅ។

គ) ប្រាជ្ញាពីធម្មជាតិដែលត្រូវបានជំរុញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។

# ការបកស្រាយ និង ការអធិប្បាយពីពាក្យសំដីនៃប្រាជ្ញា

យើងត្រូវតែដឹងថា ពាក្យសំដីនៃប្រាជ្ញា គឺពេញដោយភាពអធិធម្មជាតិ(លើសពីធម្មជាតិ)។ លោកប៉ូលបាននិយាយថា "គឺព្រះអង្គប្រទានអោយម្នាក់ចេះនិយាយប្រកបដោយប្រាជ្ញា" (គម្ពីរ១កូរិនថូស ១២:៨)។ គេមិនអាចទទួលបានវាដោយគ្រាន់តែទៅរៀននៅសាលានោះទេ។ គេមិនអាចទទួលបានវា ដោយគ្រាន់ជាមនុស្សឈ្លាសវៃពីកំណើតនោះទេ។ គេទទួលបានវា តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធតែប៉ុណ្ណោះ។

ដើម្បីជួយយើងក្នុងការស្វែងយល់ពីព្រះអំណោយទាន ដែលហៅថា ពាក្យសំដីនៃប្រាជ្ញា នេះ យើងនឹងចោទសួរសំណួរមួយចំនួនៈ

១. *តើពាក្យសំដីនៃប្រាជ្ញាត្រូវបានប្រទានទៅឲ្យអ្នកណា?*

"ប៉ុន្តែ មានព្រះវិញ្ញាណតែមួយដដែល ដែលបំពេញសកម្មភាពទាំងអស់ ហើយប្រទានអោយម្នាក់ៗមានព្រះអំណោយទានផ្សេងៗពីគ្នា តាមព្រះហឫទ័យរបស់ព្រះអង្គ"(គម្ពីរ១កូរិនថូស១២:១១)។

អ្នកខ្លះនៅគិតថា អ្នកជឿគ្រប់គ្នាសុទ្ធតែមានឱកាស ដែលត្រូវបានប្រើឲ្យសម្តែងព្រះអំណោយទានគ្រប់ទាំងអស់។ សូមអនុញ្ញាតឲ្យខ្ញុំបកស្រាយត្រង់ចំណុចនេះ។ គ្រប់ព្រះអំណោយទានទាំងអស់សុទ្ធតែមាន *នៅក្នុងព្រះវិញ្ញាណ* ។ អ៊ីចឹង ប្រសិនបើព្រះវិញ្ញាណគង់នៅក្នុងអ្នកជឿណា នោះព្រះអំណោយទាន

របស់ទ្រង់ក៏នៅក្នុងអ្នកជឿនោះដែរ។ ប៉ុន្តែ ព្រះអំណោយទានណាមួយឬព្រះអំណោយទានទាំងប៉ុន្មាន ដែលព្រះវិញ្ញាណដ៏វិសុទ្ធនឹងបើកសម្តែងតាមរយៈអ្នកជឿនោះ គឺតាមតែការបំណងព្រះហឫទ័យរបស់ទ្រង់វិញ។

ព្រះអំណោយទានរបស់ព្រះវិញ្ញាណគឺឋិតនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះអំណោយទានទាំងនោះ ត្រូវសម្តែងឡើងដោយព្រះវិញ្ញាណ តាមរយៈអ្នកជឿ ដូច្នេះ យើងអាចនិយាយបានថា វាត្រូវបានប្រទានទៅឲ្យអ្នកជឿ។

ដើម្បីឧទាហរណ៍រឿងនេះ ទាក់ទងនឹងពាក្យសំដីនៃប្រាជ្ញា សូមអានគម្ពីរកិច្ចការ ១៥:៥-២៧។ មានបញ្ហាដ៏ធំមួយបានកើតឡើងនៅក្នុងក្រុមជំនុំដំបូងបង្អស់។ វាគឺជាបញ្ហា អ្នកប្រែចិត្តជឿដែលជាសាសន៍ដទៃ។ ដើម្បីដោះស្រាយបញ្ហានេះ អ្នកដឹកនាំក្រុមជំនុំបានជួបប្រជុំជាមួយនឹង អ្នកជឿដទៃទៀត។ ពួកគេបាននិយាយពិភាក្សាគ្នាទៅវិញទៅមក។ អ្នកខ្លះមានយោបល់មួយ។ ឯអ្នកខ្លះទៀតមានគំនិតផ្សេងពីនោះ។ ចុងក្រោយ លោកយ៉ាកុប ជាអ្នកដឹកនាំម្នាក់ក៏មានប្រសាសន៍ឡើង។ បន្ទាប់ពីលោកបាននិយាយចាប់ហើយ "ក្រុមសាវ័ក ក្រុមព្រឹទ្ធាចារ្យ និងក្រុមជំនុំទាំងមូលយល់ឃើញថា"។

ពេលនេះសូមចំណាំជំហានទាំងនេះ៖

ក. បញ្ហាដ៏ធំមួយត្រូវបានលើកឡើង (ខ៥)

ខ. ព្រះកាយដែលផ្សំពីអ្នកជឿបានមកជុំគ្នា (ខ៦)

គ. ពួកគេខិតខំប្រឹងប្រែងខ្លាំងណាស់ដើម្បីដោះស្រាយបញ្ហា (ខ ៧ ដល់ ១២)

ឃ. តាមរយៈលោកយ៉ាកុប ព្រះវិញ្ញាណដ៏វិសុទ្ធ បានប្រទានចម្លើយដោយពាក្យសំដីនៃប្រាជ្ញា (ខ១៣ ដល់២១)

ង. ពាក្យសំដីនៃប្រាជ្ញា នាំឲ្យពួកគេទាំងអស់គ្នាធ្វើការសម្រេចចិត្តមួយ (ខ២២)

នៅក្នុងខគម្ពីរទាំងនេះ យើងឃើញថា ពាក្យសំដីនៃប្រាជ្ញា បានប្រទានមកដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ ពាក្យសំដីនៃប្រាជ្ញានោះ ត្រូវតែបាន*ទៅដល់*មនុស្ស។ ព្រះវិញ្ញាណដ៏វិសុទ្ធ បានគង់នៅក្នុងលោកយ៉ាកុប ហើយតាមរយៈលោក ព្រះវិញ្ញាណដ៏វិសុទ្ធបានបើកសម្តែង នូវពាក្យសំដីនៃប្រាជ្ញា ទៅកាន់ក្រុមជំនុំទាំងមូល។ ដូច្នេះ ក្រុមជំនុំបានទទួលព្រះអំណោយទានពាក្យសំដីនៃប្រាជ្ញា។

## លំហាត់អនុវត្តន៍

២ ចូរសរសេរអក្សរ ត នៅខាងមុខប្រយោគដែលត្រឹមត្រូវ និង អក្សរ ខ នៅមុខប្រយោគណាដែលខុស។

........ក) ពាក្យសំដីនៃប្រាជ្ញា មានលក្ខណៈអធិធម្មជាតិតែមួយចំណែកតែប៉ុណ្ណោះ។

........ខ) វាមិនមែនជារឿងត្រឹមត្រូវនោះទេ ដែលនិយាយថា មានតែមនុស្សមួយចំនួនប៉ុណ្ណោះដែលមានព្រះអំណោយទានពាក្យសំដីនៃប្រាជ្ញា។

.........គ) ពាក្យសំដីនៃប្រាជ្ញា គឺជាព្រះអំណោយទានសម្រាប់ក្រុមជំនុំ។

........ឃ) ពាក្យសំដីនៃប្រាជ្ញា គឺត្រូវបានស្តែងចេញតាមរយៈអ្នកមិនជឿ។

៣ ចូរអានគម្ពីរកិច្ចការ ៦:១-៧ ។ តើខណាមួយដែលអ្នកគិតថា និយាយសំដៅលើ ពាក្យសំដីនៃប្រាជ្ញា?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

---

២. *តើពាក្យសំដីនៃប្រាជ្ញា ធ្វើការយ៉ាងដូចម្តេច?*

តើវាទាមទារឲ្យគិតច្រើនដែរឬទេ? តើអ្នកជឿដែលព្រះវិញ្ញាណបានប្រទានឲ្យ នូវពាក្យសំដីនៃប្រាជ្ញាស្តែងចេញតាមរយៈពួកគេនោះ បានដឹងពីអ្វីដែលគេនឹងនិយាយចេញទៅដោយរបៀបណា?

សំណួរទាំងនេះឲ្យឆ្លើយបានដោយអស់អ្នកដែលធ្លាប់មានបទពិសោធន៍។ លោក ដូណាល់ ហ្គី ជាគ្រូបង្រៀនម្នាក់នៅក្រុមជំនុំថ្ងៃទីហាសិបជនជាតិអង់គ្លេសម្នាក់ បាននិយាយដូច្នេះ៖

> នៅក្នុងការសម្តែងពាក្យសំដីនៃប្រាជ្ញា មានអ្វីម្យ៉ាងលេចចេញមក។ មានអារម្មណ៍ដែលមកពីអាទិទេព (របស់ព្រះជាម្ចាស់) មានស្មារតីមួយដែលដឹងពីព្រះសូរសៀងដ៏ខ្ពង់ខ្ពស់លើស (ដែលនៅពី លើ) គ្រប់ទាំង... បទពិសោធន៍ដែលមនុស្ស...ធ្លាប់ឆ្លងកាត់។ អ្នកនោះពិតជាបានដឹងយ៉ាងច្បាស់ថា ..គេបាននិយាយរឿងដែលត្រឹមត្រូវ។

ពាក្យសំដីនៃប្រាជ្ញាអាចនឹងត្រូវបាននិយាយទៅកាន់ដួងចិត្តរបស់មនុស្សម្នាក់ដោយផ្ទាល់ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ។ នៅក្នុងករណីនេះ អ្នកនោះប្រាកដជានឹងយកវាទៅនិយាយនៅក្នុងព្រះកាយនៅថ្ងៃក្រោយ។ (សូមមើលនៅគម្ពីរអេភេសូ ១:១៧-១៩)

លោកប៉ូលបាននិយាយពាក្យសំដីនៃប្រាជ្ញា ទៅកាន់អ្នកក្រុងកូរិនថូស ប៉ុន្តែមុនពេលដែលលោកបាននិយាយវាចេញមក ព្រះវិញ្ញាណដ៏វិសុទ្ធបានមានព្រះបន្ទូលយ៉ាងច្បាស់ទៅក្នុងដួងចិត្តរបស់លោក (សូមអានគម្ពីរ១កូរិនថូស ២:៥-១៥)

៣. *តើនៅពេលណាដែល ពាក្យសំដីនៃប្រាជ្ញាត្រូវបានស្តែងបង្ហាញ?*

យើងមិនអាចរៀបរាប់ពីពេលណាដែលព្រះអំណោយទាននេះត្រូវបានស្តែងឲ្យឃើញនោះឡើយ។ ភាគច្រើន កាលៈទេសៈនឹងកំណត់ថាតើពេលណាដែលត្រូវការព្រះអំណោយទាននេះ។ ព្រះវិញ្ញាណដ៏វិសុទ្ធក៏អាចសម្តែងព្រះអំណោយទាននេះ នៅពេលណាដែលមានអ្នកជឿណាម្នាក់បានត្រៀមខ្លួនហើយ និង អាចឲ្យទ្រង់ប្រើប្រាស់បាន។ ដូច្នេះហើយយើងត្រូវប្រើប្រាស់ព្រះអំណោយទានរៀងៗខ្លួនរបស់យើង "ស្របតាមព្រះគុណដែលព្រះជាម្ចាស់ប្រទានមកយើង" (គម្ពីររ៉ូម១២:៦) ។ តាមរយៈការកត់ត្រាស្គាល់ពីកាលៈទេសៈទាំងឡាយណាដែលព្រះអំណោយទាននេះបានបើកសម្តែងនៅក្នុងក្រុមជំនុំដំបូងបង្អស់ វានឹងជួយយើងឲ្យស្វែងយល់ឲ្យកាន់តែច្បាស់ពីវាថែមទៀតៈ

ក. នៅពេលដែលលោកពេត្រុសកំពុងតែចែកចាយ។ យើងអាចឃើញវត្តមានព្រះអំណោយទាននេះបានសម្តែងឡើង នៅក្នុងការចែកចាយរបស់លោកពេត្រុស នៅក្នុងគម្ពីរកិច្ចការ ២: ១៦- ៣៦។ យើងក៏អាចមើលឃើញសញ្ញារបស់ព្រះអំណោយទាននេះនៅក្នុងការចែកចាយរបស់ លោកស្ទេផានក្នុងគម្ពីរកិច្ចការជំពូក៧។ (សូមមើលគម្ពីរកិច្ចការ ៦:១០ ផងដែរ)។

ខ. នៅពេលដែលមានបញ្ហាកើតមានឡើងនៅក្នុងក្រុមជំនុំ (ចូររំឭកគម្ពីរកិច្ចការជំពូក១៥)។

គ. នៅពេលដែលមានការបៀតបៀនមកដល់។ (អានគម្ពីរកិច្ចការ ៥:២៦-៣៣) ។ សូមចំណាំខទី២៩ជាពិសេសៈ "យើងខ្ញុំត្រូវស្តាប់បង្គាប់ព្រះជាម្ចាស់ជាជាងស្តាប់បង្គាប់មនុស្ស!" វាពិតជាពាក្យសំដីនៃប្រាជ្ញាដ៏មានឫទ្ធានុភាពមែន។ (សូមមើលគម្ពីរលូកា ១២: ១២ និងគម្ពីរលូកា២១:១៥ ផងដែរ)

ឃ. នៅពេលដែលមនុស្សមានបញ្ហាផ្ទាល់ខ្លួន (គម្ពីរកិច្ចការ ៥:១-១១)។

ព្រះអំណោយទានពាក្យសំដីនៃប្រាជ្ញាពិតជាមានតម្លៃ និង មានប្រយោជន៍ខ្លាំងណាស់! វាប្រាកដជាព្រះអំណោយទានមួយក្នុងចំណោមព្រះអំណោយទានដ៏អស្ចារ្យបំផុត។ យើងប្រហែលជាប្រាថ្នាចង់បានវាខ្លាំងណាស់ ដើម្បីយើងអាចមានប្រយោជន៍នៅក្នុងក្រុមជំនុំ។ ប្រសិនបើព្រះវិញ្ញាណដ៏វិសុទ្ធប្រោសប្រទានឲ្យវាបានសម្តែងចេញតាមរយៈយើងមែន នោះយើងត្រូវគិតថា "ឥឡូវនេះខ្ញុំមានព្រះអំណោយទាននេះហើយ" ។ យើងគប្បីចងចាំថា ទ្រង់ប្រើប្រាស់យើងជាបណ្តាញរបស់ទ្រង់ ដើម្បីប្រទានព្រះអំណោយទានផ្សេងទៅកាន់ព្រះកាយទ្រង់ ដែលជាក្រុមជំនុំនោះ ហើយយើងត្រូវតែសរសើរតម្កើងទ្រង់ដោយបន្ទាបខ្លួនផង។

## ***លំហាត់អនុវត្តន៍***

---

៤ អ្នកជឿផ្តល់ពាក្យសំដីនៃប្រាជ្ញាតាមរយៈ

ក) និយាយម្តងហើយម្តងទៀតនូវអ្វីដែលគេបានអាន។

ខ) ព្យាយាមរកនឹកពីអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យគេនិយាយ។

គ) ព្រះវិញ្ញាណដ៏វិសុទ្ធប្រទានពាក្យពេចន៍ឲ្យគេនិយាយ។

៥ ចូរសរសេរអក្សរ ត នៅពីមុខប្រយោគដែលត្រឹមត្រូវ និង អក្សរ ខ ពីមុខប្រយោគណាដែលខុស។

.........ក) ពាក្យសំដីនៃប្រាជ្ញា ត្រូវបានប្រទានមកនៅពេលណាដែលមានតម្រូវការ។

.........ខ) ពាក្យសំដីនៃប្រាជ្ញា អាចប្រើសម្រាប់ការចែកចាយដំណឹងល្អតែប៉ុណ្ណោះ។

.........គ) ពាក្យសំដីនៃប្រាជ្ញា មិនត្រូវបាននិយាយទៅកាន់មនុស្សដោយផ្ទាល់។

.........ឃ) នៅពេលមនុស្សដែលត្រូវបានគេធ្វើអាក្រក់លើ ពួកគេអាចនឹងទទួលបានពាក្យសំដីនៃប្រាជ្ញា។

# គោលបំណងរបស់ពាក្យសំដីនៃប្រាជ្ញា

នៅក្នុងការសិក្សាពីគោលបំណងព្រះអំណោយទានរបស់ព្រះវិញ្ញាណ យើងមាន ច្បាប់ដ៏សាមញ្ញមួយដែលយើងត្រូវចងចាំៈ "ត្រូវធ្វើការទាំងអស់នេះ ដើម្បីកសាងក្រុមជំនុំ" (គម្ពីរ១កូរិនថូស ១៤:២៦) ។ នៅក្នុងគម្ពីរបកប្រែចាស់ មានន័យកាន់តែជាក់លាក់ ៖ "ត្រូវឲ្យធ្វើការទាំងអស់ សំរាប់នឹងស្អាងចិត្តឡើង" ។ ពាក្យថា ស្អាង មានន័យថា "កសាងឡើង"។ ដូច្នេះ យើងអាចនិយាយបានថា *គោលបំណង* របស់ពាក្យសំដីនៃប្រាជ្ញា គឺការកសាងព្រះកាយរបស់ព្រះគ្រិស្ត។ ការនេះអាចធ្វើទៅបានប្រសិនបើពាក្យសំដីនៃប្រាជ្ញា ត្រូវបាននិយាយទៅកាន់សមាជិកណាម្នាក់ ក្រុមតូចណាមួយ ឬ ក្រុមមនុស្សដ៏ច្រើនកោះករជាមុនសិន។

ព្រះអំណោយទាននេះមិនមែនប្រទានឲ្យអ្នកណាម្នាក់ដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីឲ្យអ្នកនោះមានអារម្មណ៍ល្អ ឬ ប្រកបដោយព្រះវិញ្ញាណជាងអ្នកជឿដទៃទៀតនោះទេ។ វាគឺ អភ័យឯកសិទ្ធិពិសេសដែលត្រូវបានប្រើប្រាស់ដោយព្រះវិញ្ញាណដ៏វិសុទ្ធ។

## *លំហាត់អនុវត្តន៍*

៦ នៅពេលដែលមានបញ្ហានៅក្នុងក្រុមជំនុំមួយ ត្រូវបានដោះស្រាយតាមរយៈពាក្យសំដីនៃប្រាជ្ញា យើងនិយាយថា ក្រុមជំនុំត្រូវបាន

...................................................................................................................................

# ខ. ពាក្យសំដីនៃចំណេះ

**វត្ថុបំណងទី២.** *រៀបរាប់មុខងារ និង គោលបំណងរបស់ ពាក្យសំដីនៃចំណេះ។*

**វត្ថុបំណងទី៣.** *ប្រាប់ពីរបៀបដែលមនុស្សម្នាក់អាចដឹងថា តើគេបានទទួលពាក្យសំដីនៃចំណេះ ឬទេ។*

## និយមន័យ ពាក្យសំដីនៃចំណេះ

"គឺព្រះអង្គ [ព្រះវិញ្ញាណ] ប្រទានអោយម្នាក់ចេះនិយាយប្រកបដោយប្រាជ្ញា" (គម្ពីរ១កូរិនថូស ១២: ៨)។ នៅក្នុងគម្ពីរបកប្រែចាស់ ខដដែលនេះបានបន្តថា "ឲ្យម្នាក់ទៀតមាន*ពាក្យសំដីនៃចំណេះ*ចេះស្ទាត់តាមព្រះវិញ្ញាណដដែល" ។

ចំណេះ មានន័យថា "ការចេះដឹង" ។ ដូចដែលយើងបានឃើញនៅក្នុងការសិក្សាពាក្យសំដីនៃប្រាជ្ញារួចមកហើយ ឃ្លាថា*ពាក្យសំដី*គឺមកពីភាសាក្រិកថា *ឡូកូស*។ *ឡូកូស* មានន័យថា "បង្ហាញនៃ, ប្រធានបទនៃ, ខ្លឹមសារនៃ"។ដូច្នេះ ពាក្យសំដីនៃចំណេះ គឺជាការបង្ហាញពីចំណេះដឹង ប៉ុន្តែតើជាចំណេះដឹងរបស់អ្នកណា?

សូមរំឭក ម្តងទៀតថា គ្រប់ព្រះអំណោយទានរបស់ព្រះវិញ្ញាណទាំងអស់គឺជា*របស់ព្រះវិញ្ញាណ* ឬ *មកតាមរយៈព្រះវិញ្ញាណ*។ ពាក្យសំដីនៃចំណេះ ត្រូវបានប្រទានមកដោយ*ព្រះវិញ្ញាណដដែល* ដែលបានប្រទានពាក្យសំដីនៃប្រាជ្ញាមកដែរ នោះគឺព្រះវិញ្ញាណដ៏វិសុទ្ធ។

ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាអង្គទីបីនៃព្រះត្រៃឯកភាពពេញលេញ ទ្រង់មាន អំណាចគ្រប់គ្រងលើទ្រព្យសម្បត្តិនៃចំណេះដឹងដ៏ធំល្វឹងល្វើយរបស់ព្រះជាម្ចាស់។ មានពាក្យមួយដែលមានប្រភពមកពីភាសាឡាតាំង បានរៀបរាប់ ពីបរិមាណនៃចំណេះដឹងដែលព្រះជាម្ចាស់មាន។ នោះគឺពាក្យ *អ៊មនីស៊ាន (omniscient)*។ អ៊មនីស៊ានមកពីពាក្យពីរម៉ាត់ *អ៊មនី* មានន័យថា "គ្រប់ទាំងអស់" និង *ស៊ាន* មានន័យ "ការដឹង"។ ដាក់ពាក្យពីរនេះបញ្ចូលគ្នា យើងទទួលបានពាក្យថា "ដឹងគ្រប់ទាំងអស់" ។ ដូច្នេះហើយ យើងក៏និយាយថា ព្រះជាម្ចាស់ទ្រង់ជ្រាបគ្រប់ទាំងអស់។ ព្រះជាម្ចាស់ដឹងអ្វីៗគ្រប់យ៉ាង។

តាមរយៈពាក្យសំដីនៃចំណេះ ព្រះវិញ្ញាណដ៏វិសុទ្ធបានអនុញ្ញាតឲ្យអ្នកជឿបាននិយាយចេញផ្នែកតូចមួយ នៃចំណេះដឹងឥតដែនកំណត់របស់ព្រះជាម្ចាស់។ យើងអាចនិយាយបានម្យ៉ាងទៀតថា ព្រះជាម្ចាស់ធ្វើឲ្យអ្នកជឿនិយាយអ្វីដែលពួកគេមិនអាចដឹងបានដោយសមត្ថភាពផ្ទាល់ខ្លួនរបស់គេឡើយ។ ព្រះវិញ្ញាណដ៏វិសុទ្ធបានដាក់ពាក្យឲ្យពួកគេនិយាយ។ ពាក្យនេះគឺបានមកពីព្រះអំណោយទានមួយដែលសម្រាប់អ្នកជឿ ឬ សម្រាប់ព្រះកាយ គេស្គាល់ថា ពាក្យសំដីនៃចំណេះ ។ វាជាព្រះអំណោយទានសម្រាប់ព្រះកាយ ព្រោះវាគឺសម្រាប់ប្រយោជន៍របស់ព្រះកាយ ទោះបីនៅពេលដែលវាត្រូវបាននិយាយទៅកាន់អ្នកដែលមិនជឿក៏ដោយ។

***លំហាត់អនុវត្តន៍***

៧ ពាក្យសំដីនៃចំណេះគឺ

ក) ព្រះអំណោយទាន ដូចគ្នានឹងពាក្យសំដីនៃប្រាជ្ញាដែរ។

ខ) ចំណេះដឹងដែលបានមកពីការសិក្សារៀនសូត្រ។

គ) ចំណេះដឹងខ្លះៗ របស់ព្រះជាម្ចាស់ដែលប្រទានមកតាមរយៈមនុស្ស។

ឃ) ចំណេះដឹងដែលអ្នកនិយាយ មិនដែលធ្លាប់មានពីមុនមក។

## ការបកស្រាយ និង ការអធិប្បាយពីពាក្យសំដីនៃចំណេះនេះ

ការជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ជួយបង្កើនឫទ្ធានុភាពរបស់ព្រះជាម្ចាស់ នៅក្នុងជីវិតរបស់អ្នកជឿ៖ "អ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើអ្នករាល់គ្នា" (គម្ពីរកិច្ចការ ១:៨)។ ឫទ្ធានុភាពនោះ ត្រូវបានបើកសម្តែងតាមរយៈព្រះអំណោយទានរបស់ព្រះវិញ្ញាណ។ គ្រប់ព្រះអំណោយទានរបស់ព្រះវិញ្ញាណទាំងអស់ ស្តែងបង្ហាញពីឫទ្ធានុភាបរបស់ព្រះជាម្ចាស់។ ក្រុមជំនុំដំបូងទទួលបានឫទ្ធានុភាពរបស់ព្រះជាម្ចាស់ នៅបុណ្យថ្ងៃទីហាសិប។ ចាប់ពីពេលនោះមក ឫទ្ធានុភាពនោះត្រូវបានបើកសម្តែង នៅទូទាំងកណ្ឌគម្ពីរកិច្ចការ។

ពេលនេះ យើងនឹងបានឃើញពីរបៀបដែលឫទ្ធានុភាពរបស់ព្រះជាម្ចាស់ត្រូវបានបើកសម្តែងនៅក្នុងពាក្យសំដីនៃចំណេះ។

### មនុស្សដែលពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ និង ពាក្យសំដីនៃចំណេះ

នៅទូទាំងកណ្ឌគម្ពីរកិច្ចការ យើងឃើញពីការបើកសម្តែង ពាក្យសំដីនៃចំណេះជាច្រើន។ យើងនឹងឃើញថា នៅក្នុងគ្រប់ករណីទាំងអស់ដែលអ្នកជឿនិយាយ ពាក្យសំដីនៃចំណេះ គេនិយាយបានអ្វីៗដែលពួកគេគ្មានសមត្ថភាពអាចដឹងពីមុខមកឡើយ លើកលែងតែតាមរយៈព្រះវិញ្ញាណតែប៉ុណ្ណោះ។

១. សូមអានគម្ពីរកិច្ចការ ៥:១-១០។ លោកពេត្រុស *បានដឹង* ថាលោកអាណាណាស និងនាងសាភីរ៉ាបានកុហកព្រះវិញ្ញាណដ៏វិសុទ្ធ។ លោកក៏ *បានដឹង* ដែរថា ពួកគេបានព្រមព្រៀងគ្នានឹងធ្វើការកុហកនេះ។

២. សូមមើលនៅក្នុងគម្ពីរកិច្ចការ ៨:២៣។ លោកពេត្រុស *បានដឹង* ថាលោកស៊ីម៉ូនមានសេចក្តីច្រណែនជូរល្វីង និង បាប នៅក្នុងចិត្តរបស់គាត់។

៣. សូមអានគម្ពីរកិច្ចការ៩:១-១៨។ លោក អាណាណាស (មិនមែនជាលោកអាណាណាស នៅក្នុងគម្ពីរកិច្ចការជំពូក៥ទេ) បានដឹងរឿងខ្លះអំពីលោកស៊ូល តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ។

លោក *បានដឹង* ថាលោកស៊ូលនៅកន្លែងណា (ខ ១១)

លោក *បានដឹង* ថាលោកស៊ូលកំពុងតែអធិស្ឋាន (ខ១១)

លោក *បានដឹង* ថាលោកស៊ូលបានឃើញពីនិមិត្តមួយ (ខ១២)

លោក *បានដឹង* ថាលោកស៊ូលត្រូវបានជ្រើសរើសឲ្យធ្វើជានាវានាំព្រះបន្ទូល (ខ១៥)

លោក *បានដឹង* ថាលោកស៊ូលនឹងរងទុក្ខដើម្បីព្រះជាម្ចាស់ (ខ១៦)

៤. សូមមើលគម្ពីរកិច្ចការ ១០:១៩។ លោកពេត្រុស *បានដឹង* ថាមានបុរសបីនាក់បានមកជួប លោកជួសមុខឲ្យលោក កូនេលាស។

៥. សូមអានគម្ពីរកិច្ចការ ២៧:១៣-៤៤។ លោកប៉ូល *បានដឹង* ថាពួកអ្នកសំពៅ ដែលកំពុងនៅក្នុងសំពៅដែលព្យុះបោកបក់ មិនអាចមានសុវត្ថិភាពបានឡើយ លុះត្រាតែពួកគេនៅឲ្យជាប់ជាមួយសំពៅនោះ។

## *លំហាត់អនុវត្តន៍*

៨ សូមអានគម្ពីរ យ៉ូហាន ៤:៧-១៩។ តើនៅក្នុងខណៈមួយដែលព្រះយេស៊ូបានថ្លែងព្រះបន្ទូលនៃចំណេះ?

.................................................................................................................................................

## មនុស្សអាក្រក់ និង ពាក្យសំដីនៃចំណេះ

ពេលខ្លះមនុស្សអាក្រក់ ដូចជាគ្រូធ្មប់ ហាក់បីដូចជាមានអំណាច ដឹងរឿងផ្សេងៗតាមមធ្យោបាយដ៏ចម្លែក។ តើពួកគេមានពាក្យសំដីនៃចំណេះដែរឬ? អត់ទេ។ តែយ៉ាងណាមិញ វាជារឿងពិតដែលពួកគេទទួលបានចំណេះដឹង ក្នុងរបៀបមិនធម្មតាមួយ។ ប៉ុន្តែ តើវាដោយរបៀបណា?

យើងត្រូវតែចងចាំថា កាលណាមានព្រះវិញ្ញាណដ៏វិសុទ្ធ នោះក៏មានវិញ្ញាណអាក្រក់ផងដែរ។ ព្រះវិញ្ញាណដ៏វិសុទ្ធគឺជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់។ វិញ្ញាណអាក្រក់គឺបានមកពីភាវៈអាក្រក់ គឺសាតាំងនោះឯង។

សាតាំងដឹងអ្វីដែលមនុស្សអាក្រក់មិនអាចដឹងបានដោយអំណោយផ្ទាល់ខ្លួនរបស់ពួកគេ។ ប៉ុន្តែ សាតាំងគឺមិនដូចជាព្រះជាម្ចាស់នោះទេ។ វាមិនដឹងរឿងគ្រប់យ៉ាងនោះទេ វាដឹងតែ*រឿងខ្លះ* ប៉ុណ្ណោះ។

ជាឧទាហរណ៍ មានបុរសម្នាក់នៅក្រុងគេរ៉ាស៊ីន ដែលមានអារក្ស (វិញ្ញាណអាក្រក់) ជាច្រើនចូលក្នុងខ្លួនគាត់។ នៅពេលដែលព្រះយេស៊ូយាងទៅជិត គាត់បានស្រែកយំថា "ឱព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតអើយ! តើព្រះអង្គចង់ធ្វើអ្វីទូលបង្គំ? សូមមេត្តាកុំធ្វើទុក្ខទោសទូលបង្គំអី!" (គម្ពីរកិច្ចការ ៨:២៨)។

តើបុរសម្នាក់ស្គាល់ថាព្រះយេស៊ូជានរណាបានដោយរបៀបណាទៅ? តើគាត់បានដឹងពីឫទ្ធានុភាពរបស់ព្រះយេស៊ូដែលអាចដាក់ទោសគាត់ ដូចម្តេចបាន? គាត់បានដឹងរឿងនេះមកពីអារក្ស (វិញ្ញាណអាក្រក់) ដែលស្ថិតនៅក្នុងគាត់។ ចំណេះទាំងនេះមិនមែនមកពីព្រះជាម្ចាស់នោះទេ។

តើយើងអាចដឹងថា ពាក្យសំដីនៃចំណេះដែលយើងនឹងនិយាយគឺជាពាក្យបានមកពីព្រះវិញ្ញាណដ៏វិសុទ្ធបានដោយរបៀបណា? តើយើងត្រូវតែខ្លាចថា អ្វីដែលយើងអាចនឹងនិយាយគឺមកពីវិញ្ញាណអាក្រក់ដែរឬទេ?

មិនចាំបាច់ភ័យទេ ។ អ្នកជឿមិនត្រូវភ័យខ្លាចពីការនេះសោះឡើយ។ នៅពេលដែលយើងបានពេញដោយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ នោះគ្មានកន្លែងសម្រាប់ទុកឲ្យវិញ្ញាណអាក្រក់ឡើយ។ ពួកវាគ្មានកន្លែងនៅក្នុងយើងឡើយ៖ "ដ្បិតព្រះអង្គដែលគង់នៅក្នុងអ្នករាល់គ្នា ទ្រង់មានអំណាចធំជាងម្ចាស់លោកីយ៍នេះទៅទៀត។" (បានន័យថា ពិភពលោកគឺមិនវិសុទ្ធនោះទេ ។ គម្ពីរ១យ៉ូហាន ៤:៤)

## *លំហាត់អនុវត្តន៍*

៩ ចូរសរសេរអក្សរ ត នៅមុខប្រយោគដែលត្រឹមត្រូវ និង អក្សរ ខ នៅមុខប្រយោគដែលខុស នៅខាងក្រោមនេះ។

........ក) គ្រូធ្មប់អាចមានព្រះអំណោយទាន ពាក្យសំដីនៃចំណេះ របស់ព្រះវិញ្ញាណ។

........ខ) សាតាំង មានសព្វញ្ញូតភាព(ដឹងគ្រប់អ្វីៗទាំងអស់។)

........គ) អ្នកជឿត្រូវតែភ័យខ្លាច ថាពួកគេអាចនឹងនិយាយដោយវិញ្ញាណអាក្រក់ដឹកនាំ។

........ឃ) វិញ្ញាណអាក្រក់ មានអំណោចជាងព្រះវិញ្ញាណដ៏វិសុទ្ធ។

........ង) ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ ទ្រង់មិនទុកចន្លោះសម្រាប់វិញ្ញាណអាក្រក់ទេ។

## វិញ្ញាណមនុស្ស និង ពាក្យសំដីនៃចំណេះ

ពាក្យសំដីនៃចំណេះគឺលើសពីការយល់ឃើញរបស់មនុស្ស។ ពេលខ្លះមនុស្សមិនយល់ពីភាពខុសគ្នាទេ។ ពួកគេគិតអ្វីៗនៅក្នុងគំនិតរបស់ពួកគេផ្ទាល់ ហើយជឿថាវាគឺជាពាក្យសំដីនៃចំណេះ។ គំនិតរបសយើងវា អាចបោកបញ្ឆោតយើងបាន។

ខ្ញុំនៅចាំរឿងមួយដែលអាចអធិប្បាយពីចំណុចនេះបាន។ នៅរសៀលមួយ នៅក្នុងការជួបជុំអធិស្ឋានតាមផ្ទះមួយ មានអ្នកជឿចាប់ផ្តើមមានអារម្មណ៍ថា គេត្រូវការឧបករណ៍តន្រ្តី ដើម្បីជាជំនួយដល់ការច្រៀង។ ចៃដន្យ នៅផ្ទះនោះក៏មានឧបករណ៍តន្ត្រីដែលអ្នកជឿគេចង់បាន។ មានបុរសម្នាក់នៅក្នុងក្រុមនោះ ជឿថាគាត់មានពាក្យសំដីនៃចំណេះ មកពីព្រះអម្ចាស់ បានប្រាប់ទៅស្ត្រីដែលជាម្ចាស់ផ្ទះនោះភ្លាមៗ ថា ឲ្យឧបករណ៍តន្រ្តីជារបស់រួមក្នុងក្រុមទៅ។

នៅពេលដែលស្ត្រីនោះឮដូចនេះ នាងមិនយល់ទល់តែសោះ។ នាងបានប្រាប់ទៅបុរសនោះថា ឧបករណ៍តន្ត្រីនោះមិនមែនជារបស់ផ្ទាល់ខ្លួននាងទេ វាជារបស់ខ្ចីគេប៉ុណ្ណោះ។ បុរសម្នាក់នោះ បាននិយាយចេញមកនូវគំនិតរបស់គាត់ និងមិនមែនតាមរយៈ ពាក្យសំដីនៃចំណេះឡើយ។

តើយើងអាចប្រាកដថា យើងមាន ពាក្យសំដីនៃចំណេះបានដោយរបៀបណា? ខាងក្រោមនេះជាការសាកល្បងដែលអ្នកអាចធ្វើបានតាមកាលៈទេសៈនីមួយៗ៖

១. តើបំណងចិត្តអាត្មានិយមរបស់ខ្ញុំ នាំខ្ញុំឲ្យនិយាយឬ?

២. តើខ្ញុំពិតជាប្រាកដថា ខ្ញុំមានពាក្យសំដីនៃចំណេះដែលមកពីព្រះវិញ្ញាណដ៏វិសុទ្ធដែរឬទេ?

៣. តើខ្ញុំស្គាល់សន្តិភាពរបស់ព្រះជាម្ចាស់នៅក្នុងចិត្តខ្ញុំដែរឬទេ?

៤. តើខ្ញុំមានការមិនពេញចិត្ត និង មិនសប្បាយចិត្តជាមួយនរណាម្នាក់ ឬ ហេតុការណ៍អ្វីមួយដែរឬទេ?

ប្រសិនបើអ្នកមានបញ្ហាក្នុងការឆ្លើយសំណួរទាំងនេះ វាល្អជាជាងដែលអ្នកស្វែងរកព្រះអម្ចាស់មុនពេលដែលអ្នកនិយាយចេញមក។ នៅពេលដែលអ្នករីករាយជាមួយចម្លើយរបស់អ្នកចំពោះសំណួរទាំងអស់ខាងលើនេះហើយ អ្នកគួរតែមានអារម្មណ៍រីករាយក្នុងការនិយាយវាចេញមក។ អ្នកក៏ត្រូវតែដឹងផងដែរថា អ្នកជឿដែលបាននិយាយ ពាក្យសំដីនៃចំណេះ ពួកគេមានអារម្មណ៍ប្រាកដប្រជានៅក្នុងចិត្តជាមួយនឹងអ្វីដែលពួកគេនឹងនិយាយចេញមក។ បទពិសោធន៍នឹងជួយអ្នកឲ្យស្គាល់ពីចលនារបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

### *លំហាត់អនុវត្តន៍*

១០ យើងអាចដឹង ពាក្យសំដីនៃចំណេះដែលបានមកពីព្រះវិញ្ញាណដ៏វិសុទ្ធនៅពេលយើង

ក) ជាគ្រូបង្រៀនដ៏ល្អម្នាក់។

ខ) ដឹងពីសន្តិភាពរបស់ព្រះជាម្ចាស់នៅក្នុងចិត្តរបស់យើង។

គ) មានកំហឹងជាមួយនរណាម្នាក់។

ឃ) គ្មានបំណងចិត្តអាត្មានិយមចំពោះរឿងនោះ។

## គោលបំណងសម្រាប់ពាក្យសំដីនៃចំណេះ

ទាំងគោលបំណងរបស់ ពាក្យសំដីនៃប្រាជ្ញា និង ពាក្យសំដីនៃចំណេះ គឺដូចគ្នា។ វាមានគោលបំណងដើម្បីកសាងព្រះកាយរបស់ព្រះគ្រិស្ត។

ព្រះអំណោយទានទាំងពីរតែងតែធ្វើការជាមួយគ្នា ប៉ុន្តែពាក្យសំដីនៃចំណេះនាំមុខពាក្យសំដីនៃប្រាជ្ញា។ តាមរយៈពាក្យសំដីនៃចំណេះ ព្រះយេស៊ូបានមានព្រះបន្ទូលប្រាប់ស្ត្រីសាសន៍សាម៉ារីពីជីវិតពីអតីតរបស់នាង។ បន្ទាប់មក តាមរយៈពាក្យសំដី នៃប្រាជ្ញា ទ្រង់បានប្រទានដំណោះស្រាយសម្រាប់បញ្ហារបស់នាង។

### *លំហាត់អនុវត្តន៍*

១១ ចូរអានពីគោលបំណងសម្រាប់ពាក្យសំដីនៃចំណេះម្តងទៀត។ តើពាក្យអ្វីដែលបានរៀបរាប់ពីគោលបំណងរបស់ពាក្យសំដីនៃចំណេះ?

..............................................................................................................................................

..............................................................................................................................................

# គ. ជំនឿ

**វត្ថុបំណងទី៤.** *បកស្រាយពីមុខងារ និង គោលបំណងរបស់ព្រះអំណោយទាននៃជំនឿ។*

**វត្ថុបំណងទី៥.** *ប្រាប់ពីរបៀបដែលមនុស្សម្នាក់អាចដឹងថា គេមានព្រះអំណោយទាននៃជំនឿ។*

## និយមន័យជំនឿ

"ព្រះវិញ្ញាណដដែលប្រទានអោយម្នាក់ទៀតមានជំនឿ" (គម្ពីរ១កូរិនថូស ១២:៩)

បើនិយាយជាទូទៅ ជំនឿគឺជាសមត្ថភាពក្នុងការជឿ។ ប្រសិនបើមនុស្សម្នាក់មានជំនឿ យើងនិយាយថា គាត់ជឿ។ ប៉ុន្តែ*ព្រះអំណោយទាន* នៃជំនឿគឺលើសពីជំនឿធម្មតាទៅទៀត ដែលអ្នកជឿទាំងអស់មាន។ វាគឺជាជំនឿ *ពិសេស* ។ វាគឺជាជំនឿ ដែលបានប្រទានមកដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីតម្រូវការពិសេស។ យើងអាចនិយាយថា វាគឺជាផ្នែកមួយតូចនៃការទុកព្រះទ័យដ៏ឥតខ្ចោះរបស់ព្រះជាម្ចាស់ ដែលបានប្រទានមកតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធទៅដល់មនុស្សម្នាក់។

ព្រះអំណោយទាននៃជំនឿមិនមែនជាកម្មសិទ្ធិរបស់អ្នកជឿ ដែលព្រះវិញ្ញាណដ៏វិសុទ្ធបានប្រទានមកតាមរយៈពួកគេឡើយ។ ព្រះអំណោយទាននោះបានដាក់មកក្នុងដួងចិត្តរបស់មនុស្សម្នាក់នៅក្នុងពេលពិសេសមួយ សម្រាប់បំពេញតម្រូវការពិសេសមួយដែរ។ ព្រះអំណោយទាននោះគឺត្រូវបានប្រទានមកឲ្យពួកយើង។ តម្រូវការត្រូវបានបំពេញ ។ ព្រះអំណោយទាននោះក៏បានសម្រេចគោលបំណងរបស់វាដែរ។

### *លំហាត់អនុវត្តន៍*

១២ ចូរសរសេរអក្សរ ត នៅខាងមុខប្រយោគត្រឹមត្រូវ និង អក្សរ ខ នៅខាងមុខប្រយោគដែលខុស។

........ក) អ្នកជឿគ្រប់រូបអាចទទួលបានព្រះអំណោយទាននៃជំនឿបាន។

........ខ) តាមរយៈព្រះអំណោយទាននៃជំនឿ អ្នកជឿទទួលបានប្រភេទជំនឿពិសេសមួយ។

........គ) ដោយសារតែអ្នកជឿទាំងអស់ដែលពេញដោយព្រះវិញ្ញាណ មានព្រះវិញ្ញាណដ៏វិសុទ្ធនោះ ពួកគាត់ក៏អាចទទួលបានព្រះអំណោយទាននៃជំនឿដែរ។

# ការបកស្រាយ និង ការអធិប្បាយពីជំនឿ

ជំនឿគឺតែងតែផ្អែកទៅលើចំណេះដឹង។ រឿងនេះបកស្រាយពីមូលហេតុដែលជំនឿរបស់យើងអាច នឹងមានតិចតួច។ យើងមានចំណេះតិចតួច ដូច្នេះយើងក៏មានជំនឿតិចតួចដែរ។

ព្រះជាម្ចាស់អាចប្រទានព្រះអំណោយទាននៃជំនឿបាន ព្រោះទ្រង់គ្មានការសង្ស័យអំពីឫទ្ធានុភាព របស់ទ្រង់ទេ។ ទ្រង់ក៏មានចំណេះដឹងដ៏ឥតខ្ចោះផងដែរ។ តាមរយៈព្រះអំណោយទាននៃជំនឿ ផ្នែកតូច មួយនៃជំនឿដ៏ឥតខ្ចោះរបស់ព្រះជាម្ចាស់ត្រូវបានប្រទានមក ដើម្បីបំពេញតម្រូវការពិសេសៗមួយចំនួន

តាមធម្មតា មានរឿងបីយ៉ាងកើតឡើង នៅពេលដែលព្រះអំណោយទាននៃជំនឿត្រូវបានបើក សំដែង៖

១. ស្ថានការណ៍ និង ហេតុការណ៍ដែលមិនអាចទៅរួចមួយ នឹងកើតឡើង។

២. ព្រះអំណោយទាននៃជំនឿត្រូវបានប្រទានមក។

៣. ដំណោះស្រាយបញ្ហាត្រូវបានគេរកឃើញ។

រឿងរបស់លោកពេត្រុស និង លោកយ៉ូហានធ្វើដំណើរទៅព្រះវិហារដើម្បីអធិស្ឋាន នឹងជួយយើងឲ្យ ឃើញពីរបៀបដែលព្រះអំណោយទាននៃជំនឿធ្វើការ។ ចូរអានគម្ពីរកិច្ចការ ៣:១-១១ អ្នកនឹងឃើញពីការ នេះដោយផ្ទាល់។ រឿងទាំងបីដែលមានរៀបរាប់នៅខាងលើ គឺសុទ្ធតែបានកើតនៅក្នុងរឿងមួយ នេះ៖

១. បុរសពិការម្នាក់បានអង្គុយយ៉ាងអស់សង្ឃឹមនៅមុខ ខ្លោង ទ្វារលំអ របស់ព្រះវិហារ។ លោកបាន ធ្លាក់ក្នុងភាព "ពិការតាំងពីកំណើត" ប្រមាណជាសែសិបឆ្នាំមកហើយ។ អ្វីដែលគាត់អាចធ្វើ បានគឺ សុំទានដើម្បីរស់តែប៉ុណ្ណោះ។ វា*មិនអាចទៅរួច* នោះទេសម្រាប់មនុស្សមកព្យាបាល គាត់ឲ្យជាបាន។

២. លោកពេត្រុសបានមើលឃើញ ជំនឿ *ពិសេស* មួយនៅក្នុងចិត្តរបស់លោក មួយរំពេច។ ដោយ ព្រោះតែជំនឿនោះ ជាជំនឿរបស់ព្រះជាម្ចាស់ពិតមែន លោកបានមានប្រសាសន៍ទៅកាន់បុរស នោះថា "ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត* ជាអ្នកភូមិណាសារ៉ែត ចូរក្រោកឡើង ដើរទៅចុះ" (ខ៦)។

៣. យើងដឹងថាលោកពេត្រុសពិតជាមានព្រះអំណោយទាននៃជំនឿ តាមរយៈអ្វីដែល *បានកើតឡើង* ចំពោះបុរសម្នាក់នោះ! "រំពេចនោះជើងរបស់គាត់ និងសន្លាក់ឆ្អឹង ក៏ប្រែជាមាំមួន គាត់ក៏ស្ទុះឈរ ឡើង ហើយដើរបាន" (ខ៧ និង៨)។

ព្រះវិញ្ញាណដ៏វិសុទ្ធសព្វព្រះហឫទ័យធ្វើការដូច្នេះ ក្នុងពេលបច្ចុប្បន្ន។ ទ្រង់សព្វព្រះហឫទ័យ ប្រទានឲ្យអ្នកជឿនូវជំនឿពិសេសរបស់ព្រះជាម្ចាស់ សម្រាប់តម្រូវធំៗ និង បញ្ហាពិបាកៗ។ ប្រាកដណាស់ ទ្រង់ត្រូវការអ្នកជឿដូចជាលោកពេត្រុស ដែលនឹងហ៊ានធ្វើសកម្មភាពនៅរាល់ពេលដែលទ្រង់ដាក់ជំនឿនៅ ក្នុងដួងចិត្តរបស់ពួកគាត់។ អ្នកជឿតែងតែភ័យខ្លាចក្នុងការធ្វើការបញ្ចេញសកម្មភាព ហើយពេលនោះ ជំនឿក៏មិនអាចធ្វើការបានឡើយ។

តើខ្ញុំអាចដឹងថា ខ្ញុំមានព្រះអំណោយទាននៃជំនឿបានដោយរបៀបណា? យើងអាចដឹងបាននៅក្នុងបុគ្គលនៅខាងក្នុង គឺវិញ្ញាណរបស់យើងនោះឯង។ ពាក្យថា*ជំនឿ*មានន័យមួយថា " ជំនឿស៊ប់ ។ នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រទានជំនឿដ៏ឥតខ្ចោះរបស់ព្រះជាម្ចាស់មួយផ្នែកតូចមកឲ្យយើង នោះមានជំនឿស៊ប់ យ៉ាងជ្រាលជ្រៅមួយស្ថិតនៅក្នុងចិត្តរបស់យើង ថាព្រះជាម្ចាស់នឹងធ្វើរឿងអ្វីម្យ៉ាង។ អ្នកជឿដែលទទួលបានជំនឿនេះមិនត្រឹមតែ *សង្ឃឹម* ថាព្រះជាម្ចាស់នឹងធ្វើរឿងអ្វីម្យ៉ាងនោះទេ គាត់ថែមទាំង *ដឹង* ថាព្រះជាម្ចាស់នឹងធ្វើការផងដែរ។

### ***លំហាត់អនុវត្តន៍***

---

១៣ ចូរបំពេញប្រយោគខាងក្រោម។

ក) មូលដ្ឋានគ្រឹះរបស់ជំនឿគឺជា.....................................................................................................

ខ) ចំណេះដឹងដ៏ឥតខ្ចោះ គឺចាំបាច់ណាស់សម្រាប់................................................ឥតខ្ចោះ។

គ) អ្នកជឿអ្នកធ្វើបានច្រើនដូចជាលោកពេត្រុស បានធ្វើនៅខ្លោង ទ្វារលំអ ដែរ ប្រសិនបើពួកគេមាន......................................................................................................................

ឃ) តាមរយៈព្រះអំណោយទាននៃជំនឿ យើងដឹងថាព្រះជាម្ចាស់នឹង...........................................

## គោលបំណងសម្រាប់ព្រះអំណោយទាននៃជំនឿ

សម្រាប់ព្រះអំណោយទានរបស់ពាក្យសំដីនៃប្រាជ្ញា និង ពាក្យសំដីនៃចំណេះ យើងបានឃើញថាវាមានគោលស្រដៀងគ្នា។ ព្រះអំណោយទានទាំងពីរ គឺសម្រាប់កសាងព្រះកាយរបស់ព្រះគ្រិស្ត។ យើងបានឃើញពីរបៀបដែលព្រះអំណោយទានទាំងពីរធ្វើការជាមួយគ្នាដើម្បីកសាងព្រះកាយ។ គោលបំណងរបស់ព្រះអំណោយទាននៃជំនឿក៏ដូចគ្នាដែរ។

មុនពេលរៀបរាប់ឈ្មោះព្រះអំណោយទានទាំងប្រាំបួនដែលយើងកំពុងសិក្សានេះ លោកប៉ូលបានថ្លែងពីគោលបំណងតាមរបៀបមួយផ្សេង៖ "ព្រះវិញ្ញាណប្រោសប្រទានអោយម្នាក់ៗសំដែងព្រះអំណោយទាន ដើម្បីជាប្រយោជន៍រួម" (គម្ពីរ១កូរិនថូស ១២:៧).

តាមរយៈព្រះអំណោយទាននៃជំនឿ ព្រះកាយទាំងមូលទទួលបានជំនួយ និង ការកសាងឡើង។ ប្រសិនបើមានតែសមាជិកម្នាក់ ដែលទទួលបានប្រយោជន៍ពីការសំដែង ព្រះអំណោយទាននៃជំនឿ នោះព្រះកាយទាំងមូលនឹងនៅតែទទួលបានជំនួយ។ នៅពេលដែលសមាជិកម្នាក់ទទួលបានជំនួយ សមាជិកទាំងអស់ក៏ទទួលបានជំនួយដែរ៖ "ប្រសិនបើមានសរីរាង្គណាមួយឈឺចុកចាប់ សរីរាង្គទាំងអស់ក៏ឈឺចុកចាប់ជាមួយដែរ ប្រសិនបើមានសរីរាង្គណាមួយបានថ្លៃថ្នូរ សរីរាង្គទាំងអស់ក៏អរសប្បាយជាមួយដែរ" (គម្ពីរ១កូរិនថូស ១២:២៦)។

## *លំហាត់អនុវត្តន៍*

១៤ គោលបំណងរបស់ព្រះអំណោយទាននៃជំនឿគឺ

ក) មានចំណុចខ្លះ ដូចជាគោលបំណងរបស់ ពាក្យសំដីនៃប្រាជ្ញាដែរ។

ខ) ខុសគ្នាពីគោលបំណងរបស់ពាក្យសំដីនៃប្រាជ្ញា។

គ) ដូចគ្នាទៅនឹងគោលបំណងរបស់ពាក្យសំដីនៃប្រាជ្ញា។

# ការប្រឡងផ្ទាល់ខ្លួន

**ត្រូវ/ខុស។** ចូរសរសេរអក្សរ ត នៅក្នុងចន្លោះ ខាងមុខប្រយោគណាដែលត្រឹមត្រូវ និង អក្សរ ខ ខាងមុខប្រយោគណាដែលខុស។

.........១ ព្រះអំណោយទានរបស់ព្រះវិញ្ញាណ គឺស្ថិតនៅក្នុងអ្នកជឿ។

.........២ ពាក្យសំដីនៃចំណេះ គឺបានធ្វើការនៅក្នុងគម្ពីរកិច្ចការ ៨:២៣។

.........៣ ដោយនិយាយថា ព្រះជាម្ចាស់មានសព្វញ្ញុតភាព យើងបានន័យថាទ្រង់គឺមានវត្តមាននៅគ្រប់កន្លែង។

.........៤ អ្នកជឿត្រូវបានប្រើប្រាស់ជាបណ្តាញសម្រាប់ផ្តល់ព្រះអំណោយទានរបស់ព្រះជាម្ចាស់ទៅដល់ក្រុមជំនុំ។

.........៥ ព្រះអំណោយទានដែលបានសិក្សានៅក្នុងមេរៀន គឺសម្រាប់អ្នកដឹកនាំនៅក្នុងក្រុមជំនុំជាពិសេស ហើយមិនមែនសម្រាប់អ្នកជឿគ្រប់គ្នានោះទេ។

.........៦ *ពាក្យសំដីនៃប្រាជ្ញា* មានន័យថា "ផ្នែកតូចមួយ" នៃប្រាជ្ញារបស់មនុស្ស ដែលបាននិយាយឡើងនៅក្នុងពេលស័ក្តិសមមួយ។

.........៧ គោលបំណងរបស់ពាក្យសំដីនៃប្រាជ្ញា ពាក្យសំដីនៃចំណេះ និងព្រះអំណោយទាននៃជំនឿគឺដើម្បីកសាងក្រុមជំនុំឡើង។

.........៨ នៅពេលណាដែលអ្នកជឿថ្លែងពាក្យសំដីនៃចំណេះ ពួកគេនិយាយថ្លែងអ្វីម្យ៉ាងដែលពួកគេមិនអាចយល់ដឹងខ្លួនឯងបានឡើយ លុះត្រាតែតាមរយៈព្រះវិញ្ញាណវិញ។

.........៩ គោលបំណងរបស់ព្រះអំណោយទាននៃជំនឿ គឺដូចគ្នាទៅនឹងគោលបំណងរបស់អំណោយទានដទៃផ្សេងទៀតដែរ ប៉ុន្តែវាមានមុខងារផ្សេង។

# ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១ ក) ផ្នែកតូចមួយនៃប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ ដែលបាននិយាយឡើងនៅក្នុងពេលវេលាមួយដ៏ស័ក្តិសម។

៨ ខទី១៧ និង ១៨។ "ព្រះយេស៊ូមានព្រះបន្ទូលថា៖ «នាងនិយាយថា នាងគ្មានប្ដីដូច្នេះ ត្រូវមែន ព្រោះនាងធ្លាប់មានប្ដីប្រាំមកហើយ រីឯបុរសដែលនៅជាមួយនាងសព្វថ្ងៃ មិនមែនជាប្ដីរបស់នាងទេ នាងនិយាយត្រង់មែន»។"

២ ក) ខ

ខ) ត

គ) ត

ឃ) ខ

៩ ក) ខ

ខ) ខ

គ) ខ

ឃ) ខ

ង) ត

៣ "ហេតុនេះ បងប្អូនអើយ សូមនាំគ្នាជ្រើសរើសយកបុរសប្រាំពីររូបក្នុងចំណោមបងប្អូនដែលជាអ្នកមានកេរ្តិ៍ឈ្មោះល្អ ហើយពោរពេញដោយព្រះវិញ្ញាណ និងប្រាជ្ញាឈ្លាសវៃ។ យើងខ្ញុំនឹងតែងតាំងគេអោយបំពេញមុខងារនេះ" ។ (ខ៣)។

១០ ខ) ដឹងពីសន្តិភាពរបស់ព្រះជាម្ចាស់នៅក្នុងចិត្តរបស់យើង។

ឃ) គ្មានបំណងចិត្តអាត្មានិយមចំពោះរឿងនោះ។

៤ គ) ព្រះវិញ្ញាណដ៏វិសុទ្ធប្រទានពាក្យពេចន៍ឲ្យគេនិយាយ។

១១ ធ្វើឲ្យចម្រើនឡើង ,កសាងឡើង

៥ ក) ត

ខ) ខ

គ) ខ

ឃ) ត

១២ ក) ត

ខ) ត

គ) ត

៦ ធ្វើឲ្យចម្រើន , កសាងឡើង

១៣ ក) ចំណេះដឹង

ខ) ជំនឿ

គ) ព្រះអំណោយទាននៃជំនឿ

ឃ) ធ្វើសកម្មភាព

៧ គ) ចំណេះដឹងខ្លះៗ របស់ព្រះជាម្ចាស់ដែលប្រទានមកតាមរយៈមនុស្ស។

ឃ) ចំណេះដឹងដែលអ្នកនិយាយ មិនដែលធ្លាប់មានពីមុនមក។

១៤ គ) ដូចគ្នាទៅនឹងគោលបំណងរបស់ពាក្យសំដីនៃប្រាជ្ញា។

# មេរៀនទី ៨ ការប្រោសឲ្យជាពីជម្ងឺ ការធ្វើការអស្ចារ្យ និង ថ្លែងព្រះបន្ទូល

នៅក្នុងមេរៀនទាំងបីចុងក្រោយក្នុងមុខវិជ្ជារបស់យើង គឺមាននិយាយអំពីព្រះអំណោយទានរបស់ព្រះវិញ្ញាណប្រាំបួនដែលមានរៀបរាប់នៅក្នុង គម្ពីរ១កូរិនថូស ១២:៨-១០។ នៅក្នុងមេរៀនមុន យើងបានសិក្សាអំពីព្រះអំណោយទានបីដំបូង គឺមានពាក្យសំដីនៃប្រាជ្ញា ពាក្យសំដីនៃចំណេះ និង ជំនឿ។ យើងបានឃើញថា ព្រះអំណោយទានទាំងនេះ គឺជាការបើកសំដែងពីឫទ្ធានុភាពរបស់ព្រះជាម្ចាស់។ យើងក៏បានរៀនផងដែរថា ព្រះអំណោយទានទាំងអស់នេះមានលក្ខណៈអធិធម្មជាតិ (លើសធម្មជាតិ)។ គ្មានព្រះអំណោយទានណាមួយអាចត្រូវបានកាន់កាប់ដោយមនុស្សខ្លួនឯងបានឡើយ។

រឿងមួយទៀតដែលយើងបានរៀនហើយ គឺថាគ្រប់ព្រះអំណោយទានរបស់ព្រះវិញ្ញាណទាំងអស់មានគោលបំណងតែមួយ។ ព្រះអំណោយទានទាំងអស់គឺសម្រាប់កសាងព្រះកាយរបស់ព្រះគ្រិស្តឡើង។

នៅក្នុងមេរៀននេះ យើងនឹងសិក្សាពីព្រះអំណោយទានរបស់ព្រះវិញ្ញាណបីបន្ថែមទៀត។ យើងនឹងរៀនអំពីពួកវាទៅតាមលំដាប់លំដោយដែលពួកវាត្រូវបានរៀបរាប់នៅក្នុងព្រះគម្ពីររបស់អ្នក។ អ្នកប្រាជ្ញខ្លះបានដាក់វាទៅតាមលំដាប់លំដោយផ្សេងគ្នា។ យ៉ាងណាមិញ ដោយសារតែពួកវាបានមកពីព្រះវិញ្ញាណដ៏វិសុទ្ធ ការសិក្សាលំដាប់លំដោយរបស់ពួកវាគឺមិនសំខាន់នោះទេ។ យើងនឹងចំណាំថា របៀបដែលព្រះអំណោយទានទាំងនេះធ្វើការគឺ ត្រួតលើគ្នាក្នុងពេលខ្លះ។ ពេលខ្លះព្រះអំណោយទានមួយចំនួនហាក់បីដូចជាលេចឡើងនៅក្នុងពេលតែមួយ។

អ្នកប្រហែលជាបានដឹងថា ព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលមកកាន់អ្នកទាក់ទងទៅនឹងរបៀបដែលព្រះអំណោយទានទាំងនេះធ្វើការហើយ។ អ្នកនឹងចង់ស្តាប់បង្គាប់ព្រះសូរសៀងរបស់ទ្រង់។ ការអធិស្ឋាននឹងជួយអ្នក។ នៅពេលដែលអ្នកដឹងថា ព្រះវិញ្ញាណដ៏វិសុទ្ធធ្វើចលនានៅលើអ្នក សូមចុះចូលជាមួយទ្រង់។ ដំបូង វាប្រហែលជាមិនងាយស្រួលទេ ប៉ុន្តែប្រសិនបើអ្នកប្រាថ្នាចង់ឲ្យព្រះជាម្ចាស់ប្រើប្រាស់អ្នក អ្នកអាចជាព្រះពរមួយទៅដល់ព្រះកាយរបស់ទ្រង់ គឺក្រុមជំនុំនោះឯង។

## *គម្រោងនៃមេរៀន*

ក. ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ

ខ. ការធ្វើការអស្ចារ្យ

គ. ការថ្លែងព្រះបន្ទូល

## *វត្ថុបំណងនៃមេរៀន*

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. បកស្រាយពីមុខងារ និងគោលបំណងរបស់ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ។

២. ប្រាប់ពីរបៀបដែលអ្នកអាចដឹងថា តើអ្នកត្រូវបានប្រើប្រាស់ដោយព្រះវិញ្ញាណដ៏វិសុទ្ធដើម្បី សំដែងពីព្រះអំណោយទាននៃការប្រោសឲ្យជាពីជំងឺដែរឬទេ។

៣. ប្រាប់ពីមុខងារ និង គោលបំណងរបស់ព្រះអំណោយទាននៃការធ្វើការអស្ចារ្យ។

៤. ដឹងពីការអស្ចារ្យដែលកើតមាននៅក្នុងគម្ពីរកិច្ចការ ហើយបកស្រាយពីរបៀបដែលដឹងថាវា គឺជាការអស្ចារ្យមែន។

៥. ប្រាប់ពីមុខងារ និង គោលបំណងនៃការថ្លែងព្រះបន្ទូល។

## *សកម្មភាពក្នុងការសិក្សា*

១. អានគម្ពីររ៉ូម ១២:៣-៦ និង គម្ពីរ១ពេត្រុស ៤:១០-១១។

២. អានសេចក្ដីសង្ខេបពីការវិវត្តន៍របស់មេរៀន។ នៅក្នុងមេរៀនមុខ អ្នកបានសរសេរនិយមន័យនៃព្រះអំណោយទានដំបូងទាំងបីយ៉ាងនៅក្នុងសៀវភៅកត់ត្រារបស់អ្នក។ ពេលនេះ សូមធ្វើដូច្នោះទៀត ចំពោះព្រះអំណោយទានទាំងបីនៅក្នុងមេរៀននេះដែរ។

៣. ចូរមើលនិយមន័យពាក្យសំខាន់នៅក្នុងអក្ខរានុក្រមមុខពេលចាប់ផ្ដើមមេរៀននេះ។

៤. ធ្វើលំហាត់ទាំងឡាយណាដែលអ្នកបានឃើញ។

៥. ទន្ទេញខគម្ពីរ ១កូរិនថូស ១៣:១១-១២។

៦. ធ្វើការប្រឡងផ្ទាល់ខ្លួននៅចុងបញ្ចប់នៃមេរៀននេះ។

## *ពាក្យសំខាន់*

| | | |
|---|---|---|
| ផ្ទុះឡើង | គ្រូមន្តអាគម | ពហុវចនៈ |
| ពិការភាព | ឧបសគ្គ | អ្នកប្រាជ្ញ |

# ក. ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ

**វត្ថុបំណងទី១.** *បកស្រាយពីមុខងារ និងគោលបំណងរបស់ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ។*

**វត្ថុបំណងទី២.** *ប្រាប់ពីរបៀបដែលអ្នកអាចដឹងថាតើអ្នកត្រូវបានប្រើប្រាស់ដោយព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីសំដែងពីព្រះអំណោយទាននៃការប្រោសឲ្យជាពីជំងឺដែរឬទេ។*

## និយមន័យរបស់ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ

"ព្រះវិញ្ញាណដដែលប្រទានអោយម្នាក់ទៀតចេះប្រោសមនុស្សអោយជាពីជំងឺ" (គម្ពីរ១កូរិនថូស ១២:៩)

(ចំពោះភាសាក្រិកCharismataនិងអង់គ្លេសGiftsសម្រាប់អំណោយទាននេះប្រើជាពហុវចនៈនេះជាមូលហេតុដែលយើងថែមពាក្យ *ទាំងឡាយ*)

*ការប្រោសឲ្យជាពីជំងឺ* មានន័យថា "ធ្វើឲ្យដូចដើម ឬ ឲ្យប្រសើរឡើង"។ *ព្រះអំណោយទាន* មានន័យថា "ព្រះគុណ, ការគាប់ព្រះទ័យ, ការមេត្តាប្រណី"។ វាមានសារៈសំខាន់ណាស់ដែលយើងត្រូវគិតពីពាក្យថា *ព្រះអំណោយទានទាំងឡាយ។* ព្រះអំណោយទានទាំងឡាយ គឺពហុ។ *ពហុ* មានន័យថា "ច្រើនជាងមួយ" ។ នៅក្នុងករណីនេះ *ព្រះអំណោយទានទាំងឡាយ* មានន័យថា " ព្រះអំណោយទាននៃការប្រោសឲ្យជាពីជំងឺច្រើនជាងមួយ"។ យើងនឹងរៀនបន្ថែមទៀតពីរឿងនេះនៅពេលក្រោយ។

ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ គឺជាការបើកសំដែងព្រះគុណរបស់ព្រះជាម្ចាស់ ព្រមទាំងការគាប់ព្រះទ័យ និង ព្រះហឫទ័យមេត្តាប្រណីរបស់ទ្រង់ផង។ លោកហារើត ខាតជើនិយាយថា "ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺគឺជាការបើកសំដែងព្រះឫទ្ធានុភាពរបស់ព្រះជាម្ចាស់នៅក្នុងដែន វង្វង់ (ទីកន្លែង) របស់ជំងឺ។

ព្រះអំណោយទានទាំងនេះហូរចេញពីព្រះវិញ្ញាណដ៏វិសុទ្ធតាមរយៈអ្នកជឿ ហើយបន្ទាប់មកទៅដល់អស់អ្នកដែលត្រូវការការប្រោសឲ្យជាពីជំងឺ។ ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ គឺផ្តល់ទៅឲ្យអស់អ្នកដែលត្រូវការ។ ពួកវាត្រូវបានបើកសំដែងតាមរយៈពួកអ្នកជឿ។ ដូច្នេះ វាមិនត្រឹមត្រូវនោះទេ ដែលនិយាយថាអ្នកជឿណាម្នាក់ មានព្រះអំណោយទាននៃការប្រោសឲ្យជាពីជំងឺ។ វាប្រសើរជាងដែលនិយាយថា ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ ត្រូវបានបើកសំដែងនៅក្នុងក្រុមជំនុំ គឺបានមកពីព្រះវិញ្ញាណដ៏វិសុទ្ធ និង តាមរយៈពួកអ្នកជឿដែលមានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធនោះ។

## *លំហាត់អនុវត្តន៍*

១ ចូរបំពេញប្រយោគខាងក្រោម៖

ក) ពាក្យថា *ពហុ* មានន័យថា ......................................................................................

ខ) ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ គឺត្រូវបានប្រទានមកតាមរយៈ..................

គ) ពាក្យថា *ការប្រោសឲ្យជាពីជំងឺ* មានន័យថា.........................................................................

# ការបកស្រាយ និង ការអធិប្បាយពីព្រះអំណោទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ

ជំងឺ, រោគា, ពិការភាព។ ទាំងនេះគឺជារឿងធម្មតារបស់មនុស្ស។ ទោះបីជាពួកអ្នកជឿក៏មានវាដែរ។ ពួកវាគឺជាលទ្ធផលដែលមនុស្សបានធ្លាក់ទៅក្នុងអំពើបាប។

នេះមិនមែនមានន័យថាមនុស្សម្នាក់នោះ ឈឺដោយសារតែគេមានអំពើបាបនោះឡើយ។ ពួកសាវ័ករបស់ព្រះយេស៊ូបានសួរទៅកាន់ទ្រង់ថា "ព្រះគ្រូ បុរសនេះកើតមកខ្វាក់ដូច្នេះ តើបណ្តាលមកពីបាបរបស់នរណា? បាបរបស់គាត់ផ្ទាល់ ឬបាបរបស់ឪពុកម្តាយគាត់?" ។ ព្រះយេស៊ូមានព្រះបន្ទូលតបថា៖ "គាត់ខ្វាក់ មិនមែនមកពីបាបរបស់ឪពុកម្តាយគាត់ ឬបាបរបស់គាត់ទេ"។(គម្ពីរយ៉ូហាន ៩:២-៣)។

មានពេលខ្លះមនុស្សធ្លាក់ខ្លួនឈឺក៏ដោយសារតែគាត់មានបាប។ ព្រះយេស៊ូធ្លាប់បានមានព្រះបន្ទូលថា "ឥឡូវនេះ អ្នកបានជាហើយ កុំប្រព្រឹត្តអំពើបាបទៀតអោយសោះ ក្រែងលោកើតការអាក្រក់ដល់អ្នកលើសមុនទៅទៀត" (គម្ពីរយ៉ូហាន ៥:១៤)។

មិនថាមូលហេតុនៃ ជំងឺ រោគា ឬ ពិការភាពនោះជាអ្វីឡើយ ព្រះជាម្ចាស់ទ្រង់សព្វព្រះហឫទ័យ ឲ្យយើងបានជា។ ទោះជាយ៉ាងណាក៏ដោយ មានពេលខ្លះ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងមិនប្រោស អ្នកដែលត្រូវការការប្រោសឲ្យជាពីជំងឺនោះឡើយ។ មានមូលហេតុមួយចំនួនសម្រាប់រឿងនេះ។

១. *មិនជឿ។* "ព្រះជាម្ចាស់អាចសំរេចកិច្ចការសព្វគ្រប់ទាំងអស់ដល់អ្នកជឿ"។ ឪពុករបស់ក្មេងបន្លឺសំឡេងឡើងភ្លាមថា៖ "ខ្ញុំប្របាទជឿហើយ! សូមមេត្តាជួយអោយខ្ញុំប្របាទ ដែលជាអ្នកមិនជឿនេះផង!" (គម្ពីរម៉ាកុស ៩:២៣-២៤)។

២. *គ្មានទំនាក់ទំនងសមរម្យជាមួយព្រះកាយ។*" ដ្បិតអ្នកណាពិសានំប៉័ង និងពិសាពីពែងនោះដោយមិនបានយល់ដល់ព្រះកាយរបស់ព្រះអម្ចាស់ទេ អ្នកនោះយកទោសមកដាក់លើខ្លួនឯងផ្ទាល់។ ហេតុនេះហើយបានជានៅក្នុងចំណោមបងប្អូនមានគ្នាច្រើនខ្សោយកម្លាំង និងឈឺ ហើយមានមួយចំនួនធំបានស្លាប់។ (គម្ពីរ១កូរិនថូស ១១:២៩-៣០)។ *មិនខ្វល់ខ្វាយពីព្រះកាយរបស់ព្រះអម្ចាស់* បានន័យថាមិន ទទួលស្គាល់សមាជិកដទៃទៀតនៃព្រះកាយរបស់ព្រះ អម្ចាស់ ទុកជាផ្នែកនៃរូបកាយរបស់គេដែរ។

៣. មូលហេតុពិសេសៗ។ សូមអានគម្ពីរ២កូរិនថូស ១២:៧-១០។

## លំហាត់អនុវត្តន៍

២ ពេលខ្លះ គ្មានការប្រោសឲ្យជាពីជំងឺកើតមានឡើង ដោយព្រោះតែ

ក) ព្រះជាម្ចាស់ប្រើប្រាស់ ជំងឺនោះដើម្បីធ្វើការអ្វីមួយនៅក្នុងជីវិតរបស់បុគ្គលម្នាក់នោះ។

ខ) មនុស្សម្នាក់នោះត្រូវការជំនឿថែមទៀត។

គ) មនុស្សម្នាក់នោះ ធ្វើអាក្រក់ទៅលើបងប្អូនផ្សេងទៀត។

ឃ) ការមិនជឿ រារាំងមិនឲ្យព្រះជាម្ចាស់ធ្វើការបាន។

យើងចង់ស្វែងយល់ ពីរបៀបដែលព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ ធ្វើការ។ វាអាចធ្វើទៅបាន ដោយការគិតពិចារណាសំណួរមួយចំនួននេះ។

## តើនរណាដែលព្រះវិញ្ញាណដ៏វិសុទ្ធអាចប្រើប្រាស់ដើម្បីនាំព្រះអំណោយទាននៃការប្រោសឲ្យជាពីជំងឺ?

តើការបើកសំដែងព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ កំណត់សម្រាប់តែមនុស្សពិសេសមួយចំនួនឬ? ប្រាកដណាស់ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងប្រើប្រាស់នរណាក៏ដោយ ឲ្យតែទ្រង់អាចប្រទានព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺទៅកាន់មនុស្សដែលមានតម្រូវការ ប៉ុន្តែព្រះអំណោយទានទាំងនេះ នឹងបានហូរកាន់តែរលូន តាមរយៈអស់អ្នកដែលបានជ្រមុជនៅក្នុងព្រះវិញ្ញាណ។

ទោះជាយ៉ាងណាក៏ដោយ ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ ភាគច្រើនត្រូវបានបើកសំដែងតាមរយៈអ្នកដឹកនាំក្រុមជំនុំ។ នេះក៏ដោយសារតែ ជីវិតរបស់ពួកគេទាំងមូលត្រូវបានថ្វាយសម្រាប់ការបម្រើមនុស្ស។ ពួកគេក៏ អាចមានទំនាក់ទំនងជាមួយមនុស្សជាច្រើនដែលមានតម្រូវការ។

សូមមើលនៅក្នុងចំណុចទាំងប៉ុន្មានខាងក្រោមនេះ ។ អ្នកនឹងមើលឃើញ អំពីនរណាដែលព្រះវិញ្ញាណដ៏វិសុទ្ធបានប្រើប្រាស់សម្រាប់ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ នៅក្នុងគម្ពីរកិច្ចការ៖

១. លោកពេត្រុស និង លោកយ៉ូហាន (សាវ័ក) គម្ពីរកិច្ចការ ៣:១-១១។

២. លោកពេត្រុស (សាវ័ក) គម្ពីរកិច្ចការ៥:១៥។

៣. លោកភីលីព (អ្នកផ្សាយដំណឹងល្អ) គម្ពីរកិច្ចការ ៨:៥-៧។

៤. អាណាណាស (អ្នកជឿដែលគេមិនបានស្គាល់) គម្ពីរកិច្ចការ ៩:១៧-១៨។

៥. លោកពេត្រុស (សាវ័ក) គម្ពីរកិច្ចការ ៩:៣២-៣៤។

៦. លោកប៉ូល (សាវ័ក) គម្ពីរកិច្ចការ ១៤:៨-១០។

៧. លោកប៉ូល (សាវ័ក) គម្ពីរកិច្ចការ ២៨:៧-៩។

នៅក្នុងចំណុចខាងលើនេះ ការប្រោសឲ្យជាពីជំងឺ បានមកតាមរយៈពួកសាវ័ក។ យើងដឹងការនេះបាន ដោយសារតែគម្ពីរកិច្ចការ គឺជាការកត់ត្រាអំពីសកម្មភាពរបស់ពួកសាវ័ក។

លោកសាវ័កយ៉ាកុប បានផ្តល់ការណែនាំពិសេសមួយទៅដល់ក្រុមអ្នកជឿមួយទៀតដែលអាចនឹងមានព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យបានជាពីជំងឺ។ អ្នកទាំងនោះគឺជាក្រុមចាស់ទុំ៖ "ក្នុងចំណោមបងប្អូន បើនរណាមានជំងឺ ត្រូវអញ្ជើញព្រឹទ្ធាចារ្យរបស់ក្រុមជំនុំមក" (គម្ពីរយ៉ាកុប ៥:១៤) ។ ត្រង់នេះបានបង្រៀនយើងថា ព្រះវិញ្ញាណដ៏វិសុទ្ធនឹងប្រទានព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺតាមរយៈអ្នកដឹកនាំក្រុមជំនុំ។ ព្រះវិញ្ញាណដ៏វិសុទ្ធ ក៏អាចនឹងប្រើប្រាស់អ្នកជឿណាម្នាក់ នៅក្នុងព្រះអំណោយទាននៃការប្រោសឲ្យជាពីជំងឺ ដូចដែលទ្រង់បានប្រើលោកអាណាណាសដែរ។

## តើជំងឺ រោគា និង ពិការភាពប្រភេទណាដែលអាចប្រោសឲ្យជាសះស្បើយបាន?

" បន្ទាប់មក ព្រះយេស៊ូយាងទៅ....ប្រោសអ្នកជំងឺ និងអ្នកពិការគ្រប់ប្រភេទអោយបានជាផង។" (គម្ពីរម៉ាថាយ ៩:៣៥)។ រឿងដូចគ្នានេះក៏បានកើតឡើងនៅក្នុងក្រុមជំនុំដំបូងបង្អស់ដែរ៖ "មានមនុស្សជាច្រើននាំគ្នាធ្វើដំណើរមកពីភូមិនានា នៅជិតក្រុងយេរូសាឡឹម ទាំងសែងអ្នកជំងឺ និងអ្នកដែលមានវិញ្ញាណអាក្រក់ចូលមកជាមួយផង អ្នកទាំងនោះបានជា*គ្រប់ៗគ្នា*។" (គម្ពីរកិច្ចការ ៥:១៦ សូមមើលអក្សរទ្រេត)។

ឥឡូវនេះយើងនឹងមើលទៅលើ ជំងឺ រោគា និង ពិការភាពផ្សេងៗដែលមាននៅក្នុងគម្ពីរកិច្ចការ។

១. ពិការជើង (ពិការភាព) គម្ពីរកិច្ចការ៣:២
២. ជំងឺ (សេចក្តីឈឺចាប់) គម្ពីរកិច្ចការ ៥:១៦
៣. ជំងឺស្លាប់អវៈយវៈ (ជំងឺខ្វិន) និង ស្លាប់ដៃជើង (ពិការភាព) គម្ពីរកិច្ចការ ៨:៧
៤. ខ្វាក់ ( រោគា ឬ ពិការភាព) គម្ពីរកិច្ចការ ៩:១៧-១៨
៥. ជំងឺស្លាប់អវៈយវៈ (ជំងឺខ្វិន) គម្ពីរកិច្ចការ ៩:៣៣
៦. ពិការជើង ( ពិការភាព) គម្ពីរកិច្ចការ ១៤:៨-១០
៧. គ្រុន ( ជំងឺ ) និង រាគមួល (រោគា) គម្ពីរកិច្ចការ ២៨:៨

យើងអាចនិយាយបានថា គ្មានជំងឺ រោគា ឬពិការភាពណាដែលមិនអាចព្យាបាលបាន តាមរយៈព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺនេះឡើយ។

មានការនិយាយអំពីព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺនេះជាច្រើន។ ព្រះអំណោយទាននេះ គឺត្រូវបានលើកមកនិយាយបីដងនៅក្នុងជំពូកទីដប់ពីរ នៃគម្ពីរ១កូរិនថូស (៩,២៨, ៣០) ហើយរាល់ដង វាត្រូវបាននិយាយជាទម្រង់ពហុវចនៈ។ នៅក្នុង ចំណោមព្រះអំណោយទានទាំងប្រាំបួននេះមានតែព្រះអំណោយទានមួយនេះទេដែលជាពហុវចនៈ។ ព្រះអំណោយទានផ្សេងទៀត គឺជា*ព្រះអំណោយទាន*តែមួយ។ ទោះជាយ៉ាងណា យើងមិនបានដឹងពីមូលហេតុដែលធ្វើឲ្យមានភាពខុសគ្នារវាងការប្រោសឲ្យជាពីជំងឺ និង ព្រះអំណោយទានដទៃទៀតនោះទេ យើងអាចប្រាកដថា ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ គឺគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការទាំងអស់។

វាប្រហែលជាពាក្យថា *ព្រះអំណោយទានទាំងឡាយ* នោះមានន័យថា អ្នកជឿមួយចំនួនតូចត្រូវបានប្រើប្រាស់ដោយព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីប្រោស ជំងឺ រោគា ឬពិការភាពមួយចំនួន។ ឧទាហរណ៍ នៅ

ក្នុងគម្ពីរកិច្ចការ ជំពូក៨ លោកភីលីពត្រូវបានប្រើដោយព្រះវិញ្ញាណដើម្បីប្រោសមនុស្សដែលមាន ពិការភាព និង អស់អ្នកដែលមានជំងឺខ្វិនដៃជើងផង។ នៅក្នុងពេលបច្ចុប្បន្ននេះ មានបុរសម្នាក់ដែលត្រូវបានប្រើប្រាស់នៅក្នុងព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ គឺលោក ស្មិត វីហ្គល់វើដ។ គាត់ត្រូវបានប្រើនៅក្នុងការប្រោសជំងឺ និង រោគា នៅខាងក្នុង។

មកដល់ត្រង់ចំណុចនេះ សូមឲ្យយើងរំឭកខ្លួនឯងថា "មានព្រះវិញ្ញាណតែមួយដដែល ដែលបំពេញសកម្មភាពទាំងអស់ ហើយប្រទានអោយម្នាក់ៗមានព្រះអំណោយទានផ្សេងៗពីគ្នា តាមព្រះហឫទ័យរបស់ព្រះអង្គ" (គម្ពីរ១កូរិនថូស ១២:១១)។

## តើព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺដំណើរការយ៉ាងដូចម្តេច?

យើងត្រូវដឹងថា វាគ្មានការកំណត់នោះឡើយ។ ការនេះត្រូវបានគេឃើញ នៅពេលដែលគេសិក្សានៅក្នុងករណីប្រោសជំងឺនៅក្នុងកណ្ឌគម្ពីរសម្ពន្ធមេត្រីថ្មី ។ មានការព្យាបាលដោយៈ

១. ការប៉ះ និង ពាក្យសំដី (គម្ពីរម៉ាថាយ ៨:៣; ៩:២៩)។

២. ពាក្យសំដី ( គម្ពីរម៉ាថាយ ៨:៥-១៣) ។ (ចំណាំ៖ ត្រង់នេះអ្នកដែលទទួលបានការប្រោសឲ្យជាពីជំងឺ គឺមិនបាននៅនឹងកន្លែងនោះ ដើម្បីស្តាប់ពាក្យសំដីនោះឡើយ) ។

៣. ការប៉ះ (គម្ពីរម៉ាថាយ ៨:១៥)

៤. ការបង្គាប់បញ្ជា (គម្ពីរម៉ាថាយ ១២:១៣)

៥. ការលាបភក់នៅលើភ្នែកដែលខ្វាក់ និង ពាក្យសំដី ( គម្ពីរយ៉ូហាន ៩:៦)។

៦. ការបង្គាប់បញ្ជា និង លើកឡើងដោយដៃ (គម្ពីរកិច្ចការ ៣:៦-៩)។

៧. ពាក្យសំដី និង ការបង្គាប់បញ្ជារ ( គម្ពីរកិច្ចការ ៩:៣៤)។

យើងសំគាល់ឃើញថា របៀបនៃការប្រោសឲ្យជាពីជំងឺ ភាគច្រើនគឺកើតឡើងដោយសារពាក្យសំដី។ វាសំខាន់ណាស់ ដែលយើងត្រូវចងចាំការនេះ។ ការប៉ះដោយដៃ ការលើកឡើង ឬកាយវិការផ្សេងទៀតអាចនឹងជួយដល់ជំនឿរបស់មនុស្សម្នាក់ទៀត។ ប៉ុន្តែ វាហាក់បីដូចជាកិច្ចការរបស់ព្រះជាម្ចាស់ភាគច្រើនគឺមកតាមរយៈការនិយាយ។ អ្នកដឹកនាំក្រុមជំនុំដំបូងបង្អស់ គេធ្វើការងាររបស់ពួកគេ ដោយពាក្យសំដី។ មើលទៅក៏សមហេតុផលណាស់ដែរ ដែលព្រះជាម្ចាស់នឹងនៅតែដឹកនាំព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺទៅកាន់មនុស្ស តាមរបៀបដូចគ្នានេះ។

ដូច្នេះ ការសន្និដ្ឋានរបស់យើងគឺ ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ ត្រូវបានបើកសំដែងតាមរយៈអ្នកជឿ នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំគេ។

## តើអ្នកជឿអាចដឹងថាពេលណាដែលគេមានព្រះអំណោយទាននៃការប្រោសឲ្យជាពីជំងឺសម្រាប់ចែកចាយ បានដោយរបៀបណា?

សាជាថ្មីម្តងទៀត ដូចគ្នាទៅនឹងព្រះអំណោយទានរបស់ព្រះវិញ្ញាណដទៃទៀតអ៊ីចឹង យើងជឿថា បុគ្គលដែលត្រូវបើកសំដែងព្រះអំណោយទាននោះ នឹងដឹងពីវា យ៉ាងជ្រាលជ្រៅ នៅក្នុងវិញ្ញាណរបស់គាត់ដែរ។ បទពិសោធន៍របស់លោកសាំសុន នៅក្នុងកណ្ឌគម្ពីរសម្ពន្ធមេត្រីចាស់បានអធិប្បាយពីរឿង៖ "ព្រះ

វិញ្ញាណនៃព្រះអម្ចាស់យាងមកសណ្ឋិតលើលោកសាំសុន ហើយខ្សែព្ួរដែលចងដៃលោកក៏របូតចេញដោយងាយ ដូចសរសៃអំបោះត្រូវភ្លើងឆេះ។" (គម្ពីរចៅហ្វាយ ១៥:១៤)។ លោកសាំសុនមិនត្រូវបានប្រើដោយព្រះវិញ្ញាណឲ្យធ្វើការប្រោសជំងឺនោះទេ។ ប៉ុន្តែលោកត្រូវបានប្រើ ឲ្យធ្វើការដ៏មានអានុភាព។ តាមរយៈបទពិសោធន៍របស់គាត់ យើងអាចទទួលបានគំនិតខ្លះៗ ថាតើបទពិសោធន៍របស់យើងនឹងមានលក្ខណៈដូចម្ដេច នៅពេលដែលព្រះវិញ្ញាណដដែលនេះ ទ្រង់សព្វព្រះហឫទ័យបើកសំដែងអង្គទ្រង់តាមរយៈពួកយើង។

អ្នកជឿមិនអាចមានព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺបានតាមតែការចង់បានរបស់គេនោះទេ។ ពួកគេទទួលបានព្រះអំណោយទានទាំងនេះបាន តែនៅពេលដែលព្រះវិញ្ញាណទ្រង់សព្វព្រះទ័យតែប៉ុណ្ណោះ។ មានអ្នកខ្លះទទួលបានបទពិសោធន៍ នៃដំណើរការរបស់ព្រះអំណោយទាននៅក្នុងជីវិតញឹកញាប់ជាងអ្នកដទៃទៀត ប៉ុន្តែនេះក៏ដោយសារតែពួកគេបានរៀនដើរដោយជំនឿ នៅក្រោមការដឹកនាំរបស់ព្រះវិញ្ញាណ។ នេះគឺជាអាថ៌កំបាំងដ៏អស្ចារ្យ។

## *លំហាត់អនុវត្តន៍*

៣ ចូរសរសេរអក្សរ ត នៅមុខប្រយោគដែលត្រឹមត្រូវ។ សរសេរ ខ នៅមុខប្រយោគដែលមិនត្រឹមត្រូវ។

.........ក) ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ ត្រូវបានបើកសំដែង តាមរយៈអ្នកដឹកនាំក្រុមជំនុំតែប៉ុណ្ណោះ។

.........ខ) ពាក្យ *ព្រះអំណោយទានទាំងឡាយ* មានន័យថា មានព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជា ពីជំងឺ ផ្សេងៗគ្នាចំនួនដប់ពីរយ៉ាង។

.........គ) ពាក្យ *ព្រះអំណោយទានទាំងឡាយ* អាចមានន័យថាអ្នកជឿដែលត្រូវបានជ្រើសរើស គេត្រូវបានព្រះវិញ្ញាណប្រើប្រាស់ តាមរបៀបជាច្រើនផ្សេងៗ។

.........ឃ) ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ បានប្រទានមកភាគច្រើនតាមរយៈការលើកឡើងដោយដៃ។

..........ង) យើងអាចនិយាយបានថា ជំងឺ រោគា និង ពិការភាពគ្រប់ប្រភេទ អាចត្រូវបានប្រោសឲ្យជាតាមរយៈព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺនេះបាន។

## គោលបំណងរបស់ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ

ដូចដែល យើងបានឃើញរួចមកហើយ គោលបំណងជាទូទៅរបស់ព្រះអំណោយទានខាងឯវិញ្ញាណទាំងអស់ គឺដើម្បីនឹងកសាងព្រះកាយរបស់ព្រះគ្រិស្ត។ ព្រះអំណោយទានខ្លះធ្វើរឿងនេះបានតាមរបៀបមួយ ហើយខ្លះទៀតតាមរបៀបផ្សេង។ ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ ធ្វើរឿងនេះបានដោយការធ្វើឲ្យសមាជិកមានសុខភាពល្អ និង រឹងមាំខាងរូបកាយ។ ព្រះកាយទាំងមូលដែលផ្សំឡើងពីអ្នកជឿ ទទួលបានជំនួយនៅពេលដែលសមាជិកនីមួយៗ បានចម្រើនខាងរូបកាយ។

ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ តែងតែបង្ហាញខ្លួននៅក្នុងព័ន្ធកិច្ចរបស់អ្នកផ្សាយដំណឹងល្អ។ ព្រះអំណោយទានទាំងនេះ ទាក់ទាញមនុស្សមកស្ដាប់ដំណឹងល្អរបស់ព្រះគ្រិស្ត។ អ្នកជឿជំនាន់មុនបានអធិស្ឋានថា "សូមសំដែងបារមីអោយអ្នកជំងឺបានជា អោយមានទីសំគាល់ និងឫទ្ធិបាដិហារិយ៍កើតឡើង ក្នុងព្រះនាមព្រះយេស៊ូ ជាអ្នកបំរើដ៏វិសុទ្ធ*របស់ព្រះអង្គ" (គម្ពីរកិច្ចការ៤:៣០)។ ព្រះជាម្ចាស់បានឆ្លើយតបការទូលអង្វររបស់ពួកគេះ "សាវ័កបាននាំគ្នាសំដែងទីសំគាល់ដ៏អស្ចារ្យ និងឫទ្ធិបាដិហារិយ៍ជាច្រើន នៅក្នុងចំណោមប្រជាជន ... បណ្ដាជនទាំងប្រុសទាំងស្រីដែលជឿលើព្រះអម្ចាស់បានមកចូលរួមកាន់តែច្រើនឡើងៗ។ (គម្ពីរកិច្ចការ ៥:១២,១៤)។

ដូច្នេះ យើងឃើញពីគោលបំណងរបស់ព្រះអំណោយទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ គឺដើម្បីបំពេញតម្រូវការខាងសាច់ឈាម នៃព្រះកាយរបស់ព្រះគ្រិស្ត និង ដើម្បីជួយនាំមនុស្សមកឯព្រះយេស៊ូ។

# ខ. ការធ្វើការអស្ចារ្យ

**វត្ថុបំណងទី៣.** *ប្រាប់ពីមុខងារ និង គោលបំណងរបស់ព្រះអំណោយទាននៃការធ្វើការអស្ចារ្យ។*

**វត្ថុបំណងទី៤.** *ដឹងពីការអស្ចារ្យដែលកើតមាននៅក្នុងគម្ពីរកិច្ចការ ហើយបកស្រាយពីរបៀបដែលដឹងថាវាគឺជាការអស្ចារ្យមែន។*

## និយមន័យការធ្វើការអស្ចារ្យ

"អោយម្នាក់ទៀតចេះធ្វើការអស្ចារ្យ" (គម្ពីរ១កូរិនថូស ១២:១០)។ នៅក្នុងគម្ពីរបកប្រែចាស់បាននិយាយ "ឲ្យមួយទៀតបានសំដែងការឫទ្ធិបារមី" ។

ពាក្យក្រិកសម្រាប់ "ការអស្ចារ្យ" គឺ *ឌូណាមើស* (dunameis)។ ចេញពីពាក្យនោះ មានពាក្យជាភាសាអង់គ្លេស "ដាយណាមៃ"(រំសេវ)។ រំសេវជាសារធាតុផ្ទុះ។ វាមានកម្លាំងខ្លាំងអស្ចារ្យ។ វាត្រូវបានប្រើប្រាស់ដើម្បីរម្លើងផ្ទាំងថ្មធំៗ ដើម្បីបំផ្លាញអាគារចាស់ៗ និង សម្រាប់គោលបំណងជាច្រើនផ្សេងទៀត។

ពាក្យនេះត្រូវបានប្រើប្រាស់នៅក្នុងឃ្លាថា "ការធ្វើការអស្ចារ្យ" ដែលមានន័យថា "ឫទ្ធានុភាពអធិធម្មជាតិសម្រាប់ធ្វើរឿងដែលមិនអាចទៅរួច"។

លោកហារ៉ាំដ ខាតធី និយាយថា "ការធ្វើការអស្ចារ្យ...គឺជាការបើកសំដែងឫទ្ធានុភាពអធិធម្មជាតិរបស់ព្រះជាម្ចាស់ដែល កែប្រែ (ផ្លាស់ប្ដូរ) , ផ្អាក់ ( ទុកដោយឡែក) ឬ មានពេលខ្លះគ្រប់គ្រងច្បាប់នៃធម្មជាតិទៀតផង។

### *លំហាត់អនុវត្តន៍*

---

៤ តើការអស្ចារ្យអ្វីដែលបានកើតឡើងនៅក្នុងគម្ពីរកិច្ចការជំពូក១៣?

..............................................................................................................................

# ការបកស្រាយ និង ការអធិប្បាយពីការធ្វើការអស្ចារ្យ

យើងអាចបង្កើនការយល់ដឹងរបស់យើង ដោយមើលដំណើររឿងនៃការអស្ចារ្យខ្លះៗ នៅក្នុងព្រះគម្ពីរ។

## ការអស្ចារ្យនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់

មានការអស្ចារ្យជាច្រើនត្រូវរៀបរាប់នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ ។ យើងនឹងរៀបរាប់ខ្លះៗ តែប៉ុណ្ណោះ។ សូមអានរឿងនីមួយៗដោយយកចិត្តទុកដាក់។

១. លោកម៉ូសេបានធ្វើឲ្យទឹកចេញមកពីថ្ម (គម្ពីរនិក្ខមនំ ១៧:១-៦)។

២. ប្រជាជនអ៊ីស្រាអែល ឆ្លងទន្លេយ័រដាន់នៅលើដីស្ងួត (គម្ពីរយ៉ូស្វេ ៣:១៥-១៧)។

៣. លោកយ៉ូស្វេ ធ្វើឲ្យព្រះអាទិត្យនៅនឹងមួយកន្លែង ( គម្ពីរយ៉ូស្វេ ១០:១២-១៣)។

៤. លោកអេលីយ៉ាបានអធិស្ឋាន ឲ្យមានភ្លើងធ្លាក់ចុះមកពីលើមេឃ (គម្ពីរ១ពង្សាវតារក្សត្រ ១៨:៣៧-៣៨)។

៥. លោកអេលីសេបានធ្វើឲ្យផ្លែពួថៅអណ្តែត ( គម្ពីរ២ពង្សាវតារក្សត្រ ៦:១-៧)។

## ការអស្ចារ្យនៅក្នុងខ្សែព្រះជន្មរបស់ព្រះយេស៊ូ

ខាងក្រោមនេះមានរៀបរាប់ការអស្ចារ្យខ្លះៗដែលមានទាក់ទងនឹងព័ន្ធកិច្ចរបស់ព្រះយេស៊ូ។

១. ព្រះយេស៊ូធ្វើឲ្យទឹកក្លាយទៅជាស្រា ( គម្ពីរយ៉ូហាន ២:១-១១)។

២. ព្រះយេស៊ូបានធ្វើឲ្យព្យុះសមុទ្រស្ងប់ ( គម្ពីរម៉ាថាយ ៨:២៣-២៦)។

៣ . ព្រះយេស៊ូ និង លោកពេត្រុសបានដើរនៅលើទឹក ( គម្ពីរម៉ាថាយ ១៤:២២-៣១)។

៤. ព្រះយេស៊ូបានចម្អែតមនុស្សជាច្រើនដោយអាហាររបស់ក្មេងប្រុសម្នាក់ (គម្ពីរយ៉ូហាន៦:៥-១៤)

៥. ព្រះយេស៊ូបានធ្វើឲ្យបុរសម្នាក់រស់ពីស្លាប់ឡើងវិញ ( គម្ពីរយ៉ូហាន ១១:១-៤៤)។

## ការអស្ចារ្យនៅក្នុងក្រុមជំនុំដំបូង

ការអស្ចារ្យនៅក្នុងកណ្ឌគម្ពីរសម្ព័ន្ធមេត្រីចាស់ ប្រហែលជាអាចកើតឡើងដោយសារតែ ព្យាការីដ៏អស្ចារ្យជាអ្នកធ្វើការអស្ចារ្យទាំងនោះ។ ការអស្ចារ្យរបស់ព្រះយេស៊ូ ក៏ប្រហែលដោយសារតែទ្រង់គឺជាបុត្រារបស់ព្រះជាម្ចាស់។ តែការអស្ចារ្យនៅក្នុងកណ្ឌគម្ពីរកិច្ចការប្រហែលជាត្រូវបានបកស្រាយតាមរបៀបផ្សេង។ ការអស្ចារ្យដែលនៅក្នុងគម្ពីរកិច្ចការភាគច្រើន បានមកតាមរយៈមនុស្សសាមញ្ញធម្មតា ដូចជា អ្នកនេសាទ អ្នកទារពន្ធ ជាដើម។ តើពួកគេធ្វើការអស្ចារ្យបានយ៉ាងដូចម្តេច?

មុនពេលយើងធ្វើការបកស្រាយចម្លើយនោះ សូមក្រឡេកទៅមើលការអស្ចារ្យមួយចំនួនដែលមានរៀបរាប់នៅក្នុងគម្ពីរកិច្ចការសិន។ សូមចងចាំថា វាមិនមែនជារឿងងាយស្រួលនោះទេ ក្នុងការនិយាយថាកិច្ចការមួយណាជាការអស្ចារ្យ ហើយមួយណាជាព្រះអំណោយទាននៃការប្រោសឲ្យជាពីជំងឺ ហើយវាមិនខុសគ្នានោះទេ ព្រោះទាំងពីរនេះសុទ្ធតែបានមកពីព្រះវិញ្ញាណតែមួយ។

"ពេលនោះ ព្រះអម្ចាស់បានធ្វើការអស្ចារ្យដ៏ធំៗជាច្រើន តាមរយៈលោកប៉ូល គឺបើគេគ្រាន់តែយកក្រណាត់ ឬកន្សែងដែលបានប៉ះលោកប៉ូល មកដាក់ពីលើអ្នកជំងឺ អ្នកជំងឺនឹងបានជា ហើយវិញ្ញាណអាក្រក់ក៏នឹងចេញពីគេទៅដែរ។ (គម្ពីរកិច្ចការ ១៩:១១-១២)។ ខាងក្រោមនេះជាការរៀបរាប់ខ្លះៗ៖

១. រួចចេញពីគុក ( គម្ពីរកិច្ចការ ៥:១៧-២០; ១២:៥-១៧)។

២. ប្រោសឲ្យមនុស្សស្លាប់រស់ឡើងវិញ ( គម្ពីរកិច្ចការ ៩:៣៦-៤១)។

៣. ខ្មាំងសត្រូវរបស់ព្រះជាម្ចាស់បានខ្វាក់ភ្នែក (គម្ពីរកិច្ចការ ១៣:៦-១១)។

៤. ពស់ចឹកមិនឈឺ ( គម្ពីរកិច្ចការ ២៨:១-៦)។

មានអាថ៌កំបាំងមួយសម្រាប់ការអស្ចារ្យទាំងអស់នេះ ដែលត្រូវបានធ្វើឡើង។ ការអស្ចារ្យទាំងនោះមិនបានប្រើប្រាស់មនុស្សអស្ចារ្យនោះឡើយ។ វាមិនបានប្រើប្រាស់មនុស្សដែលមានអំណាចចម្លែកអស្ចារ្យខ្លួនឯងនោះទេ។ វារឹតតែមិនមែនជាសមត្ថភាពដែលមនុស្សទទួលបាននៅក្នុងសាលារៀនដែរ។ វាគឺជាឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ "រំសេវ" នៃព្រះវិញ្ញាណ គឺត្រូវបានបើកសំដែងដើម្បីបំពេញតម្រូវការដ៏ធំ របស់ព្រះកាយរបស់ព្រះគ្រិស្ត។ ភាគច្រើន ដើម្បីដោះស្រាយឧបសគ្គមួយចំនួន និង បន្តការចែកចាយដំណឹងល្អរបស់ព្រះគ្រិស្ត។

សូមយើងក្រឡេកទៅមើលការអស្ចារ្យមួយនៅក្នុងគម្ពីរកិច្ចការ ឲ្យកាន់តែលំអិតថែមទៀត។ នោះគឺជាការរស់ពីស្លាប់របស់នាងឌ័រកាស នៅក្នុងគម្ពីរកិច្ចការជំពូក៩។

បន្ទាប់ពីនាងឌ័រកាសបានស្លាប់ហើយ គេក៏បានអញ្ជើញលោកពេត្រុសឲ្យទៅជួយនាង។ លោកពេត្រុសបានដឹងថា លោកមិនអាចប្រោសមនុស្សស្លាប់ឲ្យរស់ឡើយ ប៉ុន្តែលោកដឹងថាឫទ្ធានុភាពរបស់ព្រះជាម្ចាស់អាចធ្វើបាន។ លោកក៏បានដឹងដែរថា លោកត្រូវតែអធិស្ឋានប្រសិនបើលោកចង់ឃើញការអស្ចារ្យ។ ការអធិស្ឋានអាចធ្វើឲ្យលោកក្លាយជាបណ្តាញសម្រាប់ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ ដើម្បីឲ្យការអស្ចារ្យអាចកើតមានឡើងបាន។ ដូច្នេះលោកក៏បានធ្វើការអធិស្ឋាន។ បន្ទាប់មកការអស្ចារ្យក៏បានកើតមាន។ ព្រះវិញ្ញាណដ៏វិសុទ្ធបានធ្វើចលនាយ៉ាងជ្រាលជ្រៅនៅក្នុងវិញ្ញាណរបស់លោកពេត្រុស។ លោកបាននិយាយនៅកាន់ឌ័រកាស។ ភ្នែករបស់នាងដែលបានបិទក្រោយស្លាប់យ៉ាងយូរហើយនោះក៏បានបើកឡើងវិញ ហើយនាងក្រោកអង្គុយទាំងមានជីវិតរស់ពេញបរិបូរណ៍។

នៅក្នុងមេរៀនមុន យើងបានដឹងថា អ៊ុមនីស៊ាន(omniscient )សព្វញ្ញុភាព ដែលមានន័យថាដឹងគ្រប់ទាំងអស់ ។ ព្រះជាម្ចាស់ទ្រង់ជ្រាបគ្រប់ទាំងអស់។ ឥឡូវនេះយើងបន្ថែមពាក្យថ្មីមួយទៀតគឺ៖ *អ៊ុមនីភូថេន* (omnipotent)សព្វានុភាព។ វាមានន័យថា មានឫទ្ធានុភាពលើគ្រប់ទាំងអស់"។ ព្រះជាម្ចាស់មានឫទ្ធានុភាពលើគ្រប់ទាំងអស់។

តាមរយៈព្រះអំណោយទាននៃការធ្វើការអស្ចារ្យ ព្រះវិញ្ញាណដ៏វិសុទ្ធបើកសំដែងឫទ្ធានុភាពរបស់ព្រះជាម្ចាស់តាមរយៈអ្នកជឿ។ ឫទ្ធានុភាពនោះអាចឲ្យការដែលមិនអាចទៅរួច កើតមានឡើង។

***លំហាត់អនុវត្តន៍***

៥ ចូរបំពេញប្រយោគទាំងអស់ខាងក្រោម។

ក) ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ត្រូវបានបង្ហាញនៅក្នុងកណ្ឌគម្ពីរសម្ព័ន្ធមេត្រីចាស់ ក៏ដូចជាកណ្ឌគម្ពីរសម្ព័ន្ធមេត្រីថ្មីដែរ គឺតាមរយៈការធ្វើការ...............................................................។

ខ) ការអស្ចារ្យរបស់ព្រះយេស៊ូអាចធ្វើទៅបានដោយសារទ្រង់គឺជា........................................។

គ) ការអស្ចារ្យនៅក្នុងគម្ពីរកិច្ចការអាចធ្វើទៅបានដោយសារតែ............................................។

ឃ) លោកពេត្រុសគឺជាបណ្ដាញសម្រាប់.......................................................................។

ង) ពាក្យមួយសម្រាប់រៀបរាប់ពីឫទ្ធានុភាពរបស់ព្រះជាម្ចាស់គឺ............................................។

## គោលបំណងនៃការធ្វើការអស្ចារ្យ

ហេតុអ្វីបានជាមានការអស្ចារ្យ? អ្នកខ្លះនិយាយថា ព្រោះតែពួកគេចង់ឃើញការអស្ចារ្យ។ ពួកគេគេចង់ឃើញការអស្ចារ្យព្រោះពួកគេចូលចិត្តអ្វីដែលចម្លែក។ អ្នកខ្លះទៀតចង់បានការអស្ចារ្យ សម្រាប់មូលហេតុផ្សេង ជាមូលហេតុដែលប្រកបដោយភាពអាត្មានិយម។ មានពេលមួយព្រះយេស៊ូត្រូវបាន អ្នកភូមិមួយមិនទទួលស្គាល់។ ពួកសាវ័កខឹងសម្បារយ៉ាងខ្លាំង។ ពួកគេទូលសួរថា "បពិត្រព្រះអម្ចាស់! តើព្រះអង្គសព្វព្រះហឫទ័យអោយយើងខ្ញុំហៅរន្ទះភ្លើង មកកំទេចអ្នកទាំងនេះឬ?" (គម្ពីរលូកា ៩:៥៤)។ សូមចំណាំ ការតបទៅវិញរបស់ព្រះយេស៊ូ " ព្រះយេស៊ូបែរទៅរកគេ ហើយស្ដីបន្ទោសគេយ៉ាងខ្លាំង។ បន្ទាប់មកព្រះអង្គយាងឆ្ពោះទៅកាន់ភូមិមួយផ្សេងទៀតជាមួយសិស្ស" ។ ក្នុងន័យនេះព្រះយេស៊ូចង់មានព្រះបន្ទូលថា " គ្មានការអស្ចារ្យណាមួយនឹងកើតមានឡើង សម្រាប់គោលបំណងអាត្មានិយមនោះឡើយ" ។

ការអស្ចារ្យ ក៏ដូចជាព្រះអំណោយទានរបស់ព្រះវិញ្ញាណដទៃផ្សេងទៀតដែរ គឺមានគោលបំណងចម្បងមួយ នោះគឺដើម្បីកសាងព្រះកាយរបស់ព្រះគ្រិស្ដ។ របៀបមួយដែលការធ្វើការអស្ចារ្យអាចសម្រេចគោលបំណងនេះបានគឺការដកចេញនូវឧបសគ្គដែលរារាំងដំណឹងល្អ។ នៅពេលដែលអ្នកជឿត្រូវការការអស្ចារ្យសម្រាប់មូលហេតុមួយនេះ គេនឹងបានឃើញការអស្ចារ្យជាច្រើនថែមទៀត។

នៅក្នុងគម្ពីរកិច្ចការជំពូក ៥ ឧបសគ្គដែលរារាំងការចែកចាយព្រះបន្ទូល គឺទ្វារគុក។ ពួកសាវ័កត្រូវបានគេចាប់ដាក់គុកដោយសារតែការចែកចាយ។ តាមរយៈការអស្ចារ្យ ឧបសគ្គនេះត្រូវបានដកចេញ។ ទ្វារគុក ត្រូវបានបើក ហើយពួកសាវ័កចេញមកបន្តការចែកចាយទៀត។

នៅក្នុងគម្ពីរកិច្ចការ ១៣:៦-១១ លោកប៉ូលប្រឹងប្រែងធ្វើការផ្លាស់ប្រែរាជប្រតិភូម្នាក់ ប៉ុន្តែលោកបានជួបនឹងឧបសគ្គមួយ។ គ្រូមន្តអាគមម្នាក់ ឈ្មោះបារយេស៊ូព្យាយាមបង្វែរលោករាជប្រតិភូចេញពីដំណឹងល្អ។ ព្រះវិញ្ញាណដ៏វិសុទ្ធបានប្រើប្រាស់លោកប៉ូលដើម្បីធ្វើការអស្ចារ្យ ដោយធ្វើឲ្យលោកបារយេស៊ូ ទៅជាខ្វាក់ភ្នែក។ តាមរយៈការធ្វើបែបនេះ ឧបសគ្គក៏ត្រូវបានដកចេញដែរ។

***លំហាត់អនុវត្តន៍***

៦ តើឧបសគ្គរាំងការចែកចាយដំណឹងល្អ ដែលឃើញមាននៅក្នុងគម្ពីរកិច្ចការ១២:១-៥ គឺជាអ្វី?

.................................................................................................................................

# គ. ការថ្លែងព្រះបន្ទូល

**វត្ថុបំណងទី៥.** *ប្រាប់ពីមុខងារ និង គោលបំណងនៃការថ្លែងព្រះបន្ទូល។*

## និយមន័យ ការថ្លែងព្រះបន្ទូល

"អោយម្នាក់ទៀតចេះថ្លែង*ព្រះបន្ទូល" (គម្ពីរ១កូរិនថូស ១២:១០)។

យោងទៅតាមអ្នកប្រាជ្ញព្រះគម្ពីរម្នាក់ ការថ្លែងព្រះបន្ទូលមានន័យថា "ការទស្សន៍ទាយ" នោះគឺការទាយទុកមុន ។ អ្នកប្រាជ្ញព្រះគម្ពីរម្នាក់ទៀតនិយាយថាវាជា "ការបើកបង្ហាញជាសាធារណៈ" នោះមានន័យថា ការចែកចាយ ឬ ការថ្លែងប្រកាសប្រាប់។ យើងនឹងស្វែងយល់បានកាន់តែច្បាស់ថាអ្វីទៅជាការថ្លែងព្រះបន្ទូល ប្រសិនបើយើងយល់ពីរបៀបដែលវាជាការទាយទុកមុនផង និង ជាការថ្លែងប្រកាសប្រាប់ផង។

មិនត្រូវគិតថាការថ្លែងព្រះបន្ទូល គឺដូចជាការចែកចាយធម្មតានោះឡើយ។ ក៏ដូចជាព្រះអំណោយទានរបស់ព្រះវិញ្ញាណផ្សេងទៀតដែរ វាគឺមានភាពអធិធម្មជាតិ។

លោក រ៉ាលហ្វ អិម រីក ( Ralph M. Riggs) គឺជាអ្នកប្រាជ្ញព្រះគម្ពីរជនជាតិអាមេរិកម្នាក់ លោកបាននិយាយថា ការថ្លែងព្រះបន្ទូលគឺ "ការនិយាយភាសារបស់បុគ្គលម្នាក់ប្រកបដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ឬ សមត្ថភាពវិសុទ្ធ(អាទិទេព) ក្នុងការថ្លែងប្រកាសប្រាប់ ក៏ដូចជាក្នុងការទាយទុកមុនដែរ។"

## ការបកស្រាយ និង ការអធិប្បាយ អំពីការថ្លែងព្រះបន្ទូល

នៅក្នុងមេរៀនទី៣នៃមុខវិជ្ជានេះ យើងបានសិក្សាពីអំណោយទានទាំងប៉ុន្មាននៃព័ន្ធកិច្ច។ យើងបានដឹងថា មានព្រះអំណោយទានមួយក្នុងចំណោមព្រះអំណោយទាននៃព័ន្ធកិច្ចនោះគឺ *ព្យាការី*៖ " ព្រះទ្រង់បានតាំងអ្នកខ្លះ..........ពួកគ្រូអធិប្បាយ [ព្យាការី]" (គម្ពីរបកប្រែចាស់)។ ព្រះគ្រិស្តជាព្រះសិរសារបស់ក្រុមជំនុំ ត្រូវបានគេហៅថាជាព្រះដែលបានប្រទានព្រះអំណោយទានទាំងនេះ។ ពេលនេះយើងកំពុងតែសិក្សាពីព្រះអំណោយទានរបស់ព្រះវិញ្ញាណ។ ព្រះដែលបានប្រទានព្រះអំណោយទានខាងការថ្លែងព្រះបន្ទូលនេះគឺព្រះវិញ្ញាណដ៏វិសុទ្ធ៖ "គឺព្រះអង្គ [ព្រះវិញ្ញាណ] ប្រទាន... អោយម្នាក់ទៀតចេះថ្លែង*ព្រះបន្ទូល" (គម្ពីរ១កូរិនថូស ១២:៨-១០)។

តើភាពខុសគ្នារវាង *ព្យាការី* និង *ការថ្លែងព្រះបន្ទូល* គឺជាអ្វី? ព្រះអំណោយទានជាព្យាការីគឺជាព្រះអំណោយទានរបស់អ្នកដឹកនាំពេញពេលសម្រាប់ព្រះកាយ។ ព្រះអំណោយទានខាងការថ្លែងព្រះបន្ទូលគឺជាព្រះអំណោយទាននៃការជំរុញឲ្យនិយាយ។ ព្រះអំណោយទានជាព្យាការី គឺសម្រាប់សមាជិកព្រះកាយដែលមានគ្នាតិច។ ព្រះអំណោយទានខាងការថ្លែងព្រះបន្ទូលគឺអាចទទួលបាន ដោយសមាជិកទាំងអស់គ្នា៖ "ដ្បិតបងប្អូនទាំងអស់គ្នាអាចថ្លែងព្រះបន្ទូលម្នាក់ម្តងៗ" ( គម្ពីរ១កូរិនថូស ១៤:៣១)។

ភាពខុសគ្នារបស់តំណែងជាព្យាការី និង ព្រះអំណោយទានខាងការថ្លែងព្រះបន្ទូលគឺយ៉ាងដូច្នេះ៖

អស់អ្នកដែលមានតំណែងជាព្យាការី នឹងត្រូវធ្វើការថ្លែងព្រះបន្ទូល ប៉ុន្តែអស់អ្នកដែលថ្លែងព្រះបន្ទូលមិនចាំបាច់មានតំណែងជាព្យាការីនោះទេ។

ដោយសារតែលក្ខណៈនេះហើយ ការថ្លែងព្រះបន្ទូល ប្រហែលជាព្រះអំណោយទានមួយដ៏អស្ចារ្យបំផុតដែលបាននិយាយនៅក្នុងគម្ពីរ១កូរិនថូស ១២:៨-១១។ លោកប៉ូលមានប្រសាសន៍ថា "ចូរខំប្រឹងអោយមានចិត្តស្រឡាញ់ ចូរប៉ងប្រាថ្នាចង់បានព្រះអំណោយទានរបស់ព្រះវិញ្ញាណដែរ ជាពិសេសការថ្លែងព្រះបន្ទូល*។ (គម្ពីរ១កូរិនថូស ១៤:១)។

ដូច្នេះយើងបានឃើញហើយថា ការថ្លែងព្រះបន្ទូលគឺពិតជាព្រះអំណោយទានមួយសំខាន់ខ្លាំងណាស់។ យើងត្រូវតែចង់ស្វែងយល់ពីវាឲ្យបានច្បាស់។ វាគឺសំខាន់ពិសេស ព្រោះវាគឺជាព្រះអំណោយទានដ៏អស្ចារ្យទីមួយក្នុងចំណោមព្រះអំណោយទានទាំងប្រាំបួន សម្រាប់ធ្វើការកសាងព្រះកាយ។ វាធ្វើឲ្យព្រះកាយមានភាពរស់រវើកតាមរបៀបពិសេសមួយ។ តាមរយៈព្រះអំណោយទាននេះ អ្នកជឿក៏បានរីកចម្រើន ហើយមនុស្សមានបាបក៏បានចូលទៅជិតព្រះជាម្ចាស់៖ "ផ្ទុយទៅវិញ បើបងប្អូនថ្លែងព្រះបន្ទូលទាំងអស់គ្នា ហើយមានអ្នកមិនជឿ ឬអ្នកដែលគ្រាន់តែចង់ស្តាប់ចូលមក នោះពាក្យទាំងអស់ដែលគេបានឮ មុខជានាំអោយគេដឹងថា ខ្លួនមានកំហុស ត្រូវជាប់ទោស។" (គម្ពីរ ១កូរិនថូស ១៤:២៤)។

## *លំហាត់អនុវត្តន៍*

៧ ចូរសរសេរ ត នៅមុខប្រយោគដែលត្រឹមត្រូវ។ សរសេរអក្សរ ខ សម្រាប់ប្រយោគដែលខុស។

.........ក) ពាក្យថាថ្លែងប្រកាសប្រាប់ មានន័យថា "ការប្រាប់ពីអនាគតកាល"។

.........ខ) ព្រះអំណោយទានជា "ព្យាការី" និង ព្រះអំណោយទានខាងការ "ថ្លែងព្រះបន្ទូល" គឺដូចគ្នា។

.........គ) សមាជិកទាំងអស់នៅក្នុងព្រះកាយអាចមានព្រះអំណោយទាននៃព័ន្ធកិច្ចមួយដែលហៅថា "ព្យាការី"។

........ឃ) ការថ្លែងព្រះបន្ទូលមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាអាចជួយទាំងអ្នកជឿ និងមនុស្សមានបាប។

# មុខងាររបស់ព្រះអំណោយទានខាងការថ្លែងព្រះបន្ទូល

១. *ថ្លែងប្រកាសប្រាប់*

តម្លៃដ៏អស្ចារ្យនៃការថ្លែងប្រកាសប្រាប់ គឺត្រូវបានបង្ហាញច្បាស់នៅក្នុងបុណ្យថ្ងៃទីហាសិប។ ព្រះវិញ្ញាណដ៏វិសុទ្ធបានចាក់បង្ហូរមក ហើយស្ទើរតែមួយរំពេចនោះព្រះអំណោយទាននៃការថ្លែងព្រះបន្ទូលបានបើកសំដែងនៅក្នុងការចែកចាយរបស់លោកពេត្រុស។ នោះមិនមែនជាការចែកចាយធម្មតានោះទេ។ លោកពេត្រុសមិនអាចនឹងធ្វើការចែកចាយបែបនេះបាននៅមួយថ្ងៃមុខនោះឡើយ។ អត្ថន័យនៃការចែកចាយរបស់លោកគឺមានឫទ្ធានុភាពអស្ចារ្យ និង ការជំរុញពីព្រះវិញ្ញាណដ៏វិសុទ្ធ។ លោកពេត្រុសនិយាយចេញនូវយោបល់ដែលមិនមែនជាយោបល់របស់លោក។ យោបល់នោះបានមកពីព្រះវិញ្ញាណ។

ការថ្លែងព្រះបន្ទូលគឺជាលទ្ធផលដែលបានមកពីភាពពោរពេញដោយព្រះវិញ្ញាណ។ លោកពេត្រុសមានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ *ហើយលោកបានធ្វើការថ្លែងព្រះបន្ទូល* ។ នៅក្នុងគម្ពីរកិច្ចការជំពូក១៩ ពេលដែលពួកសាវ័កនៅក្នុងទីក្រុងអេភេសូបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ពួកគេបាននិយាយភាសាចម្លែកអស្ចារ្យ និង ធ្វើការថ្លែងព្រះបន្ទូលផង ( គម្ពីរកិច្ចការ ១៩:៦)។

ការថ្លែងព្រះបន្ទូលដ៏ពិតគឺធ្វើទៅបាន ជាមួយនឹងអានុភាព និង ឫទ្ធានុភាពរបស់ព្រះជាម្ចាស់។ អ្នកជឿប្រហែលជាមានទេពកោសល្យក្នុងការនិយាយ។ ពួកគេប្រហែលជាអាចចែកចាយមេរៀនដ៏អស្ចារ្យ។ ប៉ុន្តែគ្មាននរណាម្នាក់អាចធ្វើការថ្លែងព្រះបន្ទូលដ៏ពិតបាន ដោយគ្មានព្រះវិញ្ញាណដ៏វិសុទ្ធនោះឡើយ។ (សូមមើលគម្ពីរ១ពេត្រុស ៤:១១)។

អ្នកជឿដែលធ្វើការថ្លែងព្រះបន្ទូល និយាយទៅកាន់មនុស្ស៖ "អ្នកណាថ្លែង*ព្រះបន្ទូល អ្នកនោះនិយាយទៅកាន់មនុស្ស" (គម្ពីរ១កូរិនថូស ១៤:៣) ។ តើពួកគេនិយាយ*អ្វី*ទៅកាន់មនុស្ស? តើពួកគេថ្លែងប្រកាសប្រាប់ពី*អ្វី*? ពួកគេនិយាយ និង ថ្លែងប្រកាសប្រាប់ ពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ប៉ុន្តែចុះក្រែងអ្នកចែកចាយ និង គ្រូបង្រៀនទាំងអស់ ជាអ្នកធ្វើការនេះឬអី? មែនហើយ។ ប៉ុន្តែការថ្លែងព្រះបន្ទូល គឺមិនកំណត់ទៅលើ *នរណា* ជាអ្នកថ្លែង ឬ *អ្វី*ដែលត្រូវបានថ្លែងចេញនោះទេ តែវាស្រេចលើ*របៀបណា* ដែលបុគ្គលនោះថ្លែងប្រកាសវិញ។

តាមរយៈព្រះអំណោយទានខាងការថ្លែងព្រះបន្ទូល ព្រះវិញ្ញាណដ៏វិសុទ្ធអាចដាក់ក្នុងគំនិតរបស់អ្នកនិយាយនោះ នូវអ្វីដែលគេមិនដែលធ្លាប់នឹកគិតពីមុនដោយខ្លួនឯងឡើយ។ វាក៏ពិតប្រាកដសម្រាប់ការចែកចាយដ៏អស្ចារ្យរបស់លោកពេត្រុសដែលមានរៀបរាប់នៅក្នុងគម្ពីរកិច្ចការជំពូក២ផងដែរ។

## *លំហាត់អនុវត្តន៍*

៨ នៅពេលដែលអ្នកជឿម្នាក់ធ្វើការថ្លែងប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយឫទ្ធានុភាព និង ការជំរុញរបស់ព្រះវិញ្ញាណ ការថ្លែងព្រះបន្ទូលប្រភេទនោះ យើងហៅថា

..................................................................................................................................

២. *ការទាយទុកមុន*

ការទាយទុកមុន មានន័យថា ប្រាប់ពីអ្វីមួយមុនពេលដែលវាកើតមានឡើង។ យើងបានដឹងរួចមក ហើយថាព្រះជាម្ចាស់ជ្រាបគ្រប់ការទាំងអស់។ នេះមានន័យថា ទ្រង់ជ្រាបទាំងអតីតកាល បច្ចុប្បន្នកាល និង អនាគតកាល។ មនុស្សមិនអាចដឹងពីអនាគតរបស់គេ ដោយកម្លាំងរបស់គេបានឡើយ។ មានតែ តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធតែប៉ុណ្ណោះដែលគេអាចដឹងរឿងនៅពេលអនាគតបាន។ តាមរយៈ ព្រះ អំណោយទានខាងការថ្លែងព្រះបន្ទូល ព្រះវិញ្ញាណដ៏វិសុទ្ធអាចធ្វើឲ្យអ្នកជឿ ថ្លែងប្រកាសរឿង អនាគត បាន។

ព្យាការីនៅក្នុងកណ្ឌគម្ពីរសម្ព័ន្ធមេត្រីចាស់ តែងតែទាយទុកនូវរឿងអនាគត។ ការប្រាប់ពីអនាគតគឺ ជាផ្នែកដ៏អស្ចារ្យមួយនៅក្នុងព័ន្ធកិច្ចរបស់ពួកគេ។ តាមធម្មតា គោលបំណងនៃព្រះអំណោយទាននេះគឺ ដើម្បីដាស់តឿនមនុស្សឲ្យគេត្រូវការព្រះជាម្ចាស់។ លោកយ៉ូណាសគឺជាម្នាក់ក្នុងចំណោមអ្នកដែលបានធ្វើ ការទាយពីអនាគត។ លោកបានទាយថា "សែសិបថ្ងៃទៀតព្រះអម្ចាស់នឹងបំផ្លាញក្រុងនេះហើយ!" (គម្ពីរ យ៉ូណាស ៣:៤)។

ពេលខ្លះក៏មានមនុស្សអាក្រក់ ដែលអាចទាយពីអនាគតផងដែរ។ ពួកគេត្រូវបានគេស្គាល់ថា គ្រូ ទាយ។ លោកប៉ូលធ្លាប់មានបទពិសោធន៍ម្តង ជាមួយមនុស្សបែបនេះ៖ "មានថ្ងៃមួយ ពេលយើងធ្វើ ដំណើរទៅកន្លែងអធិស្ឋាន* មានស្រីបំរើគេម្នាក់មកជួបយើង នាងមានអារក្សភីថង់ចូល នាំអោយនាងចេះ ទាយ" (គម្ពីរកិច្ចការ១៦:១៦)។ ព្រះជាម្ចាស់ទ្រង់ទាស់នឹងរបៀបនៃការទាយអនាគតតាមបែបនេះណា ស់។ វាគឺជារបស់សាតាំង។ ក្នុងនាមជាអ្នកជឿ យើងមិនត្រូវជាប់ទាក់ទងនឹងរឿងដូច្នេះឡើយ៖

ក្នុងចំណោមអ្នករាល់គ្នា មិនត្រូវអោយនរណាម្នាក់...បញ្ជាន់រូប ទស្សន៍ទាយ ប្រព្រឹត្តមន្តអាគម ឬ អំពើអាបធ្មប់ ធ្វើអំពើ ហើយក៏មិនត្រូវអោយនរណាម្នាក់ទៅរកគ្រូអន្ទងខ្មោច ទៅរកគ្រូទាយ មើលជោគ រាសី និងខាបព្រលឹងដែរ ដ្បិតព្រះអម្ចាស់ចាត់ទុកអ្នកដែលប្រព្រឹត្តអំពើទាំងនេះ ជាមនុស្សគួរស្អប់ខ្ពើម។ (គម្ពីរទុតិយកថា ១៨:១០-១២)។

សាតាំងគឺតែងតែជាអ្នកបំផ្លាញ។ វាស្វែងរកវិធីដើម្បីបំផ្លាញជំនឿ។ វាស្វែងរកវិធីបំផ្លាញអ្នកជឿ។ វា ស្វែងរកវិធីបំផ្លាញព្រះកាយរបស់ព្រះគ្រិស្ត។ ការទាយអនាគតទាំងឡាយណាដែលមកពីវា គឺមានបំណង បំផ្លាញ៖ "ចោរវាមកគិតតែពីលួចប្លន់ គិតតែពីសម្លាប់ និងបំផ្លាញប៉ុណ្ណោះ។
(គម្ពីរយ៉ូហាន ១០:១០)។

កិច្ចការរបស់ព្រះជាម្ចាស់តែងតែដើម្បីសង្គ្រោះ។ តាមរយៈព្រះអំណោយទានខាងការថ្លែងព្រះបន្ទូល ពេលខ្លះព្រះវិញ្ញាណដ៏វិសុទ្ធអាចសង្គ្រោះព្រះកាយរបស់ព្រះគ្រិស្តឲ្យផុតពីទុក្ខសោកបាន។

(សូមអានគម្ពីរកិច្ចការ ១១:២៧-៣០)។ មានពេលខ្លះទៀត តាមរយៈព្រះអំណោយទានខាងការថ្លែងព្រះបន្ទូល ព្រះកាយរបស់ទ្រង់ត្រូវបានរៀបចំសម្រាប់ទទួលទុក្ខសោកដែរ។ (សូមអានគម្ពីរ កិច្ចការ ២០:២៣; ២១:១០-១៣)។

អ្នកជឿអាចត្រូវបានល្បួងឲ្យប្រើប្រាស់ព្រះអំណោយទានខាងការថ្លែងព្រះបន្ទូល ក្នុងការជួយឲ្យពួកគេដឹងពីអ្វីដែលពួកគេត្រូវធ្វើ។ ធ្វើដូច្នេះមិនល្អទេឡើយ។ យើងនឹងដឹងបន្ថែមទៀតពីរឿងនេះនៅពេលដែលយើងសិក្សាព្រះអំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យ។

## ***លំហាត់អនុវត្តន៍***

---

៩ ចូរសរសេរអក្សរ ក នៅពីមុខប្រយោគដែលត្រឹមត្រូវ និង អក្សរ ខ នៅពីមុខប្រយោគដែលខុស។

.........ក) ការថ្លែងប្រកាសប្រាប់ មានន័យថា ការប្រាប់ពីអ្វីមួយបន្ទាប់ពីវាបានកើតឡើងហើយ។

.........ខ) ព្យាការីនៅក្នុងកណ្ឌគម្ពីរសម្ព័ន្ធមេត្រីចាស់ ភាគច្រើនជាអ្នកទស្សន៍ទាយ។

.........គ) គ្រូទាយគឺមានប្រយោជន៍ខ្លាំងណាស់សម្រាប់អ្នកជឿ។

.........ឃ) សាតាំងតែងតែស្វែងរកវិធីបំផ្លាញ ។ ព្រះជាម្ចាស់តែងតែស្វែងរកវិធីដើម្បីសង្គ្រោះ។

---

## ការណែនាំសម្រាប់ការប្រើប្រាស់ព្រះអំណោយទានខាងការថ្លែងព្រះបន្ទូល

## គម្ពីរ១កូរិនថូស ១៤:២៩-៤០

៣. ការថ្លែងព្រះបន្ទូលត្រូវតែយោងទៅតាមជំនឿដែលយើងមាន។(សូមមើលនៅក្នុងគម្ពីររ៉ូម ១២:៦)

ព្រះវិញ្ញាណដ៏វិសុទ្ធអាចធ្វើការតាមរយៈអ្នកជឿបាន ដោយសារតែផ្អែកលើជំនឿនៅក្នុងដួងចិត្តរបស់អ្នកជឿនោះប៉ុណ្ណោះ។ ការធ្វើការថ្លែងព្រះបន្ទូលដោយគ្មានជំនឿ គឺជាការថ្លែងចេញពីចិត្តរបស់យើងតែប៉ុណ្ណោះ។ ការនេះទាមទារឲ្យអ្នកជឿអធិស្ឋានឲ្យបានច្រើន ដើម្បីដឹងពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ និង បានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។

៤ . ការថ្លែងព្រះបន្ទូលមានការកំណត់ និង ការពិចារណា។
(សូមមើលនៅក្នុងគម្ពីរ១កូរិនថូស ១៤:២៩)

ព្រះជាម្ចាស់សព្វព្រះទ័យឲ្យមានសណ្តាប់ធ្នាប់នៅក្នុងការប្រជុំថ្វាយបង្គំជាសាធារណៈ។ លោកប៉ុលហាក់បីដូចជាកំពុងនិយាយថា "កុំគ្រាន់តែដើរពីកន្លែងមួយទៅកន្លែងមួយ ធ្វើការថ្លែងព្រះបន្ទូលឡើយ។ សូមទុកពេលសម្រាប់អ្នកដែលអង្គុយក្បែរនោះបានពិចារណាផង" ។ *ការពិចារណា* ត្រង់នេះមានន័យថា "ការពិចារណាត្រឹមត្រូវ"។

អ្នកជឿខ្លះទៀតត្រូវពិចារណា និងវាយតម្លៃដោយគិតគូរយ៉ាងប្រុងប្រយ័ត្នចំពោះអ្វីដែលត្រូវនិយាយនៅក្នុងការថ្លែងព្រះបន្ទូល។ ហេតុអ្វី? ព្រោះ អស់អ្នកដែលធ្វើការថ្លែងព្រះបន្ទូលគឺជាមនុស្ស។ ពួកគេអាចនិយាយបានដោយព្រះវិញ្ញាណដ៏វិសុទ្ធ។ ប៉ុន្តែពួកគេក៏អាចនឹងនិយាយចេញមកដោយវិញ្ញាណរបស់ពួកគេផ្ទាល់ ឬ អាចនិយាយចេញមកពីវិញ្ញាណអាក្រក់របស់ពួកគេផងដែរ។ជាមួយនឹងជំនួយមកពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ពួកអ្នកដែលអង្គុយក្បែរនោះជាអ្នកស្តាប់ និង ធ្វើការសម្រេចចិត្ត ប្រសិនបើអ្វី

ដែលនិយាយចេញមកនោះ វាស្របទៅនឹងព្រះបន្ទូលរបស់ព្រះ។ តែប្រសិនបើវាមិនស្របជាមួយនឹងព្រះបន្ទូលនោះទេ ពួកគេអាចដកវាទុកដោយឡែក។ ឧទាហរណ៍ ប្រសិនបើមានការថ្លែងព្រះបន្ទូលមក ប្រាប់មនុស្សថា ពួកគេត្រូវប្រទេចផ្ដាសាព្រះនាមរបស់ព្រះយេស៊ូ នោះការថ្លែងព្រះបន្ទូលនោះត្រូវតែដកចេញឲ្យឆ្ងាយ។

៥. ទាំងអស់គ្នាអាចថ្លែងព្រះបន្ទូលបាន (សូមមើលគម្ពីរ១កូរិនថូស ១៤:៣១ និង គម្ពីរ១កូរិនថូស ១៤:៥, ២៤)។

ចំណុចនេះប្រាប់យើងថា អ្នកជឿគ្រប់រូបអាចត្រូវបានប្រើប្រាស់ដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីធ្វើការថ្លែងព្រះបន្ទូល។ ព្រះអំណោយទាននេះមិនសម្រាប់តែអ្នកដឹកនាំក្រុមជំនុំនោះទេ ។ វាគឺសម្រាប់អ្នកជឿទាំងឡាយណាដែលមានពេញដោយព្រះវិញ្ញាណ។

៦. អ្នកដែលមានការថ្លែងព្រះបន្ទូលចង់ប្រកាសមិនចាំបាច់ត្រូវតែនិយាយចេញមកក្រៅនោះឡើយ។ (សូមមើលគម្ពីរ១កូរិនថូស ១៤:៣២-៣៣)។

មនុស្សដែលមានការថ្លែងព្រះបន្ទូល ជាអ្នកសម្រេចចិត្តថា នៅពេលណាដែលពួកគេនឹងថ្លែង និងពេលណាដែលពួកគេនឹងមិនធ្វើការថ្លែង។ ពួកគេមិនស្ថិតក្រោម អំណាចមន្តអាគមអ្វីមួយដែលធ្វើឲ្យពួកគេមិនអាចប្រើប្រាស់ការសម្រេចចិត្តខ្លួនឯងបាននោះឡើយ។

៧. អស់អ្នកដែលត្រូវបានប្រើប្រាស់ដោយព្រះវិញ្ញាណដ៏វិសុទ្ធ សម្រាប់ព្រះអំណោយទានខាងការថ្លែងព្រះបន្ទូល ត្រូវតែសុខចិត្តទទួលយកការណែនាំ និង ទទួលយកការកែតម្រូវ។ (សូមមើល គម្ពីរ ១កូរិនថូស ១៤:៣៧)

## *លំហាត់អនុវត្តន៍*

---

១០ ចូរគូសរង្វង់នៅជុំវិញអក្សរខាងមុខប្រយោគដែលត្រឹមត្រូវ។

ក) នៅពេលដែលបុគ្គលណាម្នាក់ទទួលបានព្រះអំណោយទានខាងការថ្លែងព្រះបន្ទូល គេមិនចាំបាច់ត្រូវរៀបចំចិត្តរបស់គេសម្រាប់ការថ្លែងព្រះបន្ទូលនោះទៀតឡើយ។

ខ) វាមិនត្រឹមត្រូវនោះទេ ដែលមនុស្សម្នាក់បានឮការថ្លែងព្រះបន្ទូល ធ្វើការវែងញែកថាវាមកពីព្រះវិញ្ញាណដ៏វិសុទ្ធឬអត់នោះ។

គ) ព្រះអំណោយទានខាងការថ្លែងព្រះបន្ទូលគឺសម្រាប់តែអ្នកដឹកនាំក្រុមជំនុំតែប៉ុណ្ណោះ។

ឃ) អ្នកជឿដែលធ្វើការថ្លែងព្រះបន្ទូល មិនមានសិទ្ធិក្នុងការសម្រេចចិត្ត ថាពេលណាពួកគេអាចធ្វើការថ្លែងព្រះបន្ទូលនោះឡើយ។

## គោលបំណងសម្រាប់ព្រះអំណោយទានខាងការថ្លែងព្រះបន្ទូល

ព្រះអំណោយទានរបស់ព្រះវិញ្ញាណ គឺសម្រាប់កសាងព្រះកាយ។ ព្រះអំណោយទាននីមួយៗមានរបៀបពិសេសរៀងៗខ្លួនក្នុងការកសាងព្រះកាយបាន។ លោកប៉ូលប្រាប់យើងពីរបៀបដែលការថ្លែងព្រះបន្ទូលអាចធ្វើការនេះបាន ៖ "អ្នកណាថ្លែង*ព្រះបន្ទូល អ្នកនោះនិយាយទៅកាន់មនុស្ស ដើម្បីជួយកសាងជាស់តឿន និងលើកទឹកចិត្តគេ។" (គម្ពីរ១កូរិនថូស ១៤:៣) ។ អ្នកជឿដែលធ្វើការថ្លែងព្រះបន្ទូល គេនិយាយចេញទៅដើម្បី ដាស់តឿន និង ដើម្បីលើកទឹកចិត្តអ្នកដទៃ។ នៅពេលដែលអ្នកដទៃទទួលបានការដាស់តឿន និង លើកទឹកចិត្តហើយ ពួកគេបានរីកចម្រើនខាងវិញ្ញាណ។ ហើយនៅពេលដែលពួកគេបានរីកចម្រើនខាងវិញ្ញាណ ព្រះកាយទាំងមូលក៏ទទួលបានជំនួយផងដែរ។

### *លំហាត់អនុវត្តន៍*

១១ នៅពេលដែលយើងនិយាយថា អ្នកដែលធ្វើការថ្លែងព្រះបន្ទូលកសាងព្រះកាយ យើងចង់បានន័យថា ព្រះកាយត្រូវបាន.......................................................................................................

# ការប្រឡងផ្ទាល់ខ្លួន

**សំណួរពហុជម្រើស**។ ចូរជ្រើសរើសចម្លើយទាំងឡាយណាដែលត្រឹមត្រូវ សម្រាប់សំណួរនីមួយៗ។ ចូរគូសរង្វង់ជុំវិញចម្លើយដែលត្រឹមត្រូវនោះ។

១ ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ ភាគច្រើនបំពេញ...........របស់មនុស្ស។

ក) តម្រូវការខាងវិញ្ញាណ។

ខ) តម្រូវការខាងរូបកាយ។

គ) តម្រូវការខាងសម្ភារៈ។

២ អ្នកអាចដឹងថាព្រះវិញ្ញាណដ៏វិសុទ្ធសព្វព្រះហឫទ័យប្រើប្រាស់អ្នកសម្រាប់ព្រះអំណោយទាននៃការប្រោសឲ្យជាពីជំងឺបាន ដោយ

ក) មើលឃើញពីតម្រូវការរបស់នរណាម្នាក់

ខ) មាននរណាម្នាក់ប្រាប់អ្នកថា អ្នកមានព្រះអំណោយទាននៃការប្រោសឲ្យជាពីជំងឺ។

គ) ដឹងពីចលនារបស់ព្រះវិញ្ញាណដ៏វិសុទ្ធយ៉ាងខ្លាំងនៅក្នុងចិត្តអ្នក ក្នុងការបំពេញតម្រូវការខាងរូបកាយរបស់នរណាម្នាក់។

៣ ការធ្វើការអស្ចារ្យគឺ

ក) អាចធ្វើបានតាមរយៈឫទ្ធានុភាពអធិធម្មជាតិប៉ុណ្ណោះ។

ខ) មិនអាចធ្វើបានឡើយបើគ្មានព្រះវិញ្ញាណដ៏វិសុទ្ធ។

គ) មានរៀនតែនៅក្នុងសាលាព្រះគម្ពីរតែប៉ុណ្ណោះ។

៤ ការថ្លែងព្រះបន្ទូលគឺ

ក) ការចែកចាយគ្រប់ប្រភេទ។

ខ) ការនិយាយដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

គ) ជាការថ្លែងប្រកាសប្រាប់ និង ជាការទាយទុកមុនផង។

៥ ព្រះអំណោយទានខាងការថ្លែងព្រះបន្ទូលនេះមានសារៈសំខាន់ ព្រោះ

ក) អ្នកជឿទាំងអស់អាចបើកសំដែងព្រះអំណោយទាននេះ។

ខ) អនាគតត្រូវបានទាយទុកមុនដោយព្រះអំណោយទាននេះ។

គ) វាជាព្រះអំណោយទានសម្រាប់ប្រកាសសារបន្ទូលរបស់ព្រះជាម្ចាស់។

៦ *ការថ្លែងប្រកាសប្រាប់* មានន័យថា

ក) ការប្រាប់ពីអ្វីមួយ មុនពេលដែលវាកើតឡើង។

ខ) ការនិយាយប្រាប់ពីសារបន្ទូលរបស់ព្រះជាម្ចាស់។

គ) ដូចគ្នាទៅនឹងការទាយទុកមុនដែរ។

**ចម្លើយខ្លីៗ ៗ** បំពេញប្រយោគខាងក្រោមដោយបំពេញពាក្យត្រឹមត្រូវ នៅក្នុងចន្លោះបន្ទាត់ដែលបានឲ្យ។

៧ ព្រះអំណោយទានរបស់ព្រះវិញ្ញាណទាំងបីយ៉ាងដែលយើងបានសិក្សានៅក្នុងមេរៀននេះគឺ

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៨ គោលបំណងសំខាន់របស់ព្រះអំណោយទាននៃការប្រោសឲ្យជាពីជំងឺគឺ....................................

៩ អ៊ុមនីភូថេន(omnipotent)សព្វានុភាព។ មានន័យថា

..........................................................................................................................................

១០ របៀបមួយដែលការធ្វើការអស្ចារ្យជួយក្នុងការកសាងព្រះកាយរបស់ព្រះគ្រិស្តគឺដោយការដក ចេញ..............................................................................................................................

១១ នៅពេលដែលសាតាំងនាំមនុស្សឲ្យទាយពីអនាគត គោលបំណងរបស់វាគឺដើម្បី........................

១២ គោលបំណងនៃព្រះអំណោយទានខាងការថ្លែងព្រះបន្ទូលគឺដើម្បីកសាងព្រះកាយរបស់ព្រះ គ្រិស្តដោយការ.............................................................................................................
និងការ.........................................................................................................................

# ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១ ក) ច្រើនជាងមួយ។

ខ) អ្នកជឿដែលមានពេញដោយព្រះវិញ្ញាណ។

គ) ធ្វើឲ្យដូចដើម ឬ ឲ្យប្រសើរឡើង។

៧ ក) ខ

ខ) ខ

គ) ខ

ឃ) ត

២ ចម្លើយទាំងអស់ជាចម្លើយត្រឹមត្រូវ

៨ ការថ្លែងប្រកាសប្រាប់

៣ ក) ខ

ខ) ខ

គ) ត

ឃ) ខ

ង) ត

៩ ក) ខ

ខ) ត

គ) ខ

ឃ) ត

៤ មនុស្សអាក្រក់ត្រូវបានធ្វើឲ្យខ្វាក់ភ្នែក។

១០ គ្មានចម្លើយត្រឹមត្រូវ

៥ ក) អស្ចារ្យ។

ខ) បុត្រារបស់ព្រះជាម្ចាស់។

គ) ព្រះវិញ្ញាណដ៏វិសុទ្ធ។

ឃ) ឫទ្ធានុភាពរបស់ព្រះជាម្ចាស់។

ង) អ៊ុមនីភូថេន(omnipotent)សព្វានុភាព។

១១ កសាងឡើង

៦ លោកពេត្រុសដែលជាអ្នកចែកចាយដំណឹងល្អត្រូវបានគេចាប់ដាក់គុក។

មេរៀនទី ៩

# ការសង្កេតស្គាល់វិញ្ញាណផ្សេងៗ ការនិយាយភាសាចម្លែកអស្ចារ្យផ្សេងៗ និង ការបកប្រែន័យភាសាចម្លែកអស្ចារ្យ

យើងបានមកដល់មេរៀនចុងក្រោយនៅក្នុងមុខវិជ្ជារបស់យើងហើយ។ យើងបានសិក្សាពី ព្រះអំណោយទានប្រាំមួយនៅក្នុងចំណោមព្រះអំណោយទានរបស់ព្រះវិញ្ញាណទាំងប្រាំបួនរួចមកហើយ។ យើងបានឃើញពីរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធ ផ្គត់ផ្គង់យ៉ាងប្រសើរសម្រាប់ការកសាងព្រះកាយរបស់ព្រះគ្រិស្ត។ យើងបានដឹងថា ព្រះអំណោយទានរបស់ព្រះវិញ្ញាណជាទូទៅត្រូវបានបើកសំដែងទៅកាន់ព្រះកាយតាមរយៈអ្នកជឿដែលមានពេញដោយព្រះវិញ្ញាណ។

នៅក្នុងមេរៀនចុងក្រោយនេះ យើងនឹងរៀនអំពីព្រះអំណោយទានចុងក្រោយទាំងបីយ៉ាង នៅក្នុងគម្ពីរ ១កូរិនថូស ១២:៨-១០។ យើងនឹងយកចិត្តទុកដាក់ជាពិសេសទៅលើព្រះអំណោយទានខាងការនិយាយភាសាចម្លែកអស្ចារ្យផ្សេងៗ ដោយសារតែវាមានច្រើននៅក្នុងពិភពលោកយើងបច្ចុប្បន្ននេះ។

អ្នកបានឃើញថា គ្រប់ព្រះអំណោយទានទាំងអស់នេះ គឺអាចកើតឡើងបានតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ។ ប្រសិនបើអ្នកមិនទាន់បានជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធទេនោះ អ្នកអាចទទួលការជ្រមុជនៅថ្ងៃនេះ។ សូមបើកចិត្តរបស់អ្នក ហើយយាងទ្រង់ចូលមកក្នុងចិត្តអ្នក។ ចាប់ផ្តើម ធ្វើការថ្វាយបង្គំ ទ្រង់ដោយជំនឿ។ ចុះចូលទាំងស្រុង ជាមួយទ្រង់។ អ្នកនឹងបានស្គាល់ទ្រង់យ៉ាងជ្រាលជ្រៅនៅក្នុងចិត្តរបស់អ្នក។ នៅពេលដែលទ្រង់បានគ្រប់គ្រងអ្នកទាំងស្រុងហើយ យើងនឹងចាប់ផ្តើមនិយាយភាសាថ្មីមួយផ្សេង។ យើងនឹងបានដឹងថា ទ្រង់យាងមកជាមួយនឹងភាពពេញបរិបូរណ៍របស់
ទ្រង់។ នោះហើយគឺជាចំណុចចាប់ផ្តើមនៃជីវិតដែលប្រកបដោយព្រះវិញ្ញាណរបស់អ្នក។ នៅពេលដែលអ្នកនៅប្រកបដោយព្រះវិញ្ញាណ ព្រះអំណោយទានរបស់ព្រះវិញ្ញាណនឹងបើកសំដែងតាមរយៈអ្នក តាមតែព្រះវិញ្ញាណសព្វព្រះហឫទ័យ។

## *គម្រោងនៃមេរៀន*

ក. ការសង្កេតស្គាល់វិញ្ញាណផ្សេងៗ

ខ. ព្រះអំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យផ្សេងៗ

គ. ការបកប្រែន័យភាសាចម្លែកអស្ចារ្យផ្សេងៗ

## *វត្ថុបំណងនៃមេរៀន*

នៅពេលដែលអ្នកបានបញ្ចប់មេរៀននេះ អ្នកអាចនឹងៈ

១. ប្រាប់ពីមុខងារ និង គោលបំណងនៃព្រះអំណោយទានខាងការសង្កេតស្គាល់វិញ្ញាណផ្សេងៗ។

២. បកស្រាយពីមុខងារ និងគោលបំណងនៃព្រះអំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យផ្សេងៗ។

៣. ប្រាប់ពីមុខងារ និង គោលបំណងនៃព្រះអំណោយទានខាងការបកប្រែន័យភាសាចម្លែកអស្ចារ្យផ្សេងៗ។

៤. បកស្រាយពីរបៀបដែលអ្នកអាចត្រូវបានប្រើប្រាស់ដោយព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីបើកសំដែងព្រះអំណោយទាននេះ។

## *សកម្មភាពនៅក្នុងការសិក្សា*

១. សូមអានគម្ពីរ ១កូរិនថូស ១៤:១-២៨

២. ចូរធ្វើតារាងមួយនៅក្នុងសៀវភៅកត់ត្រារបស់អ្នក ដែលបង្ហាញពីព្រះអំណោយនៃព្រះវិញ្ញាណដ៏វិសុទ្ធទានទាំងបីនេះ ព្រមទាំងមាននិយមន័យរបស់ពួកវាផង ដោយប្រើខគម្ពីរ១កូរិនថូស ១៤:២-៣។

៣. សិក្សាពាក្យសំខាន់មុនពេលដែលអ្នកចាប់ផ្តើមមេរៀន។

៤. ធ្វើលំហាត់នីមួយៗដែលអ្នកបានជួប។

៥. បង្ហើយការទន្ទេញខគម្ពីរ ១កូរិនថូស ជំពូក១៣ ។ សូត្រខគម្ពីរទាំងដប់បីខនោះឡើងវិញ ឲ្យមិត្តរបស់អ្នកស្តាប់។

៦. ធ្វើការប្រឡងផ្ទាល់ខ្លួនដែលនៅចុងបញ្ចប់នៃមេរៀន។

៧. បន្ទាប់ពីបានធ្វើការប្រឡងផ្ទាល់ខ្លួនរួចហើយ ចូលរំឭកមេរៀនទី៧ ដល់ទី៩(ជំពូកបី)ឡើងវិញ។ ហើយធ្វើ*ការជំពូកទីជំពូកទីបី*។

## *ពាក្យសំខាន់*

| | | |
|---|---|---|
| កាលៈទេសៈ | ការក្លែងបន្លំ | ភាពតានតឹង |

# ក. ការសង្កេតស្គាល់វិញ្ញាណផ្សេងៗ

**វត្ថុបំណងទី១.** *ប្រាប់ពីមុខងារ និង គោលបំណងនៃព្រះអំណោយទានខាងការសង្កេតស្គាល់វិញ្ញាណផ្សេងៗ។*

## និយមន័យនៃការសង្កេតស្គាល់វិញ្ញាណផ្សេងៗ

"អោយម្នាក់ទៀតចេះស្ទង់មើលវិញ្ញាណល្អ ឬអាក្រក់" (គម្ពីរ១កូរិនថូស ១២:១០)។ នៅក្នុងគម្ពីរបកប្រែចាស់និយាយថា "ឲ្យមួយទៀតសង្កេតស្គាល់អស់ទាំងវិញ្ញាណ" ។

*ការសង្កេតស្គាល់* មានន័យថា "ការមើលឲ្យផុត ផ្នែកខាងក្រៅទៅដល់ខាងក្នុង ការមើលធ្លុះ"។ ពាក្យថា*ការសង្កេតស្គាល់* ក៏មានន័យថា ឲ្យមានការវិនិច្ឆ័យ ដោយផ្អែកលើអ្វីដែលបានដឹងស្រាប់ហើយ។

ពាក្យថា *វិញ្ញាណ* មានន័យថា "ខ្យល់ដង្ហើម" ប៉ុន្តែសម្រាប់អ្នកជឿ វាមានន័យលើសពីខ្យល់ដង្ហើមនេះទៅទៀត។ វាមានន័យថា "ភាពជាវិញ្ញាណ" តែម្តង។ ដោយវាត្រូវបានយកមកប្រើនៅក្នុងឃ្លានេះ នោះវាមានន័យសំដៅទៅលើវិញ្ញាណណាមួយក្នុងចំណោមវិញ្ញាណទាំងបី គឺវិញ្ញាណរបស់មនុស្ស វិញ្ញាណរបស់ព្រះជាម្ចាស់ ឬ វិញ្ញាណអាក្រក់។ វិញ្ញាណរបស់មនុស្សគឺជាផ្នែកមួយដ៏សំខាន់របស់មនុស្សម្នាក់។ តាមរយៈវិញ្ញាណរបស់គេ មនុស្សអាចស្គាល់ព្រះជាម្ចាស់ដែលជាវិញ្ញាណបាន។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ គឺជាព្រះវិញ្ញាណដ៏វិសុទ្ធ។ ហើយវិញ្ញាណអាក្រក់គឺជាវិញ្ញាណដែលនៅក្នុងពិភពអាក្រក់។ ពួកវាជាបាវបម្រើរបស់សាតាំង។

ដូច្នេះ ការសង្កេតស្គាល់វិញ្ញាណផ្សេងៗគឺជាសមត្ថភាពពិសេសដែលបានប្រទានមកដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីមើលឃើញលើសពីអ្វីដែលមនុស្សសាមញ្ញមើលឃើញ នៅពេលដែលវិញ្ញាណណាមួយបានបើកសំដែងឡើង។ វាគឺជាសមត្ថភាព ដើម្បីស្គាល់ថាតើវិញ្ញាណមួយណាដែលកំពុងនិយាយ និង ធ្វើសកម្មភាពនៅក្នុងនរណាម្នាក់។

### *លំហាត់អនុវត្តន៍*

១ វិញ្ញាណទាំងបីប្រភេទដែលអាចបើកសំដែងតាមរយៈមនុស្សគឺមាន

.........................................................................................................,.....

...............................................................................................................

និង..........................................................................................................

២ តាមរយៈការសង្កេតស្គាល់វិញ្ញាណផ្សេងៗ អ្នកជឿអាច.......................................................

...............................................................................................................

# ការបកស្រាយ និង ការអធិប្បាយអំពីការសង្កេតស្គាល់វិញ្ញាណផ្សេងៗ

សាតាំង គឺជាអ្នកក្លែងបន្លំដ៏ធំមួយ។ នោះមានន័យថា វាព្យាយាមចម្លងតាមអ្វីដែលព្រះវិញ្ញាណដ៏វិសុទ្ធធ្វើ។ វាក៏ព្យាយាមធ្វើឲ្យមនុស្សជឿថា វាគឺជាព្រះវិញ្ញាណដ៏វិសុទ្ធនៅពេលដែលវាបង្ហាញខ្លួនវា។ ការនេះអាចធ្វើឲ្យមានបញ្ហា ព្រោះសូម្បីតែអ្នកជឿក៏ត្រូវបានបោកប្រាស់ដោយការនេះដែរ។

ដូច្នេះ ក៏ដូចគ្នានេះដែរ មនុស្សអាចនឹងនិយាយចេញមកតាមវិញ្ញាណរបស់គេផ្ទាល់។ ពួកគេអាចធ្វើពុតដូចជាពួកគេកំពុងនិយាយដោយព្រះវិញ្ញាណដ៏វិសុទ្ធអ៊ីចឹង។ រឿងនេះអាចនាំឲ្យមានបញ្ហាដល់ព្រះកាយផងដែរ។

ព្រះគ្រិស្ត គឺជាព្រះសិរសារបស់ព្រះកាយ ទ្រង់បានផ្គត់ផ្គង់សម្រាប់គ្រប់តម្រូវការរបស់ព្រះកាយទ្រង់។ នេះមានរាប់បញ្ចូលទាំងការការពារឲ្យផុតពី មនុស្សណាដែលអនុញ្ញាតឲ្យវិញ្ញាណរបស់ខ្លួនឯងធ្វើឲ្យមានការឈឺចាប់ដល់ព្រះកាយ ហើយធ្វើការសង្កេតស្គាល់វិញ្ញាណផ្សេងៗ ដើម្បីផ្តល់ការការពារសម្រាប់អ្នកជឿដែលពិតជាត្រូវបានប្រើដោយព្រះវិញ្ញាណដ៏វិសុទ្ធមែន។ ពេលខ្លះព្រះវិញ្ញាណដ៏វិសុទ្ធបង្ហាញ ពីភាពតានតឹងរបស់ព្រះជាម្ចាស់តាមរយៈអ្នកជឿម្នាក់។ នៅក្នុងករណីនេះ អ្នកជឿដទៃទៀតប្រហែលជាចង់និយាយថា វាគឺជាវិញ្ញាណអាក្រក់ ឬ វាគឺជាវិញ្ញាណផ្ទាល់ខ្លួនរបស់អ្នកនោះ។ ប៉ុន្តែការសង្កេតស្គាល់វិញ្ញាណ អាចជួយឲ្យព្រះកាយដឹងថា វិញ្ញាណមួយណាដែលកំពុងបើកសំដែងនោះ។

មានវិញ្ញាណអាក្រក់ខ្លះអាចត្រូវបានស្គាល់ ដោយមិនចាំបាច់មានព្រះអំណោយទាននៃការសង្កេតស្គាល់វិញ្ញាណផ្សេងៗនោះទេ។ លោកប៉ូលបានផ្តល់ការណែនាំអ្នកក្រុងកូរិនថូសទៅលើរឿងនេះ៖ "ហេតុនេះ ខ្ញុំសូមជំរាបបងប្អូនអោយដឹងថា ប្រសិនបើអ្នកណាម្នាក់មានព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ណែនាំ អ្នកនោះពុំអាចពោលថា «ព្រះយេស៊ូត្រូវបណ្ដាសា» កើតទេ ហើយបើគ្មានព្រះវិញ្ញាណដ៏វិសុទ្ធ*ណែនាំទេនោះ ក៏គ្មាននរណាម្នាក់អាចពោលថា «ព្រះយេស៊ូជាព្រះអម្ចាស់» បានដែរ។"
(គម្ពីរ១កូរិនថូស ១២:៣) ។ តើលោកប៉ូលចង់បានន័យយ៉ាងដូចម្តេច? លោកកំពុងតែសរសេរអំពីអស់អ្នកដែលនិយាយដោយវិញ្ញាណម្នាក់។ លោកចង់បានន័យថា ប្រសិនបើនរណាម្នាក់និយាយដោយវិញ្ញាណមួយដែលពោលថា ព្រះយេស៊ូត្រូវបានប្រទេចផ្តាសា នោះគាត់មិនមែនកំពុងនិយាយដោយព្រះវិញ្ញាណដ៏វិសុទ្ធនោះទេ។ គាត់កំពុងតែនិយាយដោយវិញ្ញាណអាក្រក់ទៅវិញទេ។ លោកក៏ចង់បានន័យថា គ្មាននរណាម្នាក់ដែលកំពុងនិយាយដោយវិញ្ញាណអាក្រក់ អាចនឹងហៅព្រះយេស៊ូថា ជាព្រះអម្ចាស់ដែរ។

ឥឡូវនេះសូមយើងក្រឡេកទៅមើលពីរបៀបដែលព្រះអំណោយទាននៃការសង្កេតស្គាល់វិញ្ញាណផ្សេងៗ ធ្វើការនៅក្នុងជីវិតរបស់ព្រះយេស៊ូ និង នៅក្នុងក្រុមជំនុំដំបូងបង្អស់ផងដែរ។ យើងត្រូវតែរំឮកខ្លួនឯងថា ព្រះអំណោយទាននៃការសង្កេតស្គាល់វិញ្ញាណផ្សេងៗនេះ គឺជាព្រះអំណោយទានអធិធម្មជាតិ។

## ការសង្កេតស្គាល់វិញ្ញាណផ្សេងៗនៅក្នុងព័ន្ធកិច្ចរបស់ព្រះយេស៊ូ

ព្រះយេស៊ូទ្រង់មានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ៖ "ព្រះអង្គដែលព្រះជាម្ចាស់ចាត់អោយយាងមកថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រោះព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកព្រះអង្គយ៉ាងបរិបូណ៌។

(គម្ពីរយ៉ូហាន ៣:៣៤)។ ដូច្នេះ ព្រះយេស៊ូអាចបែងចែកវិញ្ញាណណាល្អ វិញ្ញាណណាអាក្រក់។

១. ទ្រង់បានសង្កេតស្គាល់*វិញ្ញាណល្អ*ដែលស្ថិតនៅក្នុងលោកណាថាណែល

មុនពេលដែលព្រះយេស៊ូមានព្រះបន្ទូលជាមួយនឹងលោកណាថាណែល ទ្រង់បានស្គាល់ថា វិញ្ញាណប្រភេទណាដែលលោកមានស្រេចទៅហើយ។ នៅពេលដែលលោកភីលីពនាំលោកណាថាណែល មកគាល់ព្រះយេស៊ូ ព្រះអង្គមានព្រះបន្ទូលថា៖ "អ្នកនេះជាជាតិអ៊ីស្រាអែលដ៏ពិតប្រាកដមែន ដ្បិតគាត់គ្មានពុតត្បុតអ្វីក្នុងខ្លួនសោះ" (គម្ពីរយ៉ូហាន ១:៤៧)។

២. ទ្រង់បានសង្កេតស្គាល់*វិញ្ញាណខុសឆ្គង* នៅក្នុងលោកយ៉ាកុប និង លោកយ៉ូហាន។

ពួកគេចង់ហៅរន្ទះភ្លើងមកពីលើមេឃ ហើយកំទេចអស់អ្នកដែលមិនទទួលព្រះយេស៊ូ ។ ប៉ុន្តែ"ព្រះយេស៊ូបែរទៅរកគេ ហើយស្តីបន្ទោសគេយ៉ាងខ្លាំង។" (គម្ពីរលូកា ៩:៥៥)

៣. ទ្រង់តែងតែបានសង្កេតស្គាល់*វិញ្ញាណអាក្រក់* ។

មានពេលមួយព្រះយេស៊ូបានទតឃើញស្ត្រីម្នាក់ដែលមានពិការភាព អស់រយៈពេលដប់ប្រាំបីឆ្នាំមកហើយ។ ទ្រង់ជ្រាបថា បញ្ហារបស់នាងគឺបណ្តាលមកពីវិញ្ញាណអាក្រក់។ វិញ្ញាណនេះមិនបាននិយាយទេ តែវាបានតោងជាប់ជាមួយស្ត្រីកំសត់នោះ។ ព្រះយេស៊ូមានព្រះបន្ទូលថា " នាងអើយ! នាងបានជាសះស្បើយហើយ" (គម្ពីរលូកា ១៣:១២)។ មួយរំពេចនោះ នាងបានសះស្បើយភ្លាម។ នាងមិនត្រូវការព្យាបាលអ្វីនោះទេ។ នាងគ្រាន់តែត្រូវការ រំដោះឲ្យរួចផុតពីវិញ្ញាណអាក្រក់នោះប៉ុណ្ណោះ។

យើងបានដឹងពីរឿងនេះថា ព្រះអំណោយទាននៃការបែងចែងវិញ្ញាណ អាចជាព្រះអំណោយទានដ៏មានប្រយោជន៍ក្នុងការជួយមនុស្សដែលមានជំងឺ ឬ ពិការភាព។

## ការសង្កេតស្គាល់វិញ្ញាណផ្សេងៗនៅក្នុងក្រុមជំនុំដំបូងបង្អស់

១. តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ លោកពេត្រុសបានសង្កេតស្គាល់វិញ្ញាណខុសឆ្គងដែលនៅក្នុងលោកអាណាណាស និងនាងសាភីរ៉ា ។

លោកបានសង្កេតស្គាល់ថា ពួកគេកំពុងតែកុហកព្រះវិញ្ញាណដ៏វិសុទ្ធ។ (សូមមើលនៅក្នុងគម្ពីរកិច្ចការ ៥:៣) ។ ប្រសិនបើសាតាំងវាមិនអាចដាក់វិញ្ញាណអាក្រក់នៅក្នុងមនុស្សទេ វាព្យាយាមដាក់វិញ្ញាណដែលខុសឆ្គងនៅក្នុងមនុស្សវិញ។

២. តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ លោកពេត្រុសក៏បានសង្កេតស្គាល់វិញ្ញាណខុសឆ្គងនៅក្នុងលោកស៊ីម៉ូន។ (សូមមើលគម្ពីរកិច្ចការ៨:២៣)។

តើនេះគឺជាព្រះអំណោយទាននៃការសង្កេតស្គាល់វិញ្ញាណ ឬមួយវាគឺជាព្រះអំណោយទានពាក្យសំដីនៃចំណេះដឹង? តើអ្នកណាអាចប្រាប់ឲ្យចំៗបានទៅ? ប្រហែលជាវាគឺព្រះអំណោយទានទាំងពីរ។ ដូចដែលបានឃើញហើយ ព្រះអំណោយទានទាំងអស់នេះ ហូរចេញពីព្រះវិញ្ញាណដ៏វិសុទ្ធមក។ ពួកវាតែងតែធ្វើការរួមគ្នា។ ព្រះអំណោយទានមិនសូវសំខាន់ដូចជាគោលបំណងរបស់វានោះឡើយ។ ពួកវាអាចមានសារៈសំខាន់បាន ដរាបណាពួកវាបានជួយដល់ព្រះកាយ។

៣. តាមរយៈព្រះអំណោយទានខាងការសង្កេតស្គាល់វិញ្ញាណផ្សេងៗ លោកប៉ូលបានសង្កេតស្គាល់វិញ្ញាណអាក្រក់ស្ថិតនៅក្នុងស្រីបម្រើម្នាក់។

ដោយអ្នកជឿធម្មតាម្នាក់ ដែលប្រើសមត្ថភាពដើម្បីស្គាល់របស់ខ្លួនឯង ប្រហែលជាគេនឹងគិតថា ស្រីម្នាក់នោះក៏ជាអ្នកបម្រើរបស់ព្រះជាម្ចាស់ម្នាក់ដែរ។ សូមមើលអ្វីដែលនាងបាននិយាយ៖ " លោកទាំងនេះជាអ្នកបំរើរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុត លោកនាំដំណឹងអំពីមាគ៌ានៃការសង្គ្រោះមកប្រាប់អ្នករាល់គ្នា"។ (គម្ពីរកិច្ចការ ១៦:១៧) ។ ស្តាប់ទៅដូចជាល្អប្រពៃណាស់ ប៉ុន្តែលោកបានស្គាល់ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ថាវានោះគឺជាវិញ្ញាណអាក្រក់ដែលកំពុងនិយាយតែប៉ុណ្ណោះ។ ព្រះវិញ្ញាណដ៏វិសុទ្ធបានមានព្រះបន្ទូលទៅកាន់វិញ្ញាណរបស់លោកប៉ូល។ ទើបលោកប៉ូលបានដឹងពីការនោះ។ ដូច្នេះហើយលោកប៉ូលបាននិយាយទៅកាន់វិញ្ញាណអាក្រក់នោះថា "ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត* ចូរចេញពីនាងទៅ!" (គម្ពីរកិច្ចការ ១៦:១៨)។ បន្ទាប់មកខគម្ពីរក៏បានថែងទៀតថា "វិញ្ញាណអាក្រក់ក៏ចេញពីនាងភ្លាម"។

យើងត្រូវចាំថា លោកប៉ូលមិនត្រឹមតែអាចសង្កេតស្គាល់វិញ្ញាណអាក្រក់នោះទេ លោកក៏អាចដេញវាចេញផងដែរ។ ឫទ្ធានុភាពអធិធម្មជាតិនេះ បានប្រទានមកឲ្យអ្នកជឿតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានប្រទានឲ្យគេមានសមត្ថភាពដើម្បីដេញវិញ្ញាណអាក្រក់តាមរយៈរបៀបដូចគ្នានេះដែរ។ អ្នកមិនជឿមិនមានអំណាចមួយនេះឡើយ។ (សូមអានគម្ពីរ កិច្ចការ ១៩:១១-១៧)។

រឿងមួយទៀតដែលវិញ្ញាណអាក្រក់ធ្វើ គឺវាព្យាយាមធ្វើឲ្យអ្នកជឿទទួលយកសេចក្តីបង្រៀនក្លែងក្លាយ។ ព្រះអំណោយទាននៃការសង្កេតស្គាល់វិញ្ញាណ ជួយឲ្យអ្នកជឿអាចស្គាល់ថា អ្វីទៅជាសេចក្តីបង្រៀនរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ហើយអ្វីជាសេចក្តីបង្រៀនរបស់វិញ្ញាណអាក្រក់៖ "ខ្ញុំសរសេរមកអ្នករាល់គ្នា ស្តីអំពីពួកអ្នកដែលបានមកបញ្ឆោតអ្នករាល់គ្នាអោយវង្វេង។ .... ទ្រង់គង់នៅក្នុងអ្នករាល់គ្នាស្រាប់ហើយ ហេតុនេះ អ្នករាល់គ្នាមិនត្រូវការអោយនរណាមកបង្រៀនអ្នករាល់គ្នាឡើយ។"
(គម្ពីរ១យ៉ូហាន ២:២៦-២៧)។ យើងត្រូវរៀនស្តាប់ព្រះវិញ្ញាណដ៏វិសុទ្ធដោយយកចិត្តទុកដាក់។ ទ្រង់នឹងឲ្យយើងបានស្គាល់ថា គ្រូបង្រៀនមួយណាដែលព្យាយាមផ្តល់ការបង្រៀនក្លែងក្លាយមកឲ្យយើង។

## *លំហាត់អនុវត្តន៍*

៣ បំពេញប្រយោគខាងក្រោម។

ក) *ការក្លែងបន្លំ* មានន័យថា...........................................................................................

ខ) វិញ្ញាណទាំងបីប្រភេទអាចបើកសំដែងខ្លួនបានតាមរយៈ......................................................

គ) តាមរយៈការសង្កេតស្គាល់វិញ្ញាណ ព្រះកាយរបស់ព្រះគ្រិស្តអាចត្រូវបាន.................................

## គោលបំណងនៃការសង្កេតស្គាល់វិញ្ញាណផ្សេងៗ

គោលបំណងនៃការសង្កេតស្គាល់វិញ្ញាណផ្សេងៗជាចម្បងបំផុត គឺការការពារព្រះកាយរបស់ព្រះគ្រិស្ត។ ព្រះអំណោយទាននេះការពារព្រះកាយពីវិញ្ញាណអាក្រក់ដែល ព្យាយាមរារាំងដំណឹងល្អ។ វាក៏ជួយការពារព្រះកាយពីវិញ្ញាណខុសឆ្គងដែលតែងតែធ្វើឲ្យព្រះកាយ ឈឺចាប់ និង បែកបាក់។ លើសពីនេះ ព្រះអំណោយទាននៃការសង្កេតស្គាល់វិញ្ញាណផ្សេងៗការពារព្រះកាយពីការបង្រៀនក្លែងក្លាយ។ ការការពារទាំងអស់នេះអាចជួយដល់ការកសាងព្រះកាយរបស់ព្រះគ្រិស្តបាន។

### *លំហាត់អនុវត្តន៍*

---

៤ ចូរអានគម្ពីរ កិច្ចការ ១៦:១៦-១៨។ តើព្រះអំណោយទាននៃការសង្កេតស្គាល់វិញ្ញាណផ្សេងៗដែលបានបើកសំដែងតាមរយៈលោកប៉ូលហើយបានជួយការពារព្រះកាយ ដោយធ្វើដូចម្ដេច?

.................................................................................................................................

.........................................................................................................................

# ខ. ព្រះអំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យផ្សេងៗ

**វត្ថុបំណងទី២.** *បកស្រាយពីមុខងារ និងគោលបំណងនៃព្រះអំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យផ្សេងៗ។*

## និយមន័យនៃព្រះអំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យផ្សេងៗ

"ឲ្យម្នាក់ទៀតចេះនិយាយភាសាចម្លែកអស្ចារ្យ" (គម្ពីរ១កូរិនថូស ១២:១០)។

*ភាសា* មានន័យថា "ពាក្យសំដី"។ ភាសាចម្លែកគឺជា ពាក្យសំដីដែលគេមិនធ្លាប់បានស្គាល់។ យើងនឹកចាំពីសំដីរបស់លោកប៉ូលនៅក្នុងគម្ពីរ១កូរិនថូស ១៣:១៖ "ទោះបី ខ្ញុំចេះនិយាយភាសារបស់មនុស្សលោក និងភាសារបស់ទេវតាក្ដី"

យើងត្រូវយល់ថាព្រះអំណោយទាននេះគឺមានលក្ខណៈអធិធម្មជាតិសុទ្ធសាធ។ ព្រះអំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យផ្សេងៗគឺជាសមត្ថភាពដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រទានមកអ្នកជឿដើម្បីឲ្យអ្នកជឿអាចនិយាយភាសាដែលគាត់មិនធ្លាប់រៀនពីមុនមក។ វាអាចជាភាសារបស់មនុស្ស ឬ អាចជាភាសារបស់ទេវតា។ ព្រះអំណោយទានខាងការនិយាយភាសាចម្លែកអស្ចារ្យ គឺមិនមែនជាភាសាដែលធ្លាប់រៀននោះទេ។ វាគឺជាភាសាដែលបានប្រទានមកពីព្រះវិញ្ញាណដ៏វិសុទ្ធ។

# ការបកស្រាយ និង ការអធិប្បាយអំពីព្រះអំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យ

ព្រះអំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យគឺជាព្រះអំណោយទានរបស់ព្រះវិញ្ញាណដែលមានច្រើនជាងគេ។ វាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ព្រះកាយរបស់ព្រះគ្រិស្ត។ ដោយសារមូលហេតុនេះ សាតាំងព្យាយាមរារាំងមនុស្សមិនឲ្យនិយាយភាសាចម្លែកអស្ចារ្យបានទេ។ ដូច្នេះ យើងចង់ស្វែងយល់ឲ្យបានច្រើនពីវា តាមតែយើងអាចធ្វើបាន។

## សារៈសំខាន់នៃការនិយាយភាសាចម្លែកអស្ចារ្យ

យើងបាននិយាយហើយថា ព្រះអំណោយទានខាងការថ្លែងព្រះបន្ទូល ប្រហែលជាព្រះអំណោយទានដែលមានសារៈសំខាន់ជាងគេ។ ប៉ុន្តែ នៅក្នុងករណីខ្លះ ការនិយាយភាសាចម្លែកអស្ចារ្យក៏មានសារៈសំខាន់ស្មើគ្នានោះដែរ។ ខាងក្រោមនេះគឺជាមូលហេតុខ្លះ៖

១. ការនិយាយភាសាចម្លែកអស្ចារ្យជាព្រះអំណោយទានដែលមនុស្សទាំងអស់អាចទទួលបាន។ លោកប៉ូល  បានមានប្រសាសន៍ថា ៖ " ខ្ញុំចង់អោយបងប្អូនចេះនិយាយភាសាចំឡែកអស្ចារ្យទាំងអស់គ្នា" (គម្ពីរ១កូរិនថូស ១៤:៥)

២. ការនិយាយភាសាចម្លែកអស្ចារ្យគឺជាព្រះអំណោយទានមួយដែលអ្នកអាចបើកសំដែងពេលណាក៏បាន កន្លែងណាក៏បាន និង នៅក្នុងគ្រប់កាលៈទេសៈនៃជីវិតរបស់អ្នក។ បុគ្គលម្នាក់អាច  និយាយភាសាចម្លែកអស្ចារ្យស្ងាត់ៗ និង ឬនិយាយខ្លាំងមកក្រៅក៏បាន
( គម្ពីរ១កូរិនថូស ១៤:២៨)។

៣. ការនិយាយភាសាចម្លែកអស្ចារ្យគឺជាព្រះអំណោយទានមូលដ្ឋានគ្រឹះនៃព្រះអំណោយទានទាំងប្រាំបួន ដែលអ្នកជឿអាចកសាងខ្លួនគេឡើងបាន (គម្ពីរ១កូរិនថូស ១៤:៤)

៤. ការនិយាយភាសាចម្លែកអស្ចារ្យអាចមានមុខងារជាព្រះអំណោយទានដំបូង។ ខ្ញុំនឹងបកស្រាយវា។ នៅប្រទេសអ៊ីស្រាអែល មានជើងទៀនពីរប្រភេទ។ ខ្លះមានបែកជាងប្រាំពីរ។ ខ្លះទៀតមានបែកធាង  ប្រាំបួន។ នៅលើជើងទៀនដែលមានធាងចំនួនប្រាំបួន មានធាងមួយដែលអាចដកចេញ  ពីធាងប្រាំបីទៀត។ បន្ទាប់មកគេអុជវា ហើយជាមួយនឹងទៀនមួយនោះ គេអុជទៀនប្រាំបី   ដើមទៀត។ ព្រះអំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យក៏ដូចគ្នានោះដែរ។ វាជួយយើងនៅក្នុងពិភពអធិធម្មជាតិដ៏អស្ចារ្យ។ យើងអាចនិយាយបានថា វាជួយឲ្យយើងចាប់ផ្ដើមនៅក្នុងភាពអធិធម្មជាតិ។ វារៀបចំយើងដើម្បីបើកសំដែង ព្រះអំណោយទានទាំងប្រាំបីផ្សេងទៀត។

៥. ការនិយាយភាសាចម្លែកអស្ចារ្យគឺជាភាសារបស់វិញ្ញាណ។ ព្រះជាម្ចាស់គឺជាព្រះវិញ្ញាណ។ ការនិយាយភាសាចម្លែកអស្ចារ្យ ជួយយើងឲ្យនិយាយជាមួយព្រះជាម្ចាស់បានល្អប្រសើរជាងការនិយាយដោយសមត្ថភាពមនុស្សរបស់យើង។

## *លំហាត់អនុវត្តន៍*

៥ ចូរសរសេរអក្សរ ត នៅមុខចម្លើយត្រឹមត្រូវ និងសរសេរអក្សរ ខ នៅមុខចម្លើយដែលមិនត្រឹមត្រូវ

........ក) ការនិយាយភាសាចម្លែកអស្ចារ្យ គឺមានន័យថាភាសាដែលយើងអាចរៀននៅសាលា។

........ខ) អ្នកខ្លះដែលនិយាយភាសាចម្លែកអស្ចារ្យ គឺនិយាយភាសារបស់ទេវតា។

........គ) ការនិយាយភាសាចម្លែកអស្ចារ្យគឺជាព្រះអំណោយទានដែលមិនសូវសំខាន់ជាងគេក្នុង ចំណោមព្រះអំណោយទានរបស់ព្រះវិញ្ញាណទាំងប្រាំបួន។

.......ឃ) ការនិយាយភាសាចម្លែកអស្ចារ្យគួរតែកំណត់សម្រាប់អ្នកដឹកនាំក្រុមជំនុំបានហើយ។

## មុខងារនៃការនិយាយភាសាចម្លែកអស្ចារ្យ

ការនិយាយភាសាចម្លែកអស្ចារ្យគឺជាសភស្តុតាងនៃការជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងអាចនិយាយបានថា *នៅពេលណា* ដែលមនុស្សទទួលការជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ពួកគេនឹងនិយាយភាសាចម្លែកអស្ចារ្យ។ ពួកគេអាចនិយាយ ភាសាផ្សេងៗខុសៗគ្នាដែលគេមិនធ្លាប់បានដឹងពីមុនមក។ ហេតុអ្វីបានជាយើងជឿថាបុគ្គលម្នាក់ដែលត្រូវបានជ្រមុជនៅក្នុងព្រះវិញ្ញាណហើយ នឹងនិយាយភាសាចម្លែកអស្ចារ្យ? មានហេតុមួយចំនួនសម្រាប់ការនេះ។

នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធបានចាក់បង្ហូរជាលើកដំបូងនៅបុណ្យថ្ងៃទីហាសិប មនុស្សទាំងអស់ដែលមានវត្តមាននៅទីនោះបាននិយាយភាសាចម្លែកអស្ចារ្យ។ ក្នុងនោះរួមមាន សាវ័កទាំងដប់ពីរនាក់ និង មនុស្សប្រុសស្រីជាងមួយរយនាក់ផ្សេងទៀតដែរ។ គ្មាននរណាបានដឹងថានឹងមានរឿងអ្វី កើតឡើងនៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធយាងមកសណ្ឋិតលើពួកគេនោះឡើយ។ ពួកគេមិនដែលទទួលបានការបង្រៀនអ្វីសោះ។ ពួកគេក៏គ្មានគំនិតខុសឆ្គង។ ពួកគេមិនដែលមានគំរូអ្វីឡើយ។ ប៉ុន្តែ នៅពេលដែលពួកគេបានជ្រមុជនៅក្នុងព្រះវិញ្ញាណ។ ពួកគេទាំងអស់គ្នា មាន*បទពិសោធន៍ដូចគ្នា*។ ពួកគេ*ទាំងអស់* បាននិយាយភាសាចម្លែកអស្ចារ្យ។

ដូច្នេះ ប្រសិនបើយើងចង់ដឹងច្បាស់អំពីអ្វីដែលគួរតែទន្ទឹងចាំមើល នៅពេលដែលយើងបានជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធនោះ អ្វីដែលយើងត្រូវធ្វើ គឺមើលពីរឿងរ៉ាវដែលមនុស្សបានជ្រមុជក្នុងព្រះវិញ្ញាណលើកទីមួយ នោះគឺជាគំរូដែលមានស្រាប់។

វាហាក់បីដូចជា នៅពេលដែលមនុស្សទទួលបានការជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ នៅក្នុងក្រុមជំនុំដំបូងបង្អស់ ពេលនោះពួកគេក៏បាននិយាយភាសាចម្លែកអស្ចារ្យដែរ។ សូមយើងពិនិត្យមើលរឿងដំបូងទាំងនេះ ដោយយោងទៅតាមកណ្ឌគម្ពីរកិច្ចការ។

១. *មនុស្សមួយរយម្ភៃនាក់នៅក្នុងបន្ទប់ខាងលើ។* "អ្នកទាំងនោះបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ* ហើយចាប់ផ្ដើមនិយាយភាសាផ្សេងៗពីគ្នា តាមព្រះវិញ្ញាណប្រោសប្រទានអោយ។" (គម្ពីរកិច្ចការ ២:៤)។

២. *អ្នកស្រុកសាម៉ារី*។ សូមមើលនៅក្នុងគម្ពីរកិច្ចការ៨:១៤-១៧។ នៅក្នុងព្រះគម្ពីរមិនបានបញ្ចេញច្បាស់ៗថាពួកគេបាននិយាយភាសាចម្លែកអស្ចារ្យនោះទេ។ ប៉ុន្តែគម្ពីរក៏មិនបាននិយាយថា ពួកគេមិន និយាយភាសាចម្លែកអស្ចារ្យនោះដែរ។ នៅពេលដែលលោកស៊ីម៉ូនបានឃើញថា ព្រះវិញ្ញាណដ៏វិសុទ្ធបានប្រទានមកដោយគ្រាន់តែពួកសាវ័កដាក់ដៃលើយ៉ាងដូច្នោះ លោកក៏ចង់ទិញអំណាចនោះ ដើម្បីឲ្យគាត់មានអំណាចអាចធ្វើដូចគ្នានោះដែរ។ សួរថាតើលោកស៊ីម៉ូនបានឃើញរឿងអ្វីកើតឡើង? យើងជឿថាលោកបានឃើញ និង ឮអ្នកស្រុកសាម៉ារី និយាយភាសាចម្លែកអស្ចារ្យ។

៣. *បទពិសោធន៍របស់លោកប៉ូល*។ ចូរអានគម្ពីរកិច្ចការ ៩:១៧។ សាជាថ្មីម្ដងទៀត ក្នុងគម្ពីរមិនបានប្រាប់យើងថា លោកប៉ូលបាននិយាយ ឬមិនបាននិយាយភាសាចម្លែកអស្ចារ្យ ក្រោយពេលលោកទទួលបានការជ្រមុជនៅក្នុងព្រះវិញ្ញាណហើយនោះទេ។ ប៉ុន្តែក្រោយមកលោកប៉ូលបាននិយាយថា៖ "ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ព្រោះខ្ញុំចេះនិយាយភាសាចំឡែកអស្ចារ្យលើសបងប្អូនទាំងអស់គ្នាទៅទៀត" (គម្ពីរ១កូរិនថូស១៤:១៨) ។ តើអ្នកគិតថាលោកចាប់ផ្ដើម និយាយភាសាចម្លែកអស្ចារ្យតាំងពីពេលណា? យើងជឿថាលោកចាប់ផ្ដើមនិយាយភាសាចម្លែកអស្ចារ្យ នៅពេលដែលលោកទទួលការជ្រមុជក្នុងព្រះវិញ្ញាណ។

៤. *លោកកូនេលាស និង អ្នកផ្ទះរបស់លោក*។ សូមមើលគម្ពីរកិច្ចការ១០:៤៥-៤៧។ "ព្រោះគេបានឮសាសន៍ដទៃទាំងនោះនិយាយភាសាចំឡែកអស្ចារ្យ* ព្រមទាំងលើកតម្កើងព្រះជាម្ចាស់ផង។

៥. *អ្នកក្រុងអេភេសូ*។ សូមអានគម្ពីរកិច្ចការ ១៩:១-៦។ នៅត្រង់នេះបង្ហាញយ៉ាងច្បាស់ថា ពួកគេបាននិយាយភាសាចម្លែកអស្ចារ្យ។

ក្រោយពេលសិក្សា រឿងទាំងប្រាំនេះ យើងសង្កេតឃើញថាមនុស្សបានជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ហើយមានរឿងបីយ៉ាងដែលបានបង្ហាញយ៉ាងច្បាស់ៗថា ពួកគេបាននិយាយភាសាចម្លែកអស្ចារ្យ។ ដូច្នេះ យើងជឿថា *អស់អ្នក* ដែលបានជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធនឹងនិយាយភាសាចម្លែកអស្ចារ្យ។

## *លំហាត់អនុវត្តន៍*

៦ យើងជឿថាការនិយាយភាសាចម្លែកអស្ចារ្យ គឺជាភស្តុតាងដែលបង្ហាញថា នៅពេលដែលអ្នកជឿម្នាក់បានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធព្រោះ

ក) ការនិយាយភាសាចម្លែកអស្ចារ្យគឺមានលក្ខណៈអធិធម្មជាតិ។

ខ) ការនិយាយភាសាចម្លែកអស្ចារ្យគឺ មិនងាយស្រួលរៀននោះទេ។

គ) មនុស្សគ្រប់គ្នាដែលបានជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងបន្ទប់ខាងលើថ្ងៃនោះ មានបទពិសោធន៍ក្នុងការនិយាយភាសាចម្លែកអស្ចារ្យ។

ឃ) យោងតាមឯកសារនៅក្នុងកណ្ឌគម្ពីរកិច្ចការបានប្រាប់ថា អស់អ្នកដែលបានជ្រមុជនៅក្នុង ព្រះវិញ្ញាណដ៏វិសុទ្ធ បាននិយាយភាសាចម្លែកអស្ចារ្យ។

## ការលើកស្ទួយខាងវិញ្ញាណ

ការនិយាយភាសាចម្លែកអស្ចារ្យ បានកសាង *អ្នកជឿ* ខាងវិញ្ញាណៈ "អ្នកណានិយាយភាសាចំឡែកអស្ចារ្យ អ្នកនោះកសាងតែខ្លួនឯងប៉ុណ្ណោះ" (គម្ពីរ១កូរិនថូស ១៤:៤)។ ដូចដែលយើងបានឃើញរួចមកហើយ ការកសាងខ្លួនឯង គឺជាមុខងារដ៏សំខាន់នៃការនិយាយភាសាចម្លែកអស្ចារ្យ។ អ្នកជឿទាំងអស់គ្នា ត្រូវការរីកចម្រើនខាងវិញ្ញាណៈ "បងប្អូនជាទីស្រឡាញ់អើយ ចូរកសាងគ្នាទៅវិញទៅមក លើជំនឿដ៏វិសុទ្ធបំផុតរបស់បងប្អូន ចូរអធិស្ឋានតាមព្រះវិញ្ញាណដ៏វិសុទ្ធ។" (គម្ពីរយូដាស ២០)។ នេះគឺជាជំនួយដ៏អស្ចារ្យសម្រាប់អ្នកជឿទាំងឡាយណាដែលមានពេញដោយព្រះវិញ្ញាណ។

ព្រះវិញ្ញាណបានដាក់នៅក្នុងទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងព្រះជាម្ចាស់ព្រះវរបិតា។ សូមអានខគម្ពីរខាងក្រោមនេះៈ

១. *គម្ពីរកិច្ចការ ២:១១* ៖ "យើងបានឮគេថ្លែងអំពីស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះជាម្ចាស់"។ អ្នកខ្លះគិតថា អ្នកនិយាយនោះអាចត្រូវបានគេថ្លែងប្រាប់មនុស្សពីកិច្ចការរបស់ព្រះជាម្ចាស់។ តាមគំនិតរបស់ខ្ញុំ ពួកគេកំពុងតែថ្វាយបង្គំ និង សរសើរតម្កើងព្រះជាម្ចាស់។ ពួកគេកំពុង និយាយ *ទៅកាន់ព្រះជាម្ចាស់* ។

២. គម្ពីរកិច្ចការ ១០:៤៦៖ "គេបានឮសាសន៍ដទៃទាំងនោះនិយាយភាសាចំឡែកអស្ចារ្យ* ព្រមទាំងលើកតម្កើងព្រះជាម្ចាស់ផង។" ពួកគេក៏កំពុងនិយាយ *ទៅកាន់* ព្រះជាម្ចាស់ដែរ។

៣. គម្ពីរ១កូរិនថូស ១៤:១៤-១៥។ ត្រង់នេះ លោកប៉ូលបាននិយាយនៅក្នុងពេលដែលលោកអធិស្ឋានថាៈ "វិញ្ញាណខ្ញុំនៅអធិស្ឋាន" ។ នោះគឺការនិយាយភាសាចម្លែកអស្ចារ្យ។ លោកបាន *និយាយទៅកាន់ព្រះជាម្ចាស់* ក្នុងការអធិស្ឋានរបស់លោក។

៤. គម្ពីរ១កូរិនថូស ១៤:១៦។ "បើបងប្អូនអរព្រះគុណព្រះអង្គ ដោយវិញ្ញាណរបស់បងប្អូន...." ។ លោកប៉ូលចង់មានន័យថា "នៅពេលដែលអ្នកសរសើរព្រះជាម្ចាស់ជាភាសាចម្លែកអស្ចារ្យ"។ សាជាថ្មីម្តងទៀត ការនិយាយនោះគឺ *ទៅកាន់ព្រះជាម្ចាស់។*

៥. គម្ពីរ១កូរិនថូស១៤:១៧។"បងប្អូនបានអរព្រះគុណដូច្នេះ ល្អវិសេសវិសាលហើយ" ការអរព្រះគុណគឺទៅដល់ព្រះជាម្ចាស់។

ការនិយាយភាសាចម្លែកអស្ចារ្យ តែមួយមុខ វាជួយកសាងអ្នកជឿបាន ប៉ុន្តែការនិយាយភាសាចម្លែកដែលមានការបកប្រែផងនោះ ជួយកសាងទាំង *ព្រះកាយរបស់ព្រះគ្រិស្ត* ផង។ (គម្ពីរ១កូរិនថូស ១៤:៤-៥) ។ នៅពេលដែលភាសាអស្ចារ្យចម្លែកអស្ចារ្យត្រូវបានបកប្រែជាសាធារណៈ បទពិសោធន៍នោះនឹងកសាងព្រះកាយទាំងមូល។

តើការនិយាយភាសាចម្លែកអស្ចារ្យ ជាមួយនឹងការបកប្រែ ធ្វើការកសាងព្រះកាយទាំងមូលដោយរបៀបណា? ការនិយាយភាសាចម្លែកអស្ចារ្យជាមួយនឹងការបកប្រែ គឺស្មើនឹងការថ្លែងព្រះបន្ទូល។ គំនិតនេះគឺផ្អែកទៅលើអ្វីដែលលោកប៉ូលបាននិយាយៈ " អ្នកថ្លែងព្រះបន្ទូលសំខាន់ជាងអ្នកនិយាយភាសាចំឡែកអស្ចារ្យទៅទៀត លើកលែងតែអ្នកនិយាយនោះបកប្រែអោយគេយល់ ដើម្បីកសាងក្រុមជំនុំទើបសំខាន់។" (គម្ពីរ១កូរិនថូស ១៤:៥)។

ដូចយើងបាននិយាយរួចមកហើយ (ក្នុងមេរៀនទី៥) ថាមានពេលខ្លះនឹងមានការត្រួតលើគ្នារវាងព្រះអំណោយទានទាំងអស់។ ជាក់ស្តែង តាមរយៈព្រះអំណោយទានអធិធម្មជាតិនៃការថ្លែងព្រះបន្ទូល ដែលជាការនិយាយទៅកាន់មនុស្សនោះ ព្រះកាយរបស់ព្រះគ្រិស្តបានចម្រើនឡើង ដោយការដាស់តឿន និងលើកទឹកចិត្ត។ ព្រះកាយក៏ត្រូវបានកសាងឡើងតាមរយៈព្រះអំណោយទានអធិធម្មជាតិ នៃការនិយាយភាសាចម្លែកអស្ចារ្យ និង ការបកប្រែភាសាចម្លែកអស្ចារ្យផ្សេងៗនោះដែរ។

## *លំហាត់អនុវត្តន៍*

ចូរបំពេញប្រយោគខាងក្រោម៖

៧ ការនិយាយភាសាចម្លែកអស្ចារ្យ ដោយគ្មានការបកប្រែ អាចកសាង........................................ ...................................................... ស្របពេលជាមួយគ្នានោះ ការនិយាយភាសាចម្លែកអស្ចារ្យ ដែលមានការបកប្រែ អាចកសាង........................................................................

៨ ការនិយាយភាសាចម្លែកអស្ចារ្យដែលគ្មានការបកប្រែគឺនិយាយសំដៅឆ្ពោះទៅ.......................... .........................................................................................ដោយផ្ទាល់។

## ជំនួយពិសេស

នៅពេលដែលយើងអធិស្ឋាន ដោយភាសាចម្លែកអស្ចារ្យ យើងអាចអធិស្ឋានបាននូវសេចក្តីអធិស្ឋានដែលយើងមិនអាចធ្វើបានតាមធម្មជាតិរបស់យើង៖ "យ៉ាងណាមិញ ព្រះវិញ្ញាណក៏យាងមកជួយយើងដែលទន់ខ្សោយនេះដែរ ដ្បិតយើងពុំដឹងអធិស្ឋាន*ដូចម្ដេច ដើម្បីអោយបានសមនោះឡើយ តែព្រះវិញ្ញាណផ្ទាល់ ទ្រង់ទូលអង្វរអោយយើង ដោយព្រះសូរសៀងដែលគ្មាននរណាអាចថ្លែងបាន។" (គម្ពីររ៉ូម ៨:២៦)។

ការនិយាយភាសាចម្លែកអស្ចារ្យ អាចជាសញ្ញាសំគាល់សម្រាប់អ្នកមិនជឿ៖ "ការនិយាយភាសាចំឡែកអស្ចារ្យ ជាទីសំគាល់មួយសំរាប់អ្នកមិនជឿ គឺមិនមែនសំរាប់អ្នកជឿទេ។" (គម្ពីរ១កូរិនថូស ១៤:២២)។ នៅពេលដែលអ្នកមិនជឿម្នាក់បានឮនរណាម្នាក់និយាយភាសាចម្លែកមួយដែលអ្នកនោះផ្ទាល់មិនដែលស្គាល់ពីមុខមក អ្នកមិនជឿនោះនឹងបានដឹងថាព្រះជាម្ចាស់កំពុងតែមានព្រះបន្ទូលទៅកាន់គាត់។ ព្រះជាម្ចាស់អាចនឹងមិនមានព្រះបន្ទូលទៅកាន់គាត់ ដោយពាក្យដែលបាននិយាយចេញមកនោះទេ តែដោយភាពអធិធម្មជាតិដ៏អស្ចារ្យនៃពាក្យដែលបាននិយាយចេញមកនោះវិញ។ ទាំងពីរករណីនេះ អ្វីដែលបាននិយាយចេញមកនោះគឺសម្រាប់ប្រយោជន៍របស់អ្នកស្តាប់។

នេះគឺជាអ្វីដែលបានកើតឡើងនៅក្នុងបុណ្យថ្ងៃទីហាសិប។ មនុស្សម្នានៅក្រុងយេរូសាឡឹម ដែលមកពីប្រទេសផ្សេងៗ បានមកជួបជុំគ្នា។ នៅពេលដែលពួកគេមកជួបជុំគ្នា ពួកគេបានឮពួកមនុស្សទាំងនេះដែលមកពីស្រុកកាលីឡេ "ថ្លែងអំពីស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ជាភាសាយើងទាំងអស់គ្នាផ្ទាល់!" (គម្ពីរកិច្ចការ ២:១១)។ ការនោះបានរៀបចំអ្នកមិនជឿ ដើម្បីបានស្តាប់ដំណឹងល្អរបស់ព្រះគ្រិស្ត។ ការនិយាយភាសាចម្លែកអស្ចារ្យគឺជាសញ្ញាសំគាល់សម្រាប់ពួកគេ។

## លំហាត់អនុវត្តន៍

៩ ចូរបំពេញប្រយោគខាងក្រោម។

ក) ព្រះវិញ្ញាណដ៏វិសុទ្ធជួយយើងឲ្យអធិស្ឋាន ដោយយោងទៅតាម.............................................

ខ) ការនិយាយភាសាចម្លែកអស្ចារ្យគឺជាជំនួយសម្រាប់អ្នកជឿ ព្រោះពួកគេដឹងថា...........................
.............................................................................................................................

គ) នៅពេលដែលអ្នកមិនជឿ បានស្តាប់គ្រិស្តបរិស័ទនិយាយភាសាចម្លែកអស្ចារ្យ ពួកគេដឹងថា .........
.............................................................................................................................

## បទបញ្ញាសម្រាប់ការនិយាយភាសាចម្លែកអស្ចារ្យផ្សេងៗ

ដោយការនិយាយភាសាចម្លែកអស្ចារ្យមានច្រើន យើងត្រូវតែយល់ដឹងពីការប្រើប្រាស់ព្រះអំណោយទាននេះឲ្យបានត្រឹមត្រូវ។ ក្រុមជំនុំនៅក្រុងកូរិនថូសមានព្រះអំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យ ប៉ុន្តែមិនដឹងពីរបៀបប្រើប្រាស់ព្រះអំណោយទាននេះឲ្យបានល្អនោះទេ។ ពួកគេត្រូវការចំណេះដឹងបន្ថែម។ ដូច្នេះលោកប៉ូលបានផ្តល់ឲ្យពួកគេនូវមគ្គទេសក៍ខ្លះៗ៖

១. មិនត្រូវផ្តោតសំខាន់ខ្លាំងពេកតែទៅលើ ការនិយាយភាសាចម្លែកអស្ចារ្យនោះឡើយ។ (សូមអានគម្ពីរ១កូរិនថូស១៤:៦ និង ១៤:២៦)។ ត្រូវតែមានពេលវេលាសម្រាប់រឿងក្រៅពីការនិយាយភាសាចម្លែកអស្ចារ្យដូចការបើកសំដែង ពាក្យសំដីនៃចំណេះដឹង ការថ្លែងព្រះបន្ទូលគោលលិទ្ធិ ការច្រៀងសរសើរតម្កើង ការបកប្រែភាសា និង រឿងជាច្រើនផ្សេងទៀតផង។

២. ការនិយាយភាសាចម្លែកអស្ចារ្យគឺ មានកំណត់ត្រឹមពីរ ឬ បីដងប៉ុណ្ណោះនៅក្នុងកម្មវិធីថ្វាយបង្គំមួយ ( គម្ពីរ ១កូរិនថូស ១៤:២៧)។

៣. ការនិយាយភាសាចម្លែកអស្ចារ្យនៅកម្មវិធីជាសាធារណៈត្រូវមានការបកប្រែ ( គម្ពីរ ១កូរិនថូស ១៤:២៧)។

៤. អ្នកដែលនិយាយភាសាចម្លែកអស្ចារ្យនៅទីសាធារណៈ ត្រូវតែហាមឃាត់ឲ្យស្ងាត់ ប្រសិនបើគ្មាននរណាម្នាក់នៅទីនោះអាចបកប្រែបាន។ (គម្ពីរ១កូរិនថូស ១៤:២៨)។

៥. អ្នកដែលនិយាយភាសាចម្លែកអស្ចារ្យនៅទីសាធារណៈត្រូវតែអធិស្ឋានសូមឲ្យគេអាចបកប្រែបានដែរ។ ( គម្ពីរ១កូរិនថូស ១៤:១៣)។

៦. មិនត្រូវហាមមិនឲ្យមាន ការនិយាយភាសាចម្លែកអស្ចារ្យ។ (គម្ពីរ១កូរិនថូស ១៤:៣៩)

៧. មិនត្រូវ និយាយភាសាចម្លែកអស្ចារ្យ ដែលបង្កឲ្យមានភាពច្របូកច្របល់ឡើយ។ (គម្ពីរ១កូរិនថូស ១៤:៤០)

### ***លំហាត់អនុវត្តន៍***

១០ កត្តាដែលបានផ្តល់នូវមូលដ្ឋានគ្រឹះយ៉ាងរឹងមាំសម្រាប់ការបើកសំដែងដែលមានផលប្រយោជន៍ នៃព្រះអំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យ គឺជា.......................................................

## គោលបំណងសម្រាប់ព្រះអំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យផ្សេងៗ

គោលបំណងសម្រាប់ការនិយាយភាសាចម្លែកអស្ចារ្យ គឺមានពីរកម្រិតៈ
(១) ការកសាងអ្នកជឿដែលនិយាយភាសានោះ និង (២) ការកសាងព្រះកាយ នៅពេលណាដែលការនិយាយភាសាចម្លែកអស្ចារ្យត្រូវបានគេបកប្រែ។

អ្នកខ្លះបានព្យាយាមប្រើប្រាស់ទាំងការនិយាយភាសាចម្លែកអស្ចារ្យ និង ការថ្លែងព្រះបន្ទូលដើម្បីធ្វើការតម្រង់ផ្លូវខ្លួនឯង។ ការនេះធ្វើឲ្យមានបញ្ហាធ្ងន់ធ្ងរមួយបានកើតឡើង។ ប្រសិនបើយើងយល់ ថាការនិយាយភាសាចម្លែកអស្ចារ្យដែលគ្មានការបកប្រែ គឺជាការនិយាយទៅកាន់ព្រះជាម្ចាស់ យើងប្រាកដជាដឹងថានោះមិនមែនជារបៀបដែលព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់មនុស្សនោះទេ។ យើងមិនមានន័យថាព្រះជាម្ចាស់មិនអាចមានព្រះបន្ទូលមកកាន់មនុស្ស ជាភាសាចម្លែកសម្រាប់អ្នកនិយាយនោះទេ។ ប៉ុន្តែប្រសិនបើការនោះពិតជាបានកើតមានឡើងមែន នោះវានឹងជាការអស្ចារ្យមួយ និងវាមិនមែនជាមុខងារទូទៅរបស់ព្រះអំណោយទាននៃការនិយាយភាសាចម្លែកអស្ចារ្យនោះ។

បើនិយាយពីរឿងយកការថ្លែងព្រះបន្ទូលមកធ្វើជាការតម្រង់ផ្លូវផ្ទាល់ខ្លួន លោកដូណាល់ ហ្គី បាននិយាយថា "យើងអាចអះអាងយ៉ាងជាក់ច្បាស់ថា មិនដែលមានម្តងណាសោះឡើយ ដែលព្រះអំណោយទាននៃការថ្លែងព្រះបន្ទូលត្រូវបានយកមកធ្វើជាជំនួយសម្រាប់តម្រង់ផ្លូវផ្ទាល់ខ្លួននៅក្នុងនៅ គម្ពីរសម្ព័ន្ធមេត្រីថ្មីសោះឡើយ។

មានរឿងមួយទៀតដែលគួរតែកត់សំគាល់បន្ថែមពីលើនេះ។ នៅពេលដែលលោកប៉ូលសរសេរសំបុត្រទៅក្រុងកូរិនថូសអំពីគោលបំណងនៃការថ្លែងព្រះបន្ទូល លោកបាននិយាយថា វាគឺសម្រាប់ ដើម្បីជួយកសាង ដាស់តឿន និងលើកទឹកចិត្តគេ។ គ្មានពាក្យណាមួយ បានប្រាប់ថាព្រះអំណោយទាននេះត្រូវយកមកធ្វើជាការតម្រង់ផ្លូវផ្ទាល់ខ្លួននោះឡើយ។

យើងអាចមានសុវត្ថិភាព នៅពេលណាដែលយើងបើកសំដែងព្រះអំណោយទានទាំងនេះដោយយោងតាមការណែនាំរបស់លោកប៉ូល។ នៅពេលដែលយើងធ្វើដូច្នេះ គោលបំណងរបស់ព្រះអំណោយទានទាំងអស់ក៏ត្រូវបានបំពេញដែរ។

## *លំហាត់អនុវត្តន៍*

១១ គោលបំណងដ៏ធំមួយរបស់ព្រះអំណោយទានរបស់ព្រះវិញ្ញាណទាំងប្រាំបួន បូករួមទាំការ និយាយភាសាចម្លែកអស្ចារ្យផងនោះ គឺ.......................................................................................

# គ. ការបកប្រែន័យភាសាចម្លែកអស្ចារ្យផ្សេងៗ

**វត្ថុបំណងទី៣.** *ប្រាប់ពីមុខងារ និង គោលបំណងនៃព្រះអំណោយទានខាងការបកប្រែន័យភាសាចម្លែកអស្ចារ្យផ្សេងៗ។*

**វត្ថុបំណងទី៤.** *បកស្រាយពីរបៀបដែលអ្នកអាចត្រូវបានប្រើប្រាស់ដោយព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីបើកសំដែងព្រះអំណោយទាននេះ។*

## និយមន័យនៃការបកប្រែន័យភាសាចម្លែកអស្ចារ្យផ្សេងៗ

"អោយម្នាក់ទៀតចេះបកប្រែន័យភាសាទាំងនោះ" (គម្ពីរ១កូរិនថូស១២:១០)។

*ការបកប្រែន័យ* មានន័យថា "ការបកស្រាយ"។*ការបកស្រាយ* មានន័យថា "ផ្ដល់និយមន័យ" ។ យើងត្រូវយល់ថា ការបកប្រែន័យនេះមិនមែនមានន័យដូច "ការបកប្រែភាសា" នោះទេ។ *ការបកប្រែភាសា* មានន័យថា "ការនិយាយពាក្យដូចគ្នានៃភាសាមួយ ជាភាសាដទៃមួយទៀតប៉ុណ្ណោះ" ។

ដូច្នេះ ការបកប្រែន័យភាសាចម្លែកអស្ចារ្យគឺជា "ការផ្ដល់និយមន័យ សម្រាប់អ្វីដែលបាននិយាយជាភាសាដទៃ"។ យើងក៏ត្រូវយល់ថាសមត្ថភាពក្នុងការផ្ដល់និយមន័យភាសាចម្លែកអស្ចារ្យបានមកពីព្រះវិញ្ញាណដ៏វិសុទ្ធតែមួយគត់។

## ការបកស្រាយ និង ការអធិប្បាយអំពីការបកប្រែន័យភាសាចម្លែកអស្ចារ្យផ្សេងៗ

ការនិយាយភាសាចម្លែកអស្ចារ្យ នៅក្នុងកម្មវិធីសាធារណៈមានសណ្ដាប់ធ្នាប់បាន នៅពេលដែលវាត្រូវបានបកប្រែន័យ ៖ "បើបងប្អូននិយាយភាសាចំឡែកអស្ចារ្យ ត្រូវអោយពីរ ឬបីនាក់យ៉ាងច្រើននិយាយ ហើយនិយាយម្នាក់ម្ដងៗ ដោយមានអ្នកបកប្រែផងដែរ។" (គម្ពីរ១កូរិនថូស១៤:២៧)។

ការនិយាយភាសាចម្លែកអស្ចារ្យនៅកម្មវិធីសាធារណៈដោយគ្មានការបកប្រែន័យ គឺជាការទាស់នឹងការណែនាំរបស់លោកប៉ូល។ "បើបងប្អូនប៉ងប្រាថ្នាចង់បានព្រះអំណោយទានរបស់ព្រះវិញ្ញាណ ដូច្នេះ ត្រូវរកអោយបានច្រើនបរិបូណ៌ទៅ ជាពិសេស រកព្រះអំណោយទានសំរាប់កសាងក្រុមជំនុំ*។" (គម្ពីរ១កូរិនថូស ១៤:១២)។

ចុះបើអ្នកមានអារម្មណ៍ប៉ងប្រាថ្នានៅក្នុងវិញ្ញាណរបស់អ្នកថាចង់និយាយភាសាចម្លែងក្នុងអំឡុងពេលធ្វើកម្មវិធីថ្វាយបង្គំមួយ ហើយគ្មាននរណាម្នាក់អាចធ្វើការបកប្រែន័យ អ្វីដែលអ្នកនឹងនិយាយនោះ? តើនោះមានន័យថា អ្នកមិនត្រូវនិយាយឬមួយយ៉ាងណា? អត់ទេ។ *វាមានន័យថា អ្នកដែលនឹងត្រូវព្រះវិញ្ញាណដ៏វិសុទ្ធប្រើ ឲ្យបកប្រែន័យនោះ មិនមានជំនឿដើម្បីធ្វើការបកប្រែន័យនោះទេ។* ច្បាប់នេះក៏អាចនឹងយកទៅប្រើជាមួយនឹងការថ្លែងព្រះបន្ទូលដែរ៖ "រីឯអ្នកដែលរស់នៅតាមព្រះវិញ្ញាណ គិតតែពីអ្វីៗដែលទាក់ទងនឹងព្រះវិញ្ញាណ។" (គម្ពីររ៉ូម ៨:៥)

ក៏ដូចគ្នាផងដែរ ប្រសិនបើគ្មាននរណាម្នាក់បកប្រែន័យអ្វីដែលអ្នកនិយាយ *វាអាចមានន័យថា អ្នកមិនបានធ្វើតាមច្បាប់របស់ព្រះគម្ពីរនោះទេ៖* "ប្រសិនបើគ្មានអ្នកបកប្រែទេនោះ បងប្អូនត្រូវនៅស្ងៀម កុំនិយាយភាសាចំឡែកអស្ចារ្យក្នុងក្រុមជំនុំឡើយ ចូរនិយាយតែក្នុងចិត្ត និងនិយាយទៅកាន់ព្រះជាម្ចាស់បានហើយ។" ( គម្ពីរ១កូរិនថូស ១៤:២៨)។ ក្នុងករណីនេះ អ្នកមិនត្រូវមានអារម្មណ៍មិនល្អនោះទេ ប្រសិនបើអ្វីដែលអ្នកបាននិយាយ មិនត្រូវបានគេបកប្រែទេនោះ។ ប៉ុន្តែអ្នកគួរតែប្រុងប្រយ័ត្ន ដោយមិនត្រូវនិយាយម្តងទៀតទេ ដរាបណាអ្នកស្គាល់អ្នកបកប្រែន័យណាម្នាក់ដែលនៅទីនោះដែរ។

ម្តងទៀត ប្រសិនបើគ្មាននរណាម្នាក់បកប្រែន័យ អ្វីដែលអ្នកនិយាយទេនោះ *វាអាចមានន័យថា យើងគួរតែផ្តោតគំនិតរបស់អ្នកទៅលើអ្វីដែលលោកប៉ូលមានប្រសាសន៍នៅក្នុង គម្ពីរ១កូរិនថូស ១៤:១៣ អំពីការបកប្រែន័យភាសាចម្លែកអស្ចារ្យនោះដោយខ្លួនឯង៖* "ហេតុនេះ អ្នកដែលនិយាយភាសាចំឡែកអស្ចារ្យត្រូវអធិស្ឋាន*សុំអោយចេះបកប្រែន័យផង។"

មានសំណួរមួយទៀតទាក់ទងនឹងការបកប្រែន័យភាសាចម្លែកអស្ចារ្យ៖ តើខ្ញុំធ្វើដូចម្តេច ទើបអាចដឹងថា ព្រះវិញ្ញាណដ៏វិសុទ្ធសព្វព្រះទ័យបើកសំដែងព្រះអំណោយទាននៃការបកប្រែន័យភាសាចម្លែកអស្ចារ្យនេះតាមរយៈខ្ញុំ? ចម្លើយគឺដូចទៅនឹងអ្វីដែលយើងបានប្រាប់ ទាក់ទងនឹងព្រះអំណោយទានផ្សេងៗទៀតអ៊ីចឹង។ អ្នកនឹងមានអារម្មណ៍ប៉ងប្រាថ្នាយ៉ាងខ្លាំងនៅក្នុងវិញ្ញាណរបស់អ្នក ក្រោយពេលមាននរណាម្នាក់បាននិយាយភាសាចម្លែកអស្ចារ្យមួយ ក្នុងការចែកចាយសារបន្ទូលដែលព្រះជាម្ចាស់ប្រទានមកឲ្យអ្នក។ បន្ទាប់មក អ្នកគួរតែទូលសួរឲ្យបានច្បាស់ពីអ្វីដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រទានឲ្យអ្នកនិយាយ។ អ្នកប្រហែលជាបានទទួល តែប៉ុន្មានពាក្យតែប៉ុណ្ណោះ ក្នុងពេលដំបូង។ នៅពេលដែលអ្នកនិយាយចេញមកប្រកបដោយជំនឿ នោះពាក្យជាច្រើនទៀតនឹងមកក្នុងអ្នក។ មិនយូរប៉ុន្មាន យើងនឹងបានទទួលនិយមន័យពេញលេញនៃព្រះបន្ទូលនោះ។

## លំហាត់អនុវត្តន៍

១២ ចូរសរសេរអក្សរ ត នៅមុខចម្លើយដែលត្រឹមត្រូវ និង សរសេរអក្សរ ខ នៅមុខចម្លើយដែលខុស។

.........ក) មិនមានការកំណត់ចំនួននៃសារបន្ទូលជាភាសាចម្លែកអស្ចារ្យ និង ការបកប្រែន័យភាសានោះ នៅក្នុងកម្មវិធីថ្វាយបង្គំសាធារណៈណាមួយឡើយ។

..........ខ) សារបន្ទូលជាភាសាចម្លែកអស្ចារ្យនៅកម្មវិធីថ្វាយបង្គំសាធារណៈ ត្រូវតែមានការបកប្រែន័យ ប្រសិនបើគេត្រូវការដឹងពីគោលបំណងនៃភាសាចម្លែកអស្ចារ្យនោះ នោះគឺមានន័យថា វាត្រូវការបកប្រែន័យ ប្រសិនព្រះកាយត្រូវការការកសាង។

..........គ) ការនិយាយភាសាចម្លែកអស្ចារ្យ គឺសម្រាប់អ្នកមិនជឿជាចម្បង។

.........ឃ) ប្រសិនបើគ្មាននរណាម្នាក់បកប្រែន័យសារបន្ទូលជាភាសាចម្លែកអស្ចារ្យនៅក្នុងកម្មវិធីថ្វាយបង្គំនោះទេ អ្នកនិយាយត្រូវតែនិយាយសារបន្ទូលនោះឲ្យបានកាន់តែច្បាស់ទៀត។

១៣ អ្នកប្រហែលជាអាចដឹងថា ព្រះវិញ្ញាណដ៏វិសុទ្ធ កំពុងតែធ្វើចលនានៅលើអ្នក ដើម្បីប្រទានការបកប្រែន័យភាសាចម្លែកអស្ចារ្យ

ក) ប្រសិនបើអ្នកបានរៀនភាសាដែលបានប្រាប់មកដល់អ្នក។

ខ) ប្រសិនបើអ្នកដឹងពីចលនាមួយយ៉ាងខ្លាំងនៅក្នុងវិញ្ញាណរបស់អ្នក ដែលចង់និយាយអ្វីម្យ៉ាង ដើម្បីលើកទឹកចិត្ត និង ដាស់តឿនមនុស្ស។

គ) នៅពេលដែលអ្នកមានអារម្មណ៍ប៉ងប្រាថ្នាដ៏ខ្លាំងមួយ ក្នុងការនិយាយពាក្យពេចន៍នៃការ សរសើរតម្កើង ការអធិស្ឋាន ការថ្វាយព្រះពរ និង ការអរព្រះគុណដែលលេចឡើងនៅក្នុងគំនិត របស់អ្នកភ្លាមៗ។

## គោលបំណងសម្រាប់ការបកប្រែន័យភាសាចម្លែកអស្ចារ្យផ្សេងៗ

គោលបំណងសម្រាប់ព្រះអំណោយទាននៃការបកប្រែភាសាចម្លែកអស្ចារ្យ គឺដើម្បីនឹងកសាងព្រះកាយរបស់ព្រះគ្រិស្តដោយផ្តល់និយមន័យឲ្យអ្វីដែលបាននិយាយជាភាសាចម្លែកអស្ចារ្យនៅក្នុងកម្មវិធីថ្វាយបង្គំជាសាធារណៈ។ ព្រះកាយក៏ទទួលបានការអប់រំ នៅពេលដែលសមាជិកបានយល់ពីអ្វីដែលបាននិយាយជាភាសាចម្លែកអស្ចារ្យនោះ។ តាមមធ្យោបាយនេះ ពួកគេត្រូវបានលើកទៅដល់កម្រិតថ្មីមួយក្នុងការថ្វាយបង្គំ ការអធិស្ឋាន ការថ្វាយព្រះពរ និង ការអរព្រះគុណព្រះជាម្ចាស់។ នៅពេលមានរឿងនេះកើតឡើង អ្នកជឿតែងតែឃើញថាបន្ទុករបស់ពួកគេត្រូវបានដកចេញទៅ បញ្ហារបស់គេត្រូវបានដោះស្រាយ អំណររបស់ពួកគេបានកើនឡើង ហើយជីវិតខាងវិញ្ញាណរបស់ពួកគេត្រូវបានបង្កើនឡើងថែមទៀត។ ក្រុមជំនុំទាំងមូល មានកម្លាំងនៅពេលដែលសមាជិករួបរួមគ្នានៅក្នុងការឆ្លោះទៅរកព្រះជាម្ចាស់ដែលមានការជំរុញពីព្រះវិញ្ញាណដ៏វិសុទ្ធ។

# ការប្រឡងផ្ទាល់ខ្លួន

**សំណួរពហុជម្រើស។** ចូរជ្រើសរើសចម្លើយទាំងឡាយណាដែលត្រឹមត្រូវសម្រាប់សំណួរនីមួយៗ។ ចូរគូសរង្វង់ជុំវិញចម្លើយត្រឹមត្រូវនោះ។

១ ចូរអានគម្ពីរកិច្ចការ ២:១-៤; ១០:៤៤-៤៧; ១៩:១-៦ ដោយប្រុងប្រយ័ត្ន ហើយគូសរង្វង់ជុំវិញអក្សរនៃឃ្លាដែលអាចបង្គ្រប់ប្រយោគនេះបានត្រឹមត្រូវ។ អ្នកជឿដែលបានជ្រមុជជាមួយនឹងព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងរឿងទាំងនេះសុទ្ធតែ

ក) កំពុងស្តាប់ការចែកចាយមួយ។

ខ) កំពុងនិយាយភាសាដទៃ

គ) កំពុងលត់ជង្គង់អធិស្ឋាន

២ តើមួយណាជាច្បាប់ដឹកនាំការប្រើប្រាស់ការនិយាយភាសាចម្លែកអស្ចារ្យនៅក្នុងក្រុមជំនុំ?

ក) ការនិយាយភាសាចម្លែកអស្ចារ្យ មិនគួរធ្វើឲ្យមានការច្របូកច្របល់នោះទេ។

ខ) មានតែអ្នកគង្វាលប៉ុណ្ណោះដែលអាចផ្តល់ការបកប្រែន័យភាសាចម្លើយអស្ចារ្យបាន។

គ) ប្រសិនបើគ្មាននរណាម្នាក់នៅក្នុងកម្មវិធីថ្វាយបង្គំសាធារណៈនោះ ដើម្បីបកប្រែសារបន្ទូលជាភាសាចម្លែកអស្ចារ្យនោះទេ អ្នកដែលនិយាយភាសាចម្លែកអស្ចារ្យនោះ ត្រូវតែនោះស្ងៀម។

ឃ) គ្មានឯកសារយោងនៅក្នុងព្រះគម្ពីរមួយណា ដែលបាននិយាយថាបុគ្គលណាម្នាក់និយាយភាសាចម្លែកអស្ចារ្យដើម្បីទូលសូមព្រះជាម្ចាស់ប្រទានឲ្យគាត់នូវការបកប្រែន័យដែរនោះទេ។

**ផ្គូផ្គង។** ចូរសរសេរអក្សរដែលនៅមុខ ព្រះអំណោយទាន(ជួរឈរខាងស្តាំ) នៅក្នុងចន្លោះបន្ទាត់ដែលនៅខាងមុខការរៀបរាប់(ជួរឈរខាងឆ្វេង) របស់ព្រះអំណោយទាននោះឲ្យបានត្រឹមត្រូវ។

.........៣) នៅក្នុងគម្ពីរកិច្ចការ ១៦:១៧-១៨ ពួកសាវ័កបានស្គាល់វិញ្ញាណដែលនៅក្នុងស្ត្រីបម្រើម្នាក់ដែលមិនមែនជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នោះទេ។

.........៤) នៅក្នុងគម្ពីរកិច្ចការ២:៤ អ្នកជឿមួយក្រុមកំពុងអធិស្ឋានជុំគ្នា ក៏បានចាប់ផ្តើមនិយាយភាសាមួយដែលពួកគេមិនដែលរៀនពីមុខមក។

..........៥) ព្រះកាយដែលផ្សំឡើងពីអ្នកជឿ គឺត្រូវបានកសាងនៅពេលដែលអ្នកជឿម្នាក់ផ្តល់និយមន័យរបស់ពាក្យសំដី ឬសារបន្ទូលជាភាសាចម្លែកអស្ចារ្យ។

..........៦) មានព្រះអំណោយទានរបស់ព្រះវិញ្ញាណមួយដែលជួយរៀបចំយើងក្នុងការបើកសំដែងព្រះអំណោយទានប្រាំបីផ្សេងទៀត។

ក) ការនិយាយភាសាចម្លែកអស្ចារ្យ

ខ) ការបកប្រែន័យភាសាចម្លែកអស្ចារ្យ

គ) ការសង្កេតស្គាល់វិញ្ញាណ

**ត្រូវ/ខុស។** ចូរសរសេរអក្សរ ត នៅក្នុងចន្លោះបន្ទាត់ប្រសិនប្រយោគនោះជាប្រយោគត្រឹមត្រូវ ។ សរសេរអក្សរ ខ ប្រសិនបើវាមិនត្រឹមត្រូវ។

.........៧ នៅពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធមានព្រះបន្ទូលតាមរយៈអ្នកជឿណាម្នាក់ ជាភាសាថ្មីមួយ វាអាចជាភាសាដែលមនុស្សនៅលើផែនដីមិនដែលស្គាល់ពីមុនមកទេ។

.........៨ វិញ្ញាណអាក្រក់អាចត្រូវបានគេស្គាល់បានតាមរយៈ ព្រះអំណោយទាននៃការសង្កេតស្គាល់វិញ្ញាណប៉ុណ្ណោះ។

..........៩ ព្រះអំណោយទាននៃការសង្កេតស្គាល់វិញ្ញាណ ពេលខ្លះជាព្រះអំណោយទានមួយដែលមានប្រយោជន៍ក្នុងការជួយដល់អ្នកឈឺ និង ជនពិការ។

.........១០ មនុស្សម្នាក់អាចនិយាយចេញមកពីវិញ្ញាណរបស់គាត់ផ្ទាល់ មកពីវិញ្ញាណអាក្រក់ ឬ មកពីព្រះវិញ្ញាណដ៏វិសុទ្ធ។

.........១១ មិនមែនមនុស្សគ្រប់គ្នាដែលបានជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ សុទ្ធតែបាននិយាយភាសាចម្លែកអស្ចារ្យនោះឡើយ។

**ការបំពេញប្រយោគ៕** ចូរបំពេញប្រយោគ ដោយសរសេរពាក្យដែលបាត់នៅលើចន្លោះបន្ទាត់ដែលបានដាក់ឲ្យ។

១២ ពាក្យមួយទៀតសម្រាប់ភាសាចម្លែកអស្ចារ្យគឺ.....................................................................

១៣ គោលបំណងចម្បងនៃការសង្កេតស្គាល់វិញ្ញាណគឺ.............................................................

.......................................................................................................................

**ចម្លើយខ្លីៗ៕** ចូរសរសេរចម្លើយទៅនឹងសំណួរនីមួយៗនៅលើបន្ទាត់ដែលបានដាក់ឲ្យ។

១៤ តើត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីឲ្យការនិយាយភាសាចម្លែកអស្ចារ្យ កសាងព្រះកាយបាន ?

.......................................................................................................................

# ចម្លើយសម្រាប់លំហាត់អនុវត្តន៍

១ វិញ្ញាណរបស់មនុស្ស, ព្រះវិញ្ញាណដ៏វិសុទ្ធ, វិញ្ញាណអាក្រក់។

៨ ព្រះជាម្ចាស់

២ ស្គាល់ថាវិញ្ញាណណាដែលកំពុងតែបើកសំដែងនោះ។

៩ ក) ព្រះហឫទ័យរបស់ព្រះជាម្ចាស់។

ខ) ព្រះជាម្ចាស់កំពុងមានព្រះបន្ទូលតាមរយៈពួកគេ។

គ) ព្រះជាម្ចាស់កំពុងមានព្រះបន្ទូល។

៣ ក) ចម្លងតាម

ខ) មនុស្ស

គ) ការពារ

១០ ចំណេះដឹង

៤ ព្រះអំណោយទាននោះបានការពារ ព្រះកាយឲ្យផុតពីវិញ្ញាណអាក្រក់ដែលចង់រារាំងដំណឹងល្អ។

១១ ការកសាងព្រះកាយ

៥ ក) ខ

ខ) ត

គ) ខ

ឃ) ខ

១២ ក) ខ

ខ) ត

គ) ខ

ឃ) ខ

៦ គ) មនុស្សគ្រប់គ្នាដែលបានជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងបន្ទប់ខាងលើថ្ងៃនោះ មានបទពិសោធន៍ក្នុងការនិយាយភាសាចម្លែកអស្ចារ្យ។

ឃ) យោងតាមឯកសារនៅក្នុងកណ្ឌគម្ពីរកិច្ចការបានប្រាប់ថា អស់អ្នកដែលបានជ្រមុជ នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ បាននិយាយភាសាចម្លែកអស្ចារ្យ។

១៣ គ) នៅពេលដែលអ្នកមានអារម្មណ៍ប៉ងប្រាថ្នាដ៏ខ្លាំងមួយ ក្នុងការនិយាយពាក្យពេចន៍នៃការសរសើរតម្កើង ការអធិស្ឋាន ការថ្វាយព្រះពរ និង ការអរព្រះគុណដែលលេចឡើងនៅក្នុងគំនិតរបស់អ្នកភ្លាមៗ។

៧ អ្នកនិយាយ , ព្រះកាយ

## សូមចូលរួមអបអរសាទរ

ឥឡូវនេះអ្នកបានបញ្ចប់មេរៀននៅក្នុងជំពូកចប់សព្វគ្រប់ហើយ។ យើងសង្ឃឹមថាវាជាជំនួយ ដ៏ល្អសម្រាប់អ្នក។ ចូររំឭកមេរៀនទាំងអស់នៅក្នុងជំពូកទី៣ ហើយធ្វើ*ការប្រឡងជំពូកទីបីនេះ*។ នៅពេលដែលអ្នកបញ្ចប់ការប្រឡងនេះ ចូរធ្វើតាមការណែនាំដោយប្រុងប្រយ័ត្ន ដើម្បីដាក់ស្នើការដាក់ពិន្ទុសម្រាប់ការប្រឡងរបស់អ្នក។

# អក្ខរានុក្រម

នៅក្នុងប្រអប់ជួរឈរដែលនៅខាងស្តាំដៃមានផ្ទុកលេខមេរៀននៅក្នុងសៀវភៅសិក្សាដោយខ្លួនឯងនេះ ដែលពាក្យនោះត្រូវបានយកមកប្រើដំបូងគេបង្អស់។

| **ពាក្យគន្លឹះ** | **និយមន័យ** | **មេរៀន** |
|---|---|---|
| **ការក្លែងបន្លំ** counterfeit | ការចម្លង ដើម្បីបំភាន់គេ | ៩ |
| **ការបណ្តាលចិត្ត** inspiration | ឥទ្ធិពលនៃគំនិត; ភាគច្រើននៅក្នុងផ្លូវល្អត្រឹមត្រូវ | ៣ |
| **ការបន្តពូជ** reproduction | ដំណើរការដែលមនុស្ស សត្វ និងរុក្ខជាតិ បង្កើតកូនចៅតាមពូជរបស់ខ្លួន | ៤ |
| **ការអង្វរជួស** intercession | ការអង្វរសម្រាប់នរណាម្នាក់ទៀត (ដោយការអធិស្ឋាន) | ៦ |
| **កាលៈទេសៈ** circumstance | សភាពនៃរឿងរ៉ាវ | ៩ |
| **ខ្ពង់ខ្ពស់លើស**transcend | ទៅហួស, ប្រសើរជាង | ៧ |
| **ពិការភាព**infirmity | ភាពកម្សោយ; ភាពគ្មានកម្លាំង; អសមត្ថភាព | ៨ |
| **គ្រឹះ** foundation | ផ្នែកដែលផ្នែកផ្សេងទៀតផ្អែកលើ | ២ |
| **គ្រូមន្តអាគម** magician | បុគ្គលដែលប្រើប្រាស់មន្តអាគម | ៨ |
| **ចិត្តសប្បុរស** generous | បំណងចិត្តក្នុងការចែករំលែក, មិនអាត្មានិយម | ៦ |
| **ឆ្លាក់** etch | ចារផ្តិតការរចនា ឬរូបភាពមួយ | ៣ |

| | | |
|---|---|---|
| **ជំនឿស៊ប់**Persuasion | ជំនឿរឹងមាំ | ៧ |
| **ដឹកនាំ** govern | កាន់កាប់, គ្រប់គ្រង, រៀបចំទុកដាក់ | ២ |
| **ត្រួតលើ** overlap | គ្របលើ និង លាតសន្ធឹងផុតទៅ | ៥ |
| **ទុក្ករបុគ្គល** martyr | បុគ្គលម្នាក់ដែលត្រូវបានគេសម្លាប់ដោយសារសាសនា ឬ ជំនឿផ្សេងទៀតរបស់គេ | ៤ |
| **ទេពកោសល្យ** talent | សមត្ថភាពពិសេសពីធម្មជាតិ | ១ |
| **ទំនុកចិត្ត** confidence | ជំនឿ ឬ ការទុកចិត្តយ៉ាងរឹងមាំ | ៥ |
| **ធ្វើជាអធិបតី** preside | ទទួលខុសត្រូវ , គ្រប់គ្រង | ៦ |
| **បកប្រែ** translate | ប្តូរពីភាសាមួយ ទៅជាភាសាមួយទៀត | ៥ |
| **បង្កបង្កើត** generate | ផលិត, នាំឲ្យកើតមាន | ២ |
| **បណ្តាញ** channel | មធ្យោបាយដែលអ្វីមួយផ្លាស់ទី ឬ ដឹកនាំទៅ | ៧ |
| **បើកសំដែង** revealed | ធ្វើឲ្យស្គាល់, បង្ហាញ | ៣ |
| **បំពាក់** equip | ផ្គត់ផ្គង់នូវអ្វីដែលត្រូវការ, រៀបចំឲ្យរួច | ១ |
| **ផ្ទុះឡើង** explosive | មានកម្លាំងផ្ទុះឡើង | ៨ |
| **ភ្ជាប់គ្នា** coupled | ភ្ជាប់ជាមួយគ្នា | ៤ |
| **ពហុវចនៈ** plural | ច្រើនជាងមួយ | ៨ |
| **ព្រះត្រៃឯកភាពពេញលេញ** Godhead | មានលក្ខណៈជាអាទិទេព , សំដៅទៅលើព្រះត្រីឯកទាំងមូល | ៤ |
| **ភាពតានតឹង** severity | ភាពតឹងតែង, ភាពឃោរឃៅ | ៩ |

| | | |
|---|---|---|
| **ភាពអាត្មានិយម** Self-centeredness | ខ្វល់ខ្វាយតែខ្លួនឯង, ខ្លួនឯងជាចំណុចកណ្ដាល ឬ រឿងសំខាន់ | ៤ |
| **មុខងារ** function | ដំណើរការល្អ ការប្រើប្រាស់ | ១ |
| **វង្វេងវង្វាន់** confusion | ភាពមិនប្រក្រតី | ៦ |
| **សហគមន៍** community | មនុស្សទាំងអស់ដែលរស់នៅក្នុងកន្លែងតែមួយ | ៥ |
| **សារធាតុ** substance | គ្រឿងផ្សំ,វត្ថុធាតុ | ៦ |
| **សូរសៀង** Utterance | អ្វីដែលនិយាយចេញពីមាត់ | ៧ |
| **សាសន៍ដទៃ** Gentile | មនុស្សដែលមិនមែនជាសាសន៍យូដា | ៧ |
| **ស្គាល់** identify | ទទួលយកជាមនុស្សជាក់ច្បាស់ម្នាក់ ឬ វត្ថុជាក់ច្បាស់មួយ | ៣ |
| **អធិប្បាយ** expound | បកស្រាយ ផ្ដល់ចម្លើយ | ៣ |
| **អធិធម្មជាតិ** supernatural | លើស ឬ ក្រៅពីអ្វីដែលជាធម្មជាតិ | ២ |
| **អាណិតអាសូរ** sympathize | រំលែកទុក្ខ, បង្ហាញសេចក្ដីអាណិត | ៦ |
| **អ្នកបម្រើជំនិត** steward | មនុស្សម្នាក់ដែលមើលការខុសត្រូវទ្រព្យសម្បត្តិរបស់មនុស្សម្នាក់ | ១ |
| **អ្នកប្រាជ្ញ** scholar | មនុស្សដែលមានចំណេះដឹងជ្រៅជ្រះ | ៨ |
| **ឧបករណ៍** instrument | របស់ដែលត្រូវបានប្រើប្រាស់សម្រាប់ធ្វើអ្វីមួយ គ្រឿងប្រដាប់សម្រាប់បង្កើតអ្វីៗឬគ្រឿងសម្រាប់បង្កើតជាសូរតូរតន្ត្រី | ៧ |
| **ឧបសគ្គ** obstacle | អ្វីដែលនៅទទឹងផ្លូវ ឬ រារាំងដំណើរការ | ៨ |

# ចម្លើយសម្រាប់ការប្រឡងផ្ទាល់ខ្លួន

## មេរៀនទី១

១ ខ

២ គ

៣ ខ

៤ គ

៥ ខ

៦ គ

៧ គ

៨ ខ

៩ គ

១០ គ

១១ គ

## មេរៀនទី២

ចំណាំ ៖ សម្រាប់សំណួរទី១ដល់ទី៥ លំដាប់លំដោយនៃចម្លើយគឺមិនសំខាន់នោះទេ។

១ ក) ចំណេះដឹង

ខ) ជំនឿ

គ) បទពិសោធន៍

២ ក) ការបង្កើតឲ្យមានជំនឿ

ខ) ដឹកនាំជំនឿ

គ) កំណត់បទពិសោធន៍

៣ ក) សាវ័ក

ខ) ព្យាការី

គ) អ្នកផ្សាយដំណឹងល្អ

ឃ) អ្នកគង្វាល

ង) អ្នកបង្រៀន

ខគម្ពីរយោង៖ គម្ពីរអេភេសូ ៤:១១

៤ ក) ការទូន្មាន

ខ) ការចែកទាន

គ) ការគ្រប់គ្រង

ឃ) ការបង្ហាញក្តីមេត្តាករុណា

*ចំណាំ* ៖ ការជួយ, ការបម្រើ និង ការបង្រៀនក៏អាចស្ថិតនៅក្នុងចម្លើយនេះដែរ។

៥ ក) ពាក្យសំដីនៃប្រាជ្ញា

ខ) ពាក្យសំដីនៃចំណេះដឹង

គ) ជំនឿ

ឃ) ព្រះអំណោយទាននៃការប្រោសឲ្យជាពីជំងឺ

ង) ធ្វើការអស្ចារ្យ

ច) ចេះថ្លែងព្រះបន្ទូល(ទាយ)

ឆ) និយាយភាសាចម្លែកអស្ចារ្យផ្សេងៗ

ជ) សង្កេតឲ្យស្គាល់វិញ្ញាណផ្សេងៗ

ឈ) ការបកប្រែន័យភាសាចម្លែកអស្ចារ្យ

៦ សូមមើលគម្ពីរ១កូរិនថូស ១៣:១-២

៧ ខ) ផ្តល់គ្រឹះមូលដ្ឋានសម្រាប់ជំនឿ។

៨ ខ) ចំណេះដឹង

៩ គ) ពួកគេមិនដែលដឹងពីការនោះ

## មេរៀនទី៣

១ ង) ប្រាប់ពីអត្ថន័យ

២ គ) ជ្រើសរើស

៣ ក) ប្រាប់ទៅកាន់ ឬ និយាយចេញមកក្រៅ

៤ ឃ) ទស្សន៍ទាយ

៥ ខ) ចាត់បញ្ជូនទៅ

៦ ខ

៧ ក

៨ ខ

៩ ខ

១០ ក

១១ ព្រះជាម្ចាស់

១២ ដើម្បីនាំដំណឹងល្អទៅកាន់កន្លែងថ្មីៗ ប៉ុន្តែក៏ដើម្បីកសាង និង មើលការខុសត្រូវព្រះកាយផងដែរ។

១៣ ដើម្បីទាយទុក ឬ ទស្សន៍ទាយហេតុការណ៍ និង ថ្លែងប្រកាសប្រាប់ និងបកប្រែអត្ថន័យសារបន្ទូលរបស់ព្រះជាម្ចាស់។

## មេរៀនទី៨

១ ក) អ្នកគង្វាលព្រមទាំងអ្នកបង្រៀន

ខ) អ្នកផ្សាយដំណឹងល្អ

ង) សាវ័ក

ឆ) ព្យាការី

២ ខ) ព្រះវិញ្ញាណដ៏វិសុទ្ធ

គ) ព្រះកាយ

៣ គ) ក្រុមជំនុំជាព្រះកាយ

៤ ចម្លើយទាំងអស់ជាចម្លើយត្រឹមត្រូវ

៥ អ្នកមានចិត្តស្រឡាញ់ មិនប្រព្រឹត្តអំពើថោកទាប មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន មិនមួម៉ៅ មិនចងគំនុំ មិនអបអរនឹងអំពើទុច្ចរិតទេ តែរីករាយនឹងសេចក្ដីពិតវិញ។

## មេរៀនទី៩

១ ខ

២ គ

៣ គ

៤ ខ

៥ គ

៦ ខ

៧ ខ

៨ គ

៩ ខ

១០ គ

១១ គ

១២ ខ

១៣ គ

១៤ គ

## មេរៀនទី៦

១ ផ្តល់ឲ្យសម្ភារៈ ពេលវេលា កម្លាំង និង ទេពកោសល្យរបស់គេ។

២ ចូរជ្រើសរើសបីក្នុងចំណោមទាំងអស់នេះ៖ ពួកអ្នកត្រួតត្រា, ក្រុមព្រឹទ្ធាចារ្យ, អ្នកមើលការខុសត្រូវ, ក្រុមចាស់ទុំ, អ្នកជំនួយ

៣ ក) ការគ្រប់គ្រង

ខ) ការជួយ

គ) ការចែកទាន

ឃ) ការបង្ហាញក្តីមេត្តាករុណា

៤ ក) ការបង្ហាញក្តីមេត្តាករុណា

ខ) ការជួយ

គ) ការចែកទាន

ឃ) ការគ្រប់គ្រង

ង) ការបង្ហាញក្តីមេត្តាករុណា

៥ ការបម្រើ, ការបង្រៀន, និង ការទូន្មាន

៦ ការគ្រប់គ្រង

៧ ការចែកទាន

## មេរៀនទី៧

១ ខ

២ គ

៣ ខ

៤ គ

៥ ខ

៦ ខ

៧ គ

៨ គ

៩ គ

## មេរៀនទី៨

១ ខ) តម្រូវការខាងរូបកាយ។

២ គ) ដឹងពីចលនារបស់ព្រះវិញ្ញាណដ៏វិសុទ្ធយ៉ាងខ្លាំងនៅក្នុងចិត្តអ្នក ក្នុងការបំពេញតម្រូវការខាងរូបកាយរបស់នរណាម្នាក់។

៣ ក) អាចធ្វើបានតាមរយៈឫទ្ធានុភាពអធិជាតិប៉ុណ្ណោះ។

ខ) មិនអាចធ្វើបានឡើយបើគ្មានព្រះវិញ្ញាណដ៏វិសុទ្ធ។

៤ ខ) ការនិយាយដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

៥ គ) វាជាព្រះអំណោយទានសម្រាប់ប្រកាសសារបន្ទូលរបស់ព្រះជាម្ចាស់។

៦ ខ) ការនិយាយប្រាប់ពីសារបន្ទូលរបស់ព្រះជាម្ចាស់។

៧ ការប្រោសឲ្យជាពីជំងឺ, ការធ្វើការអស្ចារ្យ និង ការថ្លែងព្រះបន្ទូល

៨ ដើម្បីកសាងព្រះកាយរបស់ព្រះគ្រិស្ត។

៩ មានឫទ្ធានុភាពលើគ្រប់ទាំងអស់។

១០ ឧបសគ្គ

១១ បំផ្លាញ

១២ ដាស់តឿន និង លើកទឹកចិត្ត

## មេរៀនទី៩

១ ខ) កំពុងនិយាយភាសាដទៃ

២ ក) ការនិយាយភាសាចម្លែកអស្ចារ្យផ្សេងៗ មិនគួរធ្វើឲ្យមានការច្របូកច្របល់នោះទេ។

គ) ប្រសិនបើគ្មាននរណាម្នាក់នៅក្នុងកម្មវិធីថ្វាយបង្គំសាធារណៈនោះ ដើម្បីបកប្រែសារបន្ទូលជាភាសាចម្លែកអស្ចារ្យនោះទេ អ្នកដែលនិយាយភាសាចម្លែកអស្ចារ្យនោះ ត្រូវតែនោះស្ងៀម។

៣ គ) ការសង្កេតឲ្យស្គាល់វិញ្ញាណផ្សេងៗ

៤ ក) ការនិយាយភាសាចម្លែកអស្ចារ្យផ្សេងៗ

៥ ខ) ការបកប្រែន័យភាសាចម្លែកអស្ចារ្យផ្សេង

៦ ក) ការនិយាយភាសាចម្លែកអស្ចារ្យផ្សេង

៧ គ

៨ ខ

៩ គ

១០ គ

១១ ខ

១២ ពាក្យសំដី

១៣ ការការពារសម្រាប់ពួកអ្នកជឿ (ព្រះកាយ)

១៤ ការបកប្រែន័យភាសាចម្លែកអស្ចារ្យផ្សេង

# ការប្រឡងតាមជំពូក

## ការណែនាំ

នៅពេលដែលអ្នកបានបញ្ចប់ការសិក្សារបស់អ្នកទៅតាមជំពូកនីមួយៗហើយ ចូរឆ្លើយសំណួរការតាមជំពូក ដោយប្រើប្រាស់ក្រដាសចម្លើយទៅតាមលំហាត់ប្រឡងតាមជំពូកនីមួយៗ ដើម្បីកត់ត្រាចម្លើយរបស់អ្នក។

សូមអានសំណួរនីមួយៗដោយយកចិត្តទុកដាក់។ មានចម្លើយតែមួយគត់ដែលល្អជាងគេសម្រាប់សំណួរនីមួយៗ។ ចូរផាត់ពណ៌ខ្មៅទៅលើប្រឡោះចម្លើយដែលអ្នកជ្រើសរើស។ *ត្រូវតែប្រាកដថាលេខនៅក្នុងក្រដាសចម្លើយដូចទៅនឹងលេខនៅក្នុងសំណួរដែលអ្នកឆ្លើយ។*

## ឧទាហរណ៍

១ ការកើតជាថ្មីគឺមានន័យថា

ក) មានអាយុតិច

ខ) ទទួលយកព្រះយេស៊ូជាព្រះសង្គ្រោះ

គ) ចាំផ្តើមឆ្នាំថ្មី

ឃ) ស្វែងរកក្រុមជំនុំផ្សេងមួយទៀត

ចម្លើយដែលត្រឹមត្រូវគឺ **ខ) ទទួលយកព្រះយេស៊ូជាព្រះសង្គ្រោះ** ដូច្នេះអ្នកត្រូវផាត់ពណ៌ខ្មៅនៅក្នុងចន្លោះអក្សរ ខ យ៉ាងដូច្នេះ៖

១ (ក) ● (គ) (ឃ)

## ការប្រគល់ ចម្លើយនៃការប្រឡងតាមជំពូក

នៅពេលដែលអ្នកបានបញ្ចប់មុខវិជ្ជានេះ និង បានឆ្លើយសំណួរការប្រឡងតាមជំពូកទាំងអស់ហើយ សូមផ្ញើក្រដាសចម្លើយរបស់អ្នកទៅឲ្យគ្រូ ឬ ការិយាល័យដែលនៅក្នុងតំបន់របស់អ្នកដើម្បីធ្វើការកែសម្រួល។

# គ្រដាសចម្លើយការប្រឡងតាមជំពូក

CS5151 KHM ព្រះអំណោយទានខាងវិញ្ញាណ

## ព័ត៌មានរបស់សិស្ស

ឈ្មោះ..........................................................................................................................

លេខសំគាល់របស់សិស្ស.......................................................................................................

(សូមរក្សាចន្លោះនេះឲ្យនៅទទេ បើអ្នកមិនស្គាល់លេខរបស់អ្នក)

អាសយដ្ឋាន.....................................................................................................................

.......................................................................................................................................

.......................................................................................................................................

ប្រទេស..........................................................................................................................

អ៊ីម៉ែល..........................................................................................................................

**ចូរផាតពណ៌ខ្មៅដោយប្រុងប្រយ័ត្ននៅក្នុងចន្លោះចម្លើយត្រឹមត្រូវ របស់សំណួរដែលមានលេខដូចគ្នា។**

## ជំពូកទីមួយ

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១ | ក | ខ | គ | ឃ | ១១ | ក | ខ | គ | ឃ |
| ២ | ក | ខ | គ | ឃ | ១២ | ក | ខ | គ | ឃ |
| ៣ | ក | ខ | គ | ឃ | ១៣ | ក | ខ | គ | ឃ |
| ៤ | ក | ខ | គ | ឃ | ១៤ | ក | ខ | គ | ឃ |
| ៥ | ក | ខ | គ | ឃ | ១៥ | ក | ខ | គ | ឃ |
| ៦ | ក | ខ | គ | ឃ | ១៦ | ក | ខ | គ | ឃ |
| ៧ | ក | ខ | គ | ឃ | ១៧ | ក | ខ | គ | ឃ |
| ៨ | ក | ខ | គ | ឃ | ១៨ | ក | ខ | គ | ឃ |
| ៩ | ក | ខ | គ | ឃ | ១៩ | ក | ខ | គ | ឃ |
| ១០ | ក | ខ | គ | ឃ | ២០ | ក | ខ | គ | ឃ |

**សម្រាប់ការិយាល័យរបស់សាកលវិទ្យាល័យ គ្លូបល**

ថ្ងៃទី ...........................................ពិន្ទុ.....................................................

PN01.26.01

# ជំពូកទីពីរ

PN01.26.01

| | | | |
|---|---|---|---|
| ១ | ក ខ គ ឃ | ១១ | ក ខ គ ឃ |
| ២ | ក ខ គ ឃ | ១២ | ក ខ គ ឃ |
| ៣ | ក ខ គ ឃ | ១៣ | ក ខ គ ឃ |
| ៤ | ក ខ គ ឃ | ១៤ | ក ខ គ ឃ |
| ៥ | ក ខ គ ឃ | ១៥ | ក ខ គ ឃ |
| ៦ | ក ខ គ ឃ | ១៦ | ក ខ គ ឃ |
| ៧ | ក ខ គ ឃ | ១៧ | ក ខ គ ឃ |
| ៨ | ក ខ គ ឃ | ១៨ | ក ខ គ ឃ |
| ៩ | ក ខ គ ឃ | ១៩ | ក ខ គ ឃ |
| ១០ | ក ខ គ ឃ | ២០ | ក ខ គ ឃ |

**សម្រាប់ការិយាល័យរបស់សាកលវិទ្យាល័យ គ្លូបល**

ថ្ងៃទី ..............................................ពិន្ទុ.......................................................

# ជំពូកទីបី

| | | | |
|---|---|---|---|
| ១ | ក ខ គ ឃ | ១១ | ក ខ គ ឃ |
| ២ | ក ខ គ ឃ | ១២ | ក ខ គ ឃ |
| ៣ | ក ខ គ ឃ | ១៣ | ក ខ គ ឃ |
| ៤ | ក ខ គ ឃ | ១៤ | ក ខ គ ឃ |
| ៥ | ក ខ គ ឃ | ១៥ | ក ខ គ ឃ |
| ៦ | ក ខ គ ឃ | ១៦ | ក ខ គ ឃ |
| ៧ | ក ខ គ ឃ | ១៧ | ក ខ គ ឃ |
| ៨ | ក ខ គ ឃ | ១៨ | ក ខ គ ឃ |
| ៩ | ក ខ គ ឃ | ១៩ | ក ខ គ ឃ |
| ១០ | ក ខ គ ឃ | ២០ | ក ខ គ ឃ |

**សម្រាប់ការិយាល័យរបស់សាកលវិទ្យាល័យ គ្លូបល**

ថ្ងៃទី ..............................................ពិន្ទុ.......................................................

# សំណួរប្រឡងជំពូកទីមួយ

១ គម្ពីរ១កូឡូស ១:១៥-១៨ បង្រៀនយើងថា ក្រុមជំនុំ

ក) គួរតែដឹកនាំសកម្មភាពខ្លួនឯង។

ខ) គ្មានទំនាក់ទំនងជាមួយព្រះគ្រិស្តទេ

គ) កើតមានឡើងមុនអ្វីៗទាំងអស់។

ឃ) មិនអាចមានជីវិតបានឡើយបើគ្មានព្រះគ្រិស្តជាព្រះសិរសានោះ។

២ ក្នុងនាមជា ព្រះកាយរបស់ព្រះគ្រិស្ត ក្រុមជំនុំទាំងក្នុងតំបន់ និង សាកលគឺបង្កើតឡើងពី

ក) សរីរាង្គមួយចំនួនតូចតែប៉ុណ្ណោះ។

ខ) មនុស្សដែលមានភាពទាក់ទាញ និង ត្រូវបានជ្រើសរើសជាពិសេស។

គ) អ្នកជឿគ្រប់ប្រភេទមកពីគ្រប់ជាតិសាសន៍។

ឃ) អ្នកជឿដែលស័ក្តិសមនឹងជ្រើសរើស។

៣ គម្ពីររ៉ូម ១២:៦-៨ បានបង្ហាញថា សមាជិកនៃព្រះកាយរបស់ព្រះគ្រិស្តទាំងអស់ត្រូវ

ក) រំពឹងទុកថានឹងមានព្រះអំណោយទានដ៏អស្ចារ្យ។

ខ) ស្វែងរក និង ប្រើប្រាស់ព្រះអំណោយទានរបស់គាត់។

គ) មិនរំពឹងទុកចង់ប្រើប្រាស់ព្រះអំណោយទានឡើយ។

ឃ) ប្រើប្រាស់ព្រះអំណោយទានខាងឯវិញ្ញាណយ៉ាងហោចណាស់ឲ្យបានបី។

៤ អ្នកជឿម្នាក់ៗមានសារៈសំខាន់ណាស់នៅក្នុងព្រះកាយរបស់ព្រះគ្រិស្តព្រោះ

ក) មុខងារពិសេសរបស់មនុស្សម្នាក់ៗ ជាតម្រូវការរបស់អ្នកដទៃផ្សេងទៀត។

ខ) ភាពខុសគ្នា គឺគួរឲ្យចាប់អារម្មណ៍ជាងភាពស្រដៀងគ្នា។

គ) ក្រុមជំនុំមានសមាជិកច្រើនជាងម្នាក់។

ឃ) អ្នកជឿទាំងអស់មានសមត្ថភាពដូចៗគ្នា។

៥ ប្រៀបធៀបរវាងខ្លួនឯងទៅនឹងអ្នកដទៃ ធ្វើឲ្យទាស់ព្រះទ័យរបស់ព្រះជាម្ចាស់ ព្រោះព្រះជាម្ចាស់បានបង្កើតសមាជិកម្នាក់ៗនៅក្នុងព្រះកាយឲ្យ

ក) ដូចគ្នាបេះបិទ

ខ) ធ្វើឲ្យការងារដូចគ្នា

គ) ខុសៗគ្នា ជាមួយនឹងតួនាទីខុសៗគ្នាដែរ។

ឃ) ខុសៗគ្នា ប៉ុន្តែមានតួនាទីដូចគ្នាដែរ។

៦ ការប្រៀបធៀបព្រះអំណោយទានរបស់យើង ទៅនឹងព្រះអំណោយទានរបស់អ្នកដទៃ នាំឲ្យយើង និង អ្នកទាំងនោះទៅជា

ក) អ្នកសង្ស័យច្រើន។

ខ) ការបម្រើជំនិតដ៏ល្អ។

គ) រីករាយ និង មានក្តីស្រឡាញ់។

ឃ) បាក់ទឹកចិត្ត ឬ មានអំណួត។

៧ ភាពខុសគ្នារវាងអំណាយទានខាងវិញ្ញាណ និង ទេពកោសល្យពីធម្មជាតិ គឺថា

ក) ទាំងអ្នកជឿ និង អ្នកមិនជឿសុទ្ធតែអាចទទួលបានព្រះអំណោយទានខាងវិញ្ញាណ។

ខ) ព្រះអំណោយទានខាងវិញ្ញាណបានប្រទានពីព្រះជាម្ចាស់មកឲ្យអ្នកជឿតែប៉ុណ្ណោះ។

គ) ទេពកោសល្យគឺជារបស់តំណពូជ ហើយមិនមែនមកពីព្រះជាម្ចាស់នោះទេ។

ឃ) ទេពកោសល្យធម្មជាតិ ធ្វើឲ្យមានផលរំខានដល់វិញ្ញាណ។

៨ ក្នុងការណែនាំសំខាន់ពីរយ៉ាង សម្រាប់ការប្រើប្រាស់ព្រះអំណោយទានខាងវិញ្ញាណ គឺ

ក) សេចក្តីស្រឡាញ់ និង ភាពជាអ្នកបម្រើ

ខ) អំណរ និង អាត្មានិយម

គ) ជំនឿ និង ក្តីសង្ឃឹម

ឃ) សេចក្តីស្រឡាញ់ និង ជំនឿ

៩ គន្លឹះដើម្បីទទួលបានការប្រើប្រាស់ដ៏មានប្រសិទ្ធិភាព នៃព្រះអំណោយទានខាងវិញ្ញាណដែលព្រះជាម្ចាស់ត្រៀមសម្រាប់យើង គឺត្រូវ

ក) ឲ្យអ្នកដទៃដឹងថា យើងមានព្រះអំណោយទានខាងវិញ្ញាណ។

ខ) ឲ្យសេចក្តីស្រឡាញ់ ដឹកនាំការប្រើប្រាស់ព្រះអំណោយទានខាងវិញ្ញាណរបស់យើង។

គ) រង់ចាំឲ្យអ្វីម្យ៉ាងកើតមានឡើង។

ឃ) បដិសេធ ព្រះអំណោយទានឲ្យបានច្រើន។

១០ ព្រះជាម្ចាស់ទុកព្រះទ័យប្រទានព្រះអំណោយទានមកឲ្យយើង ដូច្នេះយើង

ក) មិនត្រូវប្រើប្រាស់សមត្ថភាពពីកំណើតរបស់យើង។

ខ) មិនត្រូវច្រឡំវាជាមួយនឹងទេពកោសល្យឡើយ។

គ) នឹងប្រៀបធៀបខ្លួនយើង ជាមួយអ្នកមិនជឿ។

ឃ) ប្រើប្រាស់វាសម្រាប់ព័ន្ធកិច្ចរបស់ក្រុមជំនុំ។

១១ ជំនឿគឺជាអ្វីដែលធ្វើឲ្យយើងក្លាយជាអ្នកជឿ ហើយជំនឿគឺជាបេះដូងនៃ

ក) ព្រះអំណោយទានខាងវិញ្ញាណ និង ការប្រើប្រាស់ព្រះអំណោយទានទាំងអស់នោះ។

ខ) នៅទេពកោសល្យធម្មជាតិភាគច្រើនរបស់យើង។

គ) ទំនៀមទំលាប់ប្រពៃណីរបស់ក្រុមជំនុំ។

ឃ) ជីវិតទាំងអស់។

១២ ជំនឿសម្រាប់ការយល់ដឹង និង ការប្រើប្រាស់ព្រះអំណោយទានខាងឯវិញ្ញាណ អាចកើតមានឡើងបានតាមរយៈ

ក) បំណងប្រាថ្នាមួយដ៏ខ្លាំងក្លា សម្រាប់ព្រះអំណោយទានខាងឯវិញ្ញាណនោះ។

ខ) ការស្រឡាញ់ព្រះជាម្ចាស់ឲ្យអស់ពីដួងចិត្តយើង។

គ) ចំណេះដឹងអំពីព្រះអំណោយទាន។

ឃ) ការស្តាប់បង្គាប់អ្នកគង្វាលព្រមទាំងអ្នកបង្រៀន។

១៣ ចំណេះដឹងដែលមិនពេញលេញ និង មិនពិតប្រាកដ ធ្វើឲ្យជំនឿ

ក) មានកម្លាំងដ៏អាថ៌កំបាំងមួយ

ខ) មានភាពអស្ចារ្យ

គ) មានហេតុផលដែលត្រូវមានភាពរឹងមាំ

ឃ) មានមូលដ្ឋាន មិនពេញលេញ និង មិនពិតប្រាកដដែរ។

១៤ ប្រសិនបើយើងខ្វះចំណេះដឹងអំពីព្រះអំណោយទានខាងឯវិញ្ញាណ ឬ មានចំណេះមិនគ្រប់គ្រាន់ នោះយើងនឹង

ក) មិនមានតម្រូវការចង់បានព្រះអំណោយទានខាងឯវិញ្ញាណឡើយ។

ខ) គ្មានការពិបាកអ្វីជាមួយនឹងព្រះអំណោយទានខាងឯវិញ្ញាណឡើយ។

គ) មិនយល់ និង មិនប្រើប្រាស់ព្រះអំណោយទានខាងឯវិញ្ញាណ។

ឃ) ប្រហែលជាបរាជ័យក្នុងការបម្រើព្រះជាម្ចាស់ដោយស្មោះត្រង់។

១៥ ការស្គាល់ និងការមានព្រះអំណោយទានខាងឯវិញ្ញាណ គឺមិនគ្រប់គ្រាន់នោះទេ យើងត្រូវតែ

ក) ដឹងពីរបៀបដែលអាចរីករាយជាមួយវាបាន។

ខ) ប្រាកដថាអ្នកដទៃទៀតមានព្រះអំណោយទានដូចគ្នាដែរ។

គ) លាក់វាឲ្យឆ្ងាយពីអ្នកមិនជឿ

ឃ) ដឹងពីរបៀបប្រើប្រាស់វា។

១៦ ព្រះអំណោយទានខាងឯវិញ្ញាណដែលមានរៀបរាប់នៅក្នុងព្រះគម្ពីរ គឺមិនប្រាកដច្បាស់នោះទេ ព្រោះតែព្រះអំណោយទានទាំងអស់គឺ

ក) ខុសគ្នាដាច់ស្រឡះ។

ខ) ព្រះអំណោយទានខ្លះដូចគ្នា។

គ) បានប្រទានមកដើម្បីគោលបំណងតែមួយ។

ឃ) បានប្រទានមកដើម្បីគោលបំណងខុសៗគ្នា។

១៧ "ព្រះអំណោយទានព័ន្ធកិច្ចដទៃផ្សេងទៀត" ដែលមានរៀបរាប់នៅក្នុងគម្ពីររ៉ូមជំពូក១២ និង គម្ពីរ ១ កូរិនថូសជំពូក១២ គឺត្រូវបានចាត់ទុកថា

ក) មិនសូវសំខាន់ដូចជាព្រះអំណោយទាននៃព័ន្ធកិច្ចដែលមានរៀបរាប់នៅក្នុង គម្ពីរអេភេសូ ជំពូក៤នោះទេ។

ខ) មានសារៈសំខាន់ស្មើនឹងព្រះអំណោយទាននៃព័ន្ធកិច្ច ដែលមានរៀបរាប់នៅក្នុងគម្ពីរ អេភេសូជំពូក៤ដែរ។

គ) មានសារៈសំខាន់ខ្លាំងជាងព្រះអំណោយទាននៃព័ន្ធកិច្ច ដែលមានរៀបរាប់នៅក្នុងគម្ពីរ អេភេសូជំពូក៤។

ឃ) មានសារសំខាន់តែនៅក្នុងក្រុមជំនុំ ដែលព្រះអំណោយទានផ្សេងទៀតមិនសូវជាមានតម្លៃនៅ ទីនោះ។

១៨ ព្រះអំណោយទានខាងឯវិញ្ញាណទាំងអស់សុទ្ធតែបានមកពីព្រះវិញ្ញាណដ៏វិសុទ្ធ ប៉ុន្តែមានអំណោយ ទានខ្លះៗដូចជា "ព្រះអំណោយទានរបស់ព្រះវិញ្ញាណ" មានទាក់ទងនឹង

ក) ការប្រទានទេពកោសល្យធម្មជាតិពិសេសទៅឲ្យអ្នកជឿ។

ខ) ការបើកសំដែងដ៏អធិធម្មជាតិពិសេសអស្ចារ្យ។

គ) បទពិសោធន៍អធិធម្មជាតិដែលយើងមិនអាចដឹង ក្នុងជំនាន់យើងបាន។

ឃ) សមត្ថភាពខាងឯវិញ្ញាណបន្ថែម ដើម្បីសន្សំទំនុកចិត្តរបស់មនុស្សជាមួយព្រះជាម្ចាស់។

១៩ ការនិយាយភាសានៃឋានសួគ៌ដែលមិនធ្លាប់ដឹងពីមុន គឺបានមក

ក) ជាព្រះអំណោយទានពីព្រះជាម្ចាស់សម្រាប់គោលបំណងជាក់លាក់មួយ។

ខ) ពីសមត្ថភាពមនុស្សរបស់យើង។

គ) ពីការរៀនច្បាប់ធម្មជាតិ

ឃ) ជាទេពកោសល្យពិសេស។

២០ ព្រះអំណោយទានខាងឯវិញ្ញាណ គឺមានលក្ខណៈអធិធម្មជាតិ ព្រោះវា

ក) មិនមែនជារឿងពិតសម្រាប់ជីវិតរស់នៅឡើយ។

ខ) មិនដូចជាទេពកោសល្យនោះទេ។

គ) លើសហួសច្បាប់ធម្មជាតិកំណត់។

ឃ) ទាស់ទៅនឹងច្បាប់ធម្មជាតិ។

# សំណួរការប្រឡងជំពូកទីពីរ

១ យោងទៅតាមគម្ពីរអេភេសូ៤:៧-១៣ ព្រះអំណោយទាននៃព័ន្ធកិច្ចត្រូវបានប្រទានឲ្យអ្នកជឿដោយ

ក) ព្រះវិញ្ញាណដ៏វិសុទ្ធ

ខ) អង្គព្រះគ្រិស្តផ្ទាល់

គ) អ្នកដឹកនាំក្រុមជំនុំ

ឃ) អ្នកដឹកនាំប្រទេស

២. ព្រះអំណោយទាននៃព័ន្ធកិច្ចដូចជា ព្រះអំណោយទានជាសាវ័ក

ក) ទាមទារឲ្យសាវ័កនោះបង្កើតច្បាប់ផ្ទាល់ខ្លួន។

ខ) ត្រូវបានប្រទានឲ្យបុគ្គលម្នាក់ដើម្បីការកសាងខ្លួនគេផ្ទាល់។

គ) គឺសម្រាប់តែសាវ័កដំបូងទាំងដប់ពីរនាក់តែប៉ុណ្ណោះ។

ឃ) ត្រូវបានប្រទានឲ្យបុគ្គលម្នាក់ដើម្បីកសាងក្រុមជំនុំទាំងមូល។

៣ លក្ខណៈខុសគេនៃព័ន្ធកិច្ចរបស់សាវ័កម្នាក់ គឺថា សាវ័កម្នាក់

ក) ចេញទៅដើម្បីដាំក្រុមជំនុំនៅកន្លែងថ្មី។

ខ) កើតមកជាមួយនឹងសមត្ថភាពធ្វើជាសាវ័កតែម្តង។

គ) ធ្វើការផ្សាយដំណឹងល្អ និង ការបង្រៀនជាច្រើន។

ឃ) ត្រូវបានចាត់តាំងដោយអ្នកផ្សេងដើម្បីធ្វើការនេះ។

៤ សូមអានគម្ពីរអេភេសូ ៤:១១ ។ តើអ្នកណាដែលអាចក្លាយជាសាវ័ក ឬ ព្យាការីបាន?

ក) អ្នកជឿទាំងឡាយណាដែលត្រូវបានជ្រើសរើសឲ្យកាន់តំណែងនោះ។

ខ) មានតែអ្នកជឿណាដែលត្រូវបានជ្រើសដោយព្រះគ្រិស្តសម្រាប់ការងារនេះប៉ុណ្ណោះ។

គ) អ្នកជឿណាដែលសមនឹងទទួលបានតំណែងសាវ័ក ឬព្យាការីនេះ។

ឃ) មានតែអ្នកជឿដែលប្រឹងបង្ហាញថាពួកគេស័ក្តិសមទទួលការងារនេះ។

៥ ការងារដ៏សំខាន់ជាងគេបំផុតរបស់ព្យាការីគឺ

ក) និយាយចេញទៅដោយគ្មានការភ័យខ្លាច។

ខ) ទាយយ៉ាងឆុតពីអនាគត។

គ) ទទួលសារបន្ទូលដោយផ្ទាល់ពីព្រះជាម្ចាស់មក។

ឃ) រៀបចំអ្នកជឿសម្រាប់ធ្វើកិច្ចការជាគ្រិស្តបរិស័ទ

៦ មុខងារធំបំផុតរបស់អ្នកផ្សាយដំណឹងល្អ គឺឃើញមាននៅក្នុងពាក្យថា "អ្នកផ្សាយដំណឹងល្អ" នោះតែម្តង ដែលវាមានន័យថា

ក) ចែកចាយអំពីការកាត់ទោសដ៏អស់កល្បទៅលើមនុស្សមានបាប។

ខ) ប្រកាសដំណឹងល្អរបស់ព្រះគ្រិស្ត។

គ) រៀបចំអ្នកជឿថ្មីៗដើម្បីធ្វើការជ្រមុជទឹក។

ឃ) បង្រៀននៅក្នុងសាលារបស់ក្រុមជំនុំ។

៧ ព្រះអំណោយទានជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀនហាក់បីដូចជាមានច្រើនជាងគេ ព្រោះ

ក) មានតម្រូវជាច្រើនចំពោះព័ន្ធកិច្ចមួយនោះ នៅក្នុងចំណោមអ្នកជឿ។

ខ) មានមនុស្សជាច្រើនជ្រើសរើសចង់ក្លាយជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀន និង គ្រូបង្រៀន។

គ) អ្នកគង្វាលព្រមទាំងអ្នកបង្រៀន និង គ្រូបង្រៀន នៅជំនាន់យើងនេះ មានភាពពេញនិយម។

ឃ) អ្នកគង្វាលព្រមទាំងអ្នកបង្រៀន និង គ្រូបង្រៀន ទទួលបានប្រាក់ច្រើន។

៨ សមត្ថភាពដែលព្រះយេស៊ូទ្រង់សព្វព្រះហឫទ័យចំពោះអ្នកដែលទ្រង់ប្រទានព្រះអំណោយទានជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀនទៅឲ្យនោះ គឺ

ក) គុណភាពក្នុងការអប់រំមកពីសាកលវិទ្យាល័យ។

ខ) សមត្ថភាពក្នុងការរៀនភាសានៅក្នុងព្រះគម្ពីរ។

គ) សមត្ថភាពក្នុងការមើលរំលងអាកប្បកិរិយាដែលពេញដោយអំពើបាប។

ឃ) សមត្ថភាពក្នុងការស្រឡាញ់ និង មើលថែអ្នកដទៃ។

៩ ព្រះអំណោយទានជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀន និង គ្រូបង្រៀនគឺត្រូវបានលើកយកមកនិយាយរួមតែមួយ ព្រោះ មនុស្សភាគច្រើនជឿថាពាក្យទាំងពីរនេះមានន័យថា

ក) គ្រូបង្រៀនដែលមានសមត្ថភាពជាអ្នកគង្វាលព្រមទាំងអ្នកបង្រៀន

ខ) អ្នកគង្វាលដែលមានព័ន្ធកិច្ចក្នុងការបង្រៀន។

គ) ការបង្រៀនអំពីព័ន្ធកិច្ចអ្នកគង្វាល។

ឃ) អ្នកគង្វាលដែលណែនាំគ្រូបង្រៀន។

១០ បើមានព្រះអំណោយទាននៃព័ន្ធកិច្ច ដែលបំពេញមុខងារបានល្អ នៅក្នុងក្រុមជំនុំមួយណា ក្រុមជំនុំមួយនោះ

ក) បានបន្ថែមសមាជិកជាច្រើន និង បានដឹកនាំសហគមន៍ផង។

ខ) ត្រូវបានអ្នកជឿស្អប់ខ្ពើម និង វាយប្រហារ។

គ) ត្រូវបានរាប់ចេញពីពិភពលោក។

ឃ) បានលូតលាស់ និង បង្កបង្កើតឡើង។

១១ ចូរអានគម្ពីររ៉ូម ១២:៧ ។ ពាក្យដែលល្អបំផុតសម្រាប់បកស្រាយពីព្រះអំណោយទាននៃ "ការបម្រើ" គឺ

ក) ការបម្រើ

ខ) ការច្រៀង

គ) ក្ដីសង្ឃឹម

ឃ) ជំនឿ

១២ ភាពខុសគ្នារវាង ទេពកោសល្យ និង ព្រះអំណោយទាននៃការបម្រើគឺ

ក) ព្រះវិញ្ញាណដ៏វិសុទ្ធបានធ្វើការតាមរយៈនរណាម្នាក់ជាមួយនឹងព្រះអំណោយទាននេះ។

ខ) ទេពកោសល្យមិនអាចជួយ ឬ លើកទឹកចិត្តអ្នកណាម្នាក់ខាងឯវិញ្ញាណបាននោះទេ។

គ) មានតែព្រះអំណោយទាននៃការបម្រើប៉ុណ្ណោះដែលអាចផ្តល់ជំនួយទៅឲ្យមនុស្សដែលត្រូវការ។

ឃ) បើប្រើតែទេពកោសល្យរបស់អ្នកដើម្បីជួយមនុស្ស នឹងធ្វើឲ្យព្រះជាម្ចាស់មិនគាប់ព្រះហឫទ័យ។

១៣ ព្រះអំណោយទាននៃការបង្រៀនគឺមានសារៈសំខាន់ព្រោះវា

ក) វាមានសម្រាប់មនុស្សគ្រប់គ្នា។

ខ) ធ្វើឲ្យយើងក្លាយជាគំរូមួយដ៏ល្អ។

គ) ជាគ្រឹះដ៏ល្អមួយសម្រាប់ជំនឿ។

ឃ) ជំរុញចិត្តមនុស្សឲ្យធ្វើជាអ្នកគង្វាល។

១៤ ភាពខុសគ្នារវាងព្រះអំណោយទាននៃការបង្រៀន និង ព្រះអំណោយទានអ្នកគង្វាលព្រមទាំងអ្នកបង្រៀនគឺ

ក) ព្រះអំណោយទាននៃការបង្រៀន មិនសូវសំខាន់នោះទេ។

ខ) អ្នកគង្វាលព្រមទាំងអ្នកបង្រៀន បង្រៀនរឿងផ្សេងៗជាច្រើន។

គ) មានតែអ្នកគង្វាលព្រមទាំងអ្នកបង្រៀនតែប៉ុណ្ណោះដែលអាចបង្រៀនអ្នកជឿបាន។

ឃ) អ្នកជឿណាក៏ដោយ សុទ្ធតែអាចទទួលបានព្រះអំណោយទាននៃការបង្រៀន។

១៥ អ្នកជឿដែលមានព្រះអំណោយទាននៃការទូន្មាន ឬការលើកទឹកចិត្ត បានត្រាស់ហៅមនុស្ស

ក) ឲ្យទៅជិតព្រះជាម្ចាស់ ឬ ទៅជិតបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

ខ) ឲ្យរស់នៅដើម្បីទទួលបានការសង្គ្រោះរបស់គេ។

គ) ឲ្យរស់នៅក្នុងជីវិតល្អឥតខ្ចោះដែលគ្មានបាបសោះ។

ឃ) មកដើម្បីតែងតាំងជាអ្នកបម្រើព្រះ។

១៦ យោងទៅតាម គម្ពីរ២កូរិនថូស ៨:៩ ការអធិប្បាយដ៏ល្អបំផុតសម្រាប់ព្រះអំណោយទាននៃការចែកទានគឺ

ក) ជាអ្នកដឹកនាំនៃក្រុមជំនុំរបស់យើង។

ខ) ព្រះអម្ចាស់យេស៊ូទ្រង់ផ្ទាល់

គ) ពួកសន្តវិសុទ្ធ នៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់

ឃ) ពួកសាវ័ក

១៧ ព្រះអំណោយទាននៃការចែកទានត្រូវបានប្រទានទៅឲ្យអ្នកជឿ ព្រោះ

ក) មនុស្សចូលចិត្តឲ្យលុយ។

ខ) លុយគឺជារបស់អាក្រក់។

គ) វាគឺជាមធ្យោបាយមួយដែលអ្នកជឿអាចទទួលបានលុយសម្រាប់ខ្លួនគេ។

ឃ) តាមរយៈព្រះអំណោយទាននេះ តម្រូវការខាងសម្ភារៈ របស់ព្រះកាយត្រូវបានបំពេញ។

១៨ ក្រុមនៃអ្នកជឿត្រូវការអ្នកណាម្នាក់ ដើម្បីទទួលខុសត្រូវលើពួកគេព្រោះ

ក) មានអ្នកខ្លះអាចជាអ្នកដឹកនាំដ៏ល្អ។

ខ) ត្រូវប្រើប្រាស់ព្រះអំណោយទាននៃការគ្រប់គ្រង។

គ) មិនមែនអ្នកជឿទាំងអស់សុទ្ធតែអាចគ្រប់គ្រងអ្នកដទៃបាននោះទេ។

ឃ) អ្នកជឿត្រូវការការរួបរួម និង កម្លាំង។

១៩ ព្រះអំណោយទាននៃការបង្ហាញក្ដីមេត្តាករុណា គឺមានសារៈសំខាន់ណាស់ព្រោះវាគាំទ្រ

ក) អ្នកដឹកនាំសំខាន់នៅក្នុងក្រុមជំនុំជាច្រើននាក់។

ខ) ព្រះអំណោយទាននៃព័ន្ធកិច្ចដទៃផ្សេងទៀត។

គ) ការឃោសនាផ្សាយដំណឹងល្អ។

ឃ) សាលារបស់ក្រុមជំនុំ។

២០ មើលនៅក្នុងគម្ពីរ១កូរិនថូស ១២:២៨ ព្រះអំណោយទាននៃការជួយមានន័យថាព្រះអំណោយទាននៃ

ក) ការធ្វើឲ្យធូរស្បើយ ឬ ជំនួយ។

ខ) ការឲ្យលុយដើម្បីកសាងក្រុមជំនុំ។

គ) ការណែនាំអ្នកជឿនៅភាពវិសុទ្ធរបស់ព្រះ។

ឃ) ការបណ្ដុះបណ្ដាលអ្នកគង្វាល និង អ្នកផ្សាយដំណឹងល្អ។

# សំណួរការប្រឡងជំពូកទីបី

១ ព្រះអំណោយទាននៃប្រាជ្ញាគឺខុសពីប្រាជ្ញារបស់មនុស្ស ព្រោះវា
- ក) មកពីព្រះជាម្ចាស់ដើម្បីនឹងដោះស្រាយបង្ហាញជាក់លាក់នៅក្នុងក្រុមជំនុំ។
- ខ) មកពីការវិនិច្ឆ័យល្អៗដែលផ្អែកលើចំណេះដឹង។
- គ) ត្រូវបានប្រទានមកឲ្យអស់អ្នកដែលមានប្រាជ្ញាពីកំណើត។
- ឃ) ត្រូវបាននិយាយជារឿយៗ នៅក្នុងហ្វូងមនុស្សជាច្រើន។

២ ពាក្យសំដីនៃប្រាជ្ញាដំណើរការដោយព្រះជាម្ចាស់ប្រទាន
- ក) ការរៀនសូត្រទាំងអស់ដែលយើងត្រូវការ។
- ខ) ព្រះអំណោយទានមួយដែលធ្វើឲ្យយើងមានប្រាជ្ញាពីពេលនោះតទៅមុខ។
- គ) ប្រាជ្ញាធម្មជាតិដែលជំរុញដោយព្រះវិញ្ញាណដ៏វិសុទ្ធ។
- ឃ) មួយផ្នែកតូចនៃប្រាជ្ញារបស់ទ្រង់ ដែលបាននិយាយចេញនៅក្នុងពេលវេលាដ៏ស័ក្តិសមមួយ។

៣ នៅពេលប្រើប្រាស់ព្រះអំណោយទាននេះ អ្នកជឿនិយាយពាក្យសំដីនៃប្រាជ្ញា ដោយ
- ក) ព្យាយាមគិតពីអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យគេនិយាយ។
- ខ) ព្រះវិញ្ញាណដ៏វិសុទ្ធប្រទានពាក្យសំដីដើម្បីឲ្យពួកគេបាននិយាយ។
- គ) និយាយម្តងហើយម្តងទៀតនូវអ្វីដែលគេបានត្រៀម។
- ឃ) និយាយម្តងហើយម្តងទៀតនូវអ្វីដែលគេបានអាន។

៤ ព្រះអំណោយទានពាក្យសំដីនៃចំណេះដឹង គឺជា
- ក) ផ្នែកតូចមួយនៃចំណេះរបស់ព្រះជាម្ចាស់ដែលបានប្រទានមកតាមរយៈមនុស្ស។
- ខ) ចំណេះដឹងដែលបានមកពីការសិក្សារៀនសូត្រ។
- គ) ព្រះអំណោយទានដូចជាពាក្យសំដីនៃប្រាជ្ញាដែរ។
- ឃ) សមត្ថភាពរៀនឆាប់ចេះ។

៥ យើងអាចដឹងថា ពាក្យសំដីនៃចំណេះដឹង គឺបានមកពីព្រះវិញ្ញាណដ៏វិសុទ្ធនៅពេលដែលយើង
- ក) ដឹងពីសន្តិភាពរបស់ព្រះអម្ចាស់នៅក្នុងដួងចិត្តរបស់យើង។
- ខ) មានភាពអាត្មានិយមជំរុញឲ្យចង់និយាយ។
- គ) ទាមទារការចាប់អារម្មណ៍សម្រាប់ខ្លួនឯង។
- ឃ) និយាយចេញប្រកបដោយកំហឹង។

៦ ព្រះអំណោយទាននៃជំនឿគឺលើសហួសពីជំនឿធម្មតា និង អាចត្រូវបានបកស្រាយថាជាជំនឿ
- ក) ដែលយើងបានបង្កើតឡើងដើម្បីបំពេញតម្រូវការណាមួយ។
- ខ) ដែលបានប្រទានមកដោយព្រះវិញ្ញាណដ៏វិសុទ្ធសម្រាប់បំពេញតម្រូវការណាមួយ។
- គ) ដែលយើងត្រូវបង្កើតឡើងតាមអំណាចដែលយើងមាន។
- ឃ) បង្កើតឡើងដោយទំនុកចិត្តរបស់យើងទៅលើមិត្តភក្តិណាម្នាក់។

៧ ជារឿយៗ ព្រះវិញ្ញាណដ៏វិសុទ្ធមិនអាចប្រទានព្រះអំណោយទាននៃជំនឿឲ្យយើងបាន ដោយសារតែ
ក) យើងមិនស័ក្តិសមសម្រាប់ជំនឿរបស់ទ្រង់។
ខ) យើងខ្លាចក្នុងការធ្វើសកម្មភាព។
គ) ខ្វះទំនុកចិត្តលើខ្លួនឯង។
ឃ) បន្ទាបខ្លួនខ្លាំងពេក។

៨ ព្រះអំណោយទានទាំងឡាយនៃការប្រោសឲ្យជាពីជំងឺ បានមកតាមរយៈអ្នកជឿ ប៉ុន្តែតែងតែ
ក) មកដល់អស់អ្នកដែល មានសិទ្ធិក្នុងការព្យាបាល។
ខ) មកដល់អ្នកជឿដែលសមនឹងទទួលបានក្តីស្រឡាញ់របស់ព្រះជាម្ចាស់។
គ) មកដោយឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។
ឃ) ទុកសម្រាប់សង្គ្រោះមនុស្សបាត់បង់តែងប៉ុណ្ណោះ។

៩ ពាក្យ "ការអស្ចារ្យ" ជាភាសាក្រិកនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មីមានន័យថា
ក) កម្លាំងដែលផ្ទុះឡើង
ខ) សកម្មភាពមិនធម្មតា
គ) មិនអាចគ្រប់គ្រងបាន
ឃ) មិនធម្មតា

១០ ព្រះជាម្ចាស់ប្រទានព្រះអំណោយទាននៃការធ្វើការអស្ចារ្យដើម្បី
ក) ធ្វើឲ្យអ្នកដែលមិនបរិសុទ្ធ ត្រូវទទួលការកាត់ទោស។
ខ) ឲ្យមនុស្សនៅក្នុងពិភពលោកភ្ញាក់ផ្អើល។
គ) ឧបសគ្គរបស់ដំណឹងល្អ ត្រូវបានដកចេញ។
ឃ) ឲ្យអ្នក នឹងមានបទពិសោធន៍អធិធម្មជាតិមួយ។

១១ ឫទ្ធានុភាពអធិធម្មជាតិ ក្នុងការធ្វើអ្វីដែលមិនអាចទៅរួច គឺជាព្រះអំណោយទាននៃ
ក) ការធ្វើការអស្ចារ្យ
ខ) ពាក្យសំដីនៃប្រាជ្ញា
គ) ជំនឿដ៏អស្ចារ្យ
ឃ) កិច្ចការដែលពិបាក។

១២ នៅពេលដែលយើងហៅ ព្រះអំណោយទាននៃការថ្លែងព្រះបន្ទូល ថា "ការថ្លែងប្រកាសប្រាប់" យើងចង់បានន័យថា
ក) ទាយពីអនាគត
ខ) ចែកចាយ ឬ ប្រកាសជាសាធារណៈ
គ) និយាយចេញទៅដោយវិញ្ញាណនៃក្តីស្រឡាញ់
ឃ) បើកបង្ហាញពីថ្ងៃដែលព្រះយេស៊ូទ្រង់យាងមកវិញ។

១៣ យោងទៅតាមគម្ពីរ ១កូរិនថូស ១៤:១ ព្រះអំណោយទាននៃការថ្លែងព្រះបន្ទូលគឺ

ក) មិនសំខាន់ដូចព្រះអំណោយទានខាងឯវិញ្ញាណនោះទេ

ខ) ព្រះអំណោយទានខាងឯវិញ្ញាណមួយដែលគេប៉ងប្រាថ្នាចង់បាន។

គ) គ្មាននរណាចង់បាន។

ឃ) ព្រះអំណោយទានដែលតូចជាងគេ។

១៤ ការសង្កេតឲ្យស្គាល់វិញ្ញាណផ្សេងៗ ចង្អុលបង្ហាញថាវិញ្ញាណណាមួយក្នុងចំណោម "វិញ្ញាណ" ទាំងបីនៅក្នុងពិភពលោកនេះ៖

ក) ព្រះវិញ្ញាណដ៏វិសុទ្ធ , វិញ្ញាណរបស់មនុស្ស និង វិញ្ញាណអាក្រក់។

ខ) វិញ្ញាណដូនតា, ទេវតាល្អ និង ទេវតាអាក្រក់។

គ) ភាវៈចម្លែកដ៏អាថ៌កំបាំង, វិញ្ញាណសាតាំង និង វិញ្ញាណរបស់មនុស្ស។

ឃ) ព្រះវិញ្ញាណដ៏វិសុទ្ធ, វិញ្ញាណដែលតាមសាតាំង និង មនុស្សអាក្រក់។

១៥ អ្នកជឿទទួលបានសមត្ថភាពក្នុងការសង្កេតឲ្យស្គាល់វិញ្ញាណព្រោះ

ក) អ្នកជឿត្រូវការបង្ហាញពីអំណាចអស្ចារ្យ។

ខ) វិញ្ញាណខុសឆ្គង និង វិញ្ញាញអាក្រក់អាចធ្វើទុក្ខក្រុមជំនុំបាន។

គ) មានវិញ្ញាណអាក្រក់ជាច្រើននៅក្នុងពិភពលោក។

ឃ) វិញ្ញាណអាក្រក់ស្គាល់អ្នកជឿ។

១៦ ការនិយាយភាសាចម្លែកអស្ចារ្យផ្សេងៗ គឺជាភស្តុតាងបង្ហាញពី

ក) ការជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។

ខ) ការអប់រំដ៏ល្អមួយ។

គ) គំនិតដ៏វាងវៃ

ឃ) វិញ្ញាណដែលទទេស្អាត។

១៧ គម្ពីរ១កូរិនថូស១៤:២៧-២៨ បង្ហាញប្រាប់ថា ការនិយាយភាសាចម្លែកអស្ចារ្យផ្សេងៗត្រូវតែ

ក) អនុញ្ញាតឲ្យនិយាយគ្រប់ពេល និង គ្រប់ទីកន្លែង ក្នុងអំឡុងពេលថ្វាយបង្គំរបស់ក្រុជំនុំ។

ខ) នៅឲ្យស្ងៀមនៅក្នុងកម្មវិធីថ្វាយបង្គំជាសាធារណៈរបស់ក្រុមជំនុំ។

គ) និយាយតិចៗនៅក្នុងព្រះវិហារ។

ឃ) មានសណ្តាប់ធ្នាប់នៅក្នុងការថ្វាយបង្គំជាសាធារណៈ។

១៨ គោលបំណងទាំងពីរក្នុងការនិយាយភាសាចម្លែកអស្ចារ្យផ្សេងៗគឺដើម្បីកសាង

ក) អស់អ្នកដែលប៉ងប្រាថ្នា និង ត្រូវការការកសាង។

ខ) អ្នកមិនជឿដែលបើកចិត្ត និង អ្នកសង្ស័យច្រើន

គ) ព្រះកាយដែលផ្សំឡើងពីអ្នកជឿ និង សហគមន៍

ឃ) អ្នកជឿដែលនិយាយ និង ក្រុមជំនុំទាំងមូល។

១៩ សារបន្ទូលជាភាសាចម្លែកអស្ចារ្យផ្សេងៗអាចកសាងព្រះកាយរបស់ព្រះគ្រិស្តបាន ប្រសិនបើវា

ក) ត្រូវបាននិយាយឡើងបន្ទាប់ពីអ្នកគង្វាលចែកចាយចប់។

ខ) ត្រូវបានបកប្រែន័យដើម្បីឲ្យមនុស្សគ្រប់គ្នាយល់បាន។

គ) ត្រូវបានគេនិយាយប្រកបដោយភាពជឿជាក់ និង មានអំណាច។

ឃ) ត្រូវបាននិយាយដោយចាស់ទុំ ឬអ្នកជំនួយម្នាក់។

២០ ច្បាប់ទូទៅសម្រាប់ការប្រើប្រាស់ព្រះអំណោយទានរបស់ព្រះវិញ្ញាណ គឺថា អ្នកជឿទាំងអស់ត្រូវ

ក) រៀបចំផែនការ ដើម្បីប្រើប្រាស់ព្រះអំណោយទាននោះ។

ខ) ដឹងថាព្រះអំណោយទានរបស់ពួកគេ គឺសំខាន់ជាងគេ។

គ) ធ្វើអ្វីៗគ្រប់យ៉ាងដោយក្តីស្រឡាញ់ ដើម្បីកសាងក្រុមជំនុំ។

ឃ) សមទុកមុនដើម្បីឲ្យយើងដឹងថាអ្វីដែលត្រូវធ្វើ និងត្រូវនិយាយ។

# អវសានកថា

យើងសង្ឃឹមថាការសិក្សាមួយនេះបានធ្វើឲ្យអ្នកគិតអំពីទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះជាម្ចាស់។ បន្ទាប់ពីបានសិក្សាមេរៀននេះរួច និង បានឆ្លើយគ្រប់សំណួរទាំងអស់ តើអ្នកធ្លាប់បានសួរខ្លួនឯងទេថា " តើខ្ញុំពិតជាគ្រិស្តបរិស័ទពិតប្រាកដម្នាក់ ដែរឬទេ? តើខ្ញុំស្គាល់ព្រះជាម្ចាស់ដែរឬទេ? តើទ្រង់ពិតជាគង់នៅក្នុងជីវិតរបស់ខ្ញុំ ដែរឬទេ?" យើងចង់ផ្តល់ឲ្យអ្នកនូវឱកាសក្នុងពេលនេះ ដើម្បីមានទំនាក់ទំនងជាមួយព្រះជាម្ចាស់។

យើងទាំងអស់គ្នាសុទ្ធតែធ្លាប់បានប្រព្រឹត្តខុស។ យើងធ្លាប់ធ្វើឲ្យខ្លួនឯង ព្រមទាំងអ្នកដទៃឈឺចាប់។ ព្រះគម្ពីរហៅការនោះថា ជាអំពើបាប ហើយយើងរាល់គ្នាសុទ្ធតែមានទោសៈ "គ្រប់ៗគ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប ហើយគ្មានសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយ" (គម្ពីររ៉ូម ៣:២៣) ។ អំពើបាបរបស់យើងបានរារាំងយើងមិនឲ្យស្គាល់ព្រះជាម្ចាស់ ថាជាឪពុកដែលពេញដោយក្តីស្រឡាញ់។ ប៉ុន្តែព្រះជាម្ចាស់ស្រឡាញ់យើងណាស់ ទោះបីយើងមានបាបក្តី។ ទ្រង់ស្រឡាញ់យើងខ្លាំងណាស់ បានជាទ្រង់ចាត់បុត្រារបស់ទ្រង់មកសុគតសម្រាប់យើងរាល់គ្នា។ " ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីអោយអស់អ្នកដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ច គឺមិនអោយគេវិនាសឡើយ។"
(គម្ពីរយ៉ូហាន៣:១៦)។ នៅពេលដែលទ្រង់សុគត ព្រះយេស៊ូបានទទួលយក ការដាក់ទោសដែលយើងសមនឹងទទួលបាន ដោយសារបាបរបស់យើង។

តើអ្នកចង់ធ្វើឲ្យប្រាកដថា ព្រះយេស៊ូជាព្រះសង្គ្រោះរបស់អ្នកដែរឬទេ? វាសាមញ្ញណាស់ៈ

- ទទួលស្គាល់ថាអ្នកជាមនុស្សបាបទុគ៌ត ដែលបែកចេញពីព្រះជាម្ចាស់ ហើយទូលសូមឲ្យទ្រង់លើកលែងឲ្យអ្នក។
- ជឿលើព្រះយេស៊ូ ឲ្យអស់ពីដួងចិត្តរបស់អ្នក ហើយធ្វើឲ្យទ្រង់ជ្រាបថា អ្នកពិតជាបានទទួលទ្រង់ជាព្រះសង្គ្រោះរបស់អ្នកមែន។

អ្នកអាចទូលទៅកាន់ព្រះជាម្ចាស់ដោយប្រើពាក្យផ្ទាល់ខ្លួនរបស់អ្នក ដោយថាតាមការអធិស្ឋានដូចតទៅនេះៈ

*បពិត្រព្រះយេស៊ូ ទូលបង្គំដឹងថាទូលបង្គំជាមនុស្សមានបាប។ សូមទ្រង់ប្រណីសន្តោសឲ្យទូលបង្គំផង។ ទូលបង្គំជឿថាទ្រង់គឺជាបុត្រដ៏អស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ ។ ទូលបង្គំសូមអរព្រះគុណទ្រង់សម្រាប់ការសុគតនៅលើឈើឆ្កាងសម្រាប់បាបរបស់ទូលបង្គំ។ សូមយាងមកគង់ក្នុងជីវិតរបស់ទូលបង្គំ។ ប្រោសឲ្យទូលបង្គំទៅជាមនុស្សដែលពិតប្រាកដនៅក្នុងជីវិតរបស់ទូលបង្គំ។ សូមសោយរាជ្យជាព្រះអម្ចាស់នៃជីវិតរបស់ទូលបង្គំនៅថ្ងៃនេះ។ សូមអរព្រះគុណទ្រង់សម្រាប់ការសង្គ្រោះទូលបង្គំ។*

ប្រសិនបើអ្នកអធិស្ឋានតាមសេចក្ដីអធិស្ឋាននេះ ហើយមានបំណងរកវាដាក់នៅក្នុងចិត្តរបស់អ្នកពិតមែន នោះបាបរបស់អ្នកត្រូវលើកលែង ហើយអ្នកមានជីវិតអស់កល្បជានិច្ចផងដែរ។ ព្រះយេស៊ូគឺជាព្រះអម្ចាស់នៃជីវិតរបស់អ្នក។ ព្រះគម្ពីរបានថ្លែងថា " បើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ និងសុចរិត* ទ្រង់នឹងអត់ទោសយើងអោយរួចពីបាប ព្រមទាំងជំរះយើងអោយបានបរិសុទ្ធ រួចពីគ្រប់អំពើទុច្ចរិតទាំងអស់ផង" (គម្ពីរ១យ៉ូហាន ១:៩)។

# កម្រងសំណួរសម្រាប់សិស្ស

សូមអាន និងបំពេញសំណួរនៅក្នុងទំព័រខាងក្រោម ហើយដាក់ស្នើវា មិនថាអ្នកជាសិស្សដែលចុះឈ្មោះ ឬ គ្រាន់តែជាអ្នកដែលចង់អភិវឌ្ឍខ្លួនឯង។ សូមព្រះជាម្ចាស់ប្រទានពរអ្នក ស្របពេលដែលដំណើរនៃជំនឿរបស់អ្នកបន្តទៅមុខ!

# សំណួរសម្រាប់និស្សិត

## CS5151KHM ព្រះអំណោយទានខាងវិញ្ញាណ

ឈ្មោះរបស់អ្នក..........................................................................................................

អាសយដ្ឋាន...............................................................................................................

.................................................................................................................................

អ៊ីម៉ែល......................................................................................................................

លេខទូរស័ព្ទ( មិនដាក់ក៏បាន)......................................................................................

១ តើអ្នកអធិស្ឋានដើម្បីទទួលយកព្រះយេស៊ូជាព្រះអម្ចាស់ និងជាព្រះសង្គ្រោះ ជាលើកដំបូងនៅក្នុងពេលដែលអ្នកកំពុងសិក្សាមុខវិជ្ជានេះឬ?

❑ បាទ/ចាស ❑ ទេ

បើមែន សូមចែករំលែករឿងរបស់អ្នក.............................................................................

.................................................................................................................................

.................................................................................................................................

២ តើមុខវិជ្ជានេះបានជួយអ្នកឲ្យនាំនរណាម្នាក់ចូលទៅកាន់ព្រះគ្រិស្ដដែរឬទេ?

❑ បាទ/ចាស ❑ ទេ

៣ តើមុខវិជ្ជានេះបានពង្រឹងកម្លាំងអ្នកក្នុងនាមជាគ្រិស្ដបរិស័ទដែរឬទេ?

❑ បាទ/ចាស ❑ ទេ

បើពិតមែន តើវាដោយរបៀបណា? ..................................................................................

.................................................................................................................................

.................................................................................................................................

៤ តើអ្នកអាចនឹងណែនាំមុខវិជ្ជានេះទៅកាន់អ្នកដទៃបានដែរឬទេ?

❑ បាទ/ចាស ❑ ទេ

សូមឲ្យព័ត៌មាននៃមិត្តភក្តិម្នាក់របស់អ្នក ហើយយើងនឹងទាក់ទងគេអំពីរបៀបដែលគេអាចរៀនរបស់ទាំងនេះបាន។

ឈ្មោះមិត្តរបស់អ្នក.....................................................................................................

អាសយដ្ឋាន...............................................................................................................

.................................................................................................................................

អ៊ីម៉ែល......................................................................................................................

លេខទូរស័ព្ទ (មិនឲ្យក៏បាន)........................................................................................

PN01.26.01

# សេចក្តីណែនាំសម្រាប់ការប្រឡងចុងបញ្ចប់

**សម្រាប់តែនិស្សិតដែលបានចុះឈ្មោះជាផ្លូវការ**

- រំឭកឡើងវិញនូវវត្ថុបំណង លំហាត់អនុវត្តន៍ ការប្រឡងដោយខ្លួនឯង និង ការវាយតម្លៃជំពូក ដើម្បីត្រៀមខ្លួនសម្រាប់ការប្រឡងចុងបញ្ចប់។
- ចូរធ្វើការប្រឡងចុងបញ្ចប់នៅ ប្រព័ន្ធអ៊ីធឺណែត ដោយប្រើប្រាស់លេខសម្គាល់និស្សិត និង លេខសំងាត់របស់អ្នកនៅក្នុងគេហទំព័រ http://sed.globalutraining.com។
- សម្រាប់ប្រទេសក្រៅពីសហរដ្ឋអាមេរិក សូមផ្ញើការប្រឡងចុងក្រោយ នៃសំណួរសម្រាប់និស្សិតរបស់អ្នកទៅឲ្យគ្រូរបស់អ្នក និង ការិយាល័យថ្នាក់ជាតិ។

ឥឡូវនេះដោយសារអ្នកបានបញ្ចប់ការសិក្សាមុខវិជ្ជានេះ យើងលើកទឹកចិត្តអ្នកឲ្យចាប់ផ្ដើមសិក្សាមុខវិជ្ជាបន្ទាប់ទៀត នៅក្នុងកម្មវិធីនេះ ឬសុំគ្រូរបស់អ្នក ឲ្យណែនាំមុខវិជ្ជាសិក្សាមួយផ្សេងទៀត។

GLOBAL UNIVERSITY

ACCESSIBLE | ACCREDITED | AFFORDABLE

DISTANCE LEARNING

1.800.443.1083 • web: www.globaluniversity.edu
www.globalreach.org • facebook.com/globaluniversity
1211 s. glenstone ave. • springfield, mo • 65804 • USA

# កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ

សិក្សាអំពីភាពជាអ្នកដឹកនាំក្នុងគ្រិស្តបរិស័ទ

## មុខវិជ្ជានេះនឹងជួយអ្នកឲ្យ...

- ស្គាល់អំពីព្រះអំណោយទានខាងឯវិញ្ញាណ
- ដឹងពីរបៀបដែលមនុស្សទទួលបានព្រះអំណោយទាន
- មានបទពិសោធន៍ជាមួយនឹងព្រះអំណោយទានខាងឯវិញ្ញាណ
- បម្រើអ្នកដទៃតាមរយៈព្រះអំណោយទានខាងឯវិញ្ញាណ
- ទទួលបានជីវិតជាគ្រិស្តបរិស័ទដែលល្អប្រសើរ ដោយព្រោះតែព្រះអំណោយទានខាងឯវិញ្ញាណ

សៀវភៅផ្សេងទៀតនៅក្នុងកម្មវិធីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ មានដូចជា៖

- **ការដោះស្រាយបញ្ហាជីវិត**
- **មនុស្ស កិច្ចការ និង គោលដៅ**
- **ការរស់នៅដ៏ពេញបរិបូណ៌**

សូមទំនាក់ទំនងអ្នកតំណាងក្នុងកម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ របស់អ្នក សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបយកសៀវភៅទាំងនេះទៅសិក្សា

---

កម្មវិធីសិក្សាអំពីការបម្រើព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទ រួមមាន ១៨ មុខវិជ្ជា

ចែកជាបីជំពូក ដែលជំពូកនីមួយៗមាន៦ មុខវិជ្ជា

*ព្រះអំណោយទានខាងឯវិញ្ញាណ* ជាមុខវិជ្ជាទី៥ ក្នុងជំពូកទី១

PN01.26.01
CS5151 KHM